ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តួនាទីអក្សរសិល្ប៍ពុទ្ធិសម័យក្រោយសម័យអង្គរ



កម្រងស្នាដៃសិក្សាកថា

ជ័យលាភីចំណាត់ថ្នាក់លេខ១ លេខ២ លេខ៣

ផ្នែកបកស្រាយអក្សរសិល្ប៍ក្នុងទិវាជាតិអំណានលើកទី៧

១១ មីនា ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៤ អយក.សវសល

សេចក្តីជូនដំណឹង

ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនអស់លោក លោកស្រី សាធារណជនទូទៅ ជ្រាបថា៖ ក្រសួងនឹងរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៧ ក្រោមប្រធានបទ **«អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល»** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។ ដើម្បីចូលរួមអបអរសាទរទិវានេះ ក្រសួងបានរៀបចំឱ្យមានការប្រកួតប្រជែងបកស្រាយប្រធានបទ **«តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»** ជ្រើសរើសជ័យលាភីចំនួន៣រូប។

លក្ខខណ្ឌដើម្បីចូលរួមប្រកួតប្រជែង៖

១- សមាសភាពដែលអាចចូលរួមប្រកួតប្រជែង ជាមន្ត្រីអប់រំ គ្រូបង្រៀន គរុនិស្សិត គរុសិស្ស និស្សិត និងសាធារណជនទូទៅ

២- ខ្លឹមសារស្របនឹងប្រធានបទ **«តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»** ដោយឆ្លុះបញ្ចាំងតាមរយៈស្នាដៃអក្សរសិល្ប៍មួយចំនួន

៣- បេក្ខជនត្រូវសរសេរបកស្រាយប្រធានបទឱ្យបានល្អយ៉ាងតិច១០ទំព័រ ខ្នាតក្រដាស A4 ជាសំណេរដោយកុំព្យូទ័រ ប្រើប្រាស់ទម្រង់អក្សរ Khmer OS Muol Light ទំហំ១២ និងKhmer OS Siemreap ទំហំ១២

៤- កាលបរិច្ឆេទឈប់ទទួលស្នាដៃត្រឹមថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៧:០០នាទី ជាកំហិត

៥- ទំនាក់ទំនងផ្ញើស្នាដៃតាមរយៈតេឡេក្រាម ០១០ ២២០ ៧៨៨ និងសាកសួរព័ត៌មានបន្ថែមតាមរយៈទូរសព្ទលេខ ០១១ ២២៨ ៨៥២។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ចម្លងជូន៖
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  -ដើម្បីជូនជ្រាបជាព័ត៌មាន-
- សាលារាជធានី ខេត្ត ទាំង២៥
- អង្គភាពក្រោមវិឋទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ទាំង២៥
  -ដើម្បីផ្សព្វផ្សាយ-
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
ទិវាជាតិអំណានលើកទី៧

បញ្ជីឈ្មោះបេក្ខជនជ័យលាភី ផ្នែកប្រកួតប្រជែង
បកស្រាយប្រធានបទ «តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអន្តរ»
អបអរសាទរ ទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២

ល.រ.	ឈ្មោះ	ភេទ	មុខរបរ	អង្គភាព	មកពីខេត្ត	ចំណាត់ថ្នាក់	ផ្សេងៗ
១	ជក់ សុភា	ប្រុស	គ្រូបង្រៀន	សាលាជំនាន់ថ្មី វិ.ព្រែកលាប	រាជធានីភ្នំពេញ	1	
២	ទឹម សុខហួយ	ប្រុស	គ្រូបង្រៀន	វិ.សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អង្គតាសោម	តាកែវ	2	
៣	មី សុវណ្ណ	ប្រុស	គ្រូបង្រៀន	វិទ្យាល័យបាត់ដឹង	កំពង់ស្ពឺ	3	

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២

ប្រធានគណៈកម្មការ

បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន

ជាន ឃើញ និងឯកភាព
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ស្នាដៃដសិក្សាកថា

ជ័យលាភីចំណាត់ថ្នាក់លេខ១

ដោយលោក ជក់ សុភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

๙๓๘

មន្ទីរអប់រំយុវជនកីឡានគរភ្នំពេញ

សាលាជំនាន់ថ្មី ទីក្រុងព្រែកលៀប

ស្ថាដែលបួលរួមអបអរសាទរ ទិវាជាតិអំណាន លើកទី៧

លើប្រធានបទ

"ក្លឹងទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអន្តរ"

បេក្ខជន **ជក់ សុភា** ភេទប្រុស កើតនៅថ្ងៃ៣ ខែមិថុនា ឆ្នាំ១៩៩៦

ជាបង្រៀននៅ សាលាជំនាន់ថ្មី ទីក្រុងព្រែកលៀប រាជធានីភ្នំពេញ

ទូរស័ព្ទ៖ 086 204 699

ព.ស. ๒๕๖๕

ត.ស. ๒๐๒๒

មាតិកា

សេចក្តីផ្តើម

១-ការវិវត្តនៃអក្សរសិល្ប៍ក្រោយសម័យអង្គរ.....២

១.១-អក្សរសិល្ប៍លើសិលាចារឹក.....៣

១.២-អក្សរសិល្ប៍លើសាស្ត្រា.....៣

១.៣-អក្សរសិល្ប៍លើក្រាំង.....៦

២-ឥទ្ធិពលពុទ្ធសាសនាក្រោយសម័យអង្គរ.....៧

២.១-ពុទ្ធសាសនាក្នុងសង្គមខ្មែរ.....៧

២.២-ឥទ្ធិពលពុទ្ធសាសនាមកលើអក្សរសិល្ប៍ខ្មែរ.....៧

៣-អក្សរសិល្ប៍ពុទ្ធនិយម.....១០

៣.១-ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម.....១០

៣.២-តំណែងនិពន្ធនៃរឿងបែបពុទ្ធនិយម.....១១

ក-ផ្តើមរឿង.....១១

ខ-ដំណើររឿង.....១២

គ-បញ្ចប់រឿង.....១៣

៤-តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ.....១៤

៤.១-ការអប់រំចរិយាសាស្ត្រ.....១៤

ក-សីលធម៌.....១៥

ខ-គុណធម៌.....១៩

៤.២-ការបណ្តុះស្មារតីសន្តិភាព.....២៣

៤.៣-ការបណ្តុះពុទ្ធិស្មារតី.....២៧

៤.៤-ឥទ្ធិពលទស្សនវិជ្ជាពុទ្ធសាសនាក្នុងការអប់រំចរិយាសាស្ត្រ.....៣០

ក-ទស្សនៈកម្ម-ផល.....៣០

ខ-បញ្ចសីល.....៣៣

៤.៥-តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងវិធីតំណែងនិពន្ធវណ្ណកម្មខ្មែរ.....៣៨

ក-កម្រងកែវ បទកាព្យ.....៣៨

ខ-រូបរូបារម្មណ៍.....៣៩

៤.៦-តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្នុងការផ្សព្វផ្សាយវប្បធម៌.....៣៩

ក-ជំនឿ.....៣៩

ខ-ទំនៀមទម្លាប់ប្រពៃណី.....៤១

គ-សិល្បៈ.....៤២
៤.៧- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាមកលើសង្គមខ្មែរនាពេលបច្ចុប្បន្ន.....៤៣
ក-ធម្មទេសនា.....៤៣
ខ-សិល្បៈ.....៤៤
គ-នរនាម.....៤៦
សន្និដ្ឋាន
គន្ថនិទ្ទេស

តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាសៅសម័យក្រោយអង្គរ

សេចក្តីផ្តើម

សម័យអង្គរជាពេលវេលាមួយនៃការរីកចម្រើនខ្លាំងស្ទើរគ្រប់វិស័យរហូតក្លាយជាចក្រភពអង្គរទៀតផង។ ព្រះរាជាគ្រប់ព្រះអង្គបានខិតខំកសាងប្រាង្គប្រាសាទធំស្តឹមស្តែសម្រាប់ឧទ្ទិសថ្វាយអាទិទេពក្នុងរាជរបស់ទ្រង់។ ឥទ្ធិពលរបស់អាណាចក្រអង្គរក៏មិនអាចឈរជើងបិតបៀរ រហូតឈានដល់ទីបញ្ចប់នៃសម័យដ៏រុងរឿងនេះផងដែរ។ ក្រោយការបែកបាក់នេះ កម្ពុជាបានឈានជើងចូលក្នុងភ្នក់ភ្លើងសង្គ្រាម ចម្បាំងរាំងជល់ វិបត្តិផ្ទៃក្នុងរហូតស្ទើរផុតដង្ហើមពីផែនទីពិភពលោកនេះ។ សម័យក្រោយអង្គរឬសម័យកណ្តាល ដែលគេផ្តោតសំខាន់ទៅលើសម័យកាលពីរសំខាន់គឺលង្វែក និងឧដុង្គ (១៤៣១-១៨៦០)។

ជាមួយគ្នាអក្សរសិល្ប៍ខ្មែរត្រូវបានវិវត្តទៅតាមដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្រ។ កំឡុងសម័យអង្គរ យើងរកឃើញត្រឹមតែអត្ថបទជាសិលាចារឹកតែប៉ុណ្ណោះ។ ក្រោយសម័យដ៏រុងរឿងនេះ ត្បិតសង្គមខ្មែរធ្លាក់ក្នុងកលិយុគយ៉ាងណាក្តី ក៏យើងអាចឃើញអត្ថបទអក្សរសិល្ប៍ហាក់មានសន្ទុះឡើងវិញ រហូតអ្នកប្រាជ្ញអក្សរសាស្ត្រលោកចាត់ទុកថា «យុគមាសនៃអក្សរសិល្ប៍»ទៀតផង។ សម័យក្រោយអង្គរ ប្រជារាស្ត្រខ្មែរបានធ្លាក់ក្នុងវិបត្តិផ្លូវចិត្ត ភ័យខ្លាច តក់ស្លុត ព្រាត់ប្រាស់គ្រួសារ ទុក្ខសោកញាំញីជារឿយៗ។ ត្រង់នេះជាឱកាសមួយដ៏ល្អនៃលទ្ធិពុទ្ធសាសនាបានពង្រីកខ្លួនឱ្យកាន់តែខ្លាំងក្នុងសង្គមខ្មែរ។ ពុទ្ធសាសនាបានឈានជើងចូលក្នុងសង្គមខ្មែរតាំងពីសម័យមុនអង្គរម្ល៉េះ ក្រោមទម្រង់ជាមហានិកាយ។ ប៉ុន្តែក្រោយការដួលរលំនៃអាណាចក្រអង្គរ សាសនាព្រាហ្មណ៍ដែលគោលសាសនាមួយដែលទ្រសម័យអង្គរឱ្យរឹងមាំនោះក៏បានសាបរលាបផងដែរ។ ស្ថិតក្នុងរង្វង់នៃឥទ្ធិពលពុទ្ធសាសនានេះ អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល ចង់ឬមិនចង់ក៏គង់តែទទួលឥទ្ធិពលនេះដោយខានពុំបាន។ លក្ខណៈពិសេសមួយរបស់អក្សរសិល្ប៍ពុទ្ធសាសនានោះគឺ ការលួងលោមនិងផ្តេកផ្តួលឱ្យជឿលើបុណ្យបាប កម្មផលពីអតីតជាតិ ប្រការនេះវាបានចូលរួមចំណែកបន្ធូរបន្ថយភាពតានតឹងអារម្មណ៍ប្រជាជនខ្មែរឱ្យរសាយផុតពីទុក្ខកង្វល់ ភាពរញ៉េរញ៉ៃ ញាំញីនៃវិបត្តិសង្គមជាតិ។ តែនេះមិនមែនជាមុខងារតែមួយគត់របស់អក្សរសិល្ប៍ពុទ្ធនិយមនោះទេ បើយើងស្រាយវាំងននទ្រឹស្តីពុទ្ធសាសនា យើងនឹងឃើញលំហនៃទស្សនវិជ្ជាខ្មែរ ក្នុងការអប់រំនិងទិដ្ឋភាពនៃសង្គមមនុស្សនាសម័យនោះតាមរយៈផ្នែរឿង។

ជាការពិតណាស់ជុំវិញទស្សនាទាននៃអក្សរសិល្ប៍ពុទ្ធនិយមនេះ បានបណ្តុះមនុស្សឱ្យក្លាយជាពលរដ្ឋល្អប្រកបដោយសីលធម៌ គុណធម៌ក្នុងសង្គមខ្មែរពីបុរាណកាលមកម្ល៉េះ។ តម្លៃទាំងនេះដែលធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមមិនអាចសាបសូន្យពីសង្គមខ្មែរ នៅតែបន្តអត្ថិភាពមកដល់បច្ចុប្បន្ន។ ក្នុងការសិក្សាទៅលើតួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្រោយសម័យអង្គរ យើងសូមលើកយកនូវរឿងចំនួន៦មកឆ្លុះបញ្ចាំងជាតួយ៉ាងនៃអក្សរសិល្ប៍ពុទ្ធនិយមដោយអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ យើងលើកយករឿងពីទសជាតក សុវណ្ណសាមជាតក និងវេស្សន្តរជាតក ដោយហេតុរឿងទាំងពីរនេះពេញនិយម គួរនៅលើវត្តអារាមនាសម័យកណ្តាល។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយ យើងសូមលើក

យករឿងក្រុងសុកមិត្រ និងរឿងទេវន្ទមកឆ្លុះបញ្ចាំង។ ចំណែកឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ផ្លូម) យើងសូមលើកយករឿងកោគកុលកុមារ មរណមាតា មកឆ្លុះបញ្ចាំងតែប៉ុណ្ណោះ។

១-ការវិវត្តនៃអក្សរសិល្ប៍សម័យក្រោយអង្គរ

ដូចដែលយើងបានដឹងហើយថា ការលេចឡើងនូវនិន្នាការពីរ ក្នុងការបែងចែកអក្សរសិល្ប៍ខ្មែរគឺតាម ប្រវត្តិវិទ្យា និងភាសាវិទ្យា[1]។

ប្រវត្តិវិទូបានចែកតាមលំដាប់សម័យ គឺ

- សម័យមុនអង្គរ ពីសតវត្សទី១ ដល់ ស.វ.ទី៨
- សម័យអង្គរ ពីស.វ.ទី៩ ដល់ទី១៤
- សម័យក្រោយអង្គរ ពីស.វ.ទី១៥ ដល់ ១៨
- សម័យអាណានិគមបារាំង ពីគ.ស. ទី១៨៦៣ដល់ គ.ស. ១៩៥៣
- សម័យបច្ចុប្បន្នពីគ.ស. ១៩៥៣ រហូតដល់សព្វថ្ងៃ

ដួនកាលគេចែកលម្អិតតទៅទៀតក្នុងសម័យនីមួយៗ។ ចំណែកឯភាសាវិទូ បានចែកចង្កោមអក្សរសិល្ប៍ខ្មែរតាមការវិវត្តនៃភាសា និងនិរុត្តិសាស្ត្រគឺ

- សម័យបុរាណ ដែលហៅថា ខ្មែរបុរាណ ឬខ្មែរចាស់ គឺជាភាសាខ្មែរដែលបុព្វបុរសយើងបានធ្វើចំណារលើ ផ្នាំង ឬជាពាសពេញលើអាណាចក្រយើង ប្រសិទ្ធនាមហៅថា “សិលាចារឹក”។ “ភាសាខ្មែរបុរាណ” គឺរាប់ចាប់ពីស.វ.ទី៧ ដល់ស.វ.ទី១៤។
- សម័យកណ្តាល ឬសម័យ “ភាសាខ្មែរកណ្តាល” គឺជាភាសាខ្មែរដែលយើងឃើញលើសិលាចារឹកខ្លះៗ នៅលើសាស្ត្រាស្លឹករឹត ក្រាំង គម្ពីរ ក្បួនច្បាប់ផ្សេងៗក្នុងកំឡុងស.វ.ទី ១៩។
- សម័យបច្ចុប្បន្នកាល គឺជាសម័យនៃភាសាខ្មែរទំនើបឬខ្មែរថ្មី គឺជាភាសាដែលខ្មែរយើងនិយាយសរសេរ ប្រើការរហូតដល់សព្វថ្ងៃនេះឯងគឺតាំងពីកណ្តាលស.វ.ទី១៩ ដល់ទី២០នេះ។[2]

ជារួមយើងឃើញថា តាមរយៈបញ្ជែកសម័យកាលអក្សរសិល្ប៍ខ្មែរខាងលើ អាចឱ្យយើងដឹងខ្លះៗពីទំនាក់ទំនងនៃការវិវត្តសាស្ត្រាល្បែងក្នុងប្រវត្តិអក្សរសាស្ត្រខ្មែរសម័យកណ្តាល។ ជារួមអក្សរសាស្ត្រសម័យកណ្តាល គេតែងគិតទៅលើអក្សរសាស្ត្រក្នុងសម័យកាលធំៗពីរគឺ សម័យលង្វែកនិងឧដុង្គ។

យោងតាមលោកបណ្ឌិត យីង ហុកឌី បានលើកឡើងថា អក្សរសាស្ត្រសម័យកណ្តាល គឺសំដៅចំពោះ សំណុំចង្កោម អត្ថបទទាំងឡាយដែលនិពន្ធរចនាឡើងនៅក្នុងភាសា “ខ្មែរកណ្តាល” គឺគិតតាំងពីស.វ.ទី១៥ ដល់ដើមសតវត្សទី១៩[3] ។

---

[1] យីង ហុកឌី, ***ទិដ្ឋភាពខ្លះៗនៃអក្សរសាស្ត្រខ្មែរ***, បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣, ទំ. ៤

[2] -ដ-ទំ. ៥

[3] -ដ-, ទំ. ២១

នៅក្នុងសម័យកណ្តាលនេះផងដែរ គេឃើញលេចចេញទម្រង់អក្សរសិល្ប៍២ប្រភេទគឺ អក្សរសិល្ប៍លើសិលាចារឹក និងអក្សរសិល្ប៍លើក្រាំង និងសាស្ត្រា ។

១.១-អក្សរសិល្ប៍លើសិលាចារឹក

ផ្នែកសិលាចារឹកនេះ ឃើញមានតែសិលាចារឹកជ័យនន្ទតែប៉ុណ្ណោះដែលមានលក្ខណៈអក្សរសិល្ប៍។ សិលាចារឹកជ័យនន្ទ ត្រូវបាននិពន្ធឡើងដោយ បណ្ឌិតជ័យនន្ទ បានបង្ហាញអំពីការប្រាថ្នា សុំសេចក្តីសុខសប្បាយ ជួបជុំគ្រួសារ សោយសម្បត្តិទិព្វនាអនាគតជាតិរបស់បណ្ឌិតជ័យនន្ទ តាមរយៈការបួស ក្រោមដំបូលព្រះពុទ្ធសាសនា ព្រមទាំងបញ្ជាក់អំពីការគោរពបូជាព្រះពុទ្ធសាសនា ការកសាងបដិមាព្រះពុទ្ធអំពីមាស ការធ្វើកុសលដោយដោះលែងទាសាទាសី ឱ្យមានសេរីភាព ការដាក់បណ្តាសារដល់ជនណាដែលលួចសម្បត្តិព្រះ បង្ហាញពីជំនឿលើកម្មផល បុណ្យបាបនរកសួគ៌ ថែមទៀត[4]។

អត្ថបទសិលាចារឹកដទៃនាសម័យកណ្តាលមានដូចជា សិលាចារឹកគោកស្វាយចេក(K.754) សិលាចារឹកប្រាសាទខ្វាវ (K.177) សិលាចារឹកប្រាសាទនគរបាជ័យ សិលាចារឹកតាព្រហ្មនៅវត្តបាទី(K.39) សិលាចារឹកភ្នំបាក់ខែង (K.285 K.465)...ជាដើម។

អត្ថបទសិលាចារឹកមានទំហំខ្លី ព្រោះយើងដឹងហើយថាការចារចារឹកលើផ្ទាំងថ្ម ជាការលំបាកគឺត្រូវប្រើពេលយូរណាស់ ដើម្បីឆ្លាក់អត្ថបទនីមួយៗ ដូចនេះឃើញថាទាល់តែអត្ថបទនោះមានសារៈប្រយោជន៍ខ្ពង់ខ្ពស់ ជាទីសក្ការៈ ឬទាក់ទងនឹងសត្យាប្រណិធាន។ល។ ទើបអាចរចនាលើសិលាទាំងនេះបាន។[5]

១.២- អក្សរសិល្ប៍លើសាស្ត្រា

បើនិយាយអំពីប្រវត្តិនៃសាស្ត្រាស្លឹករឹត ពុំមែនទើបតែកកើតមាននៅសម័យកណ្តាលនោះទេគឺបានកើតមានតាំងពីយូរលង់ណាស់មកហើយព្រោះថា បើគេសង្កេតទៅលើប្រវត្តិនៃការប្រើប្រាស់ឧបករណ៍សរសេររបស់ខ្មែរយើងមានអក្សរសម្រាប់សរសេរ តាំងពីរាប់រយឆ្នាំមុនគ.ស. មកម្ល៉េះ គ្រាន់តែការសេរនោះនៅមានលក្ខណៈ បុរាណប៉ុណ្ណោះ ដោយមានមតិខ្លះឱ្យដឹងថា "...ចំណែកការប្រើប្រាស់អក្សរខ្មែរចេះប្រើតាំងពីសតវត្សទី៦មុន គ្រឹស្តសករាជគឺខ្មែរចេះសរសេរឬចារច្រើនធ្វើនៅលើស្លឹក នៅលើស្បែកនៅលើក្រដាស ហើយចារនៅលើថ្ម... [6] ។ក្នុងចំណោមនោះមានតែសិលាចារឹកទេដែលសេសសល់មកដល់បច្ចុប្បន្ន ឯស្បែកសត្វនិងស្លឹកត្រូវបានខូចអស់ហើយ ពុំអាចធន់ទ្រាំដល់បច្ចុប្បន្នឡើយ។ តែទោះបីជាយ៉ាងណា យើងក៏នៅតែអាចដឹងបានថា វត្ថុទាំងនោះត្រូវបានគេយកមកប្រើប្រាស់សម្រាប់សរសេរ ដោយសម្អាងទៅលើឯកសារកំណត់ហេតុ ជីវតាក្នាន់ ដែលជាអ្នកស្រាវជ្រាវចិនបានមកដល់ស្រុកខ្មែរនាសម័យអង្គរបានឱ្យដឹងថា "លិខិតធម្មតាឬអត្ថបទទាំងអស់ ដូចជាឯកសារផ្លូវការជាដើមសុទ្ធតែសរសេរលើស្បែកសត្វ ប្រើស រមាំង ឬស្បែកសត្វដទៃទៀតដែរគេយកមក ហាលឱ្យស្ងួតលាបពណ៌ខ្មៅ។ គេកាត់ស្បែកនោះឱ្យមានទំហំ

---

[4] លាង ហាប់អាន, ***ប្រវត្តិអក្សរសាស្ត្រខ្មែរ***, បណ្ណាគារ គិម អេងលេខ, ភ្នំពេញ, ១៩៦៧, ទំ. ២១១

[5] យឹង ហុកឌី, ***ទិដ្ឋភាពខ្លះៗនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ២១

[6] លឹម ហាក់, ***សិក្សាអំពីប្រវត្តិ និងបច្ចេកទេសគម្ពីរខ្មែរ***,សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា,១៩៩៥,ទំ. ២

ធំឬតូចទៅតាមសេចក្តី ត្រូវការនិងយកម្សៅ ម្យ៉ាងមកប្រើមានសណ្ឋានដូចដីស នៅស្រុកចិនដែលគេលុញឱ្យវែង ចិតចុងស្រួចគេហៅថា សោ ហើយគេសរសេរដោយដៃបានជាប់ដឹតល្អណាស់មិនងាយនឹងរលុបឡើយ[7] ។ម្យ៉ាងទៀតក្នុងកំណត់ហេតុនេះដដែល ក៏បានបញ្ជាក់ទៀតដែរថាការប្រែពីចិនមកគេពុំនិយាយឱ្យច្បាស់ថាស្លឹករឹតនៅឡើយទេ ប៉ុន្តែលោកគិតថា លោកជីវតា ក្វាន់ពុំដឹងពីរបៀបដែលគេសរសេរលើស្លឹកនោះទេ ឯលោកផ្ទាល់សន្និដ្ឋានថាគេចារដោយប្រើដែកចារ ហើយយកធ្យូងលាបប្រេងមកលុបទើបបានជាស្នាមខ្មៅនេះ ដូច្នេះមានន័យថា ពិតជាសរសេរស្លឹករឹត។ ម្យ៉ាងទៀត ប្រភពដដែលបានឱ្យដឹងទៀតថា ស្លឹកនេះកត់ត្រានូវធម៌សម្រាប់ព្រះសង្ឃ ខាងពុទ្ធសាសនាសម្រាប់ទេសន៍ដូច្នេះគ្មានអ្វីក្រៅពីសាស្ត្រាស្លឹករឹតឡើយ។ ជាមួយគ្នានេះនៅក្នុងសិលាចារឹកខ្លះ ក៏បានឱ្យដឹងថា មានការធ្វើគម្ពីរ អំពីស្លឹក មាស ប្រាក់ ដែលគម្ពីរនោះហៅថា Rikta ។ ហើយគេសន្និដ្ឋានថា គម្ពីរ ឬ Rikta សន្លឹកនេះគឺប្រហែលជាសាស្ត្រាស្លឹករឹតបច្ចុប្បន្ន[8]។

សាស្ត្រាស្លឹករឹតត្រូវបានធ្វើពីស្លឹកទ្រាំង ឬចាស់បុរាណហៅថា “ស្លឹកសម្លាញ”ដែលប្រទះក្នុងសិលាចារឹកបុរាណផងដែរ[9] ហើយពេលខ្លះគេក៏ប្រើ ស្លឹកស្នោត ប៉ុន្តែពិបាកចារបន្តិច។ តាមវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ទ្រាំង គឺជាឈ្មោះ តចសារព្រឹក្សមួយប្រភេទ(សណ្តានជ្រៃ)មានធាងវែង “មានស្លឹកប្រើការបានច្រើនយ៉ាង គឺចារសាស្ត្រាហៅថាស្លឹករឹត... ដើមទ្រាំងនេះ ដុះពីគ្រាប់វាក្នុងព្រៃធំៗក្នុងប្រទេសកម្ពុជា មានខែត្រក្រចេះ និងខែត្រកំពង់ធំច្រើនជាងខែត្រឯទៀតជា តចសារព្រឹក្សមានប្រយោជន៍ច្រើន គេអាចដាំតាមព្រំវត្តអារាមក៏បានមិនសូវរើសដីប៉ុន្មានទេ រស់បានយូរឆ្នាំវែងជាងអាយុមនុស្ស អ្នកមានអាយុវែង ប៉ុន្តែលុះដល់កំណត់កាលក៏បញ្ចេញផ្កាត្រង់ចំកំពូលមានផ្លែ ជាធ្លាយដូចផ្លែធ្លាយផ្លែចាក លុះផ្លែទុំហើយ តចសារព្រឹក្ស នេះក៏ងាប់រាប់ថាជារុក្ខជាតិបញ្ចេញផ្កាផ្លែសម្លាប់ដើម... [10] ។ ដើមទ្រាំងនេះគេអាចយកទៅប្រើបានច្រើនយ៉ាងដោយធាងទ្រាំងគេយកទៅធ្វើជា រំពាត់ ដំបង ពន្ធមូល ជាម ...រីឯស្លឹកទ្រាំងគេយកទៅធ្វើជាសំពៀត ស្បោង កន្ទេល ស្លឹកក្តល់ ស្លឹករឹត... [11]។

រីឯព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយាបានហៅទ្រាំងថាជាស្លឹករឹតនិងឱ្យដឹងថា “ស្លឹករឹតជារុក្ខជាតិ ដុះនៅលាយឡំជាមួយនឹងរុក្ខជាតិផ្សេងៗជារុក្ខជាតិមានតែដើម ធាង ស្លឹក ដុះចេញមកជាកំពូលប៉ុណ្ណោះ គ្មានមែកទេ(សម្បុរជាងគេនៅខេត្តក្រចេះ) [12]។

សាស្ត្រាត្រូវបានគេបែកចែកជាបីគឺ សាស្ត្រាទេសន៍ សាស្ត្រាក្បួន និងសាស្ត្រាល្បែង។

ចំពោះសាស្ត្រាល្បែង គេយល់ថា ពាក្យល្បែង មានក្នុងភាសាខ្មែរជាយូរមកហើយ យើងឃើញមានដំបូងនៅក្នុងសិលាចារឹក K.254 នៅសតវត្សទី១២បន្ទាត់ ១៩ មានពាក្យ “គរុលំបែង” គឺ”គ្រូល្បែង” នេះឯង។ លោក សឺដេស យល់ថាជា “គរុ ដែលធ្វើពិធីផ្សេងៗទេ គឺមិនយកទ្រនឹប” ។ ពាក្យ ល្បែង នេះទៀតសោតយើងឃើញមាននៅពាសពេញ

---

[7]ជីវតាក្វាន់, ***ទឹកដីនិងប្រពៃណីអ្នកស្រុកចេនឡា***, រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣ ទំ.៣៨

[8] -ដ-,ទំ. ៣២

[9] អាំងដូលាន,ព្រាប ចាន់ម៉ារ៉ា, ស៊ីយ៉ុន សុភាទិទ្ធ,គង់ វីរៈ, ***កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ***,លេខ២ ធ្នូ ២០០៦ ធ្នូ២០០៧ , ចំណុច ៥.៦

[10] ជួន ណាត,***វចនានុក្រមខ្មែរភាគ***១ ២, ដ.ឯ.ម, ទំ. ៤៦៩ -៤៧០

[11] លី សុវ៉ី, ***អារិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍បែប ពុទ្ធនិយម បែបព្រហ្មនិយម បែបខ្មែរនិយម***, ភ្នំពេញ, បោះពុម្ពលើកទី២, ២០០២, ទំ. ១៦២-១៦៣

[12]អ៊ុម ស៊ុម, ***គម្ពីរស្លឹករឹត***, ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ៤៨, ១៩៩៤, ទំ. ៩៤

អត្ថបទអក្សរសាស្ត្រសម័យកណ្តាល[13]។ ជាក់ស្តែងនៅក្នុងច្បាប់ត្រីនេតិ ក្នុងច្បាប់ផ្សេងៗ ទំព័រ ៩១ ដល់៩៤៖ វគ្គ៧៤ “កុំលេងជាល្បែង រំពឹងយល់ឈ្វេង ពាក្យពុំពីរោះ ស្រដីឱ្យជាច់ ឱ្យស្រេចឱ្យស្មោះ កុំធ្វើឡេះឡោះ សសោះអន្ធង។” ។ រីឯច្បាប់ប្រុស ក្នុងច្បាប់ផ្សេង ទំព័រ ១ ដល់១០៖ វគ្គ ៥២ “ លោកថាហៅឆ្កួតបី មួយឆ្កួតស្រីមួយឆ្កួតស្រា មួយឆ្កួតល្បែង ពាលា លេងបៀប៉ោធ្លកំតាត់” ។

យ៉ាងណាមិញលោក អូ ឈៀង ក៏បានឱ្យនិយមន័យថា ល្បែង មកពីពាក្យ “លេង” ដូច្នេះ ល្បែងមានន័យថា អ្វីដែលជាទីកម្សាន្តសើចបំពេញអារម្មណ៍។ល។[14]

ជារួម សាស្ត្រាល្បែង ត្រូវបានលោកអ្នកអក្សរសាស្ត្របានឱ្យនិយមន័យខុសៗគ្នាដូចជា៖

យោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត បានលើកឡើងថា សាស្ត្រាល្បែង គឺជាប្រលោមលោកសម័យកណ្តាល។ លោកបញ្ជាក់ទៀតថា ប្រលោមលោកនេះនៅក្នុងសម័យដើម សាស្ត្រាល្បែងឬរឿងល្បែងខាងសម្រាយ ច្រើនតែងជាពាក្យកាព្យ... ខាងបាលីច្រើនតែងជា បកិណ្ណក:ឬវេយ្យាករណ៍បាឋ គឺជាពាក្យបាលីរាយៗ ជួនមានគាថាបាលីបញ្ចូលមកខ្លះដោយអន្លើៗ ដូចជាបញ្ញាសជាតកជាដើម រឿងសាស្ត្រាទាំងនោះជាពាក្យកាព្យសម្រាយក្តី ជាបាលីក្តីហៅថា “សាស្ត្រាល្បែង ឬរឿងល្បែង” ដូចគ្នា ត្រូវគ្នានឹងរឿងសាស្ត្រាសៀវភៅប្រលោមលោកសម័យបច្ចុប្បន្ននេះ[15]។

តាមទស្សន:បណ្ឌិតសភាចារ្យ សុំ ឈុំប៊ុន លើកឡើងថាក្នុងកំឡុងស.វ.ទី ១៨-១៩ អ្នកនិពន្ធខ្មែរខ្លះបានដកស្រង់យករឿងក្នុងជាតកមួយចំនួន មកប្រែសម្រួលជាភាសាខ្មែរ ដោយទុកគាថាភាសាបាលីខ្លះៗ ហើយអ្នកនិពន្ធខ្លះទៀតបានដកស្រង់ដំណើររឿងក្នុងជាតកមកតាក់តែងទៅតាមគំនិតរបស់ខ្លួន។ ស្នាដៃទាំងនោះត្រូវបានចារលើសាស្ត្រាស្លឹករឹតហៅថា សាស្ត្រាល្បែង[16]។

ស្រដៀងគ្នានេះ បណ្ឌិតសភាចារ្យ សោម សុមុនី យល់ឃើញថា សាស្ត្រាល្បែងជាប្រលោមលោកពាក្យកាព្យដែលទទួលឥទ្ធិពលពីពុទ្ធសាសនា ហើយមានលក្ខណៈឯកភាពបីគឺ ទី១ មធ្យោបាយគឺចារលើស្លឹក ឬក្រាំង ពោលគឺពុំមែនធ្លាក់លើថ្មដូចសម័យមុនទៀតឡើយ។ ទី២ ការសរសេរជាពាក្យកាព្យ លើសាស្ត្រា ហើយអ្នកនិពន្ធមាននិន្នាការពុទ្ធនិយម។ ចំណុចចុងក្រោយគឺសម័យកាល គឺត្រូវនឹងចន្លោះសតវត្សទី១៧-១៨-១៩[17]។

រីឯបណ្ឌិត ធ សោ លោកយល់ថា អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ បានដល់ស្នាដៃ ដែលជាសាស្ត្រាល្បែងកើតនៅសតវត្សទី១៧-១៨-១៩[18]។

អ្នកស្រាវជ្រាវខ្មែរដ៏ឆ្នើមម្នាក់នៅប្រទេសបារាំង បណ្ឌិតសភាចារ្យ ឃីង ហុកឌី បានឱ្យដាគំនិតថា រឿងល្បែង ជាស្នាដៃអក្សរសាស្ត្រមួយដែលច្នៃប្រឌិតសម្រាប់ប្រលោមលោកលួងលោម អារម្មណ៍អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏

---

[13] ឃីង ហុកឌី, ***ទិដ្ឋភាពខុទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ២៧

[14] -ដ- ទំ. ២៥

[15] ជួន ណាត, ***វចនានុក្រមខ្មែរ***ភាគ១ភាគ២, ដ.ឯ.ម, ទំ. ៦៦៥

[16] សុំ ឈុំប៊ុន, ***ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍***, ២០០៣

[17] សោម សុមុនី, ***ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍***, ២០០៣

[18] ធ សោ, ***សិក្សារឿងព្រះវេស្សន្តរជាតក***, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ១៩៩៤, ទំ. ៣១

ប្រណីត ពោលគឺជាកំរងអត្ថបទរឿងរ៉ាវប្រពៃណី ដែលតាក់តែងជាកំណាព្យឃ្លោងឡើងនៅរវាងស.វ.១៨-១៩។ នេះជាផលិតកម្មអក្សរសាស្ត្រមានទំហំវែងអន្លាយ ចំនួនជាមធ្យមនៃរឿងល្បែងនីមួយៗ មានប្រហែល៨០០០ឃ្លា[19]។

រឿងល្បែង គឺជាស្នាដៃអក្សរសាស្ត្រដែលច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍អ្នកអានក្នុងកម្រងកំណាព្យ ដ៏ប្រណីតពោលគឺកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណីដែលតាក់តែងជាកំណាព្យឃ្លោងឡើងនៅសតវត្សទី ១៨-១៩[20]។ រឿងល្បែងតំណាងលក្ខណៈពិសេសនៃអក្សរសាស្ត្រសម័យកណ្តាលដែលជាអត្ថបទធំជាងគេក្នុងសម័យនោះ ដោយយោងទៅលើទំហំប្រវែងនៃអត្ថបទនីមួយៗ[21]។

ឆ្លងតាមរយៈការលើកយកលោកទស្សនៈនៃអ្នកអក្សរសាស្ត្រយើងរួចមកយើងអាចសំយោគបានថា សាស្ត្រាល្បែង គឺជាប្រលោមលោកសម័យកណ្តាល ដែលតាក់តែងជាពាក្យកាព្យបុរាណ អាចឆាបឆក់ព្រលឹង អ្នកអានឱ្យរន្ធត់ញាប់ញ័រទៅតាមសាច់រឿង ខ្លឹមសារច្រើនទាក់ទងនឹងចលនាពុទ្ធនិយម ហើយចារនៅលើស្លឹករឹត កើតមាននៅក្នុងចន្លោះសតវត្សទី១៧ ដល់១៩។ ប្រភេទសាស្ត្រាល្បែងនេះបានគាំទ្រទៅលើស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមភ្លាយនិងភ្លាយ ហួសហេតុយ៉ាងសំខាន់។ ត្បិតនាសម័យក្រោយអង្គរឬសម័យកណ្តាល សាស្ត្រាល្បែងបានដើរតួនាទីក្នុងការផ្សព្វផ្សាយយ៉ាងសកម្មនូវទស្សនៈ គោលគំនិតនៃពុទ្ធសាសនា។

១.៣- អក្សរសិល្ប៍លើក្រាំង

ចំណែកឯក្រាំងវិញ ក៏ប្រហែលមកពីពាក្យថា រាំង។ ដូច្នេះក្រាំងគឺជាគម្ពីរដែលគេយកក្រដាសស្នាយរឹង មកបិទភ្ជាប់គ្នាខ្ទប់ឬខ្ទប់ ឱ្យវានៅក្នុងពុម្ពតែមួយ ឬជាសៀវភៅតែមួយក្បាល មានសណ្ឋានជាផ្ទាំងៗអង្កាញ់ៗជាមួយគ្នា ដែលជាធម្មតាមាន៣៨ផ្ទាំ[22]។

ជាមួយគ្នានេះដែរ តាមវចនានុក្រមខ្មែរ សម្តេចសង្ឃ ជួន ណាត បានលើកថា ក្រាំងគឺជាសៀវភៅធ្វើដោយក្រដាសស្នាយ ឬក្រដាសមនជាដើម បត់ជាជាន់ៗជារបៀបត្រឹមស្មើ ប្រើបានសម្រាប់ សរសេរកត់ត្រាអ្វីទាំងពួង[23]។

ជារួមយើងឃើញថា ការចារទៅលើសិលាចារឹកមានភាពលំបាកច្រើនទាំងទំហំអត្ថបទក្នុងការចារមានលក្ខណៈខ្លី ហើយអត្ថន័យនោះទៀតសោតច្រើននិយាយអំពីព្រះមហាក្សត្រ ការធ្វើអំណោយទាន ដល់ប្រាសាទ ពាក្យសច្ចាប្រណិតជានជាដើម។ ដែលនេះជាហេតុធ្វើឱ្យទម្រង់អក្សរសិល្ប៍មានលក្ខណៈចង្អៀត។ របត់ថ្មីមួយបានប្រែប្រួលបែបបទក្នុងការចារឱ្យមានលក្ខណៈងាយស្រួលជាងសរសេរលើថ្ម ហើយអាចចារបានទំហំអត្ថបទវែងនោះ ដូនតាខ្មែរបានងាកមកប្រើការចារលើសាស្ត្រាស្លឹករឹតឬក្រាំងវិញម្តង។ អត្ថបទទាំងនេះត្រូវបានចារចម្លងតៗគ្នា នៅតាមវត្តអារាមនីមួយៗទុកសម្រាប់សិក្សា សូត្រស្វាធ្យាយជាដើម។

---

[19] ឃឹង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ៨៣

[20] កេង វ៉ាន់សាក់, ***ទិដ្ឋភាពខ្លះៗនៃអក្សរសិល្ប៍ខ្មែរ***, ប្រែសម្រួលដោយ សេន សេង, បោះពុម្ពលើកទី១, ភ្នំពេញ, ២០១៦, ទំ. ៣១

[21] ឃឹង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ៨៤

[22] លឹម ហាក់, ***សិក្ខាអំពីប្រវត្តិនិងបច្ចេកទេសគម្ពីរខ្មែរ***, ដ.ឯ.ម, ទំ. ៤

[23] ជួន ណាត,***វចនានុក្រមខ្មែរភាគ***១ ២, ដ.ឯ.ម, ទំ. ៨៩

២- ឥទ្ធិពលពុទ្ធសាសនាក្រោយសម័យអង្គរ

២.១- ពុទ្ធសាសនាក្នុងសង្គមខ្មែរ

ព្រះពុទ្ធសាសនាត្រូវបានចូលមកផ្សព្វផ្សាយនៅលើដែនដីសុវណ្ណភូមិក្នុងសតវត្សទី៣មុនគ.ស. ក្នុងរជ្ជកាលព្រះបាទអសោកមហារាជ ២១៨មុនគ.ស. [24] ។រីឯបើតាមគម្ពីរមហាវង្ស ពង្សាវតារលង្កាទ្វីប ក្នុងសៀវភៅពុទ្ធសាសនាសង្ខេប បានសរសេរថា កាលដែលព្រះសោណត្ថេរនិងឧត្តរត្ថេរនិមន្តទៅដែនដីសុវណ្ណភូមិនោះ ព្រះអង្គនិមន្តទៅកោះមួយហៅថា សុវណ្ណទ្វីប មានន័យថាកោះមាស។ តាមសេចក្តីខាងលើយើងអាចដឹងពីស្លាកស្នាមនៃពុទ្ធសាសនាបានហូរចូលមកសង្គមខ្មែរតាំងពីមុនគ.ស.មកម្ល៉េះ ប៉ុន្តែឥទ្ធិពលនៃពុទ្ធសាសនាពុំទាន់ជ្រួតជ្រាបដល់ស្រទាប់នៃប្រជានុរាស្ត្រនៅឡើយ។ នៅសម័យនគរភ្នំ ត្រូវបានគេយល់ថា គេគោរពព្រះពុទ្ធសាសនាហីនយានផង និងមហាយានផង ជាក់ស្តែងគេបានឃើញព្រះពុទ្ធរូប៤០អង្គ នៅតំបន់ភាគខាងក្រោមនៃទន្លេមេគង្គ នឹងមាននៅតំបន់ជាច្រើនទៀតនៅប្រទេសថៃដែលធ្លាប់មានទំនាក់ទំនងជាមួយអាណាចក្រភ្នំ [25] ។បន្តមកដល់សម័យចេនឡា ព្រះពុទ្ធសាសនាធ្លាប់តែមានការរីកចម្រើននាសម័យនគរភ្នំនោះ ត្រូវបានចុះអានុភាពខ្លួនបន្តិចម្តងៗតែពុំសាបសូន្យភ្លាមទេ ដោយគេបានរកឃើញ ព្រះពុទ្ធរូបនៅស្រុកព្រៃកប្បាសខេត្តតាកែវដែលបានកសាងឡើងនៅស.វ.ទី៧។ ដោយឡែកសិលាចារឹកនៅវត្តព្រៃរៀវស្រុកកំពង់ត្របែក ខេត្តព្រៃវែងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១បានសរសេរថា«មានកិក្ខុពីរអង្គជាបងប្អូនបង្កើតជាក្សត្រ បានចេញទៅសាងព្រះផ្នួសហើយគង់នៅវត្តព្រៃរៀងនោះមានព្រះនាមថា កិក្ខុរតនភាណុនិងកិក្ខុរតនសិង្ហ»[26]។ ក្នុងសម័យអង្គរ ដំណាក់កាលដំបូង ព្រះពុទ្ធសាសនាហីនយាននៅតែបន្តចុះអានុភាពនៅឡើយនោះព្រះពុទ្ធសាសនាមហាយាន(អាចរិយវាទ)មានការរីកចម្រើនរុងរឿង ចាប់តាំងពីសម័យកាលព្រះបាទរាជេន្ទ្រវរ្ម័នទី១ ព្រះអង្គបានប្រោសសណ្តោសដល់ ព្រះពុទ្ធសាសនា ទោះជាព្រះអង្គគោរពព្រហ្មញ្ញសាសនាក៏ដោយ[27]។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ត្រង់ជាសាសនិកដ៏ឆ្នើមប្រតិបត្តិព្រះពុទ្ធសាសនាមហាយានគោពព្រះពោធិសត្វអវលោកិស្វរៈ និងព្រះប្រាជ្ញាបារមិតា [28] ។ក្រោយសម័យអង្គរ ព្រះពុទ្ធសាសនាថេរវាទបានមកជំនួស ព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាមហាយាន។ តួយ៉ាងព្រះបាទពញាយ៉ាតមានជំនឿលើពុទ្ធសាសនាថេរវាទ ព្រះអង្គបានចាត់ឱ្យកសាងវត្តជាច្រើនកន្លែងនៅរាជធានីចតុមុខដូចជាវត្តលង្កា វត្តកោះ វត្តព្រះពុទ្ធឃោសារាម(វត្តចិនដំដែក) វត្តឧណ្ណាលោម វត្តខ្ពបតាយ៉ង់(វត្តបទុមវតី)និងវត្តភ្នំដូនពេញ។ចូលដល់រជ្ជកាលព្រះអង្គឌួង ព្រះអង្គបានជួសជុលនឹងកែលម្អវត្តអារាមដែលនៅជុំវិញក្រុងឧដុង្គឡើងវិញ ព្រមទាំងរៀបចំជារចនាសម្ពន្ធព្រះសង្ឃតាមហានានុក្រម ដោយមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈគឺ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយចាប់ពីឆ្នាំ១៩៤៧មក[29]។

---

[24] ហួត តាត, ***ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប***, ពុទ្ធសាសនបណ្ឌិត្យ, ២៩៧០, ទំ. ៤

[25] អៀន ហៀរសែ, ***ប្រវត្តិនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១***, នគរវត្ត, ២០១០, ទំ. ១៩

[26] ហ៊ុន ធារិទ្ធ, ***អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ, និក្ខេបបទ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ***,២០១៨, ទំ.៣០

[27] -ដ-, ទំ.៣១

[28] អៀន ហៀរសែ, ***ប្រវត្តិនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១***, នគរវត្ត, ២០១០, ទំ. ៤៦-៤៧

[29] ហ៊ុន ធារិទ្ធ, ***អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ***, -ដ-ឯ-ម-, ទំ.៣២

២.២- ឥទ្ធិពលពុទ្ធសាសនាមកលើអក្សរសិល្ប៍ខ្មែរ

ព្រះពុទ្ធសាសនាថេរវាទទៅសម័យកណ្តាល បានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរជំនួសឱ្យពួកព្រាហ្មណ៍ដ៏ល្បីល្បាញនៅសម័យអង្គរ ដែលបានផុតទៅនៅកំឡុងសតវត្សរ៍ទី១៤។ នៅក្នុងឯកសារពង្សាវតារទាំងអស់ បង្ហាញឱ្យឃើញថាពុទ្ធសាសនាថេរវាទជាសាសនារដ្ឋ និងជាសាសនាផ្លូវការមួយដែលមានលក្ខណៈឯកភាពនៅទូទាំងប្រទេស តពីនោះរហូតមកដល់សព្វថ្ងៃ។ រាល់សង្គ្រាមទាំងអស់ ទាំងសង្គ្រាមជាមួយបរទេស ជាពិសេសប្រទេសសៀមនិងទាំងសង្គ្រាមក្នុងស្រុក ការកាប់ចាក់គ្នារវាងសមាជិករាជវង្សានុវង្ស ដែលអាងថាខ្លួនមានសិទ្ធិឡើងសោយរាជ្យដូចគ្នា គេតែងយកលេសមួយយកមកនិយាយគឺ “ដើម្បីសេចក្តីសុខនៃសមណជីព្រាហ្មណ៍ និងប្រជានុរាស្ត្រផងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា”។ បន្ទាប់មកគេនឹងចាប់ផ្តើមធ្វើសង្គ្រាម ឬបញ្ឈប់សង្គ្រាម ដោយមានការចរចាបង្កើតយុទ្ធសន្តិភាពដោយស្មគ្រចិត្តរៀងៗខ្លួន (Eng 1985) [30]។

ដូចដែលយើងបានដឹងហើយថា ព្រះពុទ្ធសាសនាថេរវាទបានចូលមកកម្ពុជាស្របពេលដែលកម្ពុជាកំពុងធ្លាក់ខ្លួនទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាម កលិយុគ កាប់ចាក់ ហែកហួរគ្នា រវាងប្រទេសជិតខាង រវាងរាជវង្សគ្នាឯងជាដើម។ រីឯគម្ពីរក្បួនច្បាប់ផ្សេងៗត្រូវបានខ្ទេចខ្ទីទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាមនោះផងដែរ។ ដែលនេះជាហេតុធ្វើឱ្យប្រជានុរាស្ត្របាត់បង់នូវទំនុកចិត្តលើការដឹកនាំ គ្មាននូវសេចក្តីក្លាហាន ហើយផ្តេកផ្តួលទៅលើទស្សនៈរបស់ព្រះពុទ្ធសាសនា ដូចជាទស្សនៈកម្មផល ទស្សនបុណ្យបាប ឬទស្សនៈអរិយសច្ចៈជាដើម។ ក្នុងន័យនេះអាចធ្វើឱ្យពួកគាត់មានលំនឹងចិត្តឡើងវិញ។

ប្រភពអក្សរសិល្ប៍ខ្មែរក្រោយសម័យអង្គរ ឬសម័យកណ្តាលដែលជារឿងល្បែងមួយចំនួនធំគឺ ទាញមកពីគម្ពីរជាតកនៃព្រះត្រៃបិដកព្រះពុទ្ធសាសនា គម្ពីរបញ្ញាសជាតក និងកម្រងសង្គមធម៌និងវប្បធម៌ខ្មែរយើង។ កវីនិពន្ធបានប្រើពាក្យឬបញ្ញត្តិជាច្រើនទាក់ទងនឹងពុទ្ធសាសនាដូចជាបញ្ហាកម្មផល អន្តរាគមន៍ ទេវៈ ការសជាតិ។ល។ ដែលជាលក្ខណៈពុទ្ធសាសនាដែរ។ ចំណែកទីវាល និងទីកាលទៀតសោតគឺវែងឆ្ងាយណាស់ឧទាហរណ៍ ទីកន្លែងមាននៅស្ថានសួគ៌ជាជាន់ថ្នាក់ ស្ថានកណ្តាល ពារាណសី ព្រៃហេមពាន្ត ស្ថានបាតាល ស្ថាននរក ជាជាន់ជាថ្នាក់។ល។ ឯពេលវេលាគឺមានបច្ចុប្បន្នជាតិឬសព្វថ្ងៃ អតីតជាតិឬជាតិមុននិងអនាគតជាតិឬជាតិក្រោយៗ[31]។

ជាក់ស្តែងនៅក្នុងរឿង ពុទ្ធិសែន ដែលជាស្នាដៃសាស្ត្រាល្បែងមួយដែលមានប្រជាប្រិយភាពក្នុងសង្គមខ្មែរ រហូតដល់ប្រសិទ្ធនាមភ្នំមួយឈ្មោះថា ភ្នំនាងកង្រី។ មិនត្រឹមតែប៉ុណ្ណោះ រឿងនេះបានយកលំនាំតាម រថសេនជាតក ដែលស្ថិតនៅក្នុងគម្ពីរបញ្ញាសជាតកទៀតផង។ រឿងនេះក៏បានបង្ហាញពីលក្ខណៈកម្មផល ដែលខ្លួនបានសាង។ ពោលគឺបុព្វហេតុដែលនាំឱ្យនាងទាំងដប់ពីរ បានខ្វេះភ្នែកទាំងអស់នោះគឺបណ្តាលមកនៅពេលដែលនាងទាំង១២បានវង្វេងផ្លូវ ហើយនាងទាំងអស់បានចូលទៅក្នុងស្នឹងចុះទៅចាប់ត្រីជាអាហារ។ អ្នកទាំង១២បានចាប់បានត្រីចង្វាម្នាក់ៗ បាន

[30] វង់សុធាវ៉ា ណុបសុខា, ***ប្រវត្តិសាស្ត្រខ្មែរ***, ២០១៣, ទំ.១៣៦

[31] ឃីង ហុកឌី, ***ទិដ្ឋភាពខុវទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម., ទំ. ៨៤

ដោតក្នែកទាំងសងខាងរបស់ត្រីដើម្បីយួរ។ ប្លែកតែនាងពៅមួយដោតតែម្ខាងប៉ុណ្ណោះ ដូចយ៉ាងលើកក្នុងកំណាព្យឡើងថា៖

បបួលគ្នាផ្លាស់	សំពត់បន្លាស់	ដាក់ឆ្នេរនទី
ស្បៃគាតក្តាំងក្តាត់	ក្រវាត់ឥន្ទ្រិយ	អស់រៀមប្អូនស្រី
	ចរចុះគង្គា។	
ខ្លះរាវខ្លះចាប់	ខ្លះបានសម្លាប់	សឹងត្រីចង្វា
ដោតក្នែកទាំងសង	ពុំពិចារណា	នាងពៅពុំងា
	ដោតក្នែកតែមួយ។	
ហេតុពៀរនោះហោង	រត់ពុំរួចង	វេរាឯងឱ្យ
ងូតហើយឡើងគោក	ត្រណោតសៀតក្រោយ	ផ្លាស់សំពត់ដោយ
	អង្គឯងទីទៃ។[32]	

ទាំងនេះហើយដែលជាហេតុនាំឱ្យនាងទាំង១១ ត្រូវបានខ្វេះនេត្រាទាំងសង ហើយនាងពៅខ្វេះតែម្ខាង។ ក្នុងន័យនេះបើមើលទៅលើទ្រឹស្តីកម្មផល កម្មដែលសាងនៅក្នុងបច្ចុប្បន្នជាតិ ហើយផ្តល់ផលក្នុងបច្ចុប្បន្នជាតិគេហៅថាទិដ្ឋធម្មវេទនីយកម្ម។ នាងទាំង១២បានកសាងនូវកម្មដោយដោតក្នែកត្រីនោះត្រូវបានផ្តន្ទាមកក្នុងបច្ចុប្បន្នជាតិដូច្នេះដែរ។

រីឯរឿងស្រទបចេកវិញនោះយើងឃើញថា កម្មផលដែលចៅស្រទបចេកបានសាងនៅអតីតជាតិបានទទួលផលនូវបច្ចុប្បន្នជាតិ។ កម្មដែលនាំឱ្យចៅស្រទបចេក បាត់បង់អស់គ្រួសារ ទ្រព្យសម្បត្តិ រហូតទៅគ្មានខោអាវស្លៀកពាក់ទៅយកស្រទបចេកមកបិទបាំងខ្លួននោះបណ្តាលមកពី កាលពីជាតិមុនស្រទបចេកបានទៅ វាយសម្រាតស្បង់ព្រះសង្ឃធ្វើឱ្យព្រះសង្ឃអាក្រាតរត់ខ្មាសគេ ហើយកម្មពៀរនេះបានផ្តល់ផលដូច្នេះឯង។

សាមណេរមួយណា	ចរចេញយាត្រា	ទៅតែឯកអង្គ
គាប់ជួនបុរស	ដើរស្មោះទៅត្រង់	ជួបជុំលោកសង្ឃ
	សាមណេរនោះណា។	
បុរសនោះឯង	ចាប់សម្រាតលេង	តាមតែចិន្តា
សង្ឃនោះខ្មាសគេ	ឥតឯងឧបមា	បន្តិចបុរិសា
	ប្រគេនស្បង់វិញ។	
ពៀរនោះឯងណា	តាមទាន់កុមារា	ឱ្យរងទុក្ខម្នេញ
ពៀរនោះបាំងបិទ	ចិត្តសេដ្ឋីមិញ	មិនឱ្យគិតកាញ

[32] ***ពុទ្ធិវំសៈ***, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ១៦

ក្រែងកូនក្រីក្រ។[33]

នេះសបញ្ជាក់ឱ្យឃើញថា កម្ម ទាំងឡាយដែលស្រទបចេកបានប្រព្រឹត្តកាលពីជាតិមុនត្រូវបានទទួលផលនៅបច្ចុប្បន្នជាតិនេះឯង កម្មទាំងនេះនៅក្នុងទ្រឹស្តីកម្មផលគេហៅថា ឧបបជ្ជនីយកម្ម។ យ៉ាងណាមិញ តាមរយៈរឿងនេះអ្នកនិពន្ធចង់បង្ហាញឱ្យមនុស្សទូទៅកុំទៅប្រឡែងលេងខុសទំនងជាមួយព្រះសង្ឃ រហូតមានឃ្លា “កុំក្តីក្តាំនឹងសង្ឃ” ទៀត។

ចំពោះរឿងសព្វសិទ្ធិ ដែលជាវណ្ណកម្មរបស់ហ្មឺនភក្តីអក្សរ តន់ ក៏បានបង្ហាញនូវបញ្ហាកម្មផលនេះដែរ។ នៅត្រង់មូលហេតុដែលនាំឱ្យចាបចៀបកប្បាសទាំងពីសម្លាប់ទៅក្នុងក្នក់ភ្លើងទាំងខ្លួននិងកូនទៀតនោះ ក៏ដោយសារកម្មពីជាតិមុន អ្នកទាំងពីរជាមនុស្សហើយដុតសត្វស្លាបឱ្យស្លាប់ ម្ល៉ោះហើយកម្មពៀរនោះបន្តរហូតដល់ទៅប្រាំរយជាតិ។

ភ្លើងនោះក៏ឆេះដាផេះផង់ ផាយផាត់បាត់អង្គជាធូលី
សត្វនោះនាំគ្នាស្លាប់ទាំងពីរ ព្រោះមានវើរីទីវេរ។
កាលភពមុនឡើយបក្សានោះ បានលុះបុញ្ញភាពចាប់ជាតិជា
មនុស្សហើយដុតសត្វឱ្យមរណា វេរានោះតាមតែរាល់ជាតិ។
មោះមកផ្តន្ទានាលោកិយ បក្សាបក្សីកើតវិវាទ
ដុតខ្លួនឯងវិញពុំឃ្លាឃ្លាត គ្រប់ប្រាំរយជាតិទើបរដោះ។[34]

នេះជាកម្មដែលអ្នកទាំងពីរបានសាងពីអតីតជាតិហើយបានហុចផលមកបច្ចុប្បន្នជាតិ។ ជាងនេះទៅទៀតកម្មដែលអ្នកទាំងពីរមិនទុកចិត្តគ្នា របស់សត្វចាបចៀបកប្បាសត្រូវបានឆ្លងទៅអនាគតជាតិ ពោលគឺជាតិជាសព្វសិទ្ធិនេះឯង។ នៅក្នុងទ្រឹស្តីកម្ម-ផល កាលបើកម្មខ្លះទៀតអាចផ្តល់ផលក្នុងជាតិជាលំដាប់តទៅទៀតគេហៅថា អបរាបរវេទនីយកម្ម។

តាមរយៈការលើកឡើងខាងលើនេះ អាចសបញ្ជាក់ឱ្យឃើញពីឥទ្ធិពលនៃព្រះពុទ្ធសាសនាបានជ្រៀតចូលទៅក្នុងផ្នត់គំនិតខ្មែរ តាមរយៈស្នាដៃសាស្ត្រាល្បែងដែលជាតឹកតាងនៃអក្សរសិល្ប៍ពុទ្ធនិយមនាសម័យកណ្តាល។ ទាំងអស់នេះ។ ការទាំងនេះហើយដែលធ្វើឱ្យខ្មែរមានការខ្លាចរអានូវការប្រព្រឹត្តអំពើបាបទាំងឡាយ ដែលអាចនាំឱ្យខ្លួនធ្លាក់នៅក្នុងនរកអវចីជាដើម។ ឥទ្ធិពលពុទ្ធនិយមនេះជារនាំងមួយសម្រាប់បង្ខាំងមនុស្សឱ្យប្រព្រឹត្តល្អ អំពើជាកុសល ព្រមទាំងបន្ធូរភោពតានតឹងនៅក្នុងកាលៈទេសៈប្រទេសកំពុងមានកលិយុគបានផងដែរ។

៣- អក្សរសិល្ប៍ពុទ្ធនិយម

៣.១- ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម

គោលគំនិតសំខាន់ៗនៃព្រះពុទ្ធសាសនាត្រូវបានបែកជាជាបីដែលគេហៅថា ព្រះត្រៃបិដក។ ព្រះត្រៃបិដកមានបីផ្នែកគឺ វិន័យបិដក(ព្រះវិន័យ) សុត្តន្តបិដក(ព្រះសូត្រ) និងអភិធម្មបិដក(ព្រះអភិធម្ម)។ ក្នុងនោះអក្សរសិល្ប៍ខ្មែរ

[33] យស ងិន, ***ស្រទបចេក***, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ៥២
[34] ហ្មឺនភក្តីអក្សរ តន់, ***រឿងសព្វសិទ្ធិ***, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ១១

មួយចំនួនក៏បានដកស្រង់ចេញពីគម្ពីរព្រះពុទ្ធសាសនានេះដែរ។ អក្សរសិល្ប៍ពុទ្ធនិយមគឺជារឿងរ៉ាវអត្ថបទអក្សរសិល្ប៍ជាច្រើន ដែលអ្នកនិពន្ធបានដកស្រង់ចេញមកអំពីគម្ពីរក្នុងព្រះពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដក និងគម្ពីរអដ្ឋកថា ធម្មបទ វិសុទ្ធិមគ្គ មង្គលត្ថទីបនី ទសជាតក៍ និងបញ្ញាសជាតក៍ជាដើម មកតុបតែងជាចងក្រងជាវណ្ណកម្មរបស់ខ្លួន។[35] យោងទៅតាមលោក លាង ហាប់អាន លោកបានចែកអក្សរសិល្ប៍ពុទ្ធនិយមជាបីផ្នែកគឺ ពុទ្ធនិយមមែនទែន(ពុទ្ធនិយមសុទ្ធ) ពុទ្ធនិយមក្លាយ និង ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លេម)[36]។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ គឺជារឿងដែលស្ថិតនៅក្នុងជាតិទាំង១០របស់ព្រះពោធិសត្វមុនត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ពុទ្ធនិយមសុទ្ធនេះស្ថិតក្នុងគម្ពីរទសជាតក។ រឿងទាំងនោះមានដូចជារឿង តេមិយជាតក ជនកជាតក សុវណ្ណសាមជាតកជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយ គឺជាអក្សរសិល្ប៍ដែលអ្នកនិពន្ធបានដកស្រង់ ចេញអំពីគម្ពីរបញ្ញាសជាតក ជាគម្ពីរអដ្ឋកថាកើតមាននៅប្រទេសលាវ ត្រង់ឈៀងម៉ៃ ប្រហែល៥០០ឆ្នាំប៉ុណ្ណោះ[37] ។រឿងទាំងនោះមានដូចជា ព្រះសមុទ្ឃោស រឿងព្រះសុធនកុមារ រឿងក្រុងសុភមិត្រ រឿងទេវន្ធ រឿងសុបិនកុមារ ជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លេម)គឺជារឿងដែលពុំស្ថិតនៅក្នុងគម្ពីរ ក្បួនខ្នាតអំពីបុរាណណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់នាម ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធគ្រាន់តែថាប៉ុណ្ណោះ ពុំមានដំណើររឿងដូចគ្នាបេះបិទឡើយ ឧទាហរណ៍រឿងកាកី[38]។

៣-២. តំណែងនិពន្ធនៃរឿងបែបពុទ្ធនិយម

ចំពោះអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធនិងក្លាយ គេច្រើនសរសេរជាពាក្យរាយនិងកម្រងកែវ។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសត្រូវបានអ្នកនិពន្ធ ប្រើវិធីតែងជាពាក្យកាព្យ។ រឿងសឹងតែទូទៅតែងឡើងជាកំណាព្យដ៏មានបទផ្សេងៗគ្នា មានបទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា បន្ទោលកាក ឬពំនោលជាដើម។ ការដែលយកពាក្យកាព្យមកប្រើបែបនេះជាមធ្យោបាយសម្របសម្រួលទៅតាមគោលបំណង ក្នុងឧត្តមគតិរឿងដែលបំពេរអារម្មណ៍ បន្ធូរក្តីទុក្ខព្រួយឱ្យរសាយនេះឯង[39]។

ក. ផ្តើមរឿង

ចំពោះការផ្តើមរឿងនៃប្រភេទអក្សរសិល្ប៍ពុទ្ធនិយមយើងឃើញមានលក្ខណៈឯកភាពគ្នាស្ទើរតែទាំងអស់ ដោយបានធ្វើបទនមស្ការ ព្រះរតនត្រ័យ គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំឭកគុណគ្រូបាធ្យាយជាដើម។ ក្រៅពីនេះចំពោះអក្សរសិល្ប៍ពុទ្ធនិយមក្លាយនិងក្លាយហួសហេតុ កវីនិពន្ធក៏បាន សរសេររៀបរាប់អំពីថ្ងៃខែ ពេលវេលានៃការ

---

[35] ម៉ុញ សារី, ***វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ***, មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាពកម្ពុជា, ២០១១, ទំ. ២៦៤

[36] លាង ហាប់អាន, ***សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ*** ភាគ១, ១៩៦៦, ទំ.១៨២-១៣៧

[37] ម៉ុញ សារី, ***វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ***, ដ.ឯ.ម, ទំ. ២៦៤

[38] លាង ហាប់អាន, ***សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ ភាគ១***, ១៩៦៦, ទំ.២៣៦

[39] លាង ហាប់អាន, ***សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម., ទំ. ២១៦-២១៧

តាក់តែងនិពន្ធ ដោយពេលខ្លះជាពុទ្ធសករាជ មហាសករាជ ចុល្លសករាជជាដើម។ បន្ទាប់មកអ្នកនិពន្ធអាចប្រាប់អំពីគោរម្យ៍ងារ ឋានៈ ឬ នាមរបស់ខ្លួនមកបញ្ជាក់។

ឧ. នៅក្នុងរឿងហង្សយន្ត អ្នកនិពន្ធបានលើកបានឡើងដូច្នេះ

អហំយើងខ្ញុំ	ក្លែញក្រាបប្រណម	ព្រះអង្គឥតឆ្គង
កាលកបសន្លឹក	ពោធិព្រឹក្សទន្ទង	ព្រះអង្គជាច្បង
	ទូទាំងត្រៃភព។	
ស្តេចដូចការកេ	ត្រាត្រាច់ត្រដែត	ត្រដឹងស្តប់ស្តប់
ផ្ទុកសត្វនិករ	អមរសាយសព្វ	នានាំគ្រាន់គ្រប់
	ដាក់ដល់និព្វាន។	
បង្គំព្រះធម៌	ប្រសើរមានអាថ៌	ជាសំណាញ់ពណា
សម្តេចពុទ្ធវង្ស	ស្រោចស្រង់សត្វបាន	បរិបូណ៌ឋិតឋាន
	សុខសួគ៌ទៀងទាត់។	
បង្គំសង្ឃសាង	សីលសុទ្ធលះលាង	បាបបោះបង់បាត់
ទុកសោកប្រាយប្រាស	លាកលះស្នេហ៍ស្និទ្ធ	សេពសោយសម្បត្តិ
	សួគ៌សួស្តីសេដ្ឋោ។[40]	

ជាទូទៅយើងសង្កេតឃើញថា ក្នុងផ្នែកនៃសេចក្តីផ្តើមនេះ ស្ទើតែគ្រប់រឿងពុទ្ធនិយមក្លាយនិងក្លាយហួសហេតុ សុទ្ធតែប្រើកាព្យ បទកាកគតិ[41]។

ខ. ដំណើររឿង

ចំពោះដំណើររឿង ច្រើននិយាយពីជីវិតនៃពូជពង្សរាជវង្សានុវង្សនៃព្រះពោធិសត្វ ហើយដែលធ្វើទានសន្សំកុសលបារមីផ្សេងៗ។រីឯរឿងខ្លះបង្ហាញពីព្រះពោធិសត្វធ្វើចម្បាំងជាមួយស្តេចយក្ស ស្តេចមនុស្ស សត្រូវគ្រប់ទីទិស ឬពេលខ្លះជាមួយក្រុមគ្រួសារ ញាតិវង្សដែលក្បត់គ្នាចង់ដណ្តើមរាជសម្បត្តិ ហើយភាគច្រើនតួអង្គឯកដែលតំណាងសភាវៈល្អរមែងមានជ័យជំនះលើសភាវៈអាក្រក់ជាប់ជានិច្ច។ ពេលខ្លះជម្លោះត្រូវបានបញ្ចប់ដោយសន្តិវិធី ដោយការប្រើប្រាជ្ញាក្នុងការផ្ចាញ់សត្រូវ ឯពេលខ្លះទៀតក៏មានការធ្វើចម្បាំងគ្នាដែលជាឥទ្ធិពលរឿងនៅសេសសល់ពីទំនៅរលទ្ធិព្រាហ្មណ៍និយម។ ភាគច្រើនតួអង្គច្រើនតែជាស្តេចនិងមានសិទ្ធិធំធេងលើស្ត្រី ដោយគេអាចមានប្រពន្ធច្រើនដោយគ្មានការតវ៉ាពីប្រពន្ធដើមតែជានិច្ចកាលប្រពន្ធទាំងឡាយតែងតែមានការច្រណែន និន្ទា ឈ្នានីសគ្នាឬដណ្តើមរាជសម្បត្តិគ្នាទុកឱ្យកូនរៀងៗខ្លួន បង្កទៅជាទំនាស់មានការបែងចែងបក្សពួក កាប់ចាក់គ្នាពេញព្រំង។

---

[40] ***ហង្សយន្ត,*** ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៥២, ទំ.១

[41] សេង សោភា, ***សាស្ត្រាវិល្បែង***, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ មុខជំនាញអក្សរសិល្ប៍ រាជបណ្ឌិត្យសភា, ២០០៤,ទំ. ៧៤

ពេលខ្លះដំណើររឿងនិយាយពី បញ្ហាកម្មផលដែលតួអង្គបានប្រព្រឹត្តទៅពីអតីតជាតិហើយវាឆ្លងមកដល់បច្ចុប្បន្នជាតិជាដើម។ ម៉្យាងទៀត ដំណើររឿងខ្លះទៀតក៏បានបង្ហាញពីលក្ខណៈដែលនាំឱ្យឈានទៅរកគំនិតបែបវិទ្យាសាស្ត្រផងដែរដូចជារឿងហង្សយន្តជាដើម។

ចំណែកឯដំណើររឿង នៅក្នុងផ្នែររឿងមានជួប ព្រាត់ទុក្ខសោក សប្បាយ សង្គ្រាមកាប់ចាក់ស្លាប់ ដណ្តើមរាជ្យគ្នា តណ្ហា ច្រណែន ឈ្នានីស គឺសុទ្ធសឹងជាជីវិតពិតរបស់មនុស្សក្នុងសង្គម ឬលក្ខណៈមនុស្សនិយម។

ឧ. នៅក្នុងរឿងព្រះជិនវង្សជាដើម ស្តេចដិះហង្សទៅមានប្រពន្ធពីនគរមួយទៅនគរមួយនិងមានមហេសីដល់ទៅប្រាំពីរដោយពុំមានការរិះគន់ជិនឆ្ពន់ពីសង្គមឡើយ។គេចាត់ទុកជារឿងធម្មតា សម្រាប់បុរសភេទជាពិសេសបុរសដែលមានពូជពង្សខ្ពស់មានហានៈបុណ្យសក្តិឬជារាជវង្សជាដើម។ ក្រឡេកមើលរឿង កាកី ស្តេចមានស្រីស្នំរាប់ពាន់ រឿងស្រទបចេក ស្តេចមានមហេសីពីរគឺនាងកេសរមាលា និងនាងកេសរបុប្ផា រឿងពុទ្ធិសែននាងកង្រី ស្តេចមានមហេសី១៣ រួមទាំងនាងយក្សសន្ធមារ រឿងសង្ខសិល្បជ័យ ស្តេចមានមហេសីម្តង៧ នេះមិនគិតពីស្រីស្នំ កីលៀង មីនំមីនាងជុំវិញចាំគាត់បម្រើផង ក្នុងខណៈដែលភរិយា មហេសី និងស្នំទាំងនោះត្រូវបានគេប្រដៅឱ្យប្រកបដោយភក្តីភាព ស្មោះត្រង់នឹងប្តី ស្លាប់រស់ជាមួយស្វាមីតែម្នាក់ហើយបើករណីនាងធ្វើមិនបានឬបំពាននោះមិនត្រឹមតែស្វាមីនោះទេ សូម្បីសង្គមទាំងមូលមនុស្សស្រីដូចគ្នាក៏ថ្កោលទោសនាងដែរ។ នេះជាឧទាហរណ៍គំរូមួយ ដែលជាគុណវិបត្តិពិតៗរបស់សង្គមដែលមនុស្សប្រុសតែងតែឆ្លៀតកេងចំណេញយកប្រៀបលើស្ត្រីតាំងពីផ្នែកកម្លាំងកាយ កម្លាំងចិត្ត ផ្នែកជីវភាពរស់នៅ និងតតាំងទស្សនៈក្នុងសង្គមជាដើម។[42]

ចំពោះវិធីសរសេរ គឺគេប្រើពាក្យកាព្យចម្រុះបទគ្នាពីដើមដល់ចប់ក្រៅពីនេះក៏ឃើញមានការប្រើកាព្យកាកគតិសុទ្ធពីដើមដល់ចប់ច្រើនដែរ ឯបទអ្វីផ្សេងកម្រឃើញមានការសរសេរសុទ្ធ ពីដើមដល់ចប់ដូចបទកាកគតិនេះឡើយ។

អ្នកនិពន្ធប្រើពាក្យពេចន៍ធម្មតាលាយឡំនូវមគធភាសាឬសំស្ក្រឹតបន្តិចបន្តួចតាមចំណេះដឹងរបស់ខ្លួនក្នុងការតែងរៀបរៀង[43]។

គ. បញ្ចប់រឿង

ចំពោះបញ្ចប់រឿង អ្នកកវីនិពន្ធភាគច្រើនបញ្ចប់រឿងដោយមានការសជាតិ ចំពោះរឿងទាំងឡាយដែលមានប្រភពមកពីបញ្ញាសជាតកឬនានាជាតកជាដើម។ ម៉្យាងវិញទៀតរឿងមួយចំនួនតូចខ្លះអាចបញ្ចប់ដោយការធ្វើការឧទ្ទិសប្រាថ្នានូវកងកុសលជាបែបអធិដ្ឋាន។ រីឯរឿងមួយចំនួនទៀត នៅចុងបញ្ចប់អ្នកនិពន្ធបានប្រាប់នូវស្តេចចម្លងមកពីប្រទេសជិតខាងទៅវិញ។ នេះក៏ដោយសារនាកាលសម័យខ្មែរបែកបាក់ ឯកសារទាំងអស់នោះត្រូវបានសៀមយកទៅ ក្រោយពីប្រទេសបានសុខស្រួលអ្នកចេះដឹងបានទៅពីសៀមហើយចម្លងមកវិញហើយក៏បញ្ជាក់ថាជាសេចក្តី ប្រែសម្រួលដូច្នេះ។

ឧ. នៅក្នុងរឿង ពុទ្ធិសែននាងកង្រី ដែលបានបង្ហាញពីការសជាតិរបស់តួអង្គមួយចំនួនដូចជា៖

---

[42] សេង សោភា, ***សាស្ត្រាល្បែង***, ដ.ឯ.ម., ទំ. ៧៤

[43] លាង ហាប់អាន, ***សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម., ទំ. ២១៨

កិក្ខុអើយរីសេ-	ន្ធមារកាចក-	ន្លងលោកទាំងឡាយ
ឥឡូវចាកចេញ	វិលវិញពុំធ្លាយ	ទ្រឹស្តិទ្រុស្តសប្បាយ
	ចោរចិត្តឫស្សា។	
យោនយកកំណើត	កំណត់ទៅកើត	ជាចិញ្ចាវិកា
ធ្លាក់ទៅនរក	ទល់ទុក្ខវេទនា	លលៀកមិនត្រា
	មិនបានរំដោះ។	
រីមណីកែវសូរ	នាំពុទ្ធង្កូល	លីលាហៀវហោះ
ជាមោគ្គល្លាន	ស្រេចបានរឹងស្មោះ	លើសលែងចំពោះ
	ប្រសើរពេកពន់។	
រីព្រះតាបស	ទ្រង់ធម៌សប្បុរស	ប្រសើរពេកពន់
យោងយកជាតិជា	ព្រះមហាអនន្ត	អនេកគ្រប់គ្រាន់
	ចែកចប់ម្ល៉េះហោង។[44]	

ការបញ្ចប់រឿងបែបនេះ ធ្វើឱ្យស៊ីសង្វាក់ទៅនឹងប្រភេទរឿងជាតកនានា ទោះបីជាពេលខ្លះ ការសេជាតិនេះពុំសូវត្រឹមត្រូវសមហេតុផលដូចទសជាតក ឬបញ្ញាសជាតកក៏ដោយ។ នេះដោយហេតុថា សាស្ត្រាល្បែងជាអក្សរសិល្ប៍ពុទ្ធនិយមក្លាយខេមរនិយម ដូច្នេះបានផ្តុំចម្រុះនូវទេវៈនៃសាសនានិងជីវភាពរស់នៅពិតៗរបស់មនុស្សពោលគឺពុទ្ធនិយមលាយព្រាហ្មណ៍និយម និងក្លាយខេមរនិយម។

៤- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ

៤.១- ការអប់រំចរិយាសាស្ត្រ

យើងតែងតែឮអំពីការសរសើរថាមនុស្សជំនាន់មុនរៀនក្រោមសាលាវត្តអារាមគ្មានសៀវភៅ ទំនើបបោះពុម្ព តែហាក់បីដូចជាមានសីលធម៌ ប្រកបដោយសេចក្តីយោគយល់អធ្យាស្រ័យ ឬក៏ចេះគោរពឱនលំទោន ម្តាយឪពុក ចាស់ព្រឹទ្ធាចារ្យ ព្រមទាំងចេះស្គាល់បុណ្យបាប ល្អអាក្រក់ជាដើម។ រីឯបច្ចុប្បន្ន វិទ្យាសាស្ត្រីកចម្រើន ការសិក្សាបានខ្ពង់ខ្ពស់ មានសាលាទំនើបនៅក្នុងការសិក្សា ផ្ទុយទៅវិញ បញ្ហាសីលធម៌ហាក់បីដូចជាធ្លាក់ចុះគួរឱ្យកត់សម្គាល់។ តួយ៉ាងព្រះរាជសុន្ទរកថាក្នុងវេទិកាអរិយធម៌អាស៊ីលើកទី១នៅប្រទេសចិន ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់មានព្រះរាជបន្ទូលថា *"បច្ចុប្បន្ននេះសាកលលោកយើងកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការរីកចម្រើន និងជឿនលឿន ដោយមានជំនាញខាងវិទ្យាសាស្ត្រ និងសម្ភារៈដែលមិនធ្លាប់មានពីមុន។ ប៉ុន្តែទន្ទឹមនឹងការរីកចម្រើនខាងលើនេះសីលធម៌និងអភិសមាចារ ក្នុងជីវភាពសង្គម ក៏មានការស្រុតចុះគួរឱ្យព្រួយបារម្ភណាស់ដែរ។..."* ត្រង់នេះអាចឱ្យយើងឃើញពីការព្រួយបារម្ភ មិនចំពោះតែកម្ពុជា តែសម្រាប់សាកលលោកទាំងមូលអំពីបញ្ហាសីលធម៌នេះ។

[44] ***ពុទ្ធិវំសៈ***, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧២, ទំ. ២០៤

ក- សីលធម៌

អក្សរសិល្ប៍ពុទ្ធនិយម នាសម័យកណ្តាលបានដើរតួនាទីសំខាន់នៅក្នុងការក្រិត គូសវែងនូវការប្រព្រឹត្តរបស់មនុស្សឱ្យដើរតាមផ្លូវមួយដ៏ល្អ ក្លាយជាពលរដ្ឋប្រពៃសម្រាប់សង្គមជាតិ។ ភាពចម្រុះពណ៌នៃការអប់រំទៅលើសីលធម៌របស់មនុស្សនេះហើយបានធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមនេះបានបន្តអត្ថិភាពមកបច្ចុប្បន្នយើងនេះផងដែរ។

ជាការពិតណាស់ការរស់នៅក្នុងសង្គមមិនសំងំយកតែសុខបានតែម្នាក់ឯងឡើយ ពោលគឺយើងត្រូវពឹងពាក់ជួយគ្នាទៅវិញទៅមកទើបយើងអាចរស់នៅប្រកបដោយក្តីសុខពិត។ តួយ៉ាងនៅក្នុងរឿងព្រះវេស្សន្តរដែលជាជាតិទី ១០របស់ព្រះពុទ្ធអង្គមុននឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធនោះ ទ្រង់បានបំពេញនូវទានបារមីយ៉ាងក្រាស់ក្រែលបំផុត។ក្នុងចំណោមមហាទានទាំងប្រាំនោះ យើងងាកមកចាប់អារម្មណ៍លើការបំពេញធនបរិច្ចាគ។ នៅពេលស្តេចស្រុកព្រហ្មណ៍ឈ្មោះកលិង្គរាស្ត្រនៅឯទុរ្ភិក្ខគ្រាម មានគ្រោះទុរភិក្ស គ្មានស្លៀងធ្លាក់ ស្រូវដំណាំក៏ខូចខាត ទើបទ្រង់ត្រាស់ចាត់ឱ្យព្រាហ្មណ៍ទាំងប្រាំបីមាន រាមព្រាហ្មណ៍ ធជព្រាហ្មណ៍ លក្ខណព្រាហ្មណ៍ សុជាតិព្រាហ្មណ៍ កោណ្ឌញ្ញព្រាហ្មណ៍ សុយាមព្រាហ្មណ៍ យញ្ញព្រាហ្មណ៍ សុជាតមន្តព្រាហ្មណ៍ឱ្យទៅសុំដំរី បច្ច័យនាគេន្ទ្រដែលជាដំរីនាំមកនូវមង្គលនោះ។ ដោយយល់ឃើញនៅលក្ខណៈបែបនេះហើយទើបធ្វើឱ្យព្រះវេស្សន្តទ្រង់សុខចិត្តបរិច្ចាគឱ្យទោះបីជាមានការមិនពេញចិត្តពីសំណាក់ប្រជានុរាស្ត្រក៏ដោយ។ ត្រង់នេះអាចឱ្យយើងឃើញពីចិត្តសប្បុរសធម៌ មនុស្សធម៌របស់ព្រះវេស្សន្តក្នុងនាមបុគ្គលនៅក្នុងសង្គម ដោយមិនអាចឈរមើលមនុស្សជាតិទាំងមូលស្លាប់ដោយដាច់ស្បៀងយ៉ាងអាណោចអធ័មនោះទេ។

ជាតម្លៃសីលធម៌ ក៏ទោះបីជាមនុស្សយើងធ្វើខុសចំពោះអ្នកណាក៏ដោយ ការដែលភ្ញាក់រឭក ដឹងនូវទង្វើរបស់ខ្លួនដែលបានធ្វើខុសកន្លងនោះ ក៏ចាត់ចូលជាផ្នែកសីលធម៌មួយដ៏សំខាន់ផងដែរ។ ជាក់ស្តែងនៅពេលព្រះបាទបិលយក្សបានបាញ់ធ្នូសរចំសុវណ្ណសាមហើយនោះ ព្រះអង្គក៏បាននឹកស្តាយក្រោយចំពោះអំពើរបស់ខ្លួនដែលបានជ្រុលជ្រួសនោះ។ ការដែលបាញ់ចំសុវណ្ណសាមនេះ មិនបានធ្វើឱ្យសុវណ្ណសាមឈឺចាប់ទេ សាមបានសោកស្តាយព្រោះគ្មានអ្នកមើលថែម្តាយឪពុកខ្លួន។ ដោយការគិតពិចារណា ព្រះបាទបិលយក្សមិនអាចឈរមើលម្តាយឪពុករបស់សាមនៅកំព្រាទាំងខ្វាក់នេត្រានោះទេ។ ព្រះអង្គសុំខ្លួនចូលទៅបម្រើអ្នកទាំងពីរជំនួសសាម។ ត្រង់នេះបញ្ជាក់ពីការភ្ញាក់រឭករបស់ទ្រង់ ព្រមទាំងការទទួលខុសត្រូវមួយចំពោះអ្វីដែលខ្លួនបានធ្វើឡើង។ វាបានជួយជាគំនិតដល់ជនានុជនឱ្យចេះលុបលាងនូវកំហុសរបស់ខ្លួនដែលបានកសាងតាមរយៈការភ្ញាក់រឭក និងប្រឈមមុខនឹងអំពើរបស់ខ្លួនបានធ្វើក្នុងនាមជាមនុស្សជាតិ។

ក្នុងរឿងក្រុងសុកមិត្រ ដែលស្ថិតនៅក្នុងបញ្ញាសជាតក ហើយត្រូវបានតាក់តែងនិពន្ធជាបទកាព្យដោយឧកញ៉ាកោសាធិបតី កៅ នោះក៏បានឆ្លុះបង្ហាញពីតម្លៃខាងផ្នែកសីលធម៌ផងដែរ។នៅពេលដែលចាប់ដៃគ្នាជាប្តីប្រពន្ធ អ្នកទាំងពីរបីដូចជាជារូបមួយជីវិតពីរដូច្នេះឯង។ ម្ល៉ោះហើយអ្នកទាំងពីរត្រូវរួមសុខរួមទុក្ខជាមួយគ្នាមិនថាគ្រាណាក៏ដោយ។ ស្ថិតក្នុងវេលាដ៏លំបាកនៃការបាត់បង់រាជ្យសម្បត្តិទៅឱ្យអនុជក្រុងអសុកមិត្រ ព្រះបាទសុកមិត្របានលាមហេសីយាងទៅកាន់ព្រៃតែឯកឯង។ ប៉ុន្តែត្រូវបានព្រះនាងកេសនីដំទាស់ សុំយាងទៅតាមស្វាមីផង។ ដូចលើកឡើងថា៖

បើស្តេចចៀសចាក ឱ្យប្អូនលំបាក សមនឹងក្សីណាក្ស័យ
ប្អូនសុំទៅផង រួមរងក្សត្រៃ្ល ប្រការម្តេចក្តី
ពុំលែងឡើយហោង។(ទំ. ១៤)

ត្រង់នេះបើយើងងាកចេញពីតួអង្គកន្សែសារពេជ្ជ យើងអាចឃើញពីភក្តីភាពរបស់មនុស្សស្រីធម្មតា ដែលតែងគ្រាច់រង្គត់ទៅតាមស្វាមីគ្រប់ទិសទី។ ភក្តីភាពរបស់ព្រះនាងកេសនីនេះហើយ បានផ្តល់ជាតម្លៃខាងផ្នែកសីលធម៌នៅក្នុងក្រុមគ្រួសារឱ្យស្រឡាញ់គ្នាមិនមែនតែពេលមានបាននោះទេ តែត្រូវថែរក្សាគ្នារហូតដល់ចាស់កោងខ្នង ហើយគ្រប់កាលៈទេសៈទៀតផង។

រីឯរឿងទេវន្ទរបស់ អម្រឹតក្សត្រីម៉ុក ដែលតែងជាបទកាកគតិទាំងនោះ បានឆ្លុះបញ្ចាំងអំពីទស្សនៈបញ្ហាសីលធម៌ជាច្រើន ដែលអប់រំចរិយាសាស្ត្រមនុស្សឱ្យក្លាយជាមនុស្សល្អនៅក្នុងសង្គម។ តួយ៉ាងនាងចន្ទាដែលជាប្អូនរបស់ទេវន្ទ នៅពេលដែលគេចចេញពីយក្សនន្ទិដែលក្លែងជាបិតា នាងចន្ទាបានទៅដល់នគរហេមន្ត ហើយបានជួបនឹងរាជបុត្រមួយអង្គឈ្មោះ អភ័យកុមារ។ ត្រង់នេះ អ្នកទាំងពីរបានលបលួចរួមរ័ក្សទាំងក្មេងវ័យ ដោយមិនឱ្យបងដឹង។ មិនត្រឹមតែប៉ុណ្ណោះ អ្នកទាំងពីរបានរកល្បិចកល ដើម្បីប៉ុនប៉ងសម្លាប់ទេវន្ទទៀត ដូចលើកបង្ហាញ៖

អភ័យកុមារ យាងទៅទាស់ទ្វារ អរិបអង្គនាង
ព្រឺព្រួចស្នេហ៍សិទ្ធ ជួយជិតសារពាង្គ លើកពយាសយាង់
ចូលក្នុងស្គរមាស។
នាងផាត់នាងច្រាន ប៉ុន្មានៗ ពុំមានលាកលៈ
រួបរឹតអស់អង្គ ប្រតិយង្គមិត្រមាស ព្រឺព្រួចរួមវា-
ស្នាសិទ្ធស្នេហា។ (ទំ. ១១៨)

ត្រង់នេះហើយបានបង្ហាញឱ្យឃើញពីគំនិតនៅក្មេងវ័យ ឈាមរាវ ដោយយកកាមតណ្ហាដឹកមុខភ្លេចអ្វីទាំងអស់ ដែលខ្លួនជាស្ត្រី។ ម្យ៉ាងទៀតដោយអំពើទាំងនេះ នាំឱ្យនាងនិងភ័យកុមារ មានចិត្តឈានទៅសម្លាប់ទេវន្ទដែលជាបងតែមួយទៀតផង។ ក្នុងន័យនេះ ការកសាងគ្រួសារនៅក្នុងវ័យក្មេងពេកនាំឱ្យពួកគេងាយនឹងប្រព្រឹត្តអំពើឆ្គាំឆ្គង ព្រោះចិត្តនៅចង់សប្បាយ។ លើសពីនេះ ដំណើររបស់នាងចន្ទាហាក់កំពុងភ្លេចអ្វីទាំងអស់សូម្បីតែបង កម្រត់កម្រជាមួយគ្នានៅក្នុងព្រៃ ក៏ដាច់ចិត្តសម្លាប់។ វាឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាសីលធម៌ក្នុងនាមជាមនុស្ស មិនត្រូវភ្លេចបងប្អូនដែលជាឈាមរួមឧទរជាមួយ ក៏ទោះបីជាអ្នកមានប្តីឬប្រពន្ធ បងប្អូននៅតែជាមនុស្សដែលតាមជួយអ្នក ដូចពាក្យចាស់បុរាណលើកឡើងថា «កាត់ទឹកមិនដាច់ កាត់សាច់មិនបាន»។

នៅក្នុងបទនិពន្ធរបស់ព្រះឃ្លាំងនង សាស្ត្រាល្បែងកោគកុលកុមាររយើងក៏ឃើញបានពន្លេចឱ្យឃើញពីបញ្ហាសីលធម៌ជាចម្បងដែលនាំឱ្យឈានទៅរកអធិករណ៍នៃរឿង។ ក្នុងចំណោមការអប់រំនោះយើងឃើញកវីនិពន្ធបានលើកយកចំណុចមួយក្នុងការអប់រំសីលធម៌ ចរិយាសាស្ត្ររបស់នារីខ្មែរ តាមរយៈតួអង្គព្រះមាតារបស់នាងសុខុមាលន្ធាដោយព្រះនាងលើកពី ភរិយាកាឡណ្ណីដែលមានបីប្រភេទគឺ៖

១.ឃាដកវិយា៖ តាមរយៈរឿងភោគកុលកុមារលោកបានចែកឃាដកវិយាចំនួនបួនប្រការគឺ ប្រការទី១ ជាស្ត្រីរឹងរូស ប្រទូស្តរាយនឹងប្តី សម្លក់សម្លឹងពោលពាក្យទ្រគោះបោះបោកជាដើម។ រីប្រការទី២ ចិត្តស្រើបស្រាល លួចទៅរួមរ៉ែក្ស មានសហាយជាមួយអ្នកដទៃ។ រីប្រការទី៣ មិនចេះកោតខ្លាចគោរពស្វាមី ជេរស្តីដំណៀលមើលងាយប្តីជាដើម។ រីប្រការទី៤ មានចិត្តកំណាច ទៅនិយាយដើមប្តី និយាយអាក្រក់ពីប្តីឱ្យអ្នកផងដឹងឮជាដើម។

២. ចោរកវិយា៖ ការលើកឡើងនៅក្នុងរឿងចោរកវិយាមានប្រាំប្រការគឺ ប្រការទី១ ពុំខិតខំធ្វើការងារ ឬពុំរៀបចំប្រដាប់ប្រដាឱ្យប្តីទៅបំពេញកិច្ចការ។ ប្រការទី២ ពុំចេះសន្សំសំចៃ គិតតែចាយទ្រព្យប្តី បង្ហិនឱ្យទៅមិត្តភក្តិស៊ីចាយសប្បាយ ពុំចេះគិតគូរជាដើម។ ប្រការទី៣ មាសប្រាក់ដែលប្តីបានរកមកហើយបានពុំចេះទំនុកបម្រុង ទុកដាក់គិតតែចាយវាយតែផ្តាស។ ប្រការទី៤ គិតតែចេះតុបតែងខ្លួន ដើរលេងស៊ីផឹកបនកឿន មានសហាយហើយស្អប់ប្តីខ្លួនឯងជាដើម។ រីប្រការទី៥ លោកចែងថា បើប្តីស្រឡាញ់ហើយនោះធ្វើចិត្តធំ ងុិកង៉ក់ជាដើមធ្វើឱ្យប្តីអាក់អន់ចិត្ត។

៣. សត្រូវកវិយា៖នៅក្នុងរឿងភោគកុលកុមារ សត្រូវកវិយាលោកចែកមានប្រាំមួយប្រការគឺ ប្រការទី១ ពុំចេះទំនុកបម្រុងប្តី ពុំតាមចិត្តប្តី ពោលគឺយកតែតាមចិត្តខ្លួនឯង។ ប្រការទី២ ពុំចេះរៀបចំអាហារឱ្យប្តី បើមានចំណីគិតតែធីតែម្នាក់ឯង។ ប្រការទី៣ លោកហាមមិនឱ្យមានចិត្តធំជាងស្វាមី ពោលពាក្យបន្ទោកបង្អាប់ឱ្យប្តី។ ប្រការទី៤ មានចរិតកោងកាច គិតតែជេរប្រទេសផ្តាសា បន្ទោសប្តីពុំគិតពីបាប។ ប្រការទី៥ កាលបើប្តីមានទុក្ខគិតតែមើលបំណាំ ពុំជួយសម្រាលទុក្ខ ហើយបើប្តីឈឺពុំទៅរកថ្នាំសង្កូវឬ ហៅពេទ្យហ្មមកមើលប្តីឡើយ។ និងប្រការទី៦ នៅពេលប្តីស្តីប្រដៅខឹងច្រឡោតនឹងប្តីដោយពោលពាក្យទ្រគោះបោះបោកជាដើម។

ក្រៅអំពីការអប់រំនូវសីលធម៌របស់ស្ត្រីហើយ ព្រះឃ្លាំងនងក៏បានបង្ហាញពីទុក្ខទោសដែលភរិយា បានប្រព្រឹត្តនូវកាឡណ្ណីភរិយានេះនោះនឹងធ្លាក់ទៅនរកឯទុក្ខពន់ពេក អស់កាលមួយកប្បទើបរួចមក កើតជាស្រីផ្តាមាស ឬជាយក្ខិនី ឬជាស្ត្រីមេម៉ាយអស់កាលប្រាំរយជាតិ។ សូម្បីតែស្ត្រីនោះបានកសាងទានខ្លះក៏ដោយក៏ពុំអាចមាននរណាម្នាក់ជួយឱ្យរួចផុតបានដែរ ដោយសារស្ត្រីនោះមានចិត្តក្រៅធម៌។

លើសពីនេះព្រះមាតារបស់សុខុមាលន្ទាទេវីក៏បានងាកទៅអធិប្បាយអំពី ឥរិយាបទទាំងបួនប្រភេទដែលភរិយាគួរប្រព្រឹត្តតាមនោះរួមមាន៖

១. មាតុភរិយា៖ព្រះនាងបានលើកមាតុភរិយាមានប្រាំប្រការគឺ ប្រការ១ ចេះរក្សាទ្រព្យធនដែលប្តីបានរកមកកុំឱ្យបង់បាត់ជាដើម។ ប្រការទី២ ចេះឈឺឆ្អាលពេលប្តីមានទុក្ខ ឬមានជំងឺឈឺថ្កាត់ ត្រូវចេះរត់រកពេទ្យមកជួយព្យាបាលថែទាំ។ ប្រការ៣ កាលបើមានម្ហូបអាហារថ្មីៗល្អៗត្រូវចេះទុកឱ្យស្វាមីជាអ្នកបរិភោគផង។ ប្រការ៤ ចេះទំនុបបម្រុងប្តីក្នុងរបរការងាររកស៊ីជួញប្រែទាំងឡាយ។ ប្រការ៥ ជាស្ត្រីត្រូវចេះរាប់អានញាតិផៅ កាលបើមាននំនែកត្រូវចេះចែកជូនញាតិកុំកំណាញ់តែឯង។

២. ភគិនីភរិយា៖ តាមរយៈរឿងលោកបានលើកពីភគិនីភរិយាមានបួនប្រការគឺ ត្រូវចេះស្រឡាញ់ប្តី ហើយទុកដូចជាបងខ្លួន។ ប្រការ២ ត្រូវចេះមានចិត្តអំណត់ ពុំឈ្លោះរករឿងនឹងអ្នកបម្រើផងទាំងពួង។ ប្រការ៣ ត្រូវចេះគាល់

បម្រើ ប្រណិប័តន៍ប្តី មិនត្រូវប្រចណ្ឌញុកញ៉ក់ រំខានចិត្តប្តី។ ប្រការ៤ មានមារយាទត្រឹមត្រូវមិនត្រូវហិចហើរនាំឱ្យប្រុសដទៃយល់បាននោះឡើយ។

៣. មិត្តភរិយា៖ លោកលើកឡើងថាមិត្តភរិយាមានបីប្រការគឺ ប្រការ១ មិនប្រទូស្តរាយ រឹងរូសបណ្តាលឱ្យប្តីមានការអាក់អន់ស្រពន់ចិត្ត។ ប្រការ២ ត្រូវចេះស្រឡាញ់ប្តី រាក់ទាក់ដូចមិត្ត។ ប្រការ៣ ត្រូវមានអនុកូល(សេចក្តីទំនុកបម្រុង សង្គ្រោះ ករុណា ពេញចិត្ត)នឹងស្វាមី ពុំមានកលល្បិចអ្វីឡើយ។

៤. ទាសភរិយា៖ លោកបានលើកពីទាសភរិយា មានបីប្រការគឺ ប្រការ១ ស្មោះស្ម័គ្រនឹងប្តី មានសំដីពីរោះ ចេះផ្ញើខ្លួនលើប្តីឱ្យប្តីអាណិត។ ប្រការ២ បើស្វាមីស្រឡាញ់ស្រីស្នំបរិពារ ត្រូវចេះជួយស្រឡាញ់ បំពេញចិត្តប្តីដោយក្តីស្មោះស្ម័គ្រ។ ប្រការ៣ បើប្តីខេខឹងស្រដីត្រគោះបោះបោកជេរទាំងប៉ុន្មានក៏កុំឆ្លើយឈ្លោះត ត្រូវសាសងមកវិញដោយពាក្យពីរោះវាចា។

កាលបើស្ត្រីទាំងអស់ត្រូវបានធ្វើដូចស្ត្រីទាំងបីប្រភេទខាងលើ នោះគេមិននិន្ទាដល់ម្តាយ។ មិនត្រឹមតែប៉ុណ្ណោះទេព្រ័ក្ស ទេវតាទាំងឡាយ ជួយជ្រោមជ្រែងឱ្យពរ សុខសប្បាយ លុះចប់ជាតិទៅសោយសុខនៅឋានតុសិត មានប្រាង្គប្រាសាទល្អ មានស្រីទេពអប្សរទាំងឡាយរៀបជាជួរចាំគាល់ត្រៀបត្រាក្រាស់ក្រៃ។ ម្យ៉ាងបើអស់បុណ្យនៅឋានសួគ៌នឹងច្យុតមកកើតនាត្រកូលក្សត្រ មានប្រាជ្ញាដូចទេវតាជាស្រីគ្រប់លក្ខណ៍។ មិនត្រឹមតែប៉ុណ្ណោះ នាងនឹងបានជាមហេសីក្សត្រា បរមចមចក្រាធិរាជ នរណាទៅប្រៀបផ្ទឹមបាន។ ទោះបីជាចង់បានប្រាថ្នាជាកន្សែសារពេជ្ឈ ក៏បានដូចចិត្ត ព្រោះជាបុណ្យរបស់នាង។

បើយើងងាកមកមើលសាស្ត្រាមរណមាតា ដែលពេញនិយមរបស់ខ្មែរគ្រប់ស្រទាប់វណ្ណៈ ហើយវាបានក្លាយជាផ្នត់គំនិត ទស្សនៈខ្មែរចំពោះត្រីដំរី ដែលគិតថាជាមនុស្សចាប់ជាតិ នាំឱ្យប្រជាជនមិនបរិភោគទៀតផង។ ក្នុងនោះ កវីក៏បានលើកយកបញ្ហាសីលធម៌មកពន្លេចជាចម្បងនៃចំណោទបញ្ហារឿង។ ចាប់ចេញពីបញ្ហាពុំចេះស្តាប់បង្គាប់របស់មេបាដូចនាងកុលកេសីដែលជាកូនរបស់សេដ្ឋីបានទៅលបលួចស្នេហា ទុំមុនស្រគាលជាមួយនឹងកុដុម្ពីក៍ក្បែរផ្ទះ រហូតនាំគ្នាពង្រាត់ចេញពីផ្ទះទៅឆ្ងាយ ដូចលើកឡើងថា៖

កុដុម្ពីក៍សោតបាន	រួមសុខរួមប្រាណ	នឹងកេសីណា
ស្រេចហើយកីលៀង	នាំនាងធីតា	វិលទៅគ្រឹហា
	ដូចដើមប្រក្រតី។	
កេសីឆ្លើយថា	អ្នកគិតនោះជា	ពេញត្រូវប្រាកដ
ស្រេចហើយកុដុម្ពីក៍	គិតទីកំណត់	រៀលនឹងរត់
	ប្រាប់កុលកេសី។(ទំ. ១៤)	

ដូចដែលយើងឃើញហើយថា បញ្ហាទុំមុនស្រគាលនេះ នៅក្នុងប្រព័ន្ធគំនិតខ្មែរពុំសូវពេញចិត្តនោះទេនូវបញ្ហានេះ មិនត្រឹមតែប៉ុណ្ណោះ រហូតឈានដល់ការពង្រាត់គ្នាចាកចេញពីផ្ទះ វាកាន់តែមិនសមរម្យ។ ម្តាយឪពុករមែងចង់ឃើញកូនសំពះក្រាបផ្ទឹម មានផ្តាស្លា មានមេបាតូចធំទទួលស្គាល់។ ផ្ទុយទៅវិញ ការធ្វើនូវទង្វើនេះទោះបីជាសង្គមទទួលយកក៏

ដោយ ក៏មានការនិន្ទាពីមនុស្សមួយចំនួនដដែល។ ទង្វើរបស់កុលកេសីដែលមិនស្តាប់ឪពុកម្តាយនេះ ត្រូវបានទទួលរងកម្ម ពោលគឺនាងត្រូវបានស្លាប់យ៉ាងអណោចអធ័មចោលកូនស្រី ដោយសារតែប្តីជាទីស្រឡាញ់របស់ខ្លួនរើសដោយផ្ទាល់។

ខ- គុណធម៌

គុណធម៌ជាចំណុចមួយដ៏សំខាន់សម្រាប់មនុស្ស។ យោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួនណាត គុណធម៌ គឺជា ធម៌ដែលមានដំណើរចម្រើនសេចក្តីសុខទុក្ខតាមជាន់តាមថ្នាក់ បានខាងអំពើល្អ អាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ។ គុណធម៌ មកពីពាក្យ “គុណ” ជាដំណើរធ្វើឱ្យចម្រើនឡើង ដោយលក្ខណៈដែលអ្នកដទៃគួរគោរព រីង “ធម៌” ជាឱវាទ ក្រឹត្យក្រម ច្បាប់ វិន័យ ពាក្យទូន្មានណែនាំ។ ក្នុងន័យនេះ គុណធម៌ បានសេចក្តីថា ការប្រព្រឹត្តអំពើល្អប្រសើរចំពោះអ្នកដទៃ ដែលជាអំពើនាំមកនូវភាពចម្រុងច្រើន កាន់តែច្រើនដែលគេផងរាល់គ្នាគោរព កោតសរសើរ ហើយក៏មានទឹកចិត្តកតញ្ញូ ចង់តបស្នងនូវអំពើល្អនោះត្រឡប់ទៅវិញ ដោយទឹកចិត្តជ្រះថ្លាពីក្នុងចិត្តក្នុងបេះដូងគេ។

នៅក្នុងរឿងមហាវេស្សន្តរជាតកក៏បានពន្លេចឱ្យឃើញពីតម្លៃគុណធម៌ជាមនុស្សជាតិមួយនៅលើភពផែនដី។ យើងឃើញហើយថា ការបំពេញទានរបស់ព្រះវេស្សន្តរ បើពិតថាវាជាកាតព្វកិច្ចមួយរបស់ព្រះអង្គក្នុងការបំពេញទានបារមីក៏មែនពិត តែការបំពេញទាននេះបានប៉ះពាល់ដល់នគរទាំងមូល អាក់អន់ស្រពន់ចិត្តនឹងទង្វើរបស់ព្រះអង្គដែលប្រគល់ដំរីបច្ច័យនាគេន្ទ្រទៅអ្នកស្រុកកលិង្គរាស្ត្រ។ ការនេះហើយនាំឱ្យអ្នកស្រុកស្រីពិរាស្ត្របះបោរឡើង តវ៉ាជាមួយព្រះបាទស្រីសញ្ជ័យ។ ដើម្បីបំពេញកាតព្វកិច្ចជាបុត្រល្អផង និងជាការបញ្ចៀសការមាក់ងាយមកលើព្រះអង្គដែរនោះ ព្រះវេស្សន្តរបានសុខចិត្តយាងទៅកាន់ភ្នំគិរីវង្គត។ នេះសឱ្យឃើញពីទឹកព្រះទ័យរបស់ព្រះអង្គ ក៏ទោះបីជាទ្រង់មានអំណាចយ៉ាងណា ក៏មិនប្រើគាបសង្កត់ទៅលើរាស្ត្រទ្រង់ នាំឱ្យក្តៅក្រហល់ក្រហាយពេញនគរដែរ។

ជាមួយគ្នានេះក្នុងរឿងសុវណ្ណសាមជាតក ក៏បានបង្ហាញពីតម្លៃគុណធម៌របស់តួអង្គដែលយើងអាចយកគ្រាប់តាមបានផងដែរ។ ជាគុណធម៌ក៏ដូចជាកាតព្វកិច្ចរបស់កូនៗត្រូវចេះបម្រើមាតាបិតាដោយមិនអាចអាក់ខានបានឡើយ។ ត្បិតលោកទាំងពីរបានលះបង់ដើម្បីយើងតាំងពីតូចក្រូចឆ្មារហូតដល់ពេញវ័យដឹងខុសត្រូវ។ សមដូចពុទ្ធដីកាដែលលើកឡើងថា “មាតាបិតាជាព្រះកន្លោង”។ ត្រង់នេះតួនាទីរបស់អក្សរសិល្ប៍ពុទ្ធនិយមបានអប់រំសីលធម៌កូនចៅប្រុសស្រីឱ្យចេះដឹងគុណមាតាបិតាផងដែរ។ ជាក់ស្តែងនៅក្នុងរឿងសុវណ្ណសាម តួអង្គសុវណ្ណសាម ចាត់ទុកជាអតិជាតបុត្រ ក៏ព្រោះតែនៅពេលដែលទុកូលនិងបាវិកាត្រូវបានចំហាយអាសិរ្ពិសនោះ បញ្ចេញចំហាយពិសតាមរន្ធច្រមុះបណ្តាលឲ្យឱ្យអ្នកទាំងពីរងងឹតភ្នែកមើលមិនឃើញ។ ពេលសុវណ្ណសាមដឹងហើយសុវណ្ណសាមយំតែក្រោយមកវិញក៏សើច ត្បិតគិតថាខ្លួនបានចិញ្ចឹមថៃលោកទាំងពីរដោយផ្ទាល់។ លើសពីនេះនៅពេលសុវណ្ណសាមត្រូវសរបស់បិលយក្សពាក្យដំបូងរបស់សុវណ្ណសាមគឺ អំណឹះតទៅគ្មានណាមើលថែម្តាយឪពុក។ សុវណ្ណសាមមិនបានអល់អែកនឹងការឈឺចាប់របស់ខ្លួនឡើយ។ នេះហើយសឱ្យឃើញពីគុណធម៌របស់កូនចំពោះម្តាយឪពុកដែលលោកទាំងពីរមានគុណធំធេងមិនមានអ្វីបានផ្ទឹមបាន។ នៅក្នុងដំពូកមេត្តាបារមីរបស់ព្រះសុវណ្ណសាមនេះ មិនត្រឹមតែបង្កប់នូវក្តីមេត្តាចំពោះសត្វលោកនោះនេះ ក៏បានភ្ជាប់ទៅនឹងភាពកតញ្ញូរបស់បុត្រធីតា ដែលមាតាចង់បានផងដែរ។ ពិតណាស់ម្តាយឪពុករមែង

ចង់បានបុត្រព្រោះមានបំណងប្រាំយ៉ាងគឺ ទី១ ចង់ឲ្យបុត្រចិញ្ចឹមខ្លួនវិញ។ទី២ ចង់ឱ្យបុត្រជួយធ្វើការងារ។ទី៣ ចង់ឲ្យបុត្រលើកស្ទួយវង្សត្រកូល។ទី៥ ចង់ឲ្យបុត្រទទួលមត៌ក។ និងទី៥ កាលស្លាប់ទៅចង់ឲ្យបុត្រធ្វើបុណ្យឧទ្ទិសកុសលឱ្យ [45] ។ កាលបើយើងបានបំពេញនូវកាតព្វកិច្ចទាំងនេះហើយកាលណា បុត្រធីតានឹងទទួលបានអានិសង្សជាច្រើនគួរយ៉ាងដូចព្រះសម្មាសម្ពុទ្ធសរសើរព្រះសង្ឃចិញ្ចឹមមាតាបិតា ដែលជាពុទ្ធភាសិតទ្រង់សម្តែងទុកមកក្នុងព្រហ្មសូត្រ និងសោណនន្ទជាតក ជាបទគាថាថា៖

តាយ ឯំ ចារិចរិយាយ មាតា បិតូសុ បណ្ឌិតា

ឥធេវ ឯំ បសំសន្តិ បេច្ច សគ្គេ បមោទតិ។

សេចក្តីប្រែថា (អ្នកឯណា) បានប្រតិបត្តិបម្រើនូវមាតាបិតារបស់ខ្លួនហើយ អ្នកប្រាជ្ញទាំងឡាយនោះតែងសរសើរនូវអ្នកនោះ ក្នុងលោកនេះថា អ្នកនេះជាមនុស្សមានចិត្តកតញ្ញូចេះប្រតិបត្តិនូវអ្នកមានគុណចំពោះខ្លួន ឯការប្រតិបត្តិយ៉ាងនេះហើយ ដែលជាផ្លូវឬជាជណ្តើរសម្រាប់អ្នកនោះនឹងឡើង ទៅកើតក្នុងឋានសួគ៌នោះមិនខាន ដល់វេលានឹងទៅកាន់បរលោកខាងមុខទៀត ក៏អ្នកនោះឯងនឹងគង់មានប្រទះនូវលោកយ៉ាងធំគឺសេចក្តីរីករាយសប្បាយចិត្តដោយទិព្វទ្រព្យសម្បត្តិទាំងឡាយម្តងទៀត[46]។

ក្នុងសាស្ត្រល្បែង ក្រុងសុភមិត្រដែលដកស្រង់ចេញពីបញ្ញាសជាតកនោះក៏បានបង្ហាញការគោរពទៅលើគុណធម៌ដឹងស ខ្មៅ ល្អ អាក្រក់ជាដើមនោះ។ ជាក់ស្តែងនៅពេល ក្រុងសុភមិត្របានទទួលដំណឹងថា អាមាត្ររបស់ខ្លួន ជ័យសែន និងជ័យទត្តបានទៅបៀតបៀននាងកេសនីដែលជាអ្នកជាភរិយានាយកេត្រានោះ។ ក្រុងសុភមិត្រក្រោធយ៉ាងខ្លាំង ហើយបញ្ជាឱ្យពេជ្ឈឃាតយកអ្នកទាំងពីរទៅសម្លាប់ចោល។ តែត្រូវបានព្រាហ្មណ៍ បុរោហិតទូលជំទាស់មិនឱ្យយកទៅសម្លាប់ ត្បិតវាខុសនឹងប្បវេណីពីបុរាណកាល ដូចលើកឡើងថា៖

ខ្ញុំសូមឃាត់ព្រះចក្រី ត្បិតខុសវេណី អំពីបុរាណរៀងរាជ្យ។

ពុំដែលធ្វើនឹងអំណាច សម្លាប់ជាកាច ពិតពុំមានពិចារណា។(ទំ.៨០)

ដោយយល់ឃើញយោបល់របស់ព្រាហ្មណ៍បុរោហិត ត្រឹមត្រូវព្រះអង្គក៏ត្រាស់ឱ្យយកកុមារទាំងពីរមកសួរនាំ។ យើងឃើញថាដោយសារការទូលជំទាស់របស់ព្រាហ្មណ៍ បានធ្វើឱ្យការពិតអាចលេចត្រដែតឡើង។ ក្រុងសុភមិត្រក៏បានដឹងរឿងពិត ហើយបានជួបជុំមូលគ្រួសារឡើងវិញ។ ត្រង់នេះស្តែងឱ្យឃើញថា ការដែលធ្វើអ្វីដោយមិនបានគិតពិចារណាមុនវានាំឱ្យមានវិប្បដិសារីកើតឡើងជាមិនខាន។ ការខ្វះការត្រិះរិះ ធ្វើឱ្យកម្លាំងនៃទោសៈ មោហៈ បិទបាំង សប្រែជាខ្មៅ ល្អប្រែជាអាក្រក់ជាមិនខាន។

ជាមនុស្សរស់នៅក្នុងសង្គមត្រូវប្រកបដោយចរិយាធម៌ និងប្រកាន់នូវសីលជាប់ខ្លួនជានិច្ច។ ការគោរចាស់ព្រឹទ្ធាចារ្យ ជាចរិយាធម៌ដ៏សមប្រកបដែលជនគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់ឱ្យបាន ដើម្បីសេចក្តីថ្លៃថ្នូរ ក៏ដូចជាបង្ហាញពី

[45] កិត្តិ គូ សុភាព, ***សីលធម៌ព្រះពុទ្ធសាសនា***, ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ២០០៨, ទំ.៣៨

[46] ញាន ភឿន ស៊ិន សុវណ្ណនិ, ***លំអានទំនៀមខ្មែរបុរាណ ភាគ៤***, ភ្នំពេញ, ២០១៦, ទំ. ១០៨

តម្លៃសីលធម៌ដ៏ថ្លៃថ្នូររបស់ជាតិខ្លួន។ នៅក្នុងរឿងទេវន្ទនេះដែរ បានបង្ហាញអំពីការគោរពទៅដល់ចាស់ព្រឹទ្ធាចារ្យគឺឥសីអសង្ខេយ្យ ដែលជាឥសីស្មឹងស្មាធិចម្រើនចតុពេទ្យសាស្ត្រពុទ្ធបាទនៅនាក្នុងព្រៃជ្រៅ។ ព្រះទេវន្ទ ដែលបានជិះអាជានេយ្យហោះលើអាកាស ពេលបានឃើញព្រះទេវន្ទជាឥសីចម្រើនធម៌នៅក្នុងព្រៃ ក៏បានប្រាប់សេះឱ្យចុះទាបចូលទៅដើម្បីគោរពដល់លោកតាឥសី ក្នុងបំណងជាកុសលផលបុណ្យផង និងដើម្បីសួរនាំក្រែងព្រះអង្គដឹងទីដែលមាននារីប្រកបដោយលក្ខិណា។

បងអើយត្បិតមាន	អាស្រមទីហាន	ឥសីសីលា
ចូរបងចុះទៅ	យើងនៅនមស្សការ	ប្រតិស្ឋានជា
	កុសលផលបុណ្យ។	
យើងទៅសួរសោន	រកស្រីកល្យា-	ណីនៅតំបន់
ដ្បិតលោកមានមែន	ព្រះញាណទិព្វតន់	ឯងអាចគួរគេន់
	សុះសព្វសួគ៌ព្រហ្ម។(ទំ. ២០៧)	

តាមរយៈការបង្ហាញខាងលើ ឃើញថាព្រះទេវន្ទជាមនុស្សដែលប្រកបដោយចរិយា គឺព្រះអង្គបានបង្ហាញនូវការគោរពចំពោះចាស់ព្រឹទ្ធាចារ្យដែលប្រកបដោយសីល។ ព្រះអង្គមិនបានប្រកាន់ថាខ្លួនជាក្សត្រនោះទេ គឺព្រះអង្គនៅតែសម្តែងការគោរពចំពោះឥសីអសង្ខេយ្យ ដែលជាអ្នកចម្រើននូវធម៌ក្នុងព្រៃ និងចម្រើននូវពុទ្ធសាស្ត្រ។ ដូចគ្នានេះដែរជនគ្រប់រូបក្នុងសង្គម ត្រូវចេះគោរពនូវចាស់ទុំព្រឹទ្ធាចារ្យ មិនថាជាចាស់ព្រឹទ្ធាចារ្យដែលជាអ្នករក្សាសីល ឬក៏មិនមានរក្សាសីលនោះទេ។ ជាកុលបុត្រកុលធីតា ត្រូវប្រកាន់នូវសីលធម៌ដ៏ល្អផូរផង់នៅក្នុងសង្គមដែលមានតពីបូរាណមក គឺការចេះគោរពចាស់ទុំនេះឯង។ វាជាទម្លាប់ដែលប្រកបដោយតម្លៃ បញ្ជាក់ពីអត្តសញ្ញាណរបស់ជាតិរបស់យើង។ ដូច្នេះយុវជនទាំងឡាយត្រូវប្រកាន់នូវសីលធម៌ដ៏ល្អនេះគឺ ការគោរពចាស់ព្រឹទ្ធាចារ្យ និងស្តាប់នូវដំបូន្មានរបស់គាត់។

រីឯនៅក្នុងរឿងកោគកុលកុមារ នៅពេលដែលកោគកុលកុមារត្រូវបានម្តាយឪពុកចែកឋានហើយនោះខ្លួនក៏បានដើរស្វែងរកសត្វឆ្កែដើម្បីមកចិញ្ចឹមជាមួយ។ កោគកុលកុមារក៏បានប្រទះឃើញកូនឆ្កែមួយហើយក៏រត់ដេញតាមរត់ដល់ផ្ទះស្ត្រីចាស់ម្នាក់។ កោគកុលកុមារជាក្មេងកំព្រាគ្មានទីពំនាក់ក៏បានទៅសុំទិញកូនឆ្កែនោះលោកយាយ។ ដូនចាស់បានឃើញមានចិត្តអាណិតកោគកុលកុមារ ក៏ព្រមឱ្យកូនឆ្កែនោះទៅ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ក៏បានសុំកោគកុលកុមារធ្វើជាកូនធម៌ទៀតផង។ គាត់បានរៀបចំណីអាហារ ឱ្យកោគកុលកុមារ ហើយផ្តែផ្តាំប្រសិនបើមានទុក្ខអ្វីឱ្យមកប្រាប់គាត់ គាត់នឹងជួយ ដូចលើកឡើងថា ៖

ហៃកូនកល្យាណ	អ្នកនឹងចង់បាន	កូនសុនខា
ម្តាយសោតព្រមឱ្យ	តាមដោយចិន្តា	ម្តាយពុំប្រាថ្នា
	យកថ្លៃពីអ្នក។	
ភ័ព្វម្តាយបានជួន	បានជួបអ្នកសួន	ថ្លើមថ្លៃវល័ក្ខណ៍
ល្អល្អះឆោមឆាយ	ចិត្តម្តាយស្មោះស្ម័គ្រ	ម្តាយសូមយកអ្នក

ជាកូនធម៌ថ្លៃ។(ទំ.១៨)

ដូនចាស់នោះបានយកកោគកុលកុមារមកធ្វើជាកូនធម៌ហើយបានជួយទំនុកបម្រុងកោគកុលកុមារ។ នៅពេលដែលកោគកុលកុមារបានឡើងសោយរាជ្យជាស្តេច ព្រះអង្គមិនបានភ្លេចនូវគុណូបការៈនេះឡើយ ព្រះអង្គបានឱ្យអាមាត្រទៅអញ្ជើញដូនចាស់មកក្នុងរាជវាំង។ ព្រះអង្គបានប្រទាននូវមាសប្រាក់ យសសក្តិទ្រព្យធន ខ្ញុំប្រុសស្រីរបស់ប្រើប្រាស់ តម្លើងឋានៈជាអ្នកគ្រប់គ្រងស្នំ ខុនណាងទាំងឡាយ។ លើសពីនេះព្រះរាជាបានឱ្យដូនចាស់ថែរក្សាឃ្លាំងព្រះរាជទ្រព្យនិងចាំគាល់បម្រើសព្វទិវាផងដែរ។ ទាំងនេះសឱ្យឃើញពីការប្រកាន់នូវគុណធម៌ក្នុងខ្លួន ជួយសង្គ្រោះអ្នកដទៃដោយសណ្តានចិត្ត នោះអំពើល្អទាំងនោះនឹងហុចផលមកវិញជាមិនខាន។

គុណធម៌ ជាធម៌មួយដែលបង្ហាញពីតម្លៃរបស់មនុស្សនៅក្នុងសង្គម។ គុណធម៌ធ្វើឱ្យមនុស្សស្គាល់នូវគុណ ស្គាល់នូវទោស ដឹងអ្វីត្រូវដឹងអ្វីខុស។ គុណធម៌ពិតជាសំខាន់ណាស់សម្រាប់មនុស្សនៅក្នុងសង្គម ហេតុនេះហើយទើបបានជាអ្នកនិពន្ធបានរំលេចនូវតម្លៃនៃគុណធម៌នៅក្នុងរឿងមរណមាតានេះ។ គុណធម៌ដែលស្តែងឡើងតាមរយៈរឿងមរណមាតាគឺបញ្ញាកត្តញ្ញូ។ ជាក់ស្តែង យើងឃើញតាមរយៈសកម្មភាពរបស់មរណមាតាក្នុងការដឹងគុណម្តាយរបស់នាងគឺនាងកុលកេសី។ ទោះជាមានការឈ្នានីសពីកាឡី មរណមាតានៅតែនឹកគិត នៅតែដឹងគុណម្តាយជានិច្ចហើយតែងបានបំពេញនូវកាតព្វកិច្ចជាកូនស្រីជានិច្ច។ តាំងពីម្តាយនៅជាមនុស្ស រហូតក្លាយជាត្រីដំរី ក៏នាងនៅតែស្រលាញ់ដឹងគុណ បម្រើមាតាគ្រប់ពេល។ ទោះបីជានាងកាឡីធ្វើបាប ប្រើឱ្យធ្វើការដោយគ្មានត្រាប្រណីយ៉ាងណា ក៏មរណមាតានៅតែឆ្លៀតយកចំណីទៅឱ្យត្រីដំរីដែលជាម្តាយរបស់នាងរាល់ថ្ងៃ។ រហូតដល់រូបកាយម្តាយនាងបានដុះជាដើមរលួសមាសដ៏ល្អ ក៏នាងនៅតែយកផ្តាយកគ្រឿងបូជាទៅថ្វាយម្តាយដែលរក្សានៅដើមរលួសមាសនោះជានិច្ច។ នេះបង្ហាញពីគុណធម៌របស់មរណមាតាចំពោះអ្នកមានគុណរបស់នាង។ យ៉ាងណាវិញ ទោះបីជាឪពុករបស់នាងស្រលាញ់យកចិត្តកាឡី និងកូនរបស់នាងមរណមាតានៅតែគោរពប្រណិប័តន៍ បម្រើឪពុកជានិច្ច។ សូម្បីតែខ្លួនក្លាយជាមហេសីព្រះរាជាហើយក៏នៅតែបំពេញនូវគុណធម៌ជាកូនចំពោះឪពុកថែមទៀត នៅពេលដែលកាឡីកុហកថាឪពុកឈឺ មរណមាតាក៏ប្រញាប់រៀបចំទៅមើលសួរសុខទុក្ខឪពុក ដោយមិនគិតពីកលល្បិចឪពុក និងនាងកាឡីចង់សម្លាប់ខ្លួនឡើយ។ ដូចមានបង្ហាញនៅក្នុងរឿង៖

ចំណីកាឡីនោះណា	នាងពុំភោក្តា	នាងចាំបណ្តាំជននី។
ចំណីរបស់នាងស៊ី	បើគ្មានទៅវិ	នាងអត់នាងអន់ស្ងៀមស្ងាត់។
តែងយកកន្ធក់ទៅថ្វាត់	ទៅជូនប្រណិប័តន៍	ជននីរាល់ៗវេលា។
ធ្វើវត្តប្រណិប័តន៍បិតា	ច្របាច់បាទា	មិនខានមិនឲ្យអាក់ចិត្ត។(ទំ. ៤៦)

នេះបង្ហាញពីការដឹងគុណរបស់មរណមាតាចំពោះអ្នកមានគុណ ដោយបានធ្វើការគោរពបូជាចំពោះម្តាយដែលជាអ្នកមានគុណ និងជាព្រះរបស់នាងផងដែរ។ ដោយការប្រតិបត្តិនូវគុណធម៌ចំពោះអ្នកមានគុណនេះហើយ ទើបធ្វើឱ្យនាងបានជួបនឹងព្រះរាជា ហើយបានត្រឡប់ក្លាយទៅជាព្រះអគ្គមហេសីរបស់ព្រះរាជវិមលធម្មរាជ សោយសុខក្នុងព្រះរាជវាំងតទៅ។

៤.២- ការបណ្តុះស្មារតីសន្តិភាព

សន្តិភាពគឺជាប្រការដែលមនុស្សគ្រប់គ្នារមែងចង់បាន។ ទាំងសន្តិភាពផ្លូវកាយ និងផ្លូវចិត្ត។ ត្បិតបើមនុស្សមានសន្តិភាពហើយនោះ គេក៏អាចធ្វើអ្វីបានល្អទៀតផង។ ដូចពុទ្ធភាសិតមួយលើកឡើងថា *"នត្ថិ សន្តិ បរំ សុខំ"* មានន័យថា ពុំមានសេចក្តីសុខឯណាស្មើនឹងសេចក្តីស្ងប់មិនមានឡើយ"។ ដែលនេះបង្ហាញឱ្យឃើញពីការដែលមិនទៅបៀតបៀនដោយ កាយ វាចា ចិត្តនោះ នឹងនាំមនុស្សឱ្យមានសន្តិភាពក្នុងខ្លួន។

នៅក្នុងរឿងមហាវេស្សន្តរ បានបណ្តុះនូវគំនិតស្មារតីសន្តិភាពឱ្យបុគ្គលផ្ទាល់តែម្តង។ នៅពេលដែលព្រះវេស្សន្តរត្រូវបានអ្នកស្រីពិរាស្ត្រ តិះដៀល រហូតសុំឱ្យព្រះអង្គយាងចេញពីនគរទៀតនោះ ព្រះវេស្សន្តរមិនបានទៅតបតប្រទូស្តរាយនឹងអ្នកស្រីស្រុកពិរាស្ត្រនោះទេ។ ព្រះអង្គសុខចិត្តជ្រើសរើសយកភាពស្ងប់ ចាកចេញពីព្រះនគរទៅតាមការចង់បានរបស់អ្នកស្រីពិរាស្ត្រ។ មួយវិញទៀត នៅពេលដែលទ្រង់បរិច្ចាគបុត្រទាំងពីរឱ្យទៅជូជក នាងមទ្រីបានវិញមកវិញដោយពុំឃើញបុត្រក៏បានទួញសោក ហើយថាឱ្យព្រះវេស្សន្តរ។ ទោះជាយ៉ាងណាក៏ព្រះអង្គមិនតបត ទ្រង់ដឹងថានាងនឹងយល់ពីការបំពេញទានរបស់ព្រះអង្គ។ នេះហើយសឱ្យឃើញពីការអត់ឱន អត់ធ្មត់យើងអាចបញ្ចៀសនូវជម្លោះបានទាំងអស់។ ក្រោយលក្ខណៈនៃពុទ្ធនិយមនេះ វាបានជាគំនិតដល់មនុស្សគ្រប់រូបឱ្យរក្សាភាពស្ងប់ កុំតបទៅនឹងអ្នកដទៃ និងមនុស្សក្នុងគ្រួសារក៏ដោយ ត្បិតពេលដែលមានកំហឹងមនុស្សនឹងបាត់បង់លំនឹង ការត្រិះរិះហើយនាំឱ្យមានជម្លោះ ការបែកបាក់កើតឡើង។

រីឯក្នុងរឿងសុវណ្ណសាមវិញ ក៏បានបណ្តុះស្មារតីសន្តិភាពទាំងកាយវាចាចិត្តទាំងព្រមតាមរយៈតួអង្គសុវណ្ណសាម។ តាមរយៈដំណើររឿងសុវណ្ណសាម នៅពេលព្រះបាទបិលយក្សបាញ់ព្រួញចំសុវណ្ណសាមដួសស្តូកស្តឹងនៅក្បែស្ទឹងមិគសម្មតា។ សុវណ្ណសាមមិនបានតបតអ្វីទៅកាន់បីឡយក្សនោះទេ តែទ្រង់វាចារដោយសេចក្តីផ្អែមល្ហែម៖ « លោកណាអើយ!បាញ់ខ្ញុំកំពង់ដងទឹក? ...»។ទាំងកាយក៏មិនតបត ទាំងវាចាផ្អែមល្ហែម និងទឹកចិត្តត្រជាក់ មិនមានហិង្សាទៅនឹងព្រះបាទបិលយក្ស។ អានិសង្សនៃការមិនតបត អត់ធ្មត់នេះហើយ ធ្វើឱ្យមាតាបិតា និងនាងទេវតាពហុសុន្ទរីដែលអាស្រ័យនៅឯភ្នំគន្ធមាទន៍ ចេញមកធ្វើសច្ចាធិដ្ឋានក៏ ធ្វើឱ្យសុវណ្ណសាមរស់ឡើងវិញផងដែរ។

ជាមួយគ្នានេះ រឿងក្រុងសុកមិត្រក៏បង្ហាញពីចំណុចនៃអហិង្សាដែលឈានទៅដល់ការនាំមកនូវសន្តិភាពផងដែរ។តាមរយៈដំណើររឿង ក្រុងអសុកមិត្រជាព្រះអនុជចង់ដណ្តើមរាជ្យពីបងក្រុងសុកមិត្រ។ ព្រះបាទក្រុងសុកមិត្រក៏បានសម្រេចចិត្តចាកចេញដោយឱ្យអនុជសោយរាជ្យបន្ត។ ការសម្រេចចិត្តនេះក៏កើតចេញពីការត្រិះរិះឈ្វេងយល់អំពីទុក្ខរបស់ប្រជារាស្ត្រ បើសិនជាទ្រង់មិនចាកចេញនោះទេ សង្គ្រាមបង្ហូរឈាមរវាងបងប្អូននឹងកើតឡើង មិនត្រឹមតែប៉ុណ្ណោះវាបង្កវិនាសកម្មដល់អាណានុរាស្ត្រផងដែរ។ ការឈ្វេងយល់នេះ ទើបទ្រង់យាងចាកចេញជាមួយមហេសីនិងបុត្រទាំងពីរនិរទេសទៅក្នុងព្រៃ។ ដូចយ៉ាងបានលើកឡើងថា៖

បើយើងតតាំង កងទ័ពចេញច្បាំង ឲ្យឈ្លប់ឫទ្ធិ
ក្រែងកើតកង្វល់ អម្ពលសេចក្តី អាសូរប្រណី
រាស្ត្រផងទាំងឡាយ។

នឹងកើតផ្សារក្តៅ	ព្រាត់ប្រាស់កូនចៅ	ហិនហោចខ្ចាត់ខ្ចាយ
ស្លុតស្លាប់សូន្យសោះ	ហេតុនេះអញណាយ	មិនឲ្យអន្តរាយ
	ជនជាតិឡើយហោង។(ទំ.១៣)	

នេះសបញ្ជាក់ឱ្យឃើញពីពលិកម្មដ៏ធំធេងរបស់ក្រុងសុភមិត្រដែលបាន លះបង់រាជ្យសម្បត្តិឱ្យទៅអនុជរបស់ខ្លួន ហើយខ្លួនសុខចិត្តនិរទេស លំបាក ព្រាត់ប្រាស់ប្រពន្ធកូនទៀតនោះ។ វាជាតម្លៃសន្តិភាពមួយដ៏ល្អត្បិតវាធ្វើឱ្យប្រទេសជាតិគ្មានសង្គ្រាមនិងប្រជាជនរស់នៅសុខសាន្ត។ ត្រង់នេះបើយើងពិចារណាបន្តិចទៀត យើងនឹងឃើញថារឿងនេះក៏មានកើតក្នុងសង្គមខ្មែរយើងត្រឹមតែ២៣ឆ្នាំមុនការតាក់តែងរឿងក្រុងសុភមិត្រនាគ.ស.១៧៩៨ ពោលក្នុងរាជ្យរបស់ ព្រះអង្គតន់ បានថ្វាយរាជ្យឱ្យព្រះអង្គនន់ក្នុងសម័យឧដុង្គ។

ការធ្វើឱ្យមានសន្តិភាពក៏ផ្តើមចេញពីបុគ្គលនោះប្រកាន់ខ្ជាប់ នូវសុចរិតធម៌ និងវៀរចាកនូវទុច្ចរិតធម៌ផងដែរ។ ម៉្យាងទៀតការប្រកាន់ខ្ជាប់នៃសុចរិតធម៌និងវៀសចាកទុច្ចរិតធម៌នេះ ជាស្ពានមួយឈានទៅរកសន្តិភាពសម្រាប់ខ្លួនឯងផងដែរ។ តួយ៉ាងនៅក្នុងរឿងទេវន្ទបានបង្ហាញពីទុច្ចរិតបីប្រការ ដែលនាំសត្វលោកឱ្យធ្លាក់ទៅក្នុងអវចី ប្រាសចាកពីសេចក្តីសុខ។ ទុច្ចរិតបីប្រការនោះមានដូចជា កាយទុច្ចរិត វាចាទុច្ចរិត និងមនោទុច្ចរិត។ តាមរយៈការសម្តែងធម្មទេសនារបស់ព្រះទេវន្ទ បានទេសនាទូន្មានកុម្ភណ្ឌទាក់ទងទៅនឹងទុច្ចរិតបីប្រការ ដែលនាំឱ្យសត្វទាំងឡាយធ្លាក់អវចី។ តាមការទេសនារបស់ព្រះទេវន្ទ ទុច្ចរិតមានបី កាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត។ ហើយក្នុងទុច្ចរិតបីប្រការនេះបានចែកជាដប់ប្រការថែមទៀត។ កាយទុច្ចរិតចែកចេញជាបី មួយគឺបាណា មួយគឺអទិន្នា មួយគឺកាមេ។ ឯវចីទុច្ចរិតចែកចេញជាបួន មួយគឺការនិយាយពាក្យមិនពិត មួយគឺការពោលពាក្យញុះញង់ឱ្យគេបែកបាក់គ្នា មួយគឺការពោលពាក្យទ្រគោះមិនពីរោះ មួយគឺការពោលពាក្យផ្ចាញ់ផ្ចាលបំផុតលើគេ។ ចំណែកឯមនោទុច្ចរិតមានបី មួយគឺចិត្តសង្វាតតាមព្យាបាទគេ មួយគឺចិត្តលោភ មួយគឺចិត្តមិច្ឆា។

ពោធីសត្វឆ្លើយ	ថាហៃយក្ខអើយ	រីឯលោកហៅ
ថាទុច្ចរិត	បីពិតអញនៅ	សំដែងចែងទៅ
	ឲ្យផ្សេងពីគ្នា។(ទំ. ១៣៧)	

យើងឃើញហើយថា កាលបើមនុស្សវៀរចាកនូវអំពើទុច្ចរិតទាំងនេះនាំឱ្យខ្លួនគេពុំមានការបៀតបៀនពីអ្នកដទៃរស់នៅមជ្ឈដ្ឋានមួយដែលមានការគោរពកោតស្ងប់ស្ងែងជាដើម។ ទន្ទឹមនឹងនេះ ការដែលប្រព្រឹត្តនូវទុច្ចរិតខាងលើ នឹងនាំឱ្យមនុស្សនោះទទួលបាននូវកម្មផ្សេងៗ។ ដោយសារតែកុម្ភណ្ឌទាំងបួនបានប្រព្រឹត្តិនូវទុច្ចរិតទាំងបីប្រការនេះហើយទើបធ្វើឱ្យយក្សទាំងបួននេះក្នុងបច្ចុប្បន្នជាតិមានរូបរាងអាក្រក់ មិនមាននរណាស្រលាញ់ចូលចិត្តបែបនេះ។ ក្នុងការសម្តែងនូវធម៌របស់ព្រះទេវន្ទ បានរ៉ាយរ៉ាប់ពីផលដែលដែលទទួលបានពីការប្រព្រឹត្តិនូវអំពើទុច្ចរិតទាំងបីនេះ ពេលស្លាប់ទៅនឹងទៅកើតនៅនាហាននរកលំបាករងទុក្ខវេទនា បើកើតជាមនុស្សក្នុងលោកនឹងមានរូបរាងអាក្រក់អប្រិយពន់ពេក។ អ្នកខ្លះកើតមកហើយនឹងត្រូវគេប្រល័យឱ្យក្ស័យទៅវិញ ឬដោយជំងឺព្យាធិជាដើម។ ចំពោះអ្នកធ្វើបាណាតិបាតា កម្មដែលទទួលបាននោះគឺ នឹងត្រូវគេសម្លាប់ដោយគ្រឿងសស្ត្រាផ្សេងៗ ឬដោយរោគាជាដើម។ បើមានកូនចៅ ក៏នឹងត្រូវ

ប្រាសព្រាត់ បើរបស់ជាទីស្រលាញ់ក៏ប្រែជាប្រាសបាត់ទៅវិញ។ បើអ្នកឯណាប្រព្រឹត្តិនូវអទិន្នា ដល់ស្លាប់ទៅនោះនឹងទៅរងទុក្ខវេទនា រំលោណាដែលកើតជាមនុស្ស ក៏នឹងកើតជាអ្នកខ្សត់ទ្រព្យ ហិនហោចទុគ៌ត គ្មានញាតិសណ្តានស្រលាញ់រាប់រក។ ទោះនឹងមានមាសប្រាក់ទ្រព្យសម្បត្តិ ក៏នឹងប្រែជាប្រាស់វិនាសទៅវិញដោយប្រការផ្សេងៗ ដោយចោរមកលួចយកទៅដោយអ្នកមានអំណាចយកទៅ ឬដោយគ្រោះផ្សេងៗទៀត។ មួយអ្នកប្រព្រឹត្តិនូវកាមេ ដល់កាលណាស្លាប់ទៅនឹងទៅធ្លាក់ក្នុងនរកឯទុក្ខលង់លុះមកកើតក្នុងលោកិយ។ ដល់កាលមកកើតក្នុងលោកកាលណា នឹងត្រូវកើតមកជាខ្ចើយស្ទើរប្រុសស្ទើរស្រី។ បើនឹងតាំងប្រាថ្នាអ្វីក៏សឹងពុំបានដូចបំណង។

ខុសពីទុច្ចរិតទាំងបីប្រការដែលនាំឱ្យសត្វលោកឈានទៅរកអវចី ក៏មានសុចរិតបីប្រការដែលនាំសត្វលោកឱ្យដល់នូវសេចក្តីស្ងប់សុខផងដែរគឺ កាយសុចរិត វចីសុចរិត និងមនោសុចរិត។ ហើយសុចរិតនេះឯងជាដើមហេតុនាំឱ្យមនុស្សមានសេចក្តីសុខ ហើយប្រកបដោយសេចក្តីស្ងប់។ នៅក្នុងរឿងទេវន្ទនេះដែរ ក៏បានបង្ហាញនូវសុចរិតបីប្រការផងដែរ ដែលក្នុងសុចរិតបីប្រការនេះបានបែកចែកជាផ្នែកផ្សេងៗទៀត។ តួយ៉ាង តាមរយៈការសម្តែងនូវធម៌ទេសនារបស់ព្រះទេវន្ទអំពីសុចរិតបីប្រការ ដើម្បីទូន្មានដល់កុម្ភណ្ឌ។ ព្រះទេវន្ទបានទេសនារៀបរាប់អំពីសុចរិតបីប្រការ ហើយសុចរិតបីប្រការនោះមាន កាយសុចរិត វចីសុចរិត និងមនោសុចរិត។ ដោយកុម្ភណ្ឌទាំងបួនបានវន្ទាសូមឱ្យព្រះទេវន្ទបន្ថែមបង្ហាញពីសុចរិតបីប្រការនោះឱ្យខ្លួនបានដឹង។ ពេលនោះព្រះទេវន្ទបានសម្តែងនូវធម្មទេសនាប្រាប់ទៅកុម្ភណ្ឌទាំងបួន ក្នុងសុចរិតបីប្រការនោះដែលចែកចេញជាដប់ប្រការ។ ក្នុងនោះមានកាយសុចរិតបី មនោសសុចរិតបួន និងវចីសុចរិតបី។ ដែលទាំងនេះហើយជាសុចរិតទាំងបីប្រការដែលជាធម៌មង្គលដល់ជនគ្រប់គ្នា។

យេចឥតំ　　សុចរិតំ　　យក្ខអើយនរណា
ប្រាស់ប្រែប្រព្រឹត្តិ　　នូវសុចរិតា　　ទាំងដប់ប្រការ
ហៅព្រះធម្មេ។(ទំ. ១៤៨)

តាមរយៈអត្ថបទចំណុចមួយៗនៃសុចរិតបានលើកយកមកបង្ហាញ យើងឃើញថាអំពើឬសុចរិតទាំងបីប្រការនោះ មានបែងចែកថែមជាដប់ប្រការថែមទៀតគឺ កាយសុចរិតមានការវៀរចាកនូវការសម្លាប់ជីវិតសត្វ និងមនុស្សដទៃ ការមិនលួចទ្រព្យសម្បត្តិអ្នកដទៃ និងការមិនលួចប្រពន្ធ ប្តីអ្នកដទៃ។ រីឯមនោសុចរិតមាន ការវៀរចាកនូវភោពលោភលន់ ការវៀរចាកនូវចិត្តព្យាបាទ និងការវៀរចាកនូវចិត្តមិច្ឆាទិដ្ឋិ។ ចំណែកវចីសុចរិតវិញ គឺការមិននិយាយពាក្យកុហក ការមិននិយាយពាក្យអសុរោះ ការមិននិយាយពាក្យទ្រគោះបោះបោក ការមិននិយាយពាក្យអាក្រក់ និងការមិននិយាយពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

ក្នុងការប្រព្រឹត្តនូវសុចរិតបីប្រការនេះដែរ ឃើញថាក៏នឹងទទួលបានផលមកវិញជាកុសល។ នៅក្នុងសាស្ត្រាទេវន្ទនេះផងដែរ ក៏បានបង្ហាញឱ្យឃើញពីផលដែលទទួលបានពីការប្រព្រឹត្តិនូវអំពើសុចរិតទាំងបីប្រការនេះផងដែរ។ ហើយផលដែលទទួលបាននេះ ជាផលដែលប្រកបដោយធម៌គឺ ផលជាកុសលដែលនាំមកនូវតែសេចក្តីចម្រើន ដល់ជនដែលបានប្រព្រឹត្តិនូវសុចរិតទាំងបីប្រការនេះ។ តួយ៉ាង ព្រះទេវន្ទបានទេសនាប្រាប់ពីផលដែលទទួលបានពីការប្រព្រឹត្តិនូវសុចរិតទាំងបីប្រការទៅដល់ពួកយក្សទាំងបួន។ អ្នកដែលប្រព្រឹត្តិនូវសុចរិតទាំងបីនេះ ទោះនឹងស្លាប់បង់ទៅ ក៏សោត

តែបានសោយសុខសាន្ត បើកាលកើតជាមនុស្សក៏កើតក្នុងត្រកូលអ្នកល្អប្រពៃ មានទ្រព្យធន ពុំដែលជួបប្រទះនូវទុក្ខ
ទោមនស្ស មិនដែលស្គាល់ពាក្យថាប្រាស់ព្រាត់ វិនាសញាតិបងប្អូន ម្តាយឪពុក និងប្រកបដោយយសសក្តិ។ អ្នកនោះ
ឯងក៏នឹងមានរូបសម្រស់ល្អល្អះ កម្រនឹងមានមនុស្សឯណាមកផ្ទឹមប្រៀបបាន។ ក្នុងការរស់នៅវិញតែងមានគេ
ស្រលាញ់រាប់អានចូលចិត្តទាំងមនុស្ស ទាំងទេវតា មានគេជួយយកអាសារគ្រប់ពេលវេលា។

ជារួមយើងឃើញថា ការប្រព្រឹត្តនូវសុចរិតនិងវៀរចាកទុច្ចរិតទាំងអស់នេះនាំឱ្យមនុស្សមាននូវសេចក្តីសុខក្នុង
ខ្លួន ពុំមាននូវមន្ទិល ឬសេចក្តីខ្លាចក្រោធទាំងឡាយនោះឡើយ។ ម៉្យាងក៏ទោះបីជាទស្សនៈនេះស្ថិតក្នុងពុទ្ធសាសនាក៏
ដោយ ក៏វាបានបង្ហាញពីលក្ខណៈបែបវិទ្យាសាស្ត្រមួយដែលអាចឱ្យមនុស្សរស់នៅប្រកបដោយភាពតភាព មានសន្តិភាព
ទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត។

ចំណែកឯរឿងភោគកុលកុមារ ក៏បានលើកយកនូវការចេះអធ្យាស្រ័យគ្នាក្នុងសង្គមមកបង្ហាញតាមរយៈខ្សែរឿង
ផងដែរ។ នៅពេលដែលព្រះបាទភោគកុលកុមារបានចេញប្រយុទ្ធជាមួយនឹងព្រះបាទព្រហ្មទត្តដែលមានលោភលន់
កាមតណ្ហា ចង់បានប្រពន្ធគេនោះ ហើយបានសម្លាប់ព្រះអង្គនៅពេលប្រយុទ្ធគ្នា។ ផ្ទុយទៅវិញនៅពេលព្រះបាទព្រហ្ម
ទត្តចាញ់ហើយនោះ អ្នកទាំងឡាយដែលជាពលរេហ៍ មិនបានផ្សំគំនិតជាមួយនោះ ក៏បានសុំចុះចូល រាជទានទោស
ប្រោសប្រណី ដូចលើកឡើងថា៖

ទើបព្រះពូជពង្សពុទ្ធផៅ បើកបន្ទូលទៅ ថាហៃអស់មុខមន្ត្រី។
គ្រប់គ្នាតើមានទោសអ្វី កុំភ័យទៅថ្វី អញសោតពុំយកទោសា។
មន្ត្រីត្រេកអរគ្រប់គ្នា ជ្បិតស្តេចមេត្តា ប្រោសទុកជីវិតឱ្យគង់។(ទំ. ១៤៨)

ត្រង់នេះដែលបានបង្ហាញនូវសន្តិភាពនៅក្នុងសង្គមមួយតាមរយៈការចេះប្រោសប្រណីគ្នា ក្នុងនាមជាមនុស្ស
ជាតិ។ អំពើរបស់ភោគកុលកុមារនេះ មិនត្រឹមតែជាគុណធម៌មួយនោះទេ តែវាបង្រៀនមនុស្សឱ្យចេះមានការយោគ
យល់ចំពោះគ្នាក្នុងនាមជាជាតិសាសន៍តែមួយ មិនត្រូវចេះប្រកាន់អូសដំណើរ បែងចែកបក្សពួកដែលនាំឱ្យដល់ការ
រើសអើងទៀតផង។

ការប្រកាន់ខ្ជាប់នូវការព្យាយាម អំណត់អត់ធ្មត់ រក្សានូវអហិង្សា ជាការបណ្តុះស្មារតីមួយក្នុងការរក្សានូវ
សន្តិភាព។ នៅក្នុងសាស្ត្ររឿងមរណមាតានេះ បានបណ្តុះនូវស្មារតីសន្តិភាព តាមរយៈនាងមរណមាតា តែងតែតស៊ូ
អត់ធ្មត់ក្នុងជីវិតរស់នៅ គ្រប់បញ្ហាក្នុងជីវិត នាងតែងតែបានតស៊ូដោយប្រើការតស៊ូព្យាយាម ហើយពិសេសជាងនេះទៅ
ទៀតនាងប្រកាន់ខ្ជាប់នូវភាពអហិង្សាជានិច្ច។ ទោះជាត្រូវឯការធ្វើបាប ប្រមាថមើលងាយពីអ្នកដែលតាមចងពៀរ
ឈ្នានីសនាងក៏ដោយ មរណមាតានៅតែមិនតបត ហើយព្យាយាមគេចចេញពីការចងពៀរគ្នាទៅវិញទៅមកជានិច្ច។
តួយ៉ាង កាលមរណមាតាក្លាយជាសារិកានៅពេលដែលឆន្ទាឱ្យកីលៀងយកខ្លួនទៅបោចរោម ប៉ងនឹងសម្លាប់ ចៃដន្យ
បានរួចខ្លួនទៅស្នាក់ជាមួយកណ្តុរស ហើយស្តេចកណ្តុរសចង់ទៅសម្លាប់នាងឆន្ទាសងសឹកឱ្យនាង មរណមាតាបាន
ឃាត់ស្តេចកណ្តុរសមិនឱ្យទៅចងពៀរជាមួយនឹងនាងឆន្ទាឡើយ ដូចបានរៀបរាប់ថា៖

រីឯមេឆន្ទា ចិត្តឫស្សាចោរអន្តរាយ

ធ្វើទោសប្អូនឆោមឆាយ បងជានាសម្លាប់វា។
នាងស្តាប់ឆ្លើយសាសង កុំអ្នកបងចងវេរ
ក្រែងមានពៀរនឹងគ្នា តទៅមុខទៀតមិនខាន។ ...
នឹងយុត្តនឹងតតាំង ប៉ះកម្លាំងគេដូចម្តេច
ខ្លួនយើងកម្លាំងតិច សូមអ្នកបងស្ងៀមទៅជា។(ទំ. ១៧៤)

នេះបង្ហាញឱ្យឃើញពីការប្រកាន់នូវអហិង្សារបស់មរណមាតា ដែលបានហាមឃាត់មិនឱ្យកើតមានឡើងនូវជម្លោះ ការឈ្លោះប្រកាប់ប្រចាក់គ្នា ពោលគឺខន្តីឱ្យគ្នា កុំចងពៀរបន្តទៀត។ ដោយហេតុនេះហើយ ទើបនាងអាចរស់នៅជាមួយកណ្តុរបានសុខសាន្តរហូតដល់រោមដុះជិតពេញខ្លួនវិញ។

៤.៣- ការបណ្តុះពុទ្ធិស្មារតី

អក្សរសិល្ប៍ពុទ្ធនិយម ក្រៅតែពីដើរតួនាទីក្នុងការអប់រំចរិយាសាស្ត្រ សេចក្តីថ្លៃថ្នូររបស់មនុស្ស បណ្តុះនូវសន្តិភាពរវាងគ្នានិងគ្នា វាក៏បានជួយដល់ការបណ្តុះគំនិតដល់អ្នកអាន អ្នកស្តាប់ឱ្យមានពុទ្ធិ ចំណេះដឹងតាមរយៈសកម្មភាពតួអង្គ ដំណើររឿងជាដើម។ ជាមួយគ្នានេះ អក្សរសិល្ប៍ពុទ្ធនិយមក៏បាន រំលេចក្នុងការបណ្តុះបញ្ញាមនុស្ស វាប្រៀបបានទៅនឹងមាគ៌ាមួយសម្រាប់មនុស្សឱ្យចេះត្រិះរិះគិតដោះស្រាយបញ្ហាចំពោះមុខសំដៅជានាបាននូវការអភិវឌ្ឍខ្លួន គ្រួសារ និងសង្គមជាតិទាំងមូល។

នៅក្នុងរឿងព្រះវេស្សន្តរក៏បានបណ្តុះនូវពុទ្ធិដល់មនុស្សយ៉ាងច្រើនសម្បើរបៃ។ តួយ៉ាងនៅក្នុងការអប់រំគឺជាទិសដៅសំខាន់ក្នុងការអភិវឌ្ឍខ្លួន។ ជាក់ស្តែងព្រះវេស្សន្តរក្នុងព្រះជន្ម១៦ឆ្នាំនៅពេលដែលទ្រង់បានរៀនចប់នូវសិល្ប៍សាស្ត្រគ្រប់ដំពូកហើយ ទើបព្រះរាជបិតាបាននាំព្រះរាជកញ្ញាព្រះមាននាងមទ្រី ជាព្រះមាតុធីតា អំពីមទ្ទរដ្ឋ មករៀបអភិសេក ហើយទ្រង់ដាក់រាជ្យថ្វាយព្រះវេស្សន្តរ។ ត្រង់នេះស្តែងឱ្យឃើញពីការយកចិត្តទុកដាល់លើការសិក្សាទោះបីជាក្សត្រក៏ត្រូវខំរៀនសូត្រផងដែរ។ លើសពីនេះតាមរយៈដំណើររឿងក៏បានបង្ហាញពីវិធីដោះស្រាយបញ្ហារបស់ជូជក។ ពិតណាស់ការកុហកវានឹងនាំឱ្យអន្តរាយជាមិនខាន។ តែពេលខ្លះការមុសានោះក៏អាចធ្វើឱ្យយើងរួចជីវិតដែរ។ ដូចយ៉ាងជូជកបានកុហកចេតបុត្រនិង អច្ចុតមហាឫសីថាជា ព្រាហ្មណ៍ទូតរបស់ព្រះបាទស្រីសញ្ជ័យ។ នេះហើយនាំឱ្យជូជកបានរួចរស់ជីវិត។ វាសមដូចបុរាណភាសិតខ្មែរលើកឡើងថា៖ «ផ្លូវរៀចកុំបោះបង់ ផ្លូវត្រង់កុំដើរហោង»។

រីឯនៅក្នុងរឿងសុវណ្ណសាមវិញក៏មិនខុសពីជាតកជទៃដែរក៏បានបង្ហាញពីពុទ្ធិសម្រាប់អ្នកសិក្សាទូទៅ។ ក្នុងជីវិតមនុស្សតែងតែមានការបង្កើតកំហុសឆ្គងដោយចេតនាក្តី អចេតនាក្តី។ ពេលដែលយើងទទួលជួបនូវកំហុស បញ្ហានេះហើយ យើងគប្បីភ្ញាក់រឭក កែប្រែវាឱ្យប្រសើរឡើងវិញ។ ការដាស់តឿនរបស់ទេពធីតាវេស្សន្តរីទៅឱ្យបិលយក្សថា៖ បពិត្រមហារាជ ព្រះអង្គបានធ្វើហើយនូវបាបជាទម្ងន់...ខ្ញុំនឹងពន្យល់ឱ្យរួចពីនរក បានទៅសុគតិភព ...។ ត្រង់នេះហើយទោះបីជាបិលយក្សជាអង្គក្សត្រក៏ទ្រង់ទទួលយកពាក្យរបស់ទេពធីតា មកកែប្រែនូវកំហុសរបស់ខ្លួនផងដែរ។

ចំណែករឿងក្រុងសុភមិត្រវិញក៏បានបណ្តុះនូវគតិដល់មេដឹកនាំ ក៏ដូចជាជនានុជនក្នុងការសម្រេចចិត្តកាត់សេចក្តី វិនិច្ឆ័យអ្វីមួយឱ្យប្រកបដោយគតិយុត្តិ ពោលគឺកុំធ្វើអ្វីដោយអគតិទាំងបួនគឺ ឆន្ទាគតិ ទោសាគតិ មោហាគតិ

និង ភយាគតិ។ តួយ៉ាងនៅពេលដែលនាយកេត្រាបានឃើញ ជ័យទត្តនិងជ័យសែនកំពុងឱបរឹតជាមួយមាតាគឺព្រះនាងកេសនី។ នៅពេលដែលបានឃើញដូច្នេះ កេត្រាពុំបានគិត ឬសួរនាំនោះទេក៏វិនិច្ឆ័យថាជាសហាយស្មន់នឹងគ្នា ក៏ទៅទូលព្រះរាជា។ ដូចលើកឡើងថា៖

វានេះស្មេរស្មា ចិត្តកាចពាលា ពុំគិតកេរ្តិ៍កាយ
វាតូចប៉ុណ្ណោះ ចេះមានសហាយ ហ៊ានម្តេចអម្បាយ
ចោរចង់តណ្ហា។(ទំ. ៧៨)

ដោយការវិនិច្ឆ័យមិនត្រឹមត្រូវនេះហើយ អាចនាំឱ្យជ័យទត្តនិងជ័យសែនឈានទៅដល់ការស្លាប់។ ប៉ុន្តែដោយសារ តែគុណបុណ្យរបស់ព្រាហ្មណ៍ បុរោហិតអ្នកចេះដឹង លោកបានឃាត់ឃាំងដំណើរ ត្បិតខុសនឹងប្បវេណី។ នេះហើយទើបធ្វើឱ្យការពិតបានលាតត្រដាង។ ជារួមការវិនិច្ឆ័យអ្វីមួយត្រឹមតែការបានឃើញនោះ វាពិតជាហានិភ័យដល់ការសម្រេចចិត្តជាមិនខាន។

ជាការពិតណាស់ ការសេពគប់ក៏ជាហេតុមួយក្នុងការធ្វើឱ្យខ្លួនរីកចម្រើនបានដែរ។ ការសេពគប់នូវជនជាបណ្ឌិត រមែងធ្វើឱ្យជននោះទទួលបាននូវការរីកចម្រើនផ្នែកគំនិតបញ្ញាក៏ដូចជាសមត្ថភាពការងារជាដើម។ តួយ៉ាងនៅក្នុងរឿងទេវន្ទ កុម្ភណ្ឌទាំងបួនក្រោយពីស្តាប់នូវធម្មទេសនារបស់ព្រះទេវន្ទរួចមក ក៏ទទួលបាននូវការគិតពិចារណារកឃើញនូវផ្លូវត្រឹមត្រូវសម្រាប់កសាងជីវិតរបស់ខ្លួនទៅជាតិខាងមុខ។ ដោយហេតុការសម្តែងនូវធម៌របស់ព្រះទេវន្ទបានបង្ហាញអំពីកម្មពៀរបស់កុម្ភណ្ឌទាំងបួន ដែលបណ្តាលឱ្យមកកើតជាយក្សបែបនេះ ដោយការអប់រំបង្ហាញនូវផ្លូវល្អនេះហើយទើបកុម្ភណ្ឌយក្សទាំងបួនបានភ្ញាក់រឭកមកធ្វើល្អ ហើយខំប្រឹងធ្វើល្អសាងនូវកុសលរក្សានូវសីលប្រាំ។ មិនតែប៉ុណ្ណោះ កុម្ភណ្ឌទាំងបួនបានយកទេវន្ទជាគ្រូ និងជានាបម្រើទេវន្ទលុះគ្រាអស់ជីវិតទៅ។

លុតលើព្រះបាទ ព្រះបរមននាថ ដាក់លើសិរិសា
ក្រួញក្រាបបង្គំ ប្រណម្យទូលថា យើងខ្ញុំនេះជា
ខ្ញុំព្រះអង្គហោង។
ព្រះអង្គសព្វញ្ញូ យើងទុកជាគ្រូ ជាម្ចាស់យើងផង
បម្រើបម្រុង ព្រះអង្គឥតហ្មង សិរសាប៉ាប់រង
ទទួលអាសារ។ (ទំ.១៣៤)

ត្រង់នេះបង្ហាញឱ្យឃើញថាកុម្ភណ្ឌទាំងបួនទោះបីមានសាច់ឈាមរូបរាងអាក្រក់ ប៉ុន្តែក៏នៅចេះអភិវឌ្ឍខ្លួនដើម្បីបានល្អប្រសើរ ដោយដើរតាមការទូន្មានរបស់ទេវន្ទ ដែលពួកគេចាត់ទុកស្មើបានគ្រូអាចារ្យដែលជាអ្នកណែនាំឱ្យដើរលើផ្លូវប្រកបដោយសេចក្តីប្រសើរ។ តាមរយៈតួអង្គកុម្ភណ្ឌទាំង៤ បានអប់រំដល់ជនានុជនគ្រប់រូបឱ្យចេះទទួលយកនូវការអប់រំ ការណែនាំ និងដើរតាមជនជាបណ្ឌិត ដើម្បីឱ្យផ្លូវជីវិតរបស់ខ្លួនមានការផ្លាស់ប្តូរ និងវិវត្តឡើងថែមទៀត។

កំណាព្យមួយឃ្លារបស់ក្រមង៉ុយ ក្នុងកំណាព្យច្បាប់ល្បើកថ្មីលើកឡើង “*បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់ កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើតបទ បើចេះប្រាកដ ប្រាក់រត់តាមហៅ*។” នេះជាឃ្លាកំណាព្យមួយដែលបាន

ជាស់តឿនក្រើនរំឭក អប់រំដល់យុវជនឱ្យ ឧស្សាហ៍ព្យាយាមក្នុងការសិក្សា ក៏ដូចជាការប្រកបរបរការងារជាដើម។ នៅក្នុងរឿងកោគកុលកុមារ អ្នកនិពន្ធក៏បានពន្លេចចេញនូវទស្សនៈនៃបណ្តុះស្មារតីឱ្យ យុវជនត្រូវខិតខំប្រឹងប្រែងប្រកបការងារ ចេះកែខៃច្នៃនូវជីវិតរបស់ខ្លួនឱ្យបានប្រសើរឡើង។ តាមរយៈតួអង្គកោគកុលកុមារ នៅពេលពេលដែលគ្រួសារជាសេដ្ឋីបានធ្លាក់ខ្លួនក្រីក្រ មុនពេលឪពុកស្លាប់ គាត់បានផ្តាំឱ្យកោគកុលកុមារយកសពគាត់ទៅចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី ហើយក្រោយពីនៅសល់ឆ្អឹងយកមកបង្ហូស បើទាក់ត្រង់កន្លែងណា ឱ្យកោគកុលកុមារធ្វើចម្ការត្រង់នោះ៖

បើឆ្អឹងអាពុកអ្នក ជាប់ជំពាក់នឹងនិត្យនៅ
ទីឋានណាចូរចៅ គិតកាប់ឈើធ្វើចំការ។(ទំ. ១៥)

លុះដល់ រដូវធ្វើស្រែចម្ការ កោគកុលកុមារក៏ធ្វើទៅតាមបណ្តាំ ក៏បានជាប់ទាក់នៅទួលមួយ ហើយកោគកុលកុមារក៏បានធ្វើចម្ការនៅទីនោះឯង។ តាមរយៈបណ្តាំរបស់កោគសេដ្ឋីនេះ បានពញាក់ស្មារតី ឱ្យកោគកុលកុមារមានសេចក្តីព្យាយាមឡើង ក៏ទោះបីជាអត់ពីឪពុក ហើយគ្មានទ្រព្យសម្បត្តិក៏ដោយ ក៏ត្រូវខិតខំឧស្សាហ៍ឡើងកុំចុះចាញ់នឹងវាសនា។ នៅត្រង់នេះពិតណាស់ថា តួកោគកុលកុមារជាពោធិសត្វ រមែងមានការអន្តរាគមន៍មកជួយជានិច្ចក៏ដោយ ក៏វាបានឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃសង្គម ប្រសិនបើយើងឧស្សហ៍ព្យាយាមក្នុងការប្រកបកិច្ចអ្វីមួយដោយសុចរិតនោះ លទ្ធផលចុងក្រោយយើងនឹងអាចទទួលតបស្នងពីវា និងមានកេរ្តិ៍ឈ្មោះល្អនៅក្នុងសង្គមជាតិផងដែរ។

រីឯរឿងមរណមាតា ក៏បានបង្ហាញពីលក្ខណៈពិសេសក្នុងការអប់រំទូន្មានមនុស្សឱ្យចេះប្រើប្រាស់បញ្ញារបស់ខ្លួនក្នុងការដោះស្រាយបញ្ហាចំពោះ។ ស្ថិតក្នុងស្ថានភាពដ៏គ្រោះថ្នាក់នៅពេលដែលកុលកេសីបានជួបនឹងពួកចោរហើយពួកចោរបានយកទៅជួបនឹងមេស្រុកនោះគួសង្សារនេះ អាចនឹងស្លាប់ឬរស់នៅលើការដោះស្រាយបញ្ហានោះហើយ។ នាងកុលកេសីព្យាយាមរកគំនិតដោយជូនចិញ្ចៀនទៅមេស្រុក ហើយសុំធ្វើឪពុកធម៌ ព្រោះនាងអាចគិតថាមានតែមេស្រុកទេ ដែលជាអ្នកធំអស់គេ ហើយនឹងនឹងមិនខ្លាចនូវការគម្រាមកំហែងពីពួកចោរទៀត។ លើសពីនេះ ក្រោយពីបានរស់នៅជាមួយមេស្រុកហើយ នាងព្យាយាមសង្កេតមើលទីកន្លែងសម្រាប់រកស៊ី សង្កេតមើលពីរបៀបដែលអ្នករកស៊ីជួញដូរហើយបានឆ្លៀតចាប់ផ្តើមរកស៊ីធ្វើជំនួញដោយខ្លួនឯងនិងបានកសាងផ្ទះបែកចេញពីមេស្រុកដែលជាបិតាធម៌។ នេះបង្ហាញឱ្យឃើញពីការដោះស្រាយបញ្ហាជីវភាពរស់នៅរបស់កុលកេសីក្នុងជីវភាពរស់នៅរហូតបានក្លាយជាសេដ្ឋី។ ដូចមានបង្ហាញនៅក្នុងអត្ថបទ៖

ទាំងនេះព្រោះកេសី ជាតិជាស្រីមានលក្ខណ៍ល្អ
ប្រាថ្នាទ្រព្យមិនក្រ មិនខ្វះបាយពីថ្ងៃនោះ។...
នាងកុលកេសី ប្រើខ្ញុំប្រុសស្រី ឲ្យចរឲ្យចេញ
ឲ្យជួយជួយប្រៃ ធ្វើស្រែចំណេញមាសប្រាក់បានពេញ
បានពោរទាំងផ្ទះ។ (ទំ. ១៨)

ពិតណាស់ត្រង់នេះបានស្តែងឱ្យឃើញ ពីគំនិតជាស្ត្រី ជាភរិយាដែលចេះសន្សំសំចៃមើលការខុសត្រូវក្នុងផ្ទះ ទើបគ្រួសារមានការរីកចម្រើនផងដែរ។ វាដូចទៅនឹងគំនិតខ្មែរដែលលើកឡើងថា «ផ្ទះធំស្រនុក ត្បិតភរិយាជា»។ នាង កុលកេសីបានប្រណិបត័ន្តបានយ៉ាងខ្ជាប់ខ្ជួនរហូតបានបំបែកផ្ទះ ហើយក្លាយជាអ្នកមានទ្រព្យកោដិឃ្លាំងទៀតផង។

៤.៤- ឥទ្ធិពលទស្សនវិជ្ជាពុទ្ធសាសនាក្នុងការអប់រំចរិយាសាស្ត្រ

នាសម័យកណ្តាលនេះអក្សរសិល្ប៍ភាគច្រើន ច្រើនតែលើកពីទ្រឹស្តីពុទ្ធសាសនាមករៀបរាប់។ ដោយហេតុថា ប្រជាជនជឿយ៉ាងពេញទំហឹងទៅលើពុទ្ធសាសនា។ ដូច្នេះការអប់រំត្រូវតែផ្សារភ្ជាប់នឹងទ្រឹស្តីពុទ្ធសាសនាជាចាំបាច់។ ការលើកយកទ្រឹស្តីពុទ្ធសាសនាមកនេះ ខ្លះក៏បានដកស្រង់រឿងផ្ទាល់របស់ព្រះសម្មាសម្ពុទ្ធ ចេញពីគម្ពីរព្រះត្រ័យបិដក ខ្លះទៀតចេញពីមនោគតិរបស់អ្នកនិពន្ធដោយផ្សារភ្ជាប់នឹងទស្សនៈណាមួយរបស់សាសនាតែប៉ុណ្ណោះ។

ក- ទស្សនៈកម្ម-ផល

ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ មហាវេស្សន្តរជាតកក៏បានចូលរួមស្ថាបនាសីលធម៌សង្គមតាមរយៈទស្សនៈកម្មផលនេះផងដែរ។ តម្លៃនេះទស្សនៈកម្មផលស្តែងឱ្យឃើញនៅចុងសាច់រឿងតែម្តង ពោលគឺការសជាតិរបស់តួអង្គនីមួយៗ។ យើងឃើញថា ការសាងនូវអំពើល្អក្នុងការឱ្យទានជាសប្បុរសរបស់ព្រះវេស្សន្តរនេះ បាននាំឱ្យព្រះអង្គបានក្លាយជាព្រះពុទ្ធអង្គ។ រីឯការសាងអកុសលកម្មរបស់ព្រាហ្មណ៍ជូជក ទាំងការមុសា ទាំងការធ្វើបាបជាលី និងកណ្ហាជិនា បានធ្វើឱ្យគាត់ក្លាយជាទេវទត្ត។ ទាំងនេះហើយជា បន្ទាត់ក្រិតនូវសកម្មភាពភាពរបស់មនុស្ស កុំឱ្យប្រព្រឹត្តិនូវអំពើអាក្រក់ បីដូចជូជក។ តួអង្គទេវទត្តនេះ ក្នុងផ្នត់គំនិតខ្មែរមិនល្អនោះទេ ត្បិតជាអ្នករារាំងព្រះពុទ្ធអង្គមិនឱ្យបានត្រាស់ជាសម្មាសម្ពុទ្ធញ្ញាណ។

រីឯក្នុងទសជាតកដូចគ្នានេះដែរ ក្នុងរឿងសុវណ្ណសាមជាតក យើងឃើញយ៉ាងប្រត្យក្ស នៅក្នុងអត្ថបទ បានលើកឡើងថា នៅពេលដែលទុកូលនិងបារិកា បានចូលទៅជ្រកភ្លៀងនៅលើដំបូកមួយ ដែលនៅក្រោមនោះមានសត្វអាស៊ិវិសមួយអាស្រ័យនៅ។ បន្តិចក្រោយមក ញើស និងក្លិនខ្លួនរបស់ អ្នកទាំងពីរបានប៉ះនឹងខ្ទង់ច្រមុះ ក៏នាំឱ្យអាស៊ិវិសនោះ បញ្ចេញចំហាយពិសតាមរន្ធច្រមុះ បណ្តាលឲ្យអ្នកទាំងពីរងងឹតភ្នែកមើលមិនឃើញ ។ ត្រង់នេះ យើងអាចដឹងថាផលដែលឥសីទាំងពីរនេះបានទទួល ប្រាកដជាមិនមែនកើតដោយគ្មានហេតុនោះទេ។ នៅក្នុងអដ្ឋកថា តាសាបាលីដូចបានចែងថា កាលពីអតីតជាតិ អ្នកទាំងពីរនោះកើតក្នុងត្រកូលពេទ្យ។ ពេទ្យជាប្តីបានព្យាបាល រោគភ្នែកបុរសម្នាក់ដែលជាមហាធន។ បុរសមហាធនមិនបានឱ្យទ្រព្យអ្វី បន្តិចបន្តួចដល់ពេទ្យនោះសោះ។ លំដាប់នោះ ពេទ្យខឹងហើយត្រឡប់ទៅផ្ទះខ្លួនវិញប្រាប់ប្រពន្ធថា៖ នែភាន[47], បងបានព្យាបាលរោគភ្នែកបុរសម្នាក់ ឥលូវនេះ គេមិនឱ្យថ្លៃឈ្នួលដល់បងទេ តើយើងនឹងធ្វើដូចម្តេច?”។ ប្រពន្ធពេទ្យបានស្តាប់ហើយ ខឹងឆេវដែរ ឱ្យយោបល់ទៅដល់ប្តីថា៖ “យើងចាំបាច់ត្រូវការថ្លៃឈ្នួលពីគេធ្វើអ្វីបង ផ្សំតែថ្នាំមួយមុខ ដាក់ឲ្យគេខ្វាក់ភ្នែកទាំងសងខាងទៅវាជាការស្រេច”។ ពេទ្យជាប្តីយល់ព្រម ក៏ដើរទៅកាន់សម្នាក់បុរសមហាធន បានផ្សំថ្នាំដាក់ភ្នែកតាមយោបល់របស់ប្រពន្ធ។ បុរសមហាធននោះ មិនយូរប៉ុន្មានក៏ខ្វាក់ភ្នែកទាំងសងខាង។ដោយសារបុព្វហេតុនេះ ទើបតាបសទាំងពីរនោះ ត្រូវខ្វាក់ភ្នែកទាំងសងខាងទាំងពីរ

[47] គេហ៍; ពាក្យសម្រាប់ប្តីហៅប្រពន្ធ ក្នុងទីចំពោះមុខដោយស្មោះស្មើ ជាសម្តីរាបសារបស់ប្រជាពលរដ្ឋក្នុងបុរាណសម័យ។

នាក់ ក្នុងបច្ចុប្បន្នជាតិ។[48] នេះជាកម្មដែលកើតឡើងដោយសារកម្មពីជាតិមុនរបស់អ្នកទាំងពីរបានប្រព្រឹត្ត ហើយវាបានអន្ទោលមកដល់បច្ចុប្បន្នជាតិរបស់ពួកគេ។ កម្មផលនេះគេហៅថា ទិដ្ឋធម្មវេទនីយកម្ម។ត្រង់នេះផងដែរប្រសិនបើកម្មដែលគាត់បានសាងនោះ មិនបានឲ្យផលមកបច្ចុប្បន្នជាតិនេះ កម្មនោះនឹងត្រូវទៅជាអហោសិកម្ម គឺមិនអាចនឹងឱ្យផលទៅជាតិមុខបានទៀតនោះឡើយ។ ការលើកយកនូវទស្សនៈកម្មផលជាក់បញ្ចូលនេះ បានចងជើងមនុស្សទូទៅឱ្យប្រព្រឹត្តអំពើសុចរិតជាចម្បង កុំបីមានចិត្តចងគំនុំគុំកួនគ្នាទៅវិញទៅមក។

ងាកក្រឡេកមកមើលរឿងបញ្ញាសជាតកវិញ ក្នុងដំណើររឿងក្រុងសុកមិត្រ ដើមចមដែលនាំបែកបាក់ព្រាត់ប្រាស់គ្នាប្រពន្ធកូននេះគឺបណ្តាលមកពីកម្មពៀរនេះតែម្តង។ ជាការពិត ជ័យសែននិងជ័យទត្តបានទៅយកសេកសោមពីសម្បុកហើយបានដករោមបីទង ធ្វើចេញឈាមក្រហមឆ្អិនឆ្អៅ ដូចលើកឡើងថា៖

កាលព្រះអង្គវែងទុក្ខទល់	ហេតុអំពល់អំពើពៀរ
កាលស្តេចយកបក្សី	សត្វសេកសោមឱ្យបុត្រា។
ទាំងពីរយកមកលេង	គិតពុំក្រែងពៀរវេរា
ហើយបោចរោមសារិកា	បីទងទើបឈាមច្រាលឆ្អៅ។(ទំ.៣៥)

នេះហើយជាបុព្វហេតុដែលនាំឱ្យអ្នកទាំងបួនព្រាត់ប្រាស់គ្នាគួរឱ្យសង្វេគ។ តែកម្មនេះមិនមែនអន្ទោលតែមួយជាតិនេះទេ វាអន្ទោលអស់៥០០ជាតិទៅហើយ។ ត្រង់នេះបានបង្ហាញយ៉ាងប្រត្យក្សថា ការដែលបៀតបៀនជីវិតអ្នកដទៃវានាំឱ្យខ្លួនមានកម្មពៀរ។ ម្ល៉ោះហើយ ពិតមែនថាជាទស្សនៈកម្មផលក្នុងពុទ្ធសាសនា តែវាបានបង្រៀនមនុស្ស ឱ្យខ្លាចអាក្រិត្យនូវសីលធម៌ សកម្មភាពឱ្យចៀសវាងការស្លាប់ ធ្វើបាបជីវិតអ្នកដទៃ នេះត្រឹមតែបោចរោមសត្វ៣ទង ចុះបើប៉ះពាល់ដល់ជីវិតសត្វ ឬមនុស្សទៀតតើនឹងមានពៀរប៉ុន្មានរយជាតិ។

ជាការពិតណាស់ បើយើងមើលមកលើរឿងទេវន្តនេះវិញ ឃើញថាតួអង្គព្រះនាងសុវណ្ណកេសរកាលដែលត្រូវយក្ខិនីវាយ សម្រាតយកសម្លៀកបំពាក់បែបនោះ ក៏ព្រោះតែកម្មពៀររបស់ព្រះនាងពីអតីតជាតិ។ កាលដែលនៅជានាងអាមិត្តា ជាប្រពន្ធជដិលសេដ្ឋី។ កន្លងកាលយូរទៅសេដ្ឋីក៏សុំទៅបួសជាឥសីនៅក្នុងព្រៃជារៀងរាល់ថ្ងៃនាងអាមិត្តាតែងតែយកភោជនទៅជូនឥសីជាប្រក្រតី។ រំលាមួយ នៅពេលដែលនាងយកអាហារទៅឱ្យឥសីដែលជាប្តីរបស់នាង ក៏ឃើញកិន្នរីមួយនៅ ចចារសួរនាំជាមួយឥសី ហើយក៏កើតចិត្តប្រចណ្ឌដោយមិនបានគិតពិចារណា ឬសួរនាំប្តីជាមុនហើយក៏យករំពាត់ទៅវាយនាងកិន្នរីនោះឱ្យរងឈឺចាប់ទាំងកាយ និងទាំងចិត្តផងដែរ។ ហេតុនេះហើយ បានជាពេលអស់ជីវិតទៅក៏បានធ្លាក់ទៅរងទុក្ខនៅនានរក អស់ជាច្រើនជាតិអង្វែងសែនយូរ។ លុះដល់ផលបុណ្យដែលបានសាងឱ្យផល ទើបអមិត្តាបានមកកើតជាបុត្រីរបស់ក្សត្រ។ ដោយសារកម្មដែលនាងអមិត្តាបានវាយនាងកិន្នរឈឺគ្រាំគ្រានេះហើយ ទើបបានជាជាតិនេះព្រះនាងត្រូវរងកម្មគឺយក្ខិនីវាយធ្វើបាន ប៉ងសម្លាប់ហើយបានបណ្តែតចោលទៅតាមទឹកក្នុងជាតិនេះ។ ដូចមានបញ្ជាក់នៅក្នុងអត្ថបទ៖

បានជាយក្ខិនី	វាវាយក្សត្រី	ព្រោះកាលជាតិមុន

[48] កុល ផេង, ***ព្រះសុវណ្ណសាមជាតក ពិស្តារ***,ភ្នំពេញ, ២៥៦០, ទំ.២៨

នាងវាយកិន្នរ ថ្នះមរណាជន ជាតិជាទុរុន
ទូពអាត្មា ។(ទំ. ២៦៥)

នេះបង្ហាញឱ្យឃើញពីផលកម្មរបស់ព្រះនាងសុវណ្ណកេសរ ដែលបានសាងពីអតីតជាតិ ហើយវាបន្តមកតាមរហូតដល់បច្ចុប្បន្នជាតិ ក៏បានទទួលនូវសម្បត្តិល្អដោយសារតែកុសលកម្មរបស់ព្រះនាងក្នុងអតីតជាតិដែលបានបម្រើព្រះមុនីឥសី ហើយក៏មានទទួលរងទុក្ខវេទនា ត្រូវយក្ខិនីវាយធ្វើបាបប៉ងសម្លាប់ ក៏ព្រោះតែអកុសលកម្មដែលព្រះនាងបានវាយនាងកិន្នរីក្នុងអតីតជាតិដែរ។ យើងឃើញថា បញ្ហាផលកម្មត្រូវបានពន្លេចឡើងនៅក្នុងសាស្ត្រាទេវន្ទនេះ ទាំងកុសលកម្ម និងអកុសលកម្ម។ តួយ៉ាង ព្រះនាងសុវណ្ណកេសរបានមកយកកំណើតជាបុត្រព្រះមហាក្សត្រក៏ព្រោះតែកុសលកម្មរបស់ព្រះនាងពីជាតិមុន ហើយរងទុក្ខវេទនាក្នុងនរក ក៏ដូចជាត្រូវយក្ខិនីធ្វើបាប ក៏ព្រោះតែអកុសលកម្មរបស់ព្រះនាងក្នុងអតីតជាតិដូចគ្នា។

យើងអាចឃើញយ៉ាងប្រត្យក្សនូវកម្មផលដែលកើតឡើងទាន់ហន់ នៃការប្រព្រឹត្តនូវអំពើរបស់ខ្លួននាបច្ចុប្បន្នជាតិ។ ជាក់ស្តែងគួអង្គព្រះបាទព្រហ្មទត្ត និងមេស្រុក ដែលជាអ្នកព្យាយាមព្យាបាទកោគកុលកុមារទាំងប្រជល់ដំរី លូកទឹកក្តៅ រហូតដល់ធីស៊ុត ដើម្បីយកនាងសុខុមាន្ទាទៅមកធ្វើជាមហេសី។ ទោសនៃការលួច ឬចង់បានប្រពន្ធអ្នកដទៃនេះវាជាអំពើឆ្គាំឆ្គងមួយដែលខ្លួនជាថ្នាក់ដឹកនាំទៀតផងនោះ ហ៊ានប្រព្រឹត្ត។ ការណ៍នេះបាននាំឱ្យ ព្រះបាទព្រហ្មទត្តរួមជាមួយនឹងមេស្រុកធ្លាក់ទៅក្នុងនរកមហាតាបន៍ រហូតដល់កន្លះកប្បទៀតផង។

កាលនោះឯកអង្គមហាក្សត្រ ព្រះបាទព្រហ្មទត្ត នូវគាមភោជកអប្រិយ។
កិតធ្លាក់ពីលើដំរី ដួលដល់ផែនដី ក្សីណក្សយជីវិតជន្មា។
ធ្លាក់ទៅសោយទុក្ខវេទនា នៅនរកមហា- តាបន៍ដល់កន្លះកល្បគត់។(ទំ. ១៤៧)

នេះសឱ្យឃើញពីបញ្ហាកម្មផលដែលកើតចេញពីការប្រព្រឹត្តមិនល្អនាបច្ចុប្បន្នជាតិ ហើយនាំឱ្យផលនោះឆ្លងដល់អនាគតជាតិទៀតផង។ ប្រការនេះក៏ទោះជាយកបញ្ហាកម្មផលក៏មកសម្អាងពិត តែអ្នកនិពន្ធបានបង្ហាញបម្រាមមួយជាផ្នត់គំនិតឱ្យប្រជារាស្ត្រខ្មែរ គិតគូរកុំបៀតបៀនប្រពន្ធប្តីកូនអ្នកដទៃ នាំឱ្យមានកម្មវេរបែបនេះ។

នៅក្នុងខ្សែរឿង មរណមាតាវិញ ហាក់ប្លែកអំពីសាស្ត្រាមួយចំនួន ពោលគឺបានលើកពីបញ្ហាកម្មផលដែលសាងឡើងក្នុងបច្ចុប្បន្នជាតិ ហើយទទួលផលក្នុងបច្ចុប្បន្នជាតិតែម្តង ដែលកម្មនេះគេហៅថា ទិដ្ឋធម្មវេទនីយកម្ម។ យើងឃើញថា ដោយហេតុតែគ្រួសារកាឡីបានរៀបគម្រោងការសម្លាប់មរណមាតា ហើយឱ្យកូនស្រីខ្លួននាងចន្ទណី ក្លែងខ្លួនជាមរណមាតា ហើយទៅចូលរាជវាំងធ្វើជាមហេសីព្រះរាជា។ ដោយសារកម្មពៀរដែលបានធ្វើអំពើអកុសលមកលើមរណមាតានេះហើយ គ្រួសារកាឡីត្រូវរងនូវភាពលំបាកវេទនាកម្មតាមយ៉ាងទាន់ហន់ គឺនាងចន្ទណីត្រូវបានព្រះរាជាដាក់ទោសប្រហារជីវិត ហើយចំណែកគ្រួសារនាងវិញគឺកាឡី កុជុម្ភីក៍ និងចន្ទី ត្រូវព្រាត់ប្រាស់ចេញពីភូមិឋាន ផ្ទះសម្បែងធ្លាប់ជ្រក ធ្វើដំណើររងទុក្ខវេទនាក្នុងព្រៃយ៉ាងយូរ ដូចរៀបរាប់ថា៖

អស់បានទីសប្បាយ កើតអន្តរាយរត់ចោលស្រុក
ពីថ្ងៃនេះទៅមុខ មានតែទុក្ខភ័យជាអាទិ៍។

នេះសមកម្មអំពើ ដែលយើងធ្វើចិត្តប្រមាទ
ពៀរដែលយើងពិឃាត នៃនាងមរណមាតា។ (ទំ. ១៤៤-១៤៥)

ត្រង់នេះហើយ បានបញ្ជាក់ឱ្យឃើញពីកម្មដែលអ្នកទាំងបីបានសាងដោយផ្សំគំនិតគ្នាសម្លាប់នាងមរណមាតា ហើយកម្មនេះមិនបានទុកផ្តន្ទាដល់ជាតិក្រោយនោះទេ វាបានតបស្នងនៅក្នុងបច្ចុប្បន្នជាតិនេះតែម្តង។ ការលើកឡើងរបស់កវី អ៊ុក នេះ ហាក់មានភាពត្រូវទៅនឹងបញ្ហាលោកិយសច្ចៈច្រើន ដ្បិតនរណាសាងអ្វីរមែងទទួលបាននូវផលដែលគេសាងនោះភ្លាមៗ ដោយពុំរង់ចាំជាតិខាងមុខ។

ខ- បញ្ចសីល

យើងឃើញមានធម៌ក្នុងការប្រតិបត្តិដូចជា និច្ចសីល ឧបោសសីល ទសសីល និង ចតុប្បារិសុទ្ធិសីល។ ធម៌ទាំងនេះសុទ្ធតែចូលរួមកសាង សន្តិភាពក្នុងចិត្ត សន្តិភាពផ្លូវកាយ និងសង្គមទាំងមូលដែរ។ វាធ្វើឱ្យមនុស្សវៀសចាកចរិតឥរិយាបថដែលជាអំពើអាក្រក់ទាំងពួង ហើយប្រកាន់ខ្ជាប់នូវសីលធម៌ គុណធម៌ សុជីវធម៌ជាមនុស្ស។ ជាក់ស្តែង និច្ចសីលឬ បញ្ចសីល ឬ សីលប្រាំ ជាសីលដំបូងក្នុងការប្រតិបត្តិក្នុងនាមជាពុទ្ធសាសនិក។ និច្ចសីលមានសិក្ខាបទចំនួនប្រាំ គឺ បាណាតិបាតា អទិន្នាទានា កាមេសុមិច្ឆាចារា មុសាវាទា សុរាមេរយមជ្ជប្បមាទដ្ឋានា។ក្នុងនិច្ចសីលបានអប់រំច្រើនមិនត្រឹមតែជាទ្រឹស្តីធម៌អាថ៌ប៉ុណ្ណោះទេ តែបានជួយមួយផ្នែកដល់ការអប់រំសីលធម៌ សន្តិភាពរបស់មនុស្ស។

នៅក្នុងសុវណ្ណសាមជាតកក៏បានបង្ហាញពីការទេសនារបស់សុវណ្ណសាមទៅកាន់ បិលយក្សដែលបានដឹងកំហុសខ្លួន។ ក្នុងនោះសុវណ្ណសាមបានបង្ហាញថា បើចង់រួចផុតពីកម្មទាំងឡាយ និងចង់ឱ្យព្រះអង្គទៅកើតនៅសួគ៌ទេវលោកនាយ គប្បីឱ្យប្រព្រឹត្តិគន្លងធម៌ទាំង១០ប្រការ។ លើសពីនេះព្រះពោធិសត្វបានប្រទាននូវសីលប្រាំឱ្យបិលយក្សយកទៅរក្សាផងដែរ។ នេះហើយជាឥទ្ធិពលមួយដ៏សំខាន់នៃទស្សនៈសីលប្រាំ ឬបញ្ចសីល ឬនិច្ចសីលនេះឯង បានបញ្ចូលទៅក្នុងស្នាដៃរឿង ប្រសិនបើមនុស្សចង់កើតនូវសួគ៌ឋានគប្បីរក្សា និងប្រព្រឹត្តនូវសីលនេះឯង។ នៅក្រោយការចង់បានសោយសុខនៅសួគ៌ឋាននេះ ការបើមនុស្សប្រព្រឹត្តនូវសីលទានទាំងនេះនាំឱ្យសង្គមគេទាំងមូលមានភាពសុខសាន្តគ្មានជម្លោះ គ្មានការប្រទូស្តរាយកើតឡើងនោះឡើយ។

ចំណែកឯរឿងក្រុងសុភមិត្រវិញ ក៏បានបង្ហាញពីទស្សនៈនិច្ចសីលនេះដែរសម្រាប់អប់រំជននានុជនឡាំងឡាយឱ្យប្រកាន់ខ្ជាប់។ ក្រោយពេលការដឹងគ្រប់សព្វក្រុងសុភមិត្រ បានរៀបចំឱ្យបុត្ររបស់ខ្លួនទាំងពីរគឺ ជ័យសែនជាបងឡើងគ្រងរាជ្យសម្បត្តិបន្ត រីឯជ័យទត្តជាប្អូនឡើងជាអគ្គមហាសេនា។ ពេលដែលជ័យសែនឡើងគ្រងរាជ្យទ្រង់ក៏បានប្រកាន់ខ្ជាប់នូវទសពិធរាជធម៌ សុចរិតធម៌ ព្រមទាំងទ្រង់រក្សាសីលប្រាំ អដ្ឋសីល ភាវនារៀងរាល់រាត្រី។ លើសពីនេះទ្រង់ក៏បានទូន្មានអស់សេនាមន្ត្រីឱ្យកាន់នូវសីលប្រាំជានិច្ច ដូចលើកឡើងថា៖

ស្តេចទ្រង់សីលប្រាំ អដ្ឋសីលចាំ សព្វទិនទិវា
សង្វេគសង្វាត ស្មឹងស្មាធ៍ភាវនា នៅលើប្រាង្គប្រា-
សាទសព្វរាត្រី។
ព្រះអង្គក្សត្រក្សាន្ត ស្តេចតែងទូន្មាន សេនាមន្ត្រី

ឱ្យកាន់សីលប្រាំ ចងចាំស្មារតី រាស្ត្រដ្ឋសោភី
ក្សេមក្សាន្តនគរ។(ទំ.៩៣)

នេះហើយ យើងឃើញថា ទង្វើនិងការអប់រំទូន្មានប្រៀនប្រដៅរបស់ ជ័យសែន វាពិតមែនថាជាទស្សនៈរបស់សាសនាក៏ពិតមែន តែវាបានបម្រើឱ្យសេចក្តីត្រូវការ ភាពសុខសាន្តរបស់មនុស្សទូទៅ។ ប្រសិនប្រើសេនាមន្ត្រី ប្រជានុរាស្ត្រ ចៀសវាង អំពើទាំង៥នោះ ការលួច ការសម្លាប់ ការកុហក ការចង់បានប្រពន្ធកូនគេ ការសេពគ្រឿងស្រវឹងនោះ វានឹងធ្វើឱ្យសង្គមមានស្ថិរភាព គ្មានភាពរញ៉េរញ៉ៃទៀតផង។ ទាំងនេះបើនិយាយពីផ្លូវលោក តែបើមើលទៅផ្លូវសាសនា អ្នកទាំងនោះនឹងទៅកើតនៅឋានសួគ៌ពិតប្រាកដ។

ក្នុងការរក្សានូវបញ្ចសីលនេះ ការទទួលយកនូវបញ្ចសីលក៏ជាឥទ្ធិពលមួយរបស់ទ្រឹស្តីព្រះពុទ្ធសានាផងដែរ។ តាមរយៈសាស្ត្រាទេវន្តនេះ បានបង្ហាញពីការទទួលយកនូវបញ្ចសីលពីកុម្ភណ្ឌទាំងបួន ដើម្បីបានស្តាប់នូវព្រះធម៌ទេសនាពីសំណាក់ព្រះទេវន្ត។ ហេតុតែចង់ស្តាប់នូវព្រះធម្មទេសនារបស់ព្រះទេវន្ត កុម្ភណ្ឌទាំងបួនក៏ព្រមឱនសិរសាបង្គំទទួលសុំស្មាទាននូវបញ្ចសីល។ ដូចលើកឡើងថា៖

ទើបពោធិសត្វ ពន្លកពុទ្ធវ័ត្ន បន្ទូលទៅថ្កាន
ហៃអស់មហាយក្ស សីលប្រាំស្មាទាន ចូរអ្នកឲ្យបាន
ចាំជាក់ប្រក្រតី។
បាណាតិបា- តាអទិន្នា កាមេសុវា
មិឆាចរិយា មុសាវាទិ មជ្ជំបិវិ
វេរមណា។
បាណាតិបាត ឲ្យវៀរប្រមាទ ជីវិតសត្តា
អទិន្នាទាន វៀរមានលោភា លោភលួចទ្រព្យា
នៃអស់មហាជន។
កាមេសុមិច្ឆា កុំបរទារកា វៀរលួចប្រពន្ធ
នៃអ្នកនានា ឲ្យមកជាម- ន្ទិលទាស់ទូរន់
ដូចដល់អាត្មា។
មុសាវាទី វេរមណី វៀរពាក្យមុសា
មជ្ជំបិវិ វៀរពីសុរា គឺលាមកជា
ថ្នាំបំពុលអង្គ។
ពន្លកសារពេជ្រ ឲ្យសីលប្រាំស្រេច ទៀងទើបត្រាស់ទ្រង់
បន្ទូលទៅថា ហៃមហាយក្សយង់ ចូរប្រែស្តេងទ្រង់
ស្មារតីរាល់គ្នា។(ទំ. ១៣៥-១៣៦)

នេះបង្ហាញឱ្យឃើញពីការទទួលយកនូវបញ្ចសីលរបស់កុម្ភណ្ឌទាំងបួន ដើម្បីបានស្តាប់នូវធម្មទេសនារបស់ព្រះទេវន្ត។ តាមរយៈអត្ថបទដកស្រង់ខាងលើ សបញ្ជាក់ថាតួអង្គយក្សទាំងបួនបានទទួលនូវបញ្ចសីល ដោយបានឱនកាយបង្គំព្រះទេវន្ត ដែលនមស្សការនូវសីលប្រាំឱ្យទៅដល់កុម្ភណ្ឌទាំងបួន។ យើងឃើញថាឥទ្ធិពលពុទ្ធសាសនានេះបានចាក់ឫសយ៉ាងជ្រៅក្នុងសាស្ត្រាទេវន្តនេះ ដោយបានបង្កប់នូវគោលទ្រឹស្តីព្រះពុទ្ធសាសនាគឺសីលប្រាំនេះឯង។ ម្យ៉ាងទៀតបានបង្ហាញពីការសម្តែងនូវធម៌ទេសនា ដែលជាការអប់រំទូន្មានរបស់ព្រះសម្មាសម្ពុទ្ធក្នុងសម័យពុទ្ធកាល ដែលបន្តរហូតមក ហើយអ្នកនិពន្ធបានលើកយកទ្រឹស្តីនេះមក បញ្ចូលក្នុងស្នាដៃរបស់ខ្លួន ហើយបានបង្ហាញពីតួអង្គទេវន្ត ដែលជាតួអង្គព្រះពោធិសត្វ ជាអ្នកសម្តែងនូវធម៌ទេសនាទូន្មានដល់ដល់កុម្ភណ្ឌទាំងបួន។

ជាការពិតណាស់បើក្រឡេកមកមើលរឿង កោគកុលកុមារជា ប្រភេទអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុនេះវិញ យើងឃើញថា ក្នុងការគ្រងរាជ្យរបស់ ព្រះបាទកោគកុលកុមារតែងមានព្រះទ័យសប្បុរស ធ្វើទានដល់អាណានុរាស្ត្រ។ ព្រះអង្គក៏បានប្រៀនប្រដៅអស់មន្ត្រី សេនាបតី ប្រុសស្រីទូទាំងនគរឱ្យចេះរក្សាសីល ពិសេសសីលប្រាំនេះតែម្តង ដូចលើកឡើងថា ៖

ត្រេកទ្រង់សីលប្រាំ អស្តង្គសីលចាំ ពុំភ្លាត់ភ្លេចភ្លាំង
ទូន្មានមន្ត្រី ប្រុសស្រីរាស្ត្រទាំង នគរឲ្យតាំង
រក្សាសីលធម៌។(ទំ.២០៤)

ក្នុងការទូន្មាននោះព្រះអង្គក៏បានប្រាប់ដល់រាស្ត្រនូវសិក្ខាបទទាំងប្រាំ ព្រមទាំង បាបកម្មដែលទ្រុស្តទៅនឹងសីល និងកុសលកម្មដែលបានទទួលពេលប្រព្រឹត្តសិក្ខាបទនេះ។

- ***សិក្ខាបទទីមួយ*** គឺបាណាតិបាតា ដោយទ្រង់លើកថា រីនរណាជាអ្នកសម្លាប់ឬ ចិត្តប៉ងស្លាប់ម្រឹគីម្រឹគា មច្ចា ឬមនុស្សនោះ នឹងត្រូវរងបាបក្នុងឋាននរក ដោយយមរាជបោះចូលក្នុងភ្លើងក្តៅសន្ធោសន្ធៅ។ រីឯយមបាល ចាក់នឹងស្នប្លុកដែកក្តៅ។កាលបើគម្រប់ប្រាំរយឆ្នាំ ដោយប្រាំបួនលានឆ្នាំមនុស្សទើបស្មើមួយថ្ងៃឋាននរក។ ក្រៅតែអំពីរងទុក្ខនោះហើយ កាលបើមកកើតជាមនុស្សនឹងក្លាយទៅជា មាន់ ជ្រូក ទា ត្រី ដែលគេកាប់សម្លាប់ ចំនួនប្រាំរយជាតិ។ ប្រសិនបើកើតជាមនុស្ស ត្រូវគេចាក់ កាប់ បាញ់ ដោយ អស់ប្រាំរយជាតិដូចគ្នា។លើសពីនេះគេនឹង ក្លាយទៅជាមនុស្សមានរោគា ដំបៅពក គមខ្នង ក្អែកខ្វាក់ខ្វិន ដៃជើងក្ងែងក្ងក់ ហើយប្រសិនបើមានបុណ្យសក្តិនឹងធាប់អាយុខ្លីជាដើម។ ផ្ទុយទៅវិញប្រសិនបើគេអនុវត្តខ្ជាប់ខ្ជួននូវសិក្ខាបទនេះគេនឹងទៅកើត នៅនាឋានសួគ៌ចាតុម្មហារាជិកា ជាទេវបុត្រស្អាតបិតនៅលើប្រាសាទប្រាំពីរយោជន៍ តែបើជាស្ត្រីនឹងកើតជាទេពកញ្ញាផងដែរ។ អ្នកទាំងពីរគម្រប់ ប្រាំរយឆ្នាំគត់ ទើបច្យុតចុះមកផែនដីកើតក្នុងត្រកូលក្សត្រ រស់នៅដោយសុខដុមពុំមានជំងឺ ពុំមានសត្រូវណាមកបៀតបៀនឡើយ។
- ***សិក្ខាបទទីពីរ*** ព្រះបាទកោគកុលកុមារបានទូន្មានចំពោះការប្រព្រឹត្តអទិន្នាទានា ដែលមនុស្សលួចទ្រព្យអ្នកដទៃ បោកបញ្ឆោត បំពានដោយអាងយសសក្តិលើអ្នកដទៃ។អ្នកទាំងនេះបានបានធ្លាក់នរក ហើយត្រូវបានយមបាលចាប់ចង ធាក់វាយដំ យកបន្ទាត់ដែកមុតចាក់ផ្ចាត់សព្វកាយពីក្បាលដល់ចុងជើង អស់កាលកំណត់១

ពាន់ឆ្នាំ។ មួយពាន់ឆ្នាំឋានត្រៃត្រឹង្ស ទើបមួយថ្ងៃឋាននរក។លុះសម្រេចនៅនរកហើយមកកើតជាប្រេតវិញម្តង ដែលមានកម្ពស់ខ្ពស់ចុងត្នោត អស់ប្រាំរយជាតិ។ប្រសិនបើកើតជាមនុស្សមានទ្រព្យតិចតួច មានចោរចាំលួច បើកើតជាខ្ញុំគេ ត្រូវម្ចាស់វាយដំ។ រីឯអ្នកដែលវៀរចាក នូវសិក្ខាបទនេះមិនលួច ប៉ះពាល់ទ្រព្យសម្បត្តិអ្នកដទៃ អ្នកនឹងទៅបានកើតនៅឋានសួគ៌ត្រៃត្រឹង្សមានទេពអប្សរ បរិវារកញ្ញាមួយពាន់ចោមជាបរិវារ។ នៅក្នុងប្រាសាទខ្ពស់ ទ្វាទសយោជន៍ រចនាពិចិត្រយ៉ាងប្រណិត។ គម្រប់មួយពាន់ឆ្នាំបាន ទៅកើតជាត្រកូលក្សត្រមានទ្រព្យសម្បត្តិច្រើនពន់ពេក។ បើកើតជាត្រកូលរាស្ត្រ នឹងកើតជាសេដ្ឋីមានទ្រព្យច្រើន មានសក្តិយស និង ពុំមានចោរសត្រូវណាមកបៀតបៀនឡើយ។

- ***សិក្ខាបទទីបី***គឺ កាមេសុមិច្ឆាចារ ដែលទ្រង់ទូន្មានថា នរណាដែលមិនមានចិត្តវង្វេងលួចករិយាគេ ស្រីផិតប្តីឯងជាដើម។ អ្នកទាំងនោះនឹងទទួលនូវកម្មនៅនរក ត្រូវយមបាលដេញឱ្យឡើងដើមរកាដែកជាភ្លើង ប្រមាណមួយយោជន៍។ស្រីឡើងមុន បន្ទាប់មកប្រុស ធ្លុះធ្លាយស្រែកយំគួរឱ្យសង្វេគ។ មិនតែប៉ុណ្ណោះមានឆ្កែស ប៉ុនដំរីខាំកន្ត្រាក់ ត្មាតក្អែកចាំចឹកធ្លុះធ្លាក់ខ្លួន ត្រូវភ្លើងឆេះ។ស្លាប់ក្នុងមួយថ្ងៃពីរពាន់ដង ត្រូវរងទុក្ខអស់ ពីរពាន់ឆ្នាំ ដែលអាយុពីរពាន់ឆ្នាំទិព្វ ស្មើនឹងឋានសួគ៌មួយថ្ងៃ មួយយប់នរក។ បើយោងយកកំណើតជាសត្វតិរច្ឆាន នឹងត្រូវគេក្រៀវ អស់ប្រាំរយជាតិ។កើតជាមនុស្សខ្ទើយប្រាំរយជាតិ បើកើតជាស្រីត្រូវព្រាត់ប្តីប្រាំរយជាតិ។ បើកើតជាមនុស្សប្រុស ត្រូវមានកម្មជួបប្រពន្ធផិតរហូត។ ផ្ទុយទៅវិញបើអ្នកប្រណិប័តន៍បានខ្ជាប់ខ្ជួននោះគេនឹងសោយសម្បត្តិសួគ៌បិតនៅក្នុងប្រាសាទពិចិត្រ មានទេពអប្សរពីរពាន់ចាំគាល់។ លុះអាយុបានពីរពាន់ឆ្នាំទិព្វ ច្យុតមកយោងយកកំណើតជារាជបុត្រ ប្រកបដោយលក្ខណាគ្រប់គ្រាន់។
- ***សិក្ខាបទទីបួន*** គឺមុសាវាទា កោគកុលកុមារបានអប់រំថា អ្នកឯណា កុហកកាច មានពាក្យរឹងរូស ប្រទូស្តរាយ កំហឹង បញ្ឆេះបញ្ឆោត ភូតភរឱ្យគេបង់ទ្រព្យ បង់ស្រែ ឬកើតទុក្ខជាដើមនោះ គេនឹង ទៅនរកសោយទុក្ខអស់ បួនពាន់ឆ្នាំ ព្រោះមាត់អាក្រក់។ យមបាលយកដង្កាប់ដែកមកដុត ដកអណ្តាត ទម្លាក់ចូលទៅក្នុងរណ្តៅ គម្រប់បួនពាន់ឆ្នាំស្មើនឹងឋានតុសិតមួយថ្ងៃ។ លុះបានកើតមកជាប្រេត មាត់ឆេះចេញភ្លើង ស៊ីខ្ទុះឈាមជាអាហារ។កាលបើបានកើតជាមនុស្ស ក្លាយជាមនុស្សមាត់រៀចឆៃប លង់ គង្គង់ មាត់ស្អុយជាដើម។ រីឯអ្នកដែលប្រកាន់ខ្ជាប់ស្រដីពាក្យសត្យនោះគេនឹងទៅកើតនៅឋានតុសិត អាយុបួនពាន់ឆ្នាំមានបរិវារ ទេពអប្សរចាំគាល់នៅប្រាសាទកម្ពស់ប្រាំយោជន៍។អស់និស្ស័យនឹងកើតជាអ្នកប្រាជ្ញចេះធម៌អាថ៌។
- ***សិក្ខាបទទីប្រាំ*** គឺសុរាមេរិយ ដែលសិក្ខាបទនេះបានអប់រំឱ្យចៀសវាងការផឹកស្រា នាំឱ្យភ្លេចភ្លាំងស្មារតី។ អ្នកដែលប្រព្រឹត្តនឹងធ្លាក់ទៅក្នុងនរកគឺ តាបន៍នរក អស់ប្រាំបីពាន់ឆ្នាំ។ ជននោះនឹងផឹកទឹកទង់ដែង ក្តៅក្តាត់រលាករលួយ។ គេនឹងកើតជាយក្សតិរ្ថិយ មនុស្សលីលា មានពាក្យអសុរោះរឹងទ្រគោះ ដែលអ្នកផងតិះដៀលនិន្ទា ជាមនុស្សមោហោជ្ឈជាតិខ្លួនខ្មៅជាដើម។តែបើវៀរចាកការសេពសុរា អ្នកនោះនឹងទៅបានសោយសុខនៅនិម្មានិរតី កម្ពស់ប្រាសាទសាមសិបយោជន៍ មានទេពអប្សរប្រាំបីពាន់គាល់បម្រើ។ គម្រប់ប្រាំបីពាន់ឆ្នាំទិព្វកើតជាស្តេចមានចេស្តា ប្រកបដោយប្រាជ្ញាខ្លាំងក្រៃ។ ជាមនុស្សមានចិត្តខ្ជាចបាប ពោលពាក្យល្អគំនិតជ្រៅជ្រះ។

ជាការពិតណាស់ដូចដែលយើងបានដឹងអំពីការលើកឡើងនូវការណែនាំរបស់ ព្រះបាទកោគកុលកុមារ ទៅដល់មន្ត្រីអស់រាស្ត្រទាំងនគរឱ្យប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងនាមជាពលរដ្ឋល្អនិងជាពុទ្ធសាសនិកមួយ។ ការលើកឡើងនេះមិនមែនតែជាគំនិតរបស់កោគកុលកុមារនោះទេ តែជាគំនិតរបស់កវីនិពន្ធខ្មែរ គឺព្រះឃ្លាំងនង តែម្តងក្នុងន័យអប់រំចរិយាយសម្បត្តិប្រជាជនខ្មែរឱ្យចេះគោរពគ្នា ឱ្យតម្លៃគ្នានិងរស់នៅក្នុងសង្គមមួយប្រកបដោយសន្តិភាព។ វិធីក្នុងការអប់រំរបស់លោកមិនមែនទៅយកដាវ កាំបិត ទាហានទៅបង្ក្រាប ឬប្រាប់ដោយចំៗថាខុសទៅនឹងវិន័យច្បាប់នោះទេ ។ ផ្ទុយទៅវិញ ស្ថិតនៅក្នុងចន្លោះពេលដែលខ្មែរជឿ និងទទួលឥទ្ធិពលខ្លាំងពីពុទ្ធសាសនា លោកក៏បានបញ្ជាបការអប់រំនេះ តាមរយៈស្នាដៃរបស់លោកឱ្យប្រជាជនកាន់តែរអាក្នុងការប្រព្រឹត្តអំពើអាក្រក់ទាំងពួង ដែលជាបាបកម្ម ត្រូវធ្លាក់ទៅនរកឯទុក្ខផ្សេងៗអស់កាលរាប់ពាន់ឆ្នាំ។ លើសពីនេះ លោកយល់យ៉ាងច្បាស់អំពីបរិបទសង្គមអប់រំនាពេលនោះ ដោយការសិក្សាអប់រំប្រព្រឹត្តទៅនៅវត្តអារាម ហើយការសិក្សាគឺការរៀនទៅលើសាស្ត្រានេះឯង។ ដូច្នេះការអប់រំតាមវិធីនេះអាចមានប្រសិទ្ធភាពខ្ពស់។ ម៉្យាងទៀតក្រៅពីហាត់នឿយក្នុងការងារ សាស្ត្រាល្បែង ជាប្រភពកម្សាន្តមួយដ៏សំខាន់ក្នុងអាន ឬស្តាប់តាមរយៈការនិទាន។ ម្ល៉ោះហើយ ការបញ្ចូលនូវបញ្ហាបុណ្យបាប សីលប្រាំរបស់លោកមានលក្ខណៈជ្រួតជ្រាបទៅក្នុងផ្នត់គំនិតខ្មែរសមនឹងពួកគាត់ជាពុទ្ធសាសនិកជនផងនោះ។

ទ្រឹស្តីប្រតិបត្តិនិច្ចសីលឬសីលប្រាំនេះ រមែងពុំសូវចោលតាមរយៈការឆ្លុះបញ្ចាំងក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធសាសនានោះទេ។ ជាក់ស្តែងក្នុងរឿងមរណមាតាក៏បានលើកបង្ហាញផងដែរពីទស្សនៈនេះឱ្យមនុស្សយល់ដឹង ហើយប្រកាន់ខ្ជាប់។ តួយ៉ាងនៅពេលដែលកុដុម្ពីក៍ កាឡីនិងនាងចន្ទីត្រូវបានរត់គៀសខ្លួនពីអាជ្ញារបស់ព្រះបាទវិមលធម្មរាជ អ្នកទាំងបីបានទៅដល់ស្រុកមួយដែលស្រុកនោះពុំចែងឈ្មោះក្នុងបទបាលី ហើយត្រាច់ចរង្គត់ រហូតបានទៅជួបនឹងតាបសម្នាក់។ តាបសបានជួយសង្គ្រោះអ្នកទាំងបីដោយផ្តល់នូវឱវាទឱ្យខំរក្សាសីលប្រាំឱ្យបានខ្ជាប់ខ្ជួន ព្រមទាំងរក្សាទាននិងសីល ដូចបរិយាយថា៖

ពីថ្ងៃនេះទៅមុខ ចូរតាំងទុកចិត្តតម្កល់
សតិនឹកកុសល ខំរក្សាសីលទាំងប្រាំ។...
កើតមកជារូបរាង ធម៌ពីរយ៉ាងគួររក្សា
គឺទាននិងសីលា ជាពំនាក់រូបសព្វថ្ងៃ។...
បាណាតិបាតា ចាកកិរិយាញុំាងជីវិត
មនុស្សសត្វកុំប្រព្រឹត្ត ដោយកាយឬវាចាក្តី។
អទិន្នាទានា ប្រែតាមវាៈបាលី
ទ្រព្យគេច្រើនតិចក្តី រៀរកុំបីលួចប្លន់។
កាមេសុមិច្ឆា បរទារិកាប្រពន្ធ
រៀរចាកសេពមេថុន ជារបស់អ្នកដទៃ។
មុសាវាទាទៀង ពាក្យកុំល្បៀងភូតឡើយនៃ

វៀរចាកចាំសព្វថ្ងៃ	ជាពំនាក់អង្គអាត្មា។
សុរាមេរ័យ	មជ្ជប្បមាទដ្ឋានា
ឲ្យវៀរចាកកិរិយា	គឺផឹកស្រាទឹកស្រវឹង។ (ទំ.១៤៨-១៤៩)

ដូចដែរយើងឃើញហើយថាតាបសបានទូន្មានកុដុម្ពីក៍យ៉ាងក្រាស់ក្រៃឱ្យលះបង់នូវគ្រឿងសៅហ្មងទាំងនេះ ហើយងាកមកចាប់យកកុសលធម៌វិញ។ ការដែលជួបតាបសនេះ មិនមែនជារឿងចៃដន្យនោះទេ ពោលគឺមកពីកុសលផលបុណ្យខ្លះដែលបានសាងមកពីជាតិមុននាំឱ្យគាត់បានជួបតាបសហើយស្រោចស្រង់ជីវិតបែបនេះ។ អ្នកទាំងបីបានប្រែក្លាយពីមនុស្សអាក្រក់មកជាមនុស្សល្អវិញ ដោយបានប្រកាន់ខ្ជាប់នូវអំពើជាកុសល របរសុចរិតវិញ ហើយរស់នៅជាមួយគ្នាប្រកបដោយក្តីសុខវិញ។ ត្រង់នេះសឱ្យឃើញពីការប្រណិប័តន៍អំពើជាកុសល អាចកែប្រែជីវិតខ្លួនបានល្អ។ ក្នុងន័យម្យ៉ាងទៀត រាល់កំហុសទាំងឡាយដែលមនុស្សធ្វើខុស នៅតែអាចកែប្រែខ្លួនឱ្យបានជាមនុស្សល្អវិញ វាអាស្រ័យលើការតាំងចិត្ត និងការប្រតិបត្តិរបស់មនុស្ស។

៤.៥- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងវិធីតំណែនាំពន្ធវណ្ណកម្មខ្មែរ

អក្សរសិល្ប៍ពុទ្ធនិយមមិនត្រឹមតែ អប់រំចរិយាស្ត្រមនុស្ស និងបន្ធូរបន្ថយភាពតានតឹងទៅលើបញ្ហាសង្គមនាសម័យកណ្តាលនោះទេ តែអក្សរសិល្ប៍ពុទ្ធនិយមក៏ជាពុម្ពគំរូមួយសម្រាប់ស្នាដៃអក្សរសិល្ប៍ជំនាន់ក្រោយផងដែរ។ ពិពិធភាពនៃស្នាដៃមិនថា រឿងដែលយកចេញពីទសជាតក បញ្ញាសជាតក ឬប្រភេទនានាជាតក ហើយត្រូវអ្នកនិពន្ធតាក់តែងជាកាព្យក្តីនោះតែ សុទ្ធតែបង្ហាញពីតម្លៃ ទឹកដៃខាងផ្នែកតាក់តែងនិពន្ធគ្រប់ៗរឿងសម្រាប់អ្នកនិពន្ធជំនាន់ក្រោយក្នុងការយកជាគំរូនិងលំអានទៀតផង។

ក- ក្រមួចកែវ បទកាព្យ

ជាការពិតណាស់ បើគេនិយាយពីស្នាដៃបែបកម្រងកែវគឺគេនឹកទៅដល់រឿងព្រះវេស្សន្តរនេះឯងតែម្តង។ រឿងព្រះវេស្សន្តរបានបង្ហាញពីលក្ខណៈនៃការប្រើសំនួនបែបកម្រងកែវច្រើនជាងគេ។ តួយ៉ាងនៅក្នុងកណ្ឌជូជកលើកឡើងថា “ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជកព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមច្រដោង ច្រមុះកោង ទ្រូងសឹងតែឆ្អឹងសក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ជំបៅត្រចៀកយុរយារក្រាស់ឃ្លង់ភ្លើង ជើងកាងដូចជើងសេក ក្អែកស្រលៀងស្រឡឹ ...” [49] ។ ត្រង់នេះអាចជាពុម្ពគំរូមួយនៃការតាក់តែងសម្រាប់មនុស្សទូទៅដែលចង់សិក្សាកម្រងកែវនេះ។

ងាកចេញពីកម្រងកែវ ប្រភេទរឿងបញ្ញាសជាតក និងនានាជាតក ជាច្រើនត្រូវបានអ្នកកវីនិពន្ធបានយកទៅតាក់តែងជាបទកាព្យប៉ិនប្រសប់ គួរឱ្យយកត្រាប់តាមមានចួន ផ្ចួន រណ្តំ ល្ហែងល្ហាញណែងណងយ៉ាងពីរោះ។ តួយ៉ាងរឿងក្រុងសុភមិត្រ តាក់តែងជាកាព្យ បទកាកគតិ ព្រហ្មគីតិ ពំនោល ភុជង្គលីលា។ រីឯរឿងទេវន្ទ តាក់តែងឡើងជាបទកាកគតិសុទ្ធ។ ចំណែករឿង កោគកុលកុមារ តែងជាបទកាកគតិ ព្រហ្មគីតិ ពំនោល ភុជង្គលីលា។ និងរឿងមរណមាតា

[49] ញ៉ុក ថៃម, ***មហាវេស្សន្តរជាតក***, កណ្ឌទី៥, បណ្ណាគារត្រែតេន៍, ២០២២ ទំ. ១-២

តែងជាបទ កាកគតិ ព្រហ្មគីតិ និងបទពំនោល។ យើងឃើញហើយថា ការតាក់តែងរបស់កវីបានបញ្ចូលនូវវិធីសាស្ត្រយ៉ាងល្អឯកធ្វើឱ្យដំណើររឿងមានភាពរលូន និងប្រកបដោយសោភ័ណ។

ខ- រូបារូបាកម្មណ៍

នៅក្នុងការតាក់តែងនិពន្ធ លោកកវីបានប្រើវិធីសាស្ត្រក្នុងការតែងតែងយ៉ាងល្អឯងទៅតាមសមត្ថភាពរបស់ខ្លួន។ ក្នុងនោះការប្រើប្រាស់រូបារូបាកម្មណ៍នៅក្នុងកំណាព្យក៏ជាវិធីមួយធ្វើឱ្យអត្ថបទកាព្យមានភាពរស់រវើកណាស់ដែរ។ តួយ៉ាងនៅក្នុងរឿងកោគកុលកុមារ ឧកញ៉ាព្រះឃ្លាំងនង លោកពូកែរៀបរាប់សង្កេតពីរូបរាងកាយធ្វើឱ្យយើងហាក់ឃើញតួអង្គនោះពិតៗ ដូចលើកឡើងថា៖

នាងមួយឈរមុខ	ផ្អៀងផ្អងថ្ងិចថ្ងូរ	អំពើកែក្រាយ
ថ្ពាល់ផូរផាត់ម្សៅ	ពាក់អាវលាវស្វាយ	ករកាន់ព្រះឆាយ
	ព្រះសំអាងអង្គ។(ទំ.១២០)	

រីឯអត្ថបទកាព្យរឿងទេវន្ទរបស់ អម្រឹតក្សត្រីម៉ុក វិញ លោកក៏បានបង្ហាញពីចំណាប់ចួនផ្ចួនរណ្តំ យ៉ាងល្អឯក ព្រមទាំងរៀបរាប់ព្រៃឈើយ៉ាងប៉ិនប្រសប់៖

ដកពរត្រឡាត់	ត្រឡត់កំចាត់	ត្រលៀសកុំចាយ
សំម៉សម៉ូល	ពពូលពពាយ	ពពេលវល្លិ៍វាយ
	ធ្នាធ្នង់ពង្រ។(ទំ.៦៩)	

ចំណែកនៅក្នុងរឿងមរណមាតា របស់កិក្ខុអ៊ុកវិញ ក៏បានបង្ហាញពីការរៀបមុខម្ហូប បង្អែម ប្រកបដោយភាពទាក់ទាញ៖

ខ្លះធ្វើអន្ទង់	ស្លនឹងផ្លែល្មុង	ខ្លះខួបង្កង
ខ្លះញាំពស់ប្រា	ខ្លះភ្លាអង្រែង	លូកភ្លក្សម្តងៗ
	ក្រែងសាបប្រៃពេក។(ទំ.៨៩)	
ចំណីស្រស់ជា	សុទ្ធសៀមសងខ្យា	ចាហួយសារាយ
គ្រាប់ជីសតូវ	តៅហ៊ូផ្លែអាយ	ក្រនៀវកែវក្លាយ
	រៀបរួចទុកទៅ។(ទំ.៩០)	

៤.៦- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្នុងការផ្សព្វផ្សាយវប្បធម៌

ក- ជំនឿ

ពិតណាស់ថាអក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតចម្បងក្នុងការអប់រំមនុស្សឱ្យជឿទៅលើសាសនា ទ្រឹស្តីពុទ្ធសាសនាជាដើម។ តែយ៉ាងណាមិញនៅពេលអ្នកនិពន្ធខ្មែរ លោកបានតាក់តែងនូវរឿងនោះ លោកក៏បានបញ្ចូលនូវលក្ខណៈជាតិរបស់ខ្មែររួមជាមួយផងដែរ ដូចជា ជំនឿលើអារក្សអ្នកតា សត្វ ប្រផ្នូលអ្វីមួយជាដើមនោះ។

នៅក្នុងរឿងទេវន្ទក៏បានបង្ហាញពីការជឿទៅលើទស្សន៍ទាយរបស់ហោរផងដែរ។ នៅពេលកំណើតរបស់ទេវន្ទ មានអ័ព្ទ ភ្លៀង ខ្យល់ព្យុះបោកបក់ងងឹតលើសយប់។ ពេលប្រសូតបុត្រហើយ ហោរាក៏បានទស្សន៍ទាយពីជតារាសីរបស់ទេវន្ទថា៖

ព្រាហ្មណ៍ប្រាជ្ញសិល្បសព្វ គន់គូរគ្រាន់គ្រប់ អស់ឥតហ្មងសៅ
ទើបទូលបពិត្រ មហាក្សត្រចមចៅ រាជបុត្រនពហៅ
គ្រប់លក្ខណ៍ប្រសើរ។(ទំ. ៤៧)

នេះសឱ្យឃើញពីទំនៀមនៃការទស្សន៍ទាយបែបព្រាហ្មណ៍និយមនេះមកលើសង្គមខ្មែរបច្ចុប្បន្នផងដែរ។ ត្បិតពេលមានអាសន្នអន់ក្រគេតែងទៅបូលជោគជាតារាសីមើល តើឡើងចុះ ខុសទាស់ត្រង់ណាជាដើមនោះ។

ជាមួយគ្នានេះដែរការជឿទៅលើប្រផ្នូលតាមរយៈសុបិន ពិតជាពេញនិយមក្នុងសង្គមខ្មែរតាំងពីបុរាណកាលមកម្ល៉េះ។ ក្នុងរឿងភោគកុលកុមារក៏បានបង្ហាញពីការជឿទៅលើប្រផ្នូលពោលគឺកំណើតរបស់ភោគកុលកុមារតែម្តង។ នារាត្រីនោះ ភរិយាភោគវុឌ្ឍីបានយល់សុបិនមានដើមចម្ប៉ាដុះក្នុងផើងមានត្រួតគ្នា លុះ១០ឆ្នាំផើងនោះក៏បែក។ លុះ៥ឆ្នាំបន្ទាប់ក៏លេចចេញផើងមាសថ្មី ហើយក៏បែកអណ្តែតត្រសែតនៅលើអាកាស មានក្លិនឈ្ងុយឈ្ងប ដូចលើកឡើង៖

នាក្នុងរាត្រីកាល នោះនាងនាថវរទេវី
ភរិយាភោគវុឌ្ឍី យង់យល់សប្នបូព៌និមិត្ត។(ទំ.១១)

ដោយហេតុចង់ដឹងនាងក៏បានទៅរកហោរា គន់គូរហើយក៏ដឹងពីសប្តិនោះដោយ កូនប្រុសនោះបាន១០ឆ្នាំមាតានឹងស្លាប់ ហើយ១៥ឆ្នាំបិតានឹងស្លាប់ តែនឹងបានធ្វើធំ។ត្រង់នេះយើងចង់បង្ហាញពីផ្នត់គំនិតដែលជាប់មកដល់បច្ចុប្បន្នទៅនឹងការជឿលើសប្តិទាំង៧យ៉ាងគឺ សុបិននិមិត្ត ចក្ខុសម្ផស្ស ការបរិហារ ការបូល ការកកម្រើកសរសៃវិញ្ញាណ ការលេចធ្លោឡើង សប្តិអាក្រក់ជាដើម។ ការជឿនេះបានកកើតទៅជាតម្រា ក្បួនកាត់សប្តិនិងនិងប្រាប់លេខឆ្នោតជាតិ តាមក្បួនតម្រាឥន្ទទំនាយ[50] ទៀតផង។

បើយើងងាកក្រឡេកមកមើលរឿង មរណមាតាវិញ យើងឃើញថារឿងនេះបានដិតជាមជាប់សតិអារម្មណ៍របស់ប្រជាជនខ្មែរទៀតផង។ តួយ៉ាងនៅពេលម្តាយមរណមាតាបានស្លាប់ហើយទៅកើតជាត្រីដំរី ៖

វាយវែធ្លាក់ទឹកគ្រាំ ហើយឈរច្រំនឹងច្រវា
មិនមាននឹកមេត្តា មិនអាណិតកុលកេសី។
នាងក្សីណាក្សយជន្មា ចាប់ជាតិជាត្រីដំរី
ហែលនៅជាប្រក្រតី ទីកំពង់ទឹកនោះណា។(ទំ. ៣០)

យើងឃើញហើយថា ដោយសារតែនាងកុលកេសីស្លាប់ទៅក្លាយជាត្រីដំរីដូច្នោះហើយ ទើបធ្វើឱ្យផ្នត់គំនិតប្រជាជនខ្មែរពុំសូវនិយមចូលចិត្តពិសាត្រីដំរីនោះទេ ត្បិតគេថាវាជាមនុស្ស។

[50] *សូមមើលបន្ថែម* សម្ផស្សបញ្ញោ, ***ក្បួនកាត់សប្តិ***, បោះពុម្ពសាជាថ្មីដោយ ស្រី ប៊ុនដន, ២០០៤

ខ- ទំនៀមទម្លាប់ប្រពៃណី

ទោះបីជារឿងដែលយកចេញពីទសជាតកក្តី បញ្ញាសជាតកក្តី ក៏លោកកវីនិពន្ធមិនបានចម្លងយកទាំងដុលនូវលក្ខណៈ បរិយាកាស វប្បធម៌នៃរឿងនោះមកទាំងដុលដែរ។ លោកកវីនិពន្ធបានបញ្ចេញបញ្ចូលនូវលក្ខណៈជាតិ ជាអត្តសញ្ញាណជាតិរបស់ខ្លួនទៅក្នុងស្នាដៃនោះ សំដៅចែករំលែកនូវប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើងឱ្យនៅគង់វង្សផងដែរ។

យោងតាមប្រវត្តិអាពាហ៍ពិពាហ៍ខ្មែរ មានសម្មតិកម្មខ្លះថា ការរៀបអាពាហ៍ពិពាហ៍នេះយកតាមការរៀបចំផ្សំផ្គុំមង្គលការ ជាលើនិងក្រឹស្នា ក្នុងរឿងព្រះវេស្សន្តរនេះតែម្តង។ ម្យ៉ាងទៀតបើយោងតាមទម្រង់ការព្រះជ័យចេស្តា ឃើញថាការកាត់ខាន់ស្លានេះ គឺយកតាមការកាត់ថ្លៃក្រឹស្នា ដោយព្រះវេស្សន្តរឱ្យកាត់ ៥ម៉ឺន ២ពាន់ ៨រយតម្លឹងមាសនព្វគុណ[51]។ នេះសឱ្យឃើញថាតួនាទីរបស់រឿងព្រះវេស្សន្តរ មិនត្រឹមតែអប់រំ ផ្តល់ទស្សនៈល្អនោះទេ តែក៏បានផ្សាភ្ជាប់ ផ្សព្វផ្សាយនឹងសង្គមវប្បធម៌ប្រពៃណីខ្មែរក្នុងការរស់នៅផងដែរ។

ជាមួយគ្នានេះផងដែរ រឿងក្រុងសុកមិត្រក៏បានបង្ហាញពិធីអភិសេករបស់ក្រុងសុកមិត្រផងដែរ។ លោកកវីបានបង្ហាញពីក្បួនពិធីអភិសេកយ៉ាងល្អិតល្អន់ មានទាំងគ្រឿងរណ្តាប់ពិធី មានផ្ទៃតបាំងសែង ភូតាន បៃមន់ សែនគ្វន ចាមរជាដើម។ លើសពីនេះក៏បានបង្ហាញពីពិធីកម្មរបស់ព្រាហ្មណ៍ដូចលើកឡើងថា៖

ត្រៃស័ង្ខប្រគំ សូរសព្ទរង៉ំ ទរទួងកេរី
ទើបព្រាហ្មណ៍បុរោហិត ចូលជិតពោធី សែកសូត្រស្តុតី
ចម្រើនជយា។(ទំ.៥៥)

ទន្ទឹមនឹងនេះ មុននឹងចាប់ផ្តើមរៀបមង្គលការក្នុងទំនៀមទម្លាប់ខ្មែរ មេបាលោកតែងទៅរកអាចារ្យចេះដឹងខាងពេលាមកគន់គូរ កំណត់ពេលាចេកមាសចេកប្រាក់កូនប្រុសស្រីថាអាចនឹងប្រព្រឹត្តទៅថ្ងៃណាខែណាឆ្នាំណាបាន។ អក្សរសិល្ប៍រឿងមរណមាតានេះក៏បានពាំនាំទំនៀមទម្លាប់នេះចែកចាយដល់អ្នកអានអ្នកស្តាប់ផងដែរ។ នៅពេលព្រះបាទវិមលធម្មរាជបាននាំនាងមរណមាតាមកនៅក្នុងព្រះបរមរាជវាំង ហើយក៏បានអភិសេកនាងឱ្យឡើងជាអគ្គមហេសី។ មុនព្រះរាជពិធីអភិសេកនេះ ត្រង់ក៏បានឱ្យព្រាហ្មណ៍ ហោរា រៀបគន់គូរកពេលាជ័យក្នុងការអភិសេកដូចលើកឡើងថា៖

ហោរាទាំងបួន គន់គូររាល់ខ្លួន ផ្ងៀងដួងជតា
ទិនកែទិនក្ស័យ ជោគជ័យរាជា សិទ្ធិជោគមហា
សំរឹទ្ធិជ័យ។
ហ្លួងឈៀងហ្លួងឈរ ចៀសទិនកាលមរណ៍ ទំនួលប្រពៃ
បើកបានគ្រប់ពារ ពេលាល្អក្រៃ ទូលមកក្សត្រថ្លៃ
ជ្រាបគ្រប់ប្រការ។ (ទំ. ៨៣)

[51] លី សុវីរៈ, ***ទំរង់ការ ព្រះជ័យចេស្តា***, បណ្ណាគារអង្គរ, ២០០៥, ទំ.៥

ជាការពិតណាស់ បើយើងនិយាយពីដំណើរជីវិតខ្មែរ មានការកើត ការ និងកប់។ ក្នុងពិធីបុណ្យសព ត្រូវបានគេបែងចែកជាបីផ្នែកធំៗគឺ មុនពេលស្លាប់ ក្រោយពេលស្លាប់ និង ក្បួនដង្ហែ និងរំលាយសព។កិច្ចពិធីទាំងនេះត្រូវបានគេធ្វើតាមប្រពៃណីតៗគ្នារៀងមក។ រីឯពិធីក្នុងការរំលាយសពវិញគេឃើញមាន៤យ៉ាងគឺ បោះចោលសពទៅក្នុងទន្លេ បូជាដោយភ្លើង យកសពទៅកប់ និងយកសពទៅដាក់ចោលក្នុងព្រៃស្មសាន ឱ្យសត្វស៊ី។[52] តាមរយៈរឿងកោគកុលកុមារក៏បានបង្ហាញពីលក្ខណៈនៃការរំលាយសពផងដែរ។ នៅពេលកោគវុឌ្ឍីជិតស្លាប់គាត់បានផ្តាំឱ្យ កោគកុលកុមារឱ្យរៀបចំរំលាយសពរបស់គាត់ដោយឱ្យយកសពទៅដាក់ព្រៃស្មសានឱ្យសត្វត្មាត ក្អែក ចឹងធីជាចំណី ដូចលើកឡើងថា៖

ថាបើអាពុកមរណ៍ ចូរអ្នកបបួលគ្នីគ្នា
មកសែងសពបិតា ទៅដាក់ដល់ព្រៃស្មសាន។
ឱ្យអស់សត្វត្មាតក្អែក ចឹកហួរហែកធីសោះឃ្លាន
ដងទឹកដាក់ឱ្យទាន ឱ្យអស់សត្វវាផឹកធី។(ទំ. ១៥)

ជារួមយើងឃើញថា ត្បិតអត្ថន័យនៃអក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតទៅសាសនាយ៉ាងណាក៏ដោយ ក៏អ្នកនិពន្ធមិនភ្លេចបញ្ចូលនូវរសជាតិខ្មែរទៅក្នុងផ្នែរឿង ឱ្យអ្នកអានអ្នកស្តាប់បានស្គាល់ពីវប្បធម៌ខ្មែរដ៏ផូរផង់នេះផងដែរ។

គ- សិល្បៈ

ក្រៅពីផ្តល់ពុទ្ធិចំណេះដឹង បង្ហាញពីជំនឿ ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជន អក្សរសិល្ប៍ពុទ្ធនិយមក៏បានលើកតម្កើងនូវសិល្បៈវប្បធម៌ជាតិ ដូចជារបាំ ល្ខោន គ្រឿងតូរ្យតន្ត្រី គុនដាវលំពែង ល្បែងប្រជាប្រិយជាដើម។

រឿងក្រុងសុកមិត្រក៏បានបង្ហាញពីទម្រង់របាំ ល្ខោន មហោស្រព ព្រមទាំងល្បែង កីឡាគុនដាវផងដែរ ដូចលើកឡើងថា៖

របាំមនោហ៍រា	រាំរេកគ្នា	ហាក់ហោះអាកាស
របាំល្ខោន	ទន្លោសពិលាស	ហត្ថាវង់វាស
	ដើរដិតតាមគ្នា។...	
មានល្បែងប្រជាល់	ចេះគន់កាត់ការ	ស្ទាក់ស្ទុះកែកាយ
លោលោតទៅមក៍	អួតអរវិលវាយ	ស្រែកស្រួលសប្បាយ
	លោលោតទៅទី។(ទំ. ៥៦)	

មិនខុសពីរឿងក្រុងសុកមិត្រ រឿងកោគកុលកុមារក៏បានបង្ហាញពីលក្ខណៈសិល្បៈខ្មែរផងដែរ។ តួយ៉ាងនៅពេលមង្គការព្រះនាងសុខុមាលទេវី និងកោគកុលកុមារ មានរបាំ ល្ខោន តន្ត្រី កីឡា និងមានឈ្មោះម្ហូបអាហារយ៉ាងសម្បូរបែប ដូចលើកឡើងថា៖

-ម្ហូបអាហារ៖	ខ្លះបេះសាច់ទា	សាច់មាន់ស្លដា	ទឹកនំបញ្ចុក
	ខ្លះខ្លប្រហើរ	ខ្លះធ្វើហក្នុក	ធ្វើខ្សងសម្រុក

[52] ត្រឹង ងារ,*អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់*,បោះពុម្ពលើកទី៣,១៩៧៥,ទំ.១០៦

បណ្តោញភ្ញៀវផង។(ទំ.១១៨)

-តន្ត្រីត្រែ៖	ផ្លុំត្រែស័ង្ខសម	ស័ព្ទសូរវង់	ទទួងកេរី
	គោះគងប្រគំ	សូរសេមតន្ត្រី	សាជៀវខ្លុយប៊ី
		ស្រទ្បៃពាទ្យគង។	
	ភ្លេងកនទ្រោនទ្រ	ចាប៉ីៗអ	គែនកន្ទោងគង
	សម្ភោរនាគ	ពិណពាទ្យឈឹងផង	ស្គរដោស្គរទង
		ស្គរទូងស្គរទ័ព។(ទំ.១២៥)	
-ល្ខោនរបាំ៖	រាំស្នែងទន្សោង	សួព្រ័ត្រយោលទោង	ជ្វាគូជ្វារាយ
	ល្ខោនរបាំ	រេរាំកែកាយ	ច្រៀងច្រួចនិយាយ
		ពីរោះសូរសេម។(ទំ.១២៨)	
-កីឡា៖	ទាំងបួនព្រះអង្គ	ស្តេចយាត្រាត្រង់	ទតល្បែងមហោស្រព
	លោតគុនពេនត្បាល់	ប្រដាល់ប្រតប់	ត្រីវិស័យសព្វ
		កញ្ឆេងជើតស្បែក។(ទំ.១២៧)	

ជារួមការលើកយកមកឧទាហរណ៍នេះគ្រាន់តែជាចំណែកមួយនៃអក្សរសិល្ប៍ពុទ្ធនិយមប្រភេទសាស្ត្រាល្បែងប៉ុណ្ណោះ នៅមានរឿងដទៃទៀតដែលបានបង្ហាញពីវិស័យសិល្បៈជាតិក្នុងន័យផ្សព្វផ្សាយដល់អ្នកអានអ្នកស្តាប់ឱ្យស្គាល់នូវ របាំ ល្ខោន តន្ត្រី កីឡាជារបស់ខ្មែរទាំងអស់នោះ។

៤.៧- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាមកលើសង្គមខ្មែរនាពេលបច្ចុប្បន្ន

ក- ធម្មទេសនា

គម្ពីរទសជាតក ជាគម្ពីរមួយដែលរៀបរាប់រឿងទាំងដប់ជាតិរបស់ព្រះពុទ្ធអង្គមុនត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ។ រឿងទាំងនេះ គោលដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតក មហានិបាត ដែលគេប្រកាន់ជឿថា ជាព្រះពុទ្ធវចនៈ ហើយនិងគម្ពីរជាតកដ្ឋកថា ដែលមានមកជាងពីរពាន់ឆ្នាំហើយ។[53]គម្ពីរទសជាតកនេះ និយមគាំទ្រណាស់ពីសំណាក់ប្រជាពលរដ្ឋ និងតាមវត្តអារាម។ ពីបុរាណគេក៏បានធ្វើរយៈពេល ៧ថ្ងៃ៧យប់ដើម្បីស្តាប់គម្ពីរទសជាតកនេះ គឺ ថ្ងៃទី១ គេស្តាប់ធម្មគោរព ថ្ងៃទី២ទី៣ទី៤ គេស្តាប់ជាតកទាំង៩តៗគ្នា ហើយថ្ងៃទី៥គេស្តាប់មហាជាតកគឺ វេស្សន្តរជាតក ថ្ងៃទី៦ស្តាប់បឋមត្រាស់ (ពុទ្ធប្បវត្តិ) ហើយយប់នោះត្រូវធ្វើពិធីពុទ្ធាភិសេក ស្អែកឡើងថ្ងៃទី៧ សង្គាយនាបុណ្យ។ ចំណេរក្រោយមក គេក៏កាត់ឱ្យការទេសនាខ្លីសល់ត្រឹម ២ម៉ោងនេះបើតាមលោកគ្រូព្រះបុរត្ថិមវាសី អ៊ូ ចេវ វត្តលង្កា។

ជាក់ស្តែងនាពេលបច្ចុប្បន្ន ពិធីបុណ្យទេសនាមហាជាតក៏នៅតែបន្តធ្វើតាមទីវត្តអារាមមួយចំនួនផងដែរ។ តាមបណ្តាវត្តអារាមក្នុងខេត្តសៀមរាប គេតែងជ្រើសរើសពេលសម្រាប់ធ្វើពិធីទេសន៍មហាជាតិនេះក្នុងពេលណាមួយពីខែ

[53] ឈឹម ស៊ុម,***សង្ខេបទសជាតក***, បណ្ណាគារ សុមនសុវត្តិ៍ លេខ៤២, ភ្នំពេញ, ១៩៦២

មិគសិរដល់ខែមាឃអាស្រ័យតាមការរើសរកថ្ងៃកុំឲ្យជាន់គ្នារវាងវត្តមួយនិងវត្តមួយ។ តែបើយកឧទាហរណ៍នៅទីផ្សេងវិញ ដូចជានៅតំបន់ភ្នំវល្លិ៍ក្នុងខេត្តកំពតជាដើម គេច្រើនធ្វើនៅពេលដែលរដូវភ្លៀងជិតចូលមកដល់។ តាមធម្មតាពុទ្ធបរិស័ទក្នុងភូមិចំណុះជើងវត្តចែកគ្នាកាន់វេនតាមកណ្ឌនីមួយៗដែលតំណាងរបស់ខ្លួនចាប់ឆ្នោតបាន (ឆ្នោតនេះហៅថា «ស្លាក» ឬតាមបាលីថា «សលាកបត្ត»)[54]។

ខ. សិល្បៈ

-ល្ខោន

រឿងនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមក៏បានក្លាយទៅជាល្ខោនយ៉ាងរស់រវើកសម្រាប់ប្រជាជនទស្សនាផងដែរ។ តួយ៉ាងនៅល្ងាចថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមទស្សនាល្ខោនបុរាណ រឿងមហាវេស្សន្តរជាតក ក្នុងឱកាសរំលឹកខួប៤៨ឆ្នាំ នៃការចូលទីវង្គតរបស់ព្រះសង្ឃរាជ ជួនណាត។ ល្ខោនបុរាណ រឿងមហាវេស្សន្តរជាតកនេះ ចូលរួមរួមសម្តែងដោយ លោកគ្រូ អ្នកគ្រូ អតីតសិល្បករជំនាន់មុននិងបច្ចុប្បន្ន ប្រាំជំនាន់ចំនួន១០៩នាក់ រួមគ្នាធ្វើឱ្យរស់ឡើងវិញនូវទស្សនីយភាពរឿង មហាវេស្សន្តរជាតក ដើម្បីរំឭកពីល្ខោនបុរាណខ្មែរ ជាពិសេសរក្សាអោយបានគង់វង្ស។

លើសពីនេះវិទ្យុជាតិនិងទូរទស្សន៍ជាតិក៏បានចូលរួមចំណែកក្នុងការតម្លើងជាល្ខោននិយាយ ល្ខោនយីកេ ល្ខោនបាសាក់ជាដើមដែលបានយកចេញពីអក្សរសិល្ប៍ពុទ្ធនិយមផងដែរ។ ការសម្តែងមានដូចជាការតម្លើងល្ខោនយីកេរឿងកាកី រឿងមរណមាតា... ល្ខោនបាសាក់រឿងទេវន្ទ រឿងព្រះជិនវង្ស រឿងលក្សិណវង្ស រឿងវរវង្ស សូរវង្ស រឿងហង្សយន្ត ... ល្ខោននិយាយមានរឿងសព្វសិទ្ធ រឿងសុបិនកុមារ រឿងកាកី... រីឯល្ខោនព្រះរាជទ្រព្យ ឬរបាំបុរាណ មានរឿងមរណមាតា រឿងសព្វសិទ្ធិ រឿងសុវណ្ណហង្ស រឿងព្រះសុធនកែវមនោរា ព្រះចន្ទគោរព...ជាដើម។

-គំនូរ ចម្លាក់

បើនិយាយពីវិស័យគំនូរវិញ អក្សរសិល្ប៍ពុទ្ធនិយមបានវាតទីលើវិស័យនេះជាខ្លាំង។ តាមរយៈគំនូរលើជញ្ជាំងព្រះវិហារ រៀបរាប់ពីរឿងទសជាតក រឿងក្នុងបញ្ញាសជាតក និងមានរឿងក្នុងនានាជាតកផងដែរ។ តួយ៉ាងយើងឃើញមានគំនូររឿងកាកីនៅលើបង្ហួចនៃសារមន្ទីជាតិ។ សារមន្ទីរជាតិត្រូវបានកសាងឡើងនៅក្នុងឆ្នាំ ១៩១៧ នាសម័យអាណានិគមបារាំងមកលើព្រះរាជាណាចក្រកម្ពុជា (១៨៦៣-១៩៥៣) ដែលមានស្ថាបត្យករ ជនជាតិបារាំងឈ្មោះ ហ្គ្រកហ្រ៊ូសលីយេ (George Groslier)... វាជាស្នាដៃរបស់វិចិត្រករខ្មែរដែលជា គ្រូ និងជា សិស្សរបស់សាលានេះដែលមានដូចជារឿងនាងកាកី ឬ រៀមកេរ្តិ៍ជាដើម(កាលពីសម័យ នោះអាគារនោះជាសារមន្ទីរផងនិង ជាសាលាបណ្តុះបណ្តាលផង)[55]។

[54] https://www.yosothor.org/publications/khmer-renaissance/chapter-two/pithy-puth-tes-moha-jea-duk.html

[55] http://www.mcfa.gov.kh/site/detail/29#.Yhyv-uhBy3A

បើនិយាយពីចម្លាក់វិញ យើងក៏អាចឃើញស្ថាបត្យករខ្មែរបានឆ្លាក់រឿងព្រះជិនវង្សលើលើបាំងសាចនាំវត្តព្រះប្រសព្ធ។ ចម្លាក់ព្រះជិនវង្សនេះសាងចប់នៅព.ស.២៤៦៩ ពោលគឺនៅគ.ស. ១៩២៦ [56]។ រីរឿងព្រះជិនវង្សនេះក៏បានរំលេចជាគំនូរផេងដៃរនៅវត្តកៀនស្វាយក្រៅ។ ក្នុងនោះ សាលាឆាន់វត្តកៀនស្វាយក្រៅមានគូរជារឿងព្រះជិនវង្សនៅលើបន្ទះក្តារ ដែលជាហប់របស់សាលា ។ នៅក្នុងឆ្នាំ១៩៨២មានការសិក្សាលម្អិតពីគំនូរនេះ ដោយលោក Michel Jacq-Hergoualc'h ផ្សព្វផ្សាយដោយសាលបារាំងចុងបូព៌ា នៅក្រុងប៉ារីស[57]។

-តាពយន្ត

រីឯវិស័យភាពយន្តវិញយើងឃើញមានអក្សរសិល្ប៍ពុទ្ធនិយមក្លាយមួយចំនួន ត្រូវបានអ្នកដឹកនាំយកទៅថតតាំងពីទសវត្សទី៦០ រហូតដល់បច្ចុប្បន្នមួយចំនួនមានដូចជា៖

- រឿងកោគកុលកុមារ(ដឹកនាំរឿងដោយលោកឈា នុ ផលិតកម្មពេជ្រតាយន្តក្នុងទសវត្ស៦០)
- រឿងខ្សែងសង្ខ(ត្រូវបានផលិតនៅឆ្នាំ ១៩៦៦ដឹកនាំរឿងដោយលោក ឡុង ស៊ីដេត)
- រឿងសុវណ្ណហង្ស(ត្រូវបានផលិតនៅឆ្នាំ១៩៦៧ ដោយផលិតករ លោក អ៊ីវង់ ហែម)
- រឿងកាកី(ត្រូវបានផលិតនៅឆ្នាំ ១៩៦៧ ដោយផលិតករ ប៊ីវ ឆែលាង)
- រឿងពុទ្ធិសែន នាងកង្រី(ត្រូវបានផលិតនៅឆ្នាំ ១៩៦៨ ដោយផលិករលោកលី ប៊ុនយីម)
- រឿងមរណមាតា(ត្រូវបានផលិតនៅឆ្នាំ ២០០៤ ដឹកនាំរឿងដោយ លោកហ្វៃ សំអាង)
- រឿងចៅស្រទបចេក (ដោយចាងហ្វាងលោក ប្រសើរ ខៀវ ទើបថតនាស.វ.ទី២១)
- រឿងលក្សិណវង្ស(ស្រាវជ្រាវដោយលោកយ៉ុន ប៊ុនឈឿនទើបថតនាស.វ.ទី២១)
- រឿងទិព្វសង្វារ(ថតនៅឆ្នាំ២០០៥ ដឹកនាំរឿងដោយ លោកយ៉ុន ប៊ុនឈឿន)
- រឿងកោគកុលកុមារ(ថតនៅឆ្នាំ២០០៦ ដឹកនាំរឿងដោយ លោក ជា វណ្ណា)
- រឿងសព្វសិទ្ធ(ថតនៅឆ្នាំ២០២០ ជាខ្សែភាពយន្តភាគរបស់ទូរទស្សន៍P NN)
- រឿងមរណមាតា (ថតឆ្នាំ២០២២ ជាខ្សែភាពយន្តភាគរបស់ទូរទស្សន៍CTN PNN)ជាដើម។

-ចម្រៀង

រីឯបទចម្រៀងមួយចំនួនក៏បានផលិតចេញពីលំនាំនៃរឿងល្បែងផេងដៃដូចជានៅក្នុងរឿងព្រះលក្សិណវង្ស មានបទស្នេហាព្រះព្រះលក្សិណវង្ស មន្តស្នេហ៍រនាត ទំនួញនាងព្រហ្មកេសរ ច្រៀងដោយ អ្នកស្រីហឹមស៊ីវន អ្នកនាងទូចស្រីនិច្ច លោកហេងប៊ុនលាក។ ចម្រៀងក្នុងរឿងកោគកុលកុមារ បទនាងចម្ប៉ាវង្សី និពន្ធបទភ្លេងនិងទំនុកច្រៀង ស៊ិនស៊ីសាមុត និងច្រៀងដោយរស់សេរីសុទ្ធា បទទំនួញកោគកុលកុមារ និពន្ធបទភ្លេងនិងទំនុកច្រៀងស៊ីនស៊ីសាមុត ច្រៀងដោយស៊ិនស៊ីសាមុត។ រឿងព្រះសុធននាងកែវមនោរាហ៍ ជាកម្រងបទចម្រៀងមានដូចជា បទក្រសាលស្រះស្រង់ដោយ ស៊ីវន សាវី ស្រីនីន ...។ រីឯរឿងព្រះជិនវង្សដែលផលិតកម្មអង្គរបានធ្វើទៅជាបទចម្រៀង ដោយដឹកនាំដោយអ្នក

---

[56] អាំងជូលាន,ព្រាប ចាន់ម៉ាក់, ស៊ីយ៉ុន សុភាទិទ្ធ,គង់ វីរៈ, ហេងសុផាឌី, ជីវដ្ឋោ, សួង សុខរ៉ូ ***កម្រងអត្ថបទក្នុងបណ្ណាញព័ត៌មានវប្បធម៌ខ្មែរ***, លេខ១៥, ២០២០, ទំ.៥៧

[57] -ដ-,ទំ.៥៤

ស្រី អីវែត ស ប្រមាណ៤ម៉ោងជាង ពោលគឺមួយចប់រឿងព្រះជិនវង្សតែម្តងមានបទចម្រៀងដូចជា បទផ្សំផ្គុំបុត្រយើង នាងទាសីលង់ជាដើម។ ជាមួយគ្នានេះរឿងសង្ខសិល្បជ័យ ក៏ត្រូវបានផលិតកម្មហង្សមាស បានធ្វើជាវីដេអូចម្រៀង មានរយៈពេលមួយម៉ោងជាង មួយចប់សាច់រឿងតែម្តង។ តួយ៉ាងដូចជាបទទំនួញសេនាកុត្តរាជ អាសូរៀមផង ទំនួញ នាងបទុមា បណ្តាំនាងកែវសុមន្ធា សង្គ្រាមបាស្តាជាដើម។

គ. នរនាម

មកដល់ពេលបច្ចុប្បន្ន ឈ្មោះរបស់តួអង្គក្នុងអក្សរសិល្ប៍ពុទ្ធនិយមមួយចំនួនត្រូវបានគេយកទៅដាក់ឈ្មោះឱ្យ បុត្រធីតា ដូចជា មទ្រី ជាលី ក្រឹស្នា មុជ្ជលិន កេសរមន្ទា សកុណា កេសនី...ជាដើម។ ការដែលដាក់ឈ្មោះនេះ មកពី យល់ពីអត្ថន័យនៃឈ្មោះ រួមជាមួយសកម្មភាពរបស់តួអង្គដែលនាំកើតមានសិរីសួស្តីក្នុងគ្រួសារផងដែរ។

សន្និដ្ឋាន

ជារួមមក តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរពិតជាបានចូលរួមយ៉ាងសកម្មជួយដល់ប្រជាជនខ្មែរក្នុងកំឡុងពេលកម្ពុជាធ្លាក់ក្នុងភ្នក់ភ្លើងនៃសង្គ្រាមដ៏វែងអន្លាយ។ ការឈានចូលមកដល់របស់អក្សរសិល្ប៍ពុទ្ធនិយមនេះបានបន្ធូរអារម្មណ៍ ធ្វើឱ្យមនុស្សរសាយនូវកង្វល់ទាំងឡាយដែលញាំញីដោយវិបត្តិសង្គម។ ពិតណាស់ថាអក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះនូវទស្សនៈគំនិតលើឱ្យជឿលើពុទ្ធសាសនាក្តី តែរឿងពុទ្ធនិយមបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការអប់រំចរិយាសាស្ត្រ សីលធម៌ គុណធម៌របស់មនុស្សនាសម័យ។ ត្រង់នេះពុទ្ធសាសនាហាក់បីដូចជាវាំងននមួយតែបើយើងបើកវាំងនននោះចេញយើងនឹងឃើញតម្លៃទស្សនវិជ្ជាដ៏ច្រើនសម្បូរបែបសម្រាប់អប់រំមនុស្សដូចជាបញ្ហាការឆ្ពោះទៅរកសន្តិភាពជាដើម។ លើសពីនេះអក្សរសិល្ប៍ពុទ្ធនិយមក៏បានបង្កប់និងបង្ហាញពីលក្ខណៈជាតិដ៏ច្រើនសម្បូរបែប មានដូចជាជំនឿ ទំនៀមទម្លាប់ ប្រពៃណីរបស់ក្សត្រ របស់អ្នកស្រុកជាដើម។ មួយវិញទៀតអក្សរសិល្ប៍ពុទ្ធនិយមនេះក៏ជាពុម្ពគំរូមួយដ៏សំខាន់នៃការតាក់តែងនិពន្ធសម្រាប់កវីនិពន្ធជំនាន់ក្រោយយកជាគំរូផងដែរ។

យើងឃើញហើយថា តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរនេះពិតជាមានតម្លៃខ្លាំងក្លាទាំងផ្នែកស្មារតី និងពុទ្ធិ។ ភាពចម្រុះពណ៌នេះហើយទើបធ្វើឱ្យផលិតករបានកែច្នៃរឿងទាំងនោះទៅជាសិល្បៈ ល្ខោន គំនូរ ភាពយន្ត ចម្រៀងជាដើម ដើម្បីបន្តយកទស្សនៈអប់រំនិងពិពិធភាពនៃស្នាដៃនោះមកបង្ហាញដល់កូនខ្មែរជំនាន់ក្រោយ។ ម្យ៉ាងទៀតវិស័យសោតទស្សន៍ គួរព្យាយាមបញ្ចូលនូវស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនានា ដែលបានសម្តែងជាភាពយន្តក្តីជាល្ខោនក្តីនៅក្នុងកម្មវិធីរបស់ខ្លួន។ ត្រង់នេះ វាអាចចូលរួមជួយផលិតករ ក៏ដូចជាសិល្បករក្នុងបំពេញនូវការងារផ្នែកវប្បធម៌ជាតិ។ ម្យ៉ាងនេះវាក៏បានលើគុណតម្លៃនៃអក្សរសិល្ប៍ពុទ្ធនិយមឱ្យយុវជនយល់ដឹងនឹងត្រងត្រាប់យកជាបទពិសោធទៀតផង។ មួយវិញទៀត ផលិតករភាពយន្តអាចទាញយករឿងចេញពីគម្ពីរផ្សេងៗក្នុងការថតជាខ្សែភាពយន្តព្រោះគ្រប់សេជាតិនៃជីវិតបានឆ្លុះបញ្ចាំងតាមរយៈខ្សែរឿងដ៏ល្អរបស់កវីជំនាន់មុន។ មិនត្រឹមតែប៉ុណ្ណោះ វាបានលើកតម្លៃអក្សរសាស្ត្រជាតិ ជាជាងទៅចម្លងរឿងពីបរទេសមកនាំឱ្យគេមាក់ងាយនិងតិះដៀលគំនិតរបស់ជនជាតិយើងទៀតផង។

គន្ថនិទ្ទេស

- កុល ផេង, ***ព្រះសុវណ្ណសាមជាតក***, ពិស្តារ,ភ្នំពេញ, ២៥៦០
- កែង វ៉ាន់សាក់, ***ទិដ្ឋភាពខ្លះៗនៃអក្សរសិល្ប៍ខ្មែរ***, ប្រែសម្រួលដោយ សេន សេង, បោះពុម្ពលើកទី១, ភ្នំពេញ, ២០១៦
- គូ សុភាព, ***សីលធម៌ព្រះពុទ្ធសាសនា***, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ២០០៨
- ឃិន យ៉ង់, ***អក្សរសិល្ប៍តន្តី,*** ស.ក.ក.ព. ២០១៥
- ឃីង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣
- ឃីង ហុកឌី, ***មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣
- ឃីង ហុកឌី, ***កោគកុលកុមារ*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៥
- ជីវតាក្វាន់, ***ទឹកដីនិងប្រពៃណីអ្នកស្រុកចេនឡា,*** រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣
- ឈឹម ស៊ុម,***សង្ខេបទសជាតក៍***, បណ្ណាគារ សុមនសុវត្ថិ លេខ៤២, ភ្នំពេញ, ១៩៦២
- ឈុន គឹមអៀក, ***ទ្រឹស្តីកម្មផល*** ,បោះពុម្ពលើកទី២, ២០០១
- ញាន កឿន សុិន សុវណ្ណនិ, ***លំអានទំនៀមខ្មែរបុរាណ*** ភាគ៤, ភ្នំពេញ, ២០១៦
- ញ៉ុក ថៃម, ***មហាវេស្សន្តរជាតក***, បណ្ណាគារត្រែតន៍, ២០២២
- ត្រឹង ងារ,***អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់***,បោះពុម្ពលើកទី៣,១៩៧៥
- ***ទេវិន្ទ*** ,ចងក្រងដោយនិស្សិតមួយក្រុម, ២០១៦
- ទឹម សឿន, ***សីល៥ជាធម៌របស់មនុស្ស***, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ២០០២
- ធ សោ, ***សិក្សារឿងព្រះវេស្សន្តរជាតក***, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ១៩៩៤
- ធ សោ, ***ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ*** ,ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ ១៩៩៤
- ប៊ុត សាវង្ស, ***ស្ត្រីក្នុងព្រះពុទ្ធសាសនា***, ២៥៥១
- ប្រសិទ្ធ វីជីវី, ***ល្ខោនក្បាច់បុរាណ រឿងព្រះជិនវង្ស***, សារណាបញ្ចប់បរិញ្ញាបត្រជឹកនាំរឿង, ស.ក.វ.ស,២០០៩
- ប៉ាង ខាត់, ***ប្រវត្តិពុទ្ធសាសនានៅប្រទេសកម្ពុជា*** ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦១
- ពុទ្ធសាសនបណ្ឌិត្យ, ***វចនានុក្រមខ្មែរ ភាគ១ភាគ២*** ,ភ្នំពេញ, ១៩៦៨
- ពុទ្ធសាសនបណ្ឌិត្យ,***សុបិនកុមារ***, ភ្នំពេញ, ព.ស. ២៥០២
- ពុទ្ធសាសនបណ្ឌិត្យ,***ទិព្វសង្ខារ*** ,ភ្នំពេញ, ១៩៦៣
- ពុទ្ធសាសនបណ្ឌិត្យ,***សង្ខសិល្បជ័យ*** ,ភ្នំពេញ, ១៩៦៦
- ពុទ្ធសាសនបណ្ឌិត្យ ***ហង្សយន្ត*** ភ្នំពេញ ១៩៨៤
- ពុទ្ធសាសនបណ្ឌិត្យ,***ពុទ្ធិសែននាងកង្រី*** ,ភ្នំពេញ, ១៩៧២

- ពុទ្ធសាសនបណ្ឌិត្យ,*ច្បាប់ផ្សេងៗ*,ភ្នំពេញ, ១៩៧៥
- ពន់ ធាយ, *អក្សរសិល្ប៍ប្រៀបធៀប ខ្មែរ - ឥណ្ឌា*,ភ្នំពេញ ២០១៣
- ពៅ សាមី,*មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ភាគ១-២-៣*,គ្រឹស្ថានបោះពុម្ព សុកមង្គល, ភ្នំពេញ ,២០១២
- ព្រះធម្មបញ្ញា អ៊ុក, *មរណមាតា*,ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥០៧
- ព្រះមហា ជា សុខ, *ពុទ្ធសាសនា ធ្វើប្រយោជន៍ដល់សង្គមមនុស្សអ្វីដែរ?* ,ពុទ្ធសាសនបណ្ឌិត្យ ១៩៦៦
- ព្រះអរិយគាមុនីហ៊ីង, *ព្រះជិនវង្ស*,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤
- ម៉ុញ សារី, *វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ*, មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាពកម្ពុជា, ២០១១
- ម៉ែម ទីន មន, *កម្ម អ្នកសាងលោកពិត*,រោងពុម្ពម៉ែងហាវ, ភ្នំពេញ, ២០១៥
- យ៉ាន់ សុកី, *រឿងក្បាច់បុរាណ ព្រះនាងចំប៉ាថោង*, សារណាបញ្ចប់បរិញ្ញាបត្រជឹកនាំរឿង, ស.ក.វ.ល,២០០៥
- យស ងិន, *ស្រទបចេក*,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៧
- លាង ហាប់អាន, *ប្រវត្តិអក្សរសាស្ត្រខ្មែរ*, បណ្ណាគារ គិម អេងលេខ, ភ្នំពេញ, ១៩៦៧
- លាង ហាប់អាន, *សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ* ភាគ១, ១៩៦៦
- លឹម ហាក់, *សិក្សាអំពីប្រវត្តិ និងបច្ចេកទេសគម្ពីរខ្មែរ*,សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា,១៩៩៥
- លី សុវីរៈ, *អរិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍បែប ពុទ្ធនិយម បែបព្រហ្មនិយម បែបខ្មែរនិយម*, ភ្នំពេញ, បោះពុម្ព លើកទី២, ២០០២
- លី សុវីរៈ, *ទំរង់ការ ព្រះជ័យវេស្ស*, បណ្ណាគារអង្គរ, ២០០៥, ទំ.៥
- លី ធាមតេង, *អក្សរសាស្ត្រខ្មែរ*,១៩៦០
- លាស់ ឡាយ, *ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន*, ២៥០៨
- វង់សុធារ៉ា ណុបសុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ២០១៣
- សុខ ខឿន, *រឿងក្បាច់បុរាណ រឿងសង្ខ័សិល្បជ័យ*, សារណាបញ្ចប់បរិញ្ញាបត្រជឹកនាំរឿង, ស.ក.វ.ស,២០០៤
- សុំ ឈុំប៊ុន, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍,* ២០០៣
- សោម សុមុនី, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍*, ២០០៣
- សម ញាណ, *ប្រវត្តិពុទ្ធសាសនា ដែលផ្សាយចូលមកប្រទេសកម្ពុជា*,១៩៥៧
- សេង សុវណ្ណដារ៉ា, *អម្រឹតក្សត្រី ម៉ុក កវីនិពន្ធខ្មែរនាសតវត្សទី១៩*,និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រ ខ្មែរ ស.ក.ភ.ព. ២០១៩
- សេង សោភា, *សាស្ត្រាល្បែង*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ មុខជំនាញអក្សរសិល្ប៍ រាជបណ្ឌិត្យសភា, ២០០៤
- ស្រី. ធម្មានន្ទ, *អ្វីខ្លះពុទ្ធសាសនិកជឿ*,ពុទ្ធសាសនាបណ្ឌិត្យ, ២០១៩
- សម្ដេចព្រះសង្ឃរាជ, *ក្បួនកាត់សប្ដិ*, បោះពុម្ពសាជាថ្មីដោយ ស្រី ប៊ុនដន, ២០០៤

- ***ហង្សយន្ត,*** ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៥២
- ហ៊ឺនកក្តីអក្សរតន់ ***សព្វសិទ្ធិ*** ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៧
- ហួត តាត, ***ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប***, ពុទ្ធសាសនបណ្ឌិត្យ, ២៩៧០
- ហ៊ុន ធារិទ្ធ, ***អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ***, និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ ,២០១៨
- ហង់ជួន ណារ៉ុន, ***វិភាគទានការសិក្សាអក្សរសិល្ប៍ខ្មែរ ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា***, គ្រឹះស្ថានបោះពុម្ពស៊ីប៉ា, ២០១៩
- ឡុង សៀម, ***សាកល្បងសិក្សារឿងមហាវេស្សន្តរ***, ការផ្សាយរបស់អ្នកនិពន្ធ
- អាំងដូលាន,ព្រាប ចាន់ម៉ារ៉ា, ស៊ីយ៉ុន សុការិទ្ធ,គង់ រិះ, ***កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ***,លេខ១-១៦
- អៀន ហ៊ែរីស, ***ប្រវត្តិនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១***, នគរវត្ត, ២០១០
- អ៊ុម ស៊ុម, ***គម្ពីរស្លឹករឹត***, ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ៤៨, ១៩៩៤
- អុក ចួន, ***ចំនោទនិងសំរាយបញ្ហា ក្នុងអក្សរសិល្ប៍ខ្មែរ***,សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១៩៨៨
- អ៊ុំ មារឌី, ***អត្ថបទវិជ្ជា រឿងក្រុងសុភមិត្រ*** ,ភ្នំពេញ, ១៩៦៣
- ឧកញ៉ាកោសាធិបតី កៅ, ***ក្រុងសុភមិត្រ*** ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦០
- ឧកញ៉ា ព្រះឃ្លាំងនង, ***កោគកុលកុមារ*** ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៦
- ឧកញ៉ាសុភាធិបតី អ៊ុក, ***ខ្សែសង្ខ*** ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦០
- https://www.yosothor.org/
- http://5000-years.org/
- https://khmerarchaeo.wordpress.com/
- https://www.efeo.fr/base.php?s=10
- https://www.academia.edu/
- https://www.pdfdrive.com/
- https://ams.com.kh/khmercivilization/
- http://www.mcfa.gov.kh/

ស្នាដៃសិក្សាកថា

ជ័យលាភីចំណាត់ថ្នាក់លេខ២

ដោយលោក ទឹម សុខហួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ
ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកត្រាំកក់
វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អង្គតាសោម

ចូលរួមអបអរទិវាអំណាន លើកទី៧

លើប្រធានបទ៖

«ភ្ជាធីអក្សរសិល្ប៍ពុទ្ធនិយម ដៅសម័យក្រោយអង្គរ»

ព.ស. ២៥៦៥

គ.ស. ២០២២

-ឈ្មោះ	៖ **ទឹម សុខហួយ**
-ភេទ	៖ ប្រុស
-ថ្ងៃខែឆ្នាំកំណើត	៖ ០៩ មីនា ១៩៨៩
-មុខរបរ	៖ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ
-អង្គភាពបម្រើការងារ	៖ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អង្គតាសោម (ខេត្តតាកែវ)
-លេខទូរស័ព្ទ	៖ 086 96 77 27 / 088 855 53 53

មាតិកា

១. សេចក្តីផ្តើម.....១
២. បញ្ញត្តិនៃអក្សរសិល្ប៍ពុទ្ធនិយម.....៣
៣. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ.....៥
    ២.១. អក្សរសិល្ប៍ខ្មែរសម័យលង្វែក.....៨
    ២.២. អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ.....៩
៤. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម.....១១
៥. លក្ខណៈពិសេសនៃអក្សរសិល្ប៍ពុទ្ធនិយម.....១៣
៦. ឥទ្ធិពលពុទ្ធសាសនាក្នុងសង្គម.....១៦
៧. តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ.....១៧
    ៧.១. តួនាទីអប់រំដើម្បីស្វែងរកសច្ចភាពនៃជីវិត.....១៧
    ៧.២. តួនាទីកម្សាន្តបន្ធូរអារម្មណ៍ផ្សារភ្ជាប់ការអប់រំ.....២០
    ៧.៣. តួនាទីអប់រំស្វែងរកសច្ចភាពនៃជីវិតតាមរយៈស្នាដៃអក្សរសិល្ប៍ទសជាតក.....២០
    ៧.៤. តួនាទីកម្សាន្តតាមរយៈស្នាដៃអក្សរសិល្ប៍មរណមាតា.....៤៨
៨. សន្និដ្ឋាន.....៤៩

១. សេចក្តីផ្តើម

ពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សទី៦ មុនគ្រិស្តសករាជ ប្រហែលគ្នានឹងកំណើតព្រាហ្មណ៍និយមដែរ។ នៅសតវត្សទី ៣មុនគ្រិស្តសករាជ ក្នុងរជ្ជកាល**ព្រះបាទអសោក**ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញទាំងក្នុងប្រទេសឥណ្ឌាទាំងក្រៅប្រទេស។ តាមប្រវត្តិសាស្ត្រកន្លងមក គេបានដឹងថានៅពុទ្ធសតវត្សទី៣(ព.ស.២៣៤)គឺមុនគ.ស.៣០០ឆ្នាំម្ល៉េះ ព្រះបាទអសោកពុទ្ធសាសនិកដ៏ឆ្នើមក្នុងប្រទេសឥណ្ឌាបានបញ្ជូនសមណទូត ពីរអង្គគឺ**ព្រះសោណត្ថេរ** និង**ព្រះឧត្តរត្ថេរ**ឱ្យនាំយកពុទ្ធសាសនាថេរវាទមកផ្សាយនៅសុវណ្ណភូមិ(អាស៊ីអាគ្នេយ៍)។

តាមសិលាចារឹកវ៉ូកាញ់(នៅវៀតណាមខាងត្បូង)ទំនងជាពុទ្ធសាសនាចូលមកប្រតិស្ថានក្នុងប្រទេសខ្មែរនៅសតវត្សទី២ នៃគ្រិស្តសករាជក្នុងរជ្ជកាល**ព្រះបាទស្រីមារៈ ឬហ្វាន់ចេវម៉ន**។ ស្ថាបនិកនៃពុទ្ធសាសនា គឺព្រះពុទ្ធគោតម(៥៦៤-៤៨៣មុនគ. ស.)។ ព្រះអង្គបានចូលបរិនិព្វាននៅប្រទេសឥណ្ឌាភាគឦសាន ពេលដែលទស្សនៈឥណ្ឌាបុរាណកំពុងចោទជាបញ្ហាអំពីសុពលភាពនៃសម្មតិកម្មខ្លះៗជាគ្រឹះផ្ទាល់របស់ខ្លួន។ ប៉ុន្តែព្រះធម៌ជាពាក្យប្រៀនប្រដៅទាំងឡាយ និងឥទ្ធិពលរបស់ព្រះអង្គបានផ្សព្វផ្សាយទៅ ទូទាំងទ្វីបអាស៊ីភាគកណ្តាល ខាងត្បូង និងខាងជើងដែលនៅទីនោះៗបានបន្តផ្តល់ឱ្យមានចំណងវប្បធម៌រួមគ្នាមួយ ហើយព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គក៏ត្រូវបានគេស្គាល់នាពេលសព្វថ្ងៃនេះ នៅក្នុងអឌ្ឍគោលខាងលិចផងដែរ ។ នៅពេលខាងក្រោយមក ពុទ្ធសាសនាត្រូវបែកចេញជានិកាយផ្សេងៗ។ និកាយទាំងឡាយនោះ នៅតែបានរក្សាប្រពៃណីនៃជីវភាពរបស់ព្រះអង្គ។ ប្រពៃណីទាំងនោះភាគច្រើនឃើញមាននៅក្នុងភាសាបាលី ភាសាសំស្ក្រឹត ភាសាចិន និងភាសាទីបេ ។ ចេញពីភាសាទាំងនោះ ការសិក្សាប្រវត្តិសាស្ត្រសម័យថ្មី ស្វែងរកឃើញក្របខណ្ឌព្រឹត្តិការណ៍សំខាន់ៗ មានស្ថិរភាពបង្ហូរនៅក្នុងចរិតមួយ ដែលគេនៅតែធ្វើបុណ្យអបអរ សាទរនៅឡើយក្រោយពេល ២៥០០ឆ្នាំបានកន្លងទៅ។

ឯកសារអក្សរសិល្ប៍ គឺជាឃ្លាំងផ្ទុកនូវចំណេះដឹងស្តីពីបាតុភូតជាក់ស្តែងដែលកើតមាននៅក្នុងជីវភាពរស់នៅរបស់មនុស្ស (រាប់បញ្ចូលទាំងសង្គមមនុស្សថ្នាក់ទាបបំផុត រហូតដល់សង្គមមនុស្សថ្នាក់ខ្ពស់បំផុត) ពោលគឺអក្សរសិល្ប៍គឺជាកញ្ចក់សម្រាប់ខ្លួនបញ្ជាំងនូវតថភាពសង្គម នូវហេតុការណ៍ទាំងឡាយ ដែលមាននៅក្នុងសង្គមមនុស្ស ក្រុមមនុស្សប្រភេទមនុស្ស ប្រពៃណី ទំនៀមទម្លាប់ ភូមិសាស្ត្រប្រវត្តិសាស្ត្រជាដើម ។ ម្យ៉ាងវិញទៀតរាល់អត្ថបទអក្សរសិល្ប៍ គឺសុទ្ធតែបានផ្តល់ដល់អ្នកអាននូវបញ្ហារបស់មនុស្សនាសម័យណាមួយជាមិនខាន ។ ឧទាហរណ៍ បើយើងអានរឿងទុំទាវ នោះយើងនឹងបានដឹងពី ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យលង្វែក ហើយបើយើងអានរឿងភូមិគិរីប្លាន នោះយើងនឹងអាចដឹងពី ជីវភាពរបស់ប្រជាជនខ្មែរនាសម័យអាណានិគមបារាំង។

សម័យក្រោយអង្គរ ប្រទេសខ្មែរមានវិបរិតដោយសារតែសង្គ្រាម។ គ្រោះមហន្តរាយទាំងអស់នេះធ្វើឱ្យការសិក្សា តែងនិពន្ធ ក្បួនខ្នាត ឬការចងក្រងកត់ត្រានូវព្រឹត្តិការណ៍ផ្សេងៗថយចុះដាលំដាប់។ ទោះជាយ៉ាងនេះក៏ដោយអ្នកនិពន្ធ ក៏បណ្ឌិតខ្មែរពុំលះបង់សេចក្តីព្យាយាមចងក្រងអត្ថបទរឿងរ៉ាវកត់ត្រាលើឬ និងការលើក្រាំង ឬស្លឹករឹតដើម្បីលាតត្រដាងនូវទឹកចិត្តរបស់ខ្លួនសម្រាប់ទុកជាកេរមរតក និងជាវិភាគទានយ៉ាងធំក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិដែរ។ អត្ថន័យនៃអត្ថបទមានលក្ខណៈរឿងប្រឌិតតាមបែបមនោសញ្ចេតនា ។ រឿងក្នុងជាតកបែបបាលី បានច្នៃតែងផ្សំប្រមុំតាមចិត្តគំនិតរបស់ខ្លួន ដើម្បីសម្របទៅតាមជំនឿ បញ្ហាជីវភាពរស់នៅនាសម័យនោះ។ អត្ថបទភាគច្រើនសរសេរជាពាក្យកាព្យមានបទកាកគតិ ពំនោល ព្រហ្មគីតិ បទកុដង្គលីលាជាដើម ។

អក្សរសិល្ប៍ពុទ្ធនិយម គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ រឿងក្នុងគោលពុទ្ធនិយមមានលក្ខណៈខុសប្លែកពី រឿងក្នុងគោលព្រាហ្មណ៍និយម ដោយគោលគំនិតធំ ឬ មូលបញ្ហានៃរឿងពុទ្ធនិយម គឺការសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។ ដំណោះស្រាយបញ្ហាក្នុងរឿងពុទ្ធនិយម គឺអហិង្សា ឬ សន្តិវិធី ។ រឿងតួអង្គឯកប្រុសជាព្រះពោធិសត្វ និងតួអង្គឯកស្រីជាកន្សែសពេជ្ជ ។ ចុងបញ្ចប់នៃរឿង គឺការសរជាតិ ។ រឿងក្នុងអក្សរសិល្ប៍ពុទ្ធនិយម មានពីរបែប គឺរឿងពុទ្ធនិយមសុទ្ធសាធ និងរឿងបែបពុទ្ធនិយមក្លាយ[1]។

ដូច្នេះ ការសិក្សាអក្សរសិល្ប៍នាពេលនេះ គឺយើងធ្វើការសិក្សាឱ្យយល់ពីប្រវត្តិអក្សរសិល្ប៍ខ្មែរតាមសម័យកាលនីមួយៗទៅតាមលំដាប់លំដោយតាំងពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ន ដោយយើងនឹងធ្វើការសិក្សាពីសម័យទាំងនោះតាមរយៈស្នាដៃរបស់អ្នកនិពន្ធនីមួយៗដូចតទៅ ។

២.បញ្ញត្តិអក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍ពុទ្ធនិយម > អក្សរសិល្ប៍ + ពុទ្ធនិយម

២.១.បញ្ញត្តិ "អក្សរសិល្ប៍"

អក្សរសិល្ប៍ជាសព្ទមួយ ដែលមានការផ្តល់និយមន័យទីទៃពីគ្នាជំច្រើន ពីសំណាក់អ្នកសិក្សាខាងវិជ្ជាមួយនេះ ដូចជា៖

- ក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥នៅឆ្នាំ១៩៦៧ បានបង្ហាញថា៖ អក្សរសិល្ប៍ > អក្សរ + សិល្ប៍
  - **អក្សរ** ស្នាមគំនូសមានរាងផ្សេងៗសម្រាប់ប្រើសរសេរកត់ត្រាពាក្យសេចក្តី និងសម្តីទាំងពួងមិនចេះអស់។
  - **សិល្ប៍** សំដៅដល់ការរចនាតាក់តែងដ៏វិចិត្រផ្សេងៗ។ ម្យ៉ាងទៀតខ្មែរច្រើនហៅចំមន្តអាគមផ្សេងៗ។
- លោក កែង វ៉ាន់សាក់ (១៩២៥-២០០៨) នៅក្នុង "ទិដ្ឋភាពខ្លះចំពោះអក្សរសិល្ប៍ខ្មែរ" បានឱ្យនិយមន័យអក្សរសិល្ប៍នេះថា ៖ "**អក្សរសិល្ប៍**គឺជាវិទ្យាស្សង់ ដែលចោទ និងដោះស្រាយបញ្ហាមនុស្សទៅតាមសង្គមនីមួយៗ និងដោយសិល្ប៍វិធី"។
- លោក លាង ហាប់អាន បានកំណត់និយមន័យនៃពាក្យអក្សរសិល្ប៍ថា ៖ "**អក្សរសិល្ប៍**ជាការសម្គាល់អក្សរសាស្ត្រដែលទាក់ទងនឹងផ្នែកផ្សេងៗនៃការតែងនិពន្ធដូចជា សន្ទស្សន៍អក្សរសិល្ប៍ (ប្រភេទ) ប្រលោមអក្សរសិល្ប៍ (មនោគតិ) នាដ្យកម្មអក្សរសិល្ប៍ ឧបទេសអក្សរសិល្ប៍ ឧបារម្ភអក្សរសិល្ប៍ និងសុន្ទរកថា»។[2]
- លោកបណ្ឌិត ធ សោ បានឱ្យនិយមន័យអក្សរសិល្ប៍ថា ៖ "**អក្សរសិល្ប៍** គឺជាពាក្យបណ្តាំពាក្យពេចន៍ ឃ្លាប្រយោគ"។

២.២.បញ្ញត្តិ "អក្សរសិល្ប៍ពុទ្ធនិយម"

អក្សរសិល្ប៍ពុទ្ធនិយម គឺជាការនិយមរាប់អានទៅលើទ្រឹស្តីរបស់ព្រះពុទ្ធបរមគ្រូនៃយើង។ លោកបណ្ឌិត ញ៉ុក ថែម បានឲ្យនិយមន័យថា ៖ តាមធម្មតា រឿងជាតកទាំងឡាយដែលស្ថិតនៅលើមូលដ្ឋាននៃចលនាពុទ្ធនិយម តែងមានរបៀបនិពន្ធជាបីយ៉ាង គឺមានសេចក្តីផ្តើមរឿង ដំណើរសេចក្តីរឿង និងបញ្ចប់រឿងដោយការសរជាតិ[3] ។

---

[1] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទំព័រ៦៥

[2] លាង ហាប់អាន សិក្សាអត្ថបទ ភាគទី១ (សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) ភ្នំពេញ ១៩៦៦ ទំព័រ២៦ ។

[3] បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក ទំព័រ១ (១៩៦៣)

ចំណែកលោក ជុំ កាណាល់ បានឲ្យនិយមន័យថា ៖ **អក្សរសិល្ប៍ពុទ្ធនិយម**ក្នុងទីនេះ ទោះបីលើកយកកម្ម និងផល មកធ្វើជាធំក្តី។ បានសេចក្តីថា បើនរណាប្រព្រឹត្តអំពើល្អ ពិតជាឲ្យផលល្អនៅខាងក្រោយ តែបើនរណាប្រព្រឹត្តនូវបាបកម្មអាក្រក់ ក៏ប្រាកដជានឹងទទួលកម្មអកុសលជាក្រោយវិញមិនខានឡើយ[4] ។

ជាមួយគ្នានេះដែរ លោកបណ្ឌិត ឈឹម សុមន៍ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ក៏បានបញ្ជាក់នៅក្នុងស្នាដៃរបស់ព្រះអង្គថា៖ **អក្សរសិល្ប៍ពុទ្ធនិយម** ជាឯកសារជារឿងរ៉ាវផ្សេងៗ ដែលនិយាយដល់ការកសាងបារមីរបស់តួអង្គពោធិសត្វ ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធក្នុងអនាគតជាតិ[5]។

ចំណែកលោក លី ធាមតេង អ្នកស្រាវជ្រាវអក្សរសាស្ត្រខ្មែរក៏បានបញ្ចេញទស្សនៈក្នុងស្នាដៃរបស់ខ្លួនថា ៖ **អក្សរសិល្ប៍ពុទ្ធនិយម**គឺជាអតីតប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមគ្រូ មុនព្រះជាតិដែលបានត្រាស់ដឹង។ រឿងនេះប្រភពដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតមហានិបាត ដែលគេប្រកាន់ជឿថាព្រះពុទ្ធវចនៈ ហើយនិងក្នុងគម្ពីរជាតកអដ្ឋកថា មានជាង ២០០០ឆ្នាំមកហើយ[6]។

អក្សរសិល្ប៍ពុទ្ធនិយម និងអក្សរសិល្ប៍ទាំងឡាយណា ដែលលើកយកលទ្ធិរបស់ព្រះពុទ្ធមកធ្វើការឆ្លុះបញ្ចាំង ត្រូវលះបង់នូវអំពើអាក្រក់ ហើយទៅជឿបុណ្យបាប ខិតខំកសាងកុសលដើម្បីបានសេចក្តីសុខបច្ចុប្បន្នជាតិ និងអនាគតជាតិ។ **អក្សរសិល្ប៍ពុទ្ធនិយម** គឺជាអក្សរសិល្ប៍មួយបែប ដែលទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនា បានចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីយើងតាំងពីយូរយារណាស់មកហើយ ទាំងក្នុងបេះដូងមនុស្ស និងលើគ្រប់វិស័យ[7]។

ពុទ្ធសាសនាមានកំណើតនៅប្រទេសឥណ្ឌា តាំងពីសតវត្សរ៍ទី៦មុនគ្រិស្តសករាជ ហើយបានចូលមកប្រទេសកម្ពុជាក្នុងអំឡុងសតវត្សរ៍ទី១ ប៉ុន្តែមានឥទ្ធិពលតិចតួច លុះដល់ចុងសម័យអង្គរក៏ចាប់ផ្តើមរីកចម្រើន និងមានឥទ្ធិពលខ្លាំងនៅសម័យកណ្តាលរហូតមក។

បើយោងទៅតាមអត្ថន័យ និងកាលបរិច្ឆេទ គេអាចបែងចែកអក្សសិល្ប៍ពុទ្ធនិយមជាបីប្រភេទ[8] គឺ៖

- អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ (គម្ពីរទសជាតក)
- អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយ (គម្ពីរបញ្ញាសជាតក)
- អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ (សាស្ត្រាល្បែង)

និយាយពីអក្សរសិល្ប៍ពុទ្ធនិយមនេះ យើងឃើញថាអ្នកសិក្សាបានចែកអក្សរសិល្ប៍ពុទ្ធនិយមនេះជាបីគឺ

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ និយាយដ៏ដំណើរដប់ជាតិរបស់ព្រះពុទ្ធ ដែលយើងហៅថា«ទសជាតក» ក្នុងនោះរួមមានរឿងតេមិយជាតក មហាជនកជាតកសុវណ្ណសាមជាតក នេមិរាជជាតក វិធូរជាតក ព្រះវេស្សន្តរជាតក...។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយ យើងហៅថា បញ្ញាសជាតក ឬជាតក៥០ទាំងអស់នេះ សុទ្ធតែនិយាយពីរឿងរ៉ាវទាក់ទងនឹងព្រះពុទ្ធបរមគ្រូនៃយើង ចំនួន៥០ជាតិ ត្រូវបានអ្នកនិពន្ធបញ្ចេញបញ្ចូលទស្សនៈរបស់ខ្លួនមួយចំនួនផង

[4] ជុំ កាណាល់ សិក្សាស្វែងយល់អក្សរសាស្ត្រខ្មែរសង្ខេបបែបទំនើប ទំព័រ២៦ (១៩៩៦)

[5] បណ្ឌិត ឈឹម ស៊ុមន៍ សង្ខេបទសជាតក ទំព័រ១៨ (១៩៥៩)

[6] លី ធាមតេង អក្សរសាស្ត្រខ្មែរ ទំព័រ ៣៥ (១៩៦៦)

[7] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៤ (១៩៩៤)

[8] បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក ទំព័រ ១ (១៩៦៣)

ដែរ។តាមទស្សនៈអ្នកសិក្សាមួយបាននិយាយថា ៖ ចំពោះបញ្ញាសជាតកពាក្យនេះប្រែថា ជាតក៥០រឿង ឬ៥០ជាតក។ ច្បាប់ដើមជាភាសាបាលី ជាគម្ពីរសោស្ត្រាស្លឹករឹត។ គម្ពីរនេះគេឃើញមានប្រទេសនៅក្នុងតំបន់ឥណ្ឌូចិន គឺមានប្រទេសខ្មែរ ថៃ លាវ និងភូមា។ ក្នុងនេះយើងលើកយកឈ្មោះទាំង ៥០ នោះ មកបង្ហាញដូចទសជាតកទេ[9]។ បញ្ញាសជាតកនេះ ពិតមែនតែជាគម្ពីរបាលី ហើយក៏មិនមែនជាគម្ពីររបស់ជំនាន់មុន ឬជំនាន់អង្គរទេ គឺជាគម្ពីរអ្នកប្រាជ្ញភាសាបាលីបាននិពន្ធឡើងក្រោយសម័យអង្គរ ជាសម័យដែលប្រជាជនខ្មែរ លែងជឿជាក់ប្រកាន់លទ្ធិព្រាហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន ហើយបែរមកគោរពព្រះពុទ្ធសាសនាហីនយានវិញ។ **អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬអក្សរសិល្ប៍ពុទ្ធនិយមផ្លូម** គឺជារឿងរ៉ាវ ដែលនិយាយទាក់ទងនឹងអតីតតួអង្គព្រះពុទ្ធបរមគ្រូនៃយើងមានចំនួន៥០រឿង ឬ៥០ជាតក យើងហៅថាអក្សរសិល្ប៍ល្បែង ឬសាស្ត្រាល្បែង មានការពេញនិយមខ្លាំង ចាប់តាំងពីសម័យលង្វែកមកម្ល៉េះ។

៣. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ

តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា បន្ទាប់ពីមានភាសាសម្រាប់និយាយប្រាស្រ័យទាក់ទងគ្នាមកមនុស្សបានបង្កើតតួអក្សរដើម្បីកត់ត្រាចារភាសាទាំងនោ ដូច្នេះបុព្វបុរសខ្មែរយើងក៏មានគំនិតបង្កើតភាសា ដោយខ្ចីតួអក្សរព្រាហ្មី ពីឥណ្ឌាភាគខាងត្បូងយកមកប្រើ [10] ។ ការដែលមានភាសា និងការមានអក្សររបស់ជនជាតិនីមួយៗនេះហើយ ដែលបង្កើតបានជាអក្សរសោស្ត្រ-អក្សរសិល្ប៍ឡើង។ យ៉ាងណាមិញ អក្សរខ្មែរយើងបានចាប់មានកំណើតតាំងពីសម័យនគរភ្នំមកម្ល៉េះ បើសំអាងលើសិលាចារឹក**រ៉ូកាញ់** ស.វទី៣ នៃគ.ស. ដែលនេះសបញ្ជាក់ឱ្យឃើញថា អក្សរខ្មែរបានកើតឡើង ហើយមានការវិវត្តប្រែប្រួលទៅតាមរបត់សង្គម។ តួយ៉ាងដូចជានៅចុងសម័យអង្គរ លទ្ធិទេវរាជបានចាប់ចុះឥទ្ធិពលរបស់ខ្លួនបន្តិចម្តងៗ ទន្ទឹមនឹងការហូរចូលមកដល់នៃព្រះពុទ្ធសាសនា (ហីនយាន) ដែលនាំចូលពីស្រីលង្កា។ សាសនាថ្មីនេះ បានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងសតិអារម្មណ៍របស់ប្រជាពលរដ្ឋខ្មែរនាសម័យនោះ ហើយមានប្រៀបជាងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន ។ ទន្ទឹមនឹងនោះ ខ្មែរយើងក៏បានទទួលភាសាមួយទៀត គឺ**ភាសាបាលី** ។ ជាបណ្តើរៗ ខ្មែរបានបោះបង់ចោលភាសាសំស្ក្រឹត ប៉ុន្តែខ្មែរមិនបង់ភាសាខ្លួនចោលទាំងស្រុងនោះទេ ហើយអ្វីដែលពិសេសនោះ គឺខ្មែរយើងរក្សា និងបង្កើតភាសាជាតិ ដោយបានកាឡៃពាក្យបាលីឱ្យមានសូរសំឡេងជាភាសាខ្មែរថែមទៀត ។ឧទាហរណ៍ ៖ ជយ > ជ័យ អាចម> អាចម៍ ... ជាដើម

អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល គឺសំដៅចំពោះសំណុំ ចង្កោមអត្ថបទទាំងឡាយណាដែលអ្នកនិពន្ធរចនាឡើងជាភាសាខ្មែរកណ្តាល គឺគិតចាប់ពីស.វ ទី១៥ ដល់ ស.វ ទី១៩ ដែលភាគច្រើនជាអត្ថបទសាស្ត្រា ឬក្រាំង។ អក្សរសិល្ប៍សម័យនេះមាន សម័យលង្វែក(១៤៣១-១៦១៨) សម័យឧដុង្គ(១៦១៨-១៨៦៣) និងសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣) ។

បើតាមលោក លាង ហាប់អាន[11] លោកបានបែងចែកសម័យកាលប្រវត្តិអក្សរសាស្ត្រខ្មែរជា៤ ផ្នែកធំៗគឺ៖

- សម័យនគរភ្នំ ស.វ.ទី១ ដល់ ស.វ.ទី៦
- សម័យមុនអង្គរ ស.វ.ទី៦ ដល់ស.វ.ទី៩

[9] បណ្ឌិត ញ៉ុក ថែម មហាវេស្សន្តរជាតក ទំព័រ ២៣ (១៩៦៣)

[10] ត្រឹង ងា , អរិយធម៌ខ្មែរ, ឆ្នាំ១៩៧៥ ទំព័រ៩៣

[11] លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរសម័យនគរភ្នំ ដល់សម័យឧដុង្គ (ស.វ.ទី១ ដល់ឆ្នាំ១៨៥៩)* ឆ្នាំ១៩៦៧ ទំព័រ៥-១១។

- សម័យអង្គរ ស.វ.ទី៩ ដល់ស.វ.ទី១៤
- សម័យក្រោយអង្គរ ចុងស.វ.ទី១៤ ដល់បច្ចុប្បន្ន ហើយនៅក្នុងផ្នែកទី៤នេះ លោកបានបែងចែកជាបីផ្នែកតូចៗទៀតគឺ៖
  - សម័យលង្វែក ១៥២៥-១៥៩៣
  - សម័យឧដុង្គ ចាប់ពីរជ្ជកាលព្រះបាទជ័យជេដ្ឋា(១៦១៨-១៦២៨) ដល់រជ្ជកាលអង្គឌួង(១៨៤៥-១៨៥៩)
  - សម័យក្រុងភ្នំពេញ គិតចាប់ពីឆ្នាំ១៨៥៩ រហូតដល់សព្វថ្ងៃ។

  រីឯលោក យីង ហុកឌី[12] គេបានបែងចែកអក្សរសិល្ប៍ទៅតាមសម័យកាលប្រវត្តិសាស្ត្រគឺ៖
- សម័យមុនអង្គរ ស.វ.ទី១ ដល់ស.វ.ទី៩
- សម័យអង្គរ ស.វ.ទី៩ ដល់ស.វ.ទី១៥
- សម័យក្រោយអង្គរ ស.វ.ទី១៥ ដល់ស.វ.ទី១៨
- សម័យបារាំង ឆ្នាំ១៨៦៣-១៩៥៣
- សម័យបច្ចុប្បន្ន ឆ្នាំ១៩៥៣ ដល់បច្ចុប្បន្ន។

បើនិយាយពីចុងសម័យអង្គរ គឺបច្ចាមិត្របានរុករានទន្ទ្រានប្រទេសខ្មែរ នាំឱ្យស្តេចខ្មែរលើករាជធានីមកតាំងនៅចតុមុខវិញ តែនៅតែមិនទទួលបានសេចក្តីសុខក្សេមក្សាន្តដដែល ពោលគឺដោយមានបញ្ហាធំពីរគឺ ការឈ្លានពានពីសំណាក់បរទេស និងទំនាស់វិបត្តិផ្ទៃក្នុង ដែលបានជះឥទ្ធិពលអាក្រក់ដល់វិស័យនានាក្នុងសង្គមខ្មែរ ជាពិសេសគឺវិស័យអក្សរសាស្ត្រ។ ក៏ប៉ុន្តែទោះបីជាស្រុកទេសស្ថិតក្នុងសភាពមានវិបត្តិច្របូកច្របល់ក៏ដោយ ក៏វប្បធម៌ជាតិ អក្សរសាស្ត្រជាតិ បានជ្រកពួនតាមទីវត្តអារាមដែលមានព្រះសង្ឃជាអ្នកការពារ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋខ្មែរ ។ វត្តអារាមជាសាលារៀន ហើយសិក្ខាកាមនៅសាលាវត្តនេះហើយ ដែលជាអ្នកផលិតអក្សរសាស្ត្រនាសម័យកណ្តាលដោយបានចារសរសេរលើវត្ថុស្រាលៗ ដូចជា ស្លឹករឹត ស្លឹកត្នោត និងក្រាំង ។

ចំពោះការកត់ត្រាលើឯកសារទាំងនោះមាន៣បែបគឺ៖

- <u>បែបទី១</u> : កត់ត្រាលើក្រាំង ដែលមានសន្លឹកបើកបានសងខាង។ គេសរសេរដោយប្រើស្លាបប៉ា)ឬស្លាបសត្វជាមួយទឹកខ្មៅចិន។ សន្លឹកក្រដាសនេះធ្វើនៅក្នុងប្រទេស ហើយមានកម្រាស់ក្រាស់ អាចរក្សាទុកបានយូរដោយធ្វើពីស្លឹកស្នាយ និងស្លឹកមន ។
- <u>បែបទី២</u> : កត់ត្រាលើក្រាំងដូចបែបទី១ដែរ តែក្រដាសមានពណ៌ខ្មៅ ហើយសរសេរដោយដីសឬ។
- <u>បែបទី៣</u> : កត់ត្រាលើស្លឹករឹតដោយប្រើដែកចារចោះទម្លុះ ហើយមានចោះរន្ធចងខ្សែតាមលេខរៀងទំព័រដែលយើងហៅថា សាស្ត្រា ។

  ក្នុងសំណុំចង្កាមឯកសារសម័យកណ្តាលទាំងនេះ លោក ***អូ រឈៀង*** បានចែកជា៣ប្រភេទគឺ៖
- **សាស្ត្រាទេសន៍**: ជាអត្ថបទទាក់ទងនឹងការសម្តែងធម៌ ពោលគឺការអប់រំទាក់ទងនឹងពុទ្ធសាសនា។
- **សាស្ត្រាល្បែង** : ជាអត្ថបទសម្រាប់អានកម្សាន្តចិត្ត ឱ្យសប្បាយរីករាយ បំពេរអារម្មណ៍ឱ្យរន្ធត់ញាប់ញ័រភ្លើតភ្លើន ដោយកម្រងភាសាដ៏ប្រណិត។

[12] យីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ* ឆ្នាំ១៩៧៧ ទំព័រ២៣-២៤។

- **សាស្ត្រាក្បួន** : គឺជាអត្ថបទដែលតាក់តែងជាក្បួនខ្នាត បែបបទ ឬកំណត់ជាគោលចារឹកនៃការធ្វើអ្វីមួយ ដូចជា ក្បួនទាយ ក្បួនថ្នាំ ក្បួនច្បាប់ ក្បួនសាវតារ ។ល។

ចំពោះផ្នែកសិលាចារឹកវិញ ចាប់តាំងពីដើម ស.វ ទី១៤ រៀងមក អ្នកសិក្សាស្រាវជ្រាវពុំឃើញមានសិលាចារឹកនៅប្រទេសខ្មែរទៀតទេ(ទោះបីទំហំខ្លីខ្លី វែងក្តី)។ លុះមកដល់រជ្ជកាលព្រះបាទចន្ទរាជា ទោះបីពេលនោ រាជធានីពិតប្រាដកតាំងនៅលង្វែកក៏ដោយក៏ព្រះរាជាខ្មែរតែងតែនាំមន្ត្រីបរិវារទៅតំបន់អង្គរ ហើយបានកសាងសិលាចារឹកឡើងវិញ ដោយធ្វើការចារសិលាចារឹកនៅប្រាសាទអង្គរវត្ត ៣អន្លើ គឺនៅត្រង់[13]៖

- សិលាចារឹកនៅ ***ព្រះពាន់*** ត្រង់ដែលមានព្រះពុទ្ធរូបច្រើន។
- សិលាចារឹកនៅថ្នាក់លើបំផុតហៅថា ***បាកាណ***។
- សិលាចារឹកលេខ៣៨ ***នៅព្រះរបៀងថ្នាក់ក្រោម*** គឺស្ថិតពីខាងកើតត្រង់ព្រះចេតិយដោយថ្មបាយក្រៀម។

សិលាចារឹកទាំងនោះ មាន៤០ផ្ទាំង មានចុះគោលកំណត់ពី គ.ស. ១៥៦៥ដល់១៧៤៦។ ប៉ុន្តែសកវាជ ដែលប្រើ គឺមហាសកវាជ។

សេចក្តីក្នុងសិលាចារឹកនោះ និយាយពីរឿងធ្វើបុណ្យផ្សេងៗ គឺប្រោសខ្ញុំឱ្យរួចជាអ្នកជា បំបួសមនុស្ស លាបំណន់ សាងព្រះ សាងពិដាន និងថ្វាយរបស់ជាពុទ្ធបូជា។ល។ ជាស្តេចខ្លះ ជាមន្ត្រីខ្លះ[14]។ អ្នកស្រាវជ្រាវមួយក្រុមបានបន្ថែមសេចក្តីទៀតថា« *សេចក្តីអស់នោះ ជាពាក្យចាលចាញ់ ហើយមានទីពឹង ទីរលឹក ចំពោះព្រះរតនត្រ័យប៉ុណ្ណោះ ជាអ្នកសុខចិត្តទទួលព្រមសេចក្តីលំបាកវេទនាដោយយល់ថាវាជាផលនៃកម្មអាក្រក់ ដែលខ្លួនបានធ្វើក្នុងអតីតជាតិ តែពុំបានអស់កម្លាំងនឹងសេចក្តីប្រឹងប្រែងឡើយ គេតែងតែខំសន្សំបុណ្យកុសល ដើម្បីសេចក្តីចម្រើនដល់ខ្លួន និងដល់ប្រទេស*»[15]។

ភាសាដែលគេប្រើក្នុងសិលាចារឹកទាំងនោះ ជាភាសាខ្មែរធម្មតាក្នុងសម័យកណ្តាល និងមានពាក្យពេចន៍បុរាណលាយឡំខ្លួនដែរ តែយើងអាចមើលយល់សេចក្តីបាន ។ តួយ៉ាង សិលាចារឹកនគរវត្តរបស់បណ្ឌិត ជ័យនន្ទ ក៏ស្ថិតនៅសម័យនេះដែរ ដោយយោងតាមសូរ និងអក្សរ។

ដូច្នេះ ក្រោយសម័យអង្គរ ឬសម័យកណ្តាល គឺគិតចាប់ពីការចាកចោលក្រុងអង្គរហូតដល់សម័យអាណានិគមបារាំង ដែលជាសម័យប្រែប្រួលខ្លាំងនៃស្នាដៃអក្សរសិល្ប៍ ជាពិសេសគឺ ការកើតឡើងប្រភេទអក្សរសិល្ប៍ថ្មី គឺការកត់ត្រាលើស្លឹកឫត(សាស្ត្រា) ហើយដែលការប្រែប្រួលនេះ គឺអាស្រ័យទៅលើស្ថានភាពសង្គម(ស្ថានភាពប្រវត្តិសាស្ត្រ ស្ថានភាពនយោបាយដឹកនាំ ស្ថានភាពជំនឿសាសនា ស្ថានភាពអប់រំ និងជីវភាពរស់នៅ) ដែលនេះសបញ្ជាក់ឱ្យឃើញពីភាពទំនាក់ទំនងគ្នារវាងសង្គម និងអក្សរសាស្ត្រ ។

[13] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ ភាគ២ ទំព័រ៨០

[14] សិលាចារឹកនគរវត្ត និងបទានុក្រម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៥៨។

[15] គោលប្រវត្តិនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ ការផ្សាយរបស់បណ្ណាគារភ្នំពេញ ឆ្នាំ១៩៥៦។

៣.១. អក្សរសិល្ប៍ខ្មែរសម័យលង្វែក

អក្សរសិល្ប៍ សម័យលង្វែកគឺជាអក្សរសិល្ប៍មួយរបស់ខ្មែរដែល ចាប់គិតពីឆ្នាំ(១៤៣១ដល់ ១៦១៨)[16] ។ យើងបានដឹងរួចមកហើយថា សម័យលង្វែក ជាសម័យដែលខ្មែរបានចាកចោលក្រុងអង្គរក៏ដូចជាការចាកចោលព្រហ្មញ្ញសាសនា(ពិធីទេវរាជ) និងអាចនិយាយបានថា ជាសម័យដែលខ្មែរចុះអន់ថយ ទាំងខាងផ្នែកកសាង និងផ្នែកការពារ ។ ជាមួយគ្នានេះដែរ វិស័យតែងនិពន្ធក៏បានងាកទៅរកភាពស្រមើស្រមៃតាមបែបជំនឿសាសនា ហើយចំពោះស្នាដៃដែលជាអក្សរសាស្ត្រ-អក្សរសិល្ប៍ គេឃើញមានដូចជា សិលាចារឹកនិងសាស្ត្រា។ ក្នុងចំណោមសាស្ត្រា(សាស្ត្រាទេសន៍ សាស្ត្រាល្បែងនិងសាស្ត្រាក្បួន), សាស្ត្រាល្បែងមាននៅតិចតួចណាស់ ហើយយើងពុំទាន់រកឃើញនូវកាលបរិច្ឆេទនៃការតែងនិពន្ធបញ្ជាក់ឱ្យបានច្បាស់នៅឡើយទេ ព្រោះសាស្ត្រាទាំងនោះ ត្រូវបាត់បង់ដោយសារសង្គ្រាម ជាពិសេសនៅពេលដែលសៀមវាយបែកបន្ទាយលង្វែក ។

និន្នាការអក្សរសិល្ប៍នៅសម័យលង្វែកត្រូវបានកត់ត្រាឡើងជាពីរប្រភេទគឺ កត់ត្រានៅលើថ្ម(សិលាចារឹក) និងកត់ត្រាលើក្រាំង សាស្ត្រា ។

- **ផ្នែកសិលាចារឹក**

នៅសម័យលង្វែកយើងឃើញមានសិលាចារឹកមួយផ្ទាំង ដែលមានចុះកាលបរិច្ឆេទ ហើយអត្ថបទសិលាចារឹកនេះនិពន្ធដោយ បណ្ឌិត ជ័យ នន្ទ ។ សរសេរជាអត្ថបទកំណាព្យមាន១០៩ឈ្នះ ដែល៤៥ឈ្នះខាងលើសរសេរជាបទព្រហ្មគីតិ ៥៩ឈ្នះបន្ទាប់សរសេរជាបទកុដង្គលីលា និង៥ឈ្នះចុងក្រោយសរសេរជាបទកាកគតិ ។ តាមរយៈខ្លឹមសារនៃអត្ថបទសិលាចារឹកឃើញថា វាមាននិន្នាការទៅរកព្រះពុទ្ធសាសនា ព្រោះបណ្ឌិតជ័យ នន្ទ បានធ្វើការអធិដ្ឋានសុំកើតជាតិក្រោយៗបានជួបប្រសព្វតែក្នុង**ព្រះពុទ្ធសាសនា** ។

- **ផ្នែកសាស្ត្រា**

សាស្ត្រាសម័យលង្វែកពិតជាមានច្រើន ប៉ុន្តែក្នុងចំណោមនោះឃើញមានតែល្បើកអង្គរវត្តមួយទេដែលមានចុះកាលបរិច្ឆេទ។ ថ្វីត្បិតតែរឿងល្បើកនេះ បានលើកឡើងពីតួអង្គអមនុស្សក្តីតែបានបង្ហាញយ៉ាងច្បាស់ពីស្ថានឬបញ្ហារបស់មនុស្សសុទ្ធសាធ ។

ស្នាដៃមួយដែលគេស្គាល់ឈ្មោះអ្នកនិពន្ធពិតប្រាកដគឺ ល្បើកអង្គរ និពន្ធដោយ អ្នកប៉ាង ក្នុងឆ្នាំ១៥៩៨ ជាពាក្យកាព្យ និយាយពីការកសាងប្រាសាទអង្គរវត្តតាមរបៀបរឿងទេពនិទាន។ ប៉ុន្តែអ្នកស្រាវជ្រាវខ្មែរ បានកំណត់រឿងនេះឱ្យខិតមកមុខបន្តិច គឺនៅឆ្នាំ១៦០៩វិញ[17]។

តើសាស្ត្រាល្បែងគឺជាអ្វី ?

ដែលហៅថា **សាស្ត្រាល្បែង** គឺជារឿងរ៉ាវទាំងឡាយ ដែលសរសេរជាពាក្យកាព្យ មានច្រើនខ្សែ ហើយកវីច្រើនផ្នែកលើការយល់សប្តិ លើមន្តអាគម ចេះហោះ ចេះហើរ ដើរលើអាកាស ជ្រែកទឹក ជ្រែកដី ដែលមនុស្សធម្មតាមិនអាចធ្វើបាន និងមិនសមហេតុផល ។ កវីទាំងនោះ លោកបង្កើតរឿងទាំងនេះឡើងគឺដើម្បីចង់សម្រាលទុក្ខប្រជារាស្ត្រដែលរងទុក្ខវេទនាដោយសារស្រុកទេសកើតសង្គ្រាម។ ក្រៅពីអត្ថបទខាងលើនេះ មានអត្ថបទទូន្មានជាច្រើនសម្រាប់

[16] ម៉ក់ ស៊ីនេត *អក្សរសិល្ប៍ក្រោយអង្គរ*

[17] ឃួន សុខម្ភ *គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ* សន្និសីទធ្វើទៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៤ នៅភ្នំពេញ ។

អប់រំខ្លួន និងកូនចៅជំនាន់ក្រោយៗទៀត។ ច្បាប់ទាំងនោះ មានន័យសម្រាប់ការអប់រំ និងពត់មនុស្សឱ្យចេះរស់នៅក្នុងសង្គម និងគោរពច្បាប់(ច្បាប់ធម្មជាតិ និងច្បាប់រដ្ឋ)។

ជាការគួរឱ្យសោកស្តាយ ព្រោះមានសាស្ត្រាស្លឹករឹត និងកាំងជាច្រើនត្រូវវិនាសខូចខាតខ្ទេចខ្ទីអស់ជាច្រើនដែលនេះទំនងជាមកពីសត្រូវជិតខាង ដែលចូលមកលុកលុយក្នុងប្រទេសកម្ពុជា គេនាំគ្នាដឹកជញ្ជូនយកទ្រព្យសម្បត្តិទាំងនោះ ទៅទុកជាទ្រព្យសម្បត្តិគេផ្ទាល់ ហើយម្យ៉ាងទៀត ប្រហែលជាត្រូវភ្លើងឆេះ ក្នុងគ្រាមានសង្គ្រាមនោះផងក៏មិនដឹង។ ប្រសិនបើមាននៅសេសសល់ គឺយើងសង្កេតឃើញមាននៅតាមទីវត្តអារាម តែច្រើនតែពុំមានឈ្មោះអ្នកនិពន្ធទេ ។ ចំពោះរឿងនេះ មានមតិខ្លះយល់ថា មកពីរបបគ្រប់គ្រង ទើបធ្វើឱ្យអ្នកនិពន្ធខ្លាច មិនហ៊ានបញ្ចេញឈ្មោះខ្លួនឱ្យគេស្គាល់ និងមានមតិខ្លះថា មកពីអ្នកចារមានទម្លាប់អាក្រក់មួយ គឺលុបបំបាត់ឈ្មោះនអ្នកនិពន្ធចោលហើយតាំងខ្លួនជាអ្នកនិពន្ធជំនួសវិញ។

៣.២. អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ

ក- អត្ថន័យនៃអត្ថបទ

អត្ថបទរឿងរ៉ាវផ្សេងៗនៃសម័យឧដុង្គគឺសឹងតែជាទូទៅ មានលក្ខណៈជារឿងប្រឌិត ចងក្រងតាមបែបមនោសញ្ចេតនា។ អ្នកនិពន្ធជ្រើសរើសយករឿងក្នុង**ជាតកបែបបាលី** (បញ្ញាសជាតក ឬជាតក ក្នុងអដ្ឋកថា[18] នៃព្រះត្រៃបិតកជាដើម) មកកែច្នៃតាក់តែងតាមទស្សនៈរបស់អ្នកនិពន្ធ ដើម្បីសម្រេចទៅតាមជំនឿ ការរស់នៅ (ស្របតាមកាលៈទេសៈ) របស់មនុស្សនាសម័យនោះ ។ គេឃើញមានរឿងផ្សេងព្រេង ដោយមានអច្ឆរិយៈហេតុផ្សេងៗដូចជា តួអង្គទេវៈ ខ្មោចយក្ខ អារក្ស អ្នកតា ឬមនុស្សមានមន្តអាគមខ្លាំងពូកែ (ចេះហោរហើរ កាប់មិនមុតដុតមិនឆេះ) យកមកនិទាន ។

សម័យកាលនោះ មនុស្សហាក់បីដូចជាអស់សង្ឃឹមក្នុងជីវិត ហើយប្រើមនោគតិជឿទៅលើហេតុផលអស្ចារ្យដែលខ្លួនយល់ថាពូកែ អាចជួយរំដោះទុក្ខលំបាក ឬបញ្ហាស្មុគស្មាញរបស់ខ្លួនក្នុងបច្ចុប្បន្ននិងអនាគតជាតិ ។ ក្នុងន័យនេះ គេយកទស្សនៈកម្មផល(ព្រះពុទ្ធសាសនា) មកធ្វើជាបញ្ហាចោទ និងស្រាយក្នុងអត្ថន័យនៃអត្ថបទរឿងជាច្រើននាសម័យឧដុង្គ ។

ការកើតមាននូវ**បញ្ហាកម្មផល** ជាមូលហេតុក្នុងរឿងនៃអក្សរសាស្ត្របែបនេះ បុព្វហេតុគឺមកពីការភិតភ័យលំបាកវេទនារបស់ប្រជាពលរដ្ឋ ដោយសារស្រុកទេសកើតចម្បាំងរាំងជល់ ដែលបង្កឡើងដោយពួកសត្រូវឈ្លានពាន ប្លន់ទឹកដីខ្មែរនាសម័យឧដុង្គ ដើម្បីរំសាយនូវទុក្ខសោករោគភ័យ ដែលញាំញីក្នុងសន្តានចិត្តរបស់ខេមរជន ។ ចំពោះហេតុការណ៍នេះ អ្នកនិពន្ធបានរិះរកមធ្យោបាយមួយ ដើម្បីព្យាបាលនោះ គឺ**ឱសថ**(ភាពអស្ចារ្យ) និង(បញ្ហាកម្មផល) ដើម្បីជួយអ្នករងគ្រោះ ដូចជា តួអង្គព្រះពោធិសត្វ(បញ្ហាកម្មផល) ដោយយកទស្សនៈបាប បុណ្យ ល្អ អាក្រក់ សុខ ទុក្ខ មកធ្វើជាគោលបញ្ហាដោះស្រាយ ឧទាហរណ៍ អ្នកណាធ្វើល្អបានល្អ អ្នកណាធ្វើអាក្រក់បានអាក្រក់ជាដើម ។

ឯរង្វាន់ផ្តល់ចំពោះមនុស្សល្អ គេបានបង្កើតឋានសួគ៌ ឋានទេវលោក សម្រាប់លើកទឹកចិត្ត ហើយដើម្បីផ្តន្ទាទោសចំពោះមនុស្សអាក្រក់ គេក៏បង្កើតឋាននរកប្រែត សម្រាប់បំភ័យឱ្យអនុជនខ្លាច ស្អប់អកុសលកម្ម ហើយខិតខំ

[18] ពាក្យអធិប្បាយសេចក្តីឱ្យងាយយល់ ។

ធ្វើអំពើល្អ។ គ្រប់អត្ថបទអក្សសិល្ប៍នៅសម័យឧដុង្គអ្នកនិពន្ធមានទិសដៅសម្រាលទុក្ខសោករបស់ប្រជាពលរដ្ឋឱ្យ មានសភាពធូរស្រាល និងមានសង្ឃឹមក្នុងធាកជីវិតរស់នៅ។

ខ- អត្ថរូបនៃអត្ថបទ

វិធីតាក់តែងអត្ថបទសម័យឧដុង្គ គេបានប្រើពាក្យកាព្យជាមធ្យោបាយ។ អត្ថបទអក្សរសិល្ប៍រចនាឡើងជា កំណាព្យមានបទផ្សេងៗគ្នា (បទកាកគតិ ព្រហ្មគីតិ ពំនោល ជាដើម) នោះ ជាមធ្យោយសម្របសម្រួលទៅតាម គោលបំណងក្នុងឧត្តមគតិរឿង ដែលបំពេញអារម្មណ៍ បន្ធូរក្តីទុក្ខព្រួយឱ្យរសាយ ។

របៀបតែងមានដូចខាងក្រោមនេះ៖

សេចក្តីផ្តើម: ជាបទនមស្ការ ព្រះរតនត្រ័យ រំលឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំលឹកគុណព្រះមហាក្សត្រ មាតាបិតា គ្រូបាធ្យាយជាដើម ។ ឯកសារខ្លះមានបញ្ជាក់កាលបរិច្ឆេទនៃការតាក់តែងរបស់អ្នកនិពន្ធ ។ ឆ្នាំដែលគេ ប្រើ ច្រើនជាពុទ្ធសករាជ មហាសករាជ ហើយមានប្រាប់ឈ្មោះងារស័ក្តិលំនៅដ្ឋានរបស់អ្នកនិពន្ធ។ ស្នាដៃខ្មែរទៀត មានបញ្ជាក់ពីប្រភពរឿង ដែលអ្នកនិពន្ធបានដកស្រង់យកមកតាក់តែងរចនា។ ប៉ុន្តែរឿងមួយភាគធំ បែរជាពុំមាន ឬ បាត់នូវកាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធជាដើម ។

គួរសេចក្តី អ្នកនិពន្ធច្រើនប្រើភាសាបាលី មគធភាសា ឬសំស្ក្រឹត ទៅតាមចំណេះដឹងរបស់អ្នកនិពន្ធ ក្នុងការ តាក់តែងរៀបរៀងរឿង។ ដំណើររឿងជឿលើបញ្ហាកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។

បញ្ចប់សេចក្តី អ្នកនិពន្ធបញ្ចប់រឿង ដោយធ្វើការឧទ្ទិសប្រាថ្នាកុសលបែបអធិដ្ឋាន ឬការសរជាតិ (ដំណើរ រឿងមានប្រភពពីព្រះពុទ្ធសាសនា) ។

គ- អត្ថរសនៃអត្ថបទ

ដោយដំណើររឿង ជារឿងសម្រាលទុក្ខប្រជាពលរដ្ឋ ដូច្នេះរឿងត្រូវមានភាពអស្ចារ្យ អច្ឆរិយៈ(អច្ឆរិយរស) ធម្មតា(សាមញ្ញរស) កំសត់(ទារុណរស) កំប្លែង (ហាសរស) ដែលជាលក្ខណៈទ្រទ្រង់នៃអត្ថរសទូទៅរបស់អត្ថបទ ។

ឃ. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អក្សរសិល្ប៍ខ្មែរនាសម័យឧដុង្គមានការរីកចម្រើនឡើងវិញ គឺដោយសារតែព្រះមហាក្សត្រ នាម៉ឺនសព្វមុខមន្ត្រីគ្រប់ជាន់ថ្នាក់បានយកព្រះទ័យ និងយកចិត្តទុកដាក់ជាខ្លាំងទៅលើវិស័យនេះ ។ បើទោះបីជាអ្នក និពន្ធតាក់តែងប្រឌិតរឿងតាមលក្ខណៈអណ្តែតអណ្តូងនិយមយ៉ាងណាក៏ដោយ ក៏វាមានតម្លៃយ៉ាងពិតប្រាកដមួយ ដែរ ព្រោះតាមរយៈស្នាដៃទាំងនេះហើយ ដែលបានជួយលើកស្ទួយអក្សរសាស្ត្រជាតិឱ្យស្ថិតនៅរហូតដល់សព្វថ្ងៃ ។ ម្យ៉ាងវិញទៀត ទោះបីជាស្នាដៃទាំងនោះ បានទទួលឥទ្ធិពលពីសាសនាក៏ដោយ ក៏ដំណើររឿងបានបង្ហាញពីជីវភាព រស់នៅជាក់ស្តែងរបស់សង្គមមនុស្សដូចជា៖ បញ្ហាស្នេហា បញ្ហាកិត្តិយស បញ្ហាផិតក្បត់ បញ្ហាច្រណែនឈ្នានីស ជា ដើម ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះគឺ ស្នាដៃអក្សរសិល្ប៍នាសម័យឧដុង្គ បានដល់នូវចំណេះដឹងខាង ផ្នែកអប់រំតាមបែបព្រះពុទ្ធសាសនា ដោយផ្តោតទៅលើបញ្ហាកម្មផល បុណ្យ និងបាប ដែលបុគ្គលម្នាក់ៗបានធ្វើឡើង។

ដូច្នេះដៃអក្សរសិល្ប៍សម័យឧដុង្គ គឺពិតជាមានសារប្រយោជន៍ និងបានចូលរួមចំណែកក្នុងការទ្រទ្រង់វិស័យ អក្សរសាស្ត្រជាតិឱ្យឆ្ពោះទៅរកវឌ្ឍនភាពយ៉ាងពិតប្រាកដ ។

៤. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម

ដោយយោងទៅលើអត្ថន័យរបស់រឿង និងកាលបរិច្ឆេទតែង គេចែកអក្សរសិល្ប៍ពុទ្ធនិយមជាពីរប្រភេទគឺ៖ អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ។

៤.១. អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ

រឿងពុទ្ធនិយមសុទ្ធសាធ គឺសំដៅលើរឿងទសជាតក ឬរឿងនានាជាតក ដែលដំណើររឿងទាក់ទងនឹងទស្សនៈគោលសំខាន់ៗក្នុងព្រះពុទ្ធសាសនា ដោយអ្នកនិពន្ធលើកយករឿងបុណ្យ បាបកម្មផលល្អអាក្រក់របស់តួអង្គមកចោទ និងដោះស្រាយ ។ រឿងទាំងឡាយត្រូវបានរៀបរៀងឡើងជាភាសាបាលី តែក្រោយមកមានសម្រាយជាខេមរភាសា មានសរសេរជាពាក្យកាព្យ ។ ចំពោះអត្ថបទសរសេរជាពាក្យរាយគេច្រើន សរសេរឱ្យឈ្មោះថា រឿងជាតកឬគម្ពីរជាតក គម្ពីរទសជាតក គម្ពីរបញ្ញាសជាតក គម្ពីរនានាជាតកជាដើម ។ រឿងក្នុងជាតក គឺជារឿងរបស់ព្រះពុទ្ធអង្គ កាលកំពុងវិលអន្លោលយកកំណើតក្នុងបុព្វជាតិ ដើម្បីត្រាស់ដឹង ដើម្បីស្រង់សត្វលោក ដែលស្ថិតក្នុងវាលវដ្តសង្សារ។ រឿងក្នុងទសជាតកជារឿងដែលព្រះពោធិសត្វកសាងបារមីដូចជា ៖

- រឿង តេមិយជាតក បំពេញ នេក្ខកម្មបារមី
- រឿង មហាជនក បំពេញ វិរិយបារមី
- រឿង សុវណ្ណសាម បំពេញ មេត្តាបារមី
- រឿង នេមិរាជ បំពេញ អធិដ្ឋានបារមី
- រឿងមហោសថជាតក បំពេញ បញ្ញាបារមី
- រឿងភូរិទត្តជាតក បំពេញ សីលបារមី
- រឿងចន្ទកុមារជាតក បំពេញ ខន្តីបារមី
- រឿងនារទជាតក បំពេញ ឧបេក្ខាបារមី
- រឿងវិធុរជាតក បំពេញ សច្ចៈបារមី
- រឿង ព្រះវេស្សន្តរ បំពេញ ទានបារមី

ក្នុងការបែងចែកលំដាប់នៃការបំពេញបារមីនៃអង្គពោធិសត្វ ក្នុងវចនានុក្រមសម្តេចជួនណាតបានបង្ហាញថាទសបារមី[19] ឬបារមី ១០ គឺចរិយាដ៏លើសលន់ ឬគុណជាតិដ៏ល្អ ដែលគួរបំពេញមាន ១០ យ៉ាងគឺ ៖

- ទានបារមី ៖ ការធ្វើអំណោយ
- សីលបារមី ៖ ការរក្សាកាយវាចាឱ្យបរិសុទ្ធប្រពៃ
- នេក្ខម្មៈបារមី ៖ ការចេញចាកកាម គឺចេញបួស
- បញ្ញាបារមី ៖ ការដឹងច្បាស់នូវសេចក្តីពិត
- វិរិយៈបារមី ៖ ព្យាយាម
- ខន្តីបារមី ៖ សេចក្តីអត់ធន
- សច្ចៈបារមី ៖ ការកាន់សំដីពិតមិនរើរុះ
- អធិដ្ឋានបារមី ៖ ការអធិដ្ឋានឲ្យឃើញជាក់ស្តែងតាមហេតុពិត

[19] សម្តេច ជួន ណាត, វចនានុក្រមខ្មែរ ១៩៦៧

- មេត្តាបារមី ៖ ការផ្សាយសេចក្តីរាប់អានចំពោះសព្វសត្វមិនរើសមុខ
- ឧបេក្ខាបារមី ៖ ដំណើរតាំងចិត្តដើយព្រងើយដោយស្មោះស្មើ ។

បារមីទាំង ១០ នេះឯងដែលពោធិសត្វរាល់ព្រះអង្គបំពេញឱ្យបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ។

៤.២. អក្សរសិល្ប៍ពុទ្ធនិយមភ្លាយ

រឿងពុទ្ធនិយមភ្លាយចែកជាពីរ[20]៖ ពុទ្ធនិយមភ្លាយធម្មតា និងពុទ្ធនិយមភ្លាយហួសហេតុ(ផ្លូម)។

ក. រឿងពុទ្ធនិយមភ្លាយធម្មតា : ជាអត្ថបទដែលទាក់ទងនឹងទស្សនៈក្នុងព្រះពុទ្ធសាសនាតិចតួចហើយរឿងទៀតសោតពុំស្ថិតក្នុងគម្ពីរត្រឹមត្រូវជាពុទ្ធវចនៈ(ក្នុងគម្ពីរព្រះត្រៃបិតក) ដូចជារឿងទសជាតកឡើយ ។ អត្ថបទរឿងបែបពុទ្ធនិយមភ្លាយច្រើនស្ថិតក្នុងគម្ពីរបញ្ញាសជាតក(៥០ជាតិ) មាន៥០រឿង ។ បញ្ញាសជាតករបស់ខ្មែរមាន[21]៖

១-សមុទ្ទឃោសៈ	២-សុធនកុមារ	៣-សុធនុកុមារ	៤-រតនប្បជោត	៥-សិរីវិបុលកិត្តិ
៦-វិបុលរាជ	៧-សិរិចូឌាមណី	៨-ចន្ទរាជ	៩-សុភមិត្រ	១០-សិរិធរសេដ្ឋី
១១-សព្វសិទ្ធិ	១២-ទុលភបណ្ឌិត	១៣-អាទិត្តរាជ	១៤-ទុកម្មានិក	១៥-មហាសុរសេន
១៦-កនកវណ្ណរាជ	១៧-វិរិយបណ្ឌិត	១៨-ធម្មសោណ្ឌក	១៩-សុទស្សមហារាជ	២០-វត្តង្គលីរាជ
២១-បោរាណកបិលរាជ	២២-ធម្មិកបណ្ឌិតរាជ	២៣- ចាគទាន	២៤-ធម្មរាជ	២៥-នរជីវៈ
២៦-សុរូប	២៧-មហាបទុម	២៨-កណ្ហាការ	២៩-ពហុលគាវី	៣០-សេតបណ្ឌិត
៣១-បុប្ផរាជ	៣២-ពារាណសិរាជ	៣៣-ព្រហ្មយោសរាជ	៣៤-ទេវរុក្ខកុមារ	៣៥-សលកៈ
៣៦-សោនន្ទ	៣៧-ទេវន្ទ	៣៨-នរជីវកបិន	៣៩-រថសេន	៤០-វរនេវរនុជ
៤១-សង្ខបត្ត	៤២-សព្វសិទ្ធិ	៤៣-សិសោរាជ	៤៤-សុបិនកុមារ	៤៥-សុបិនកុមារ
៤៦-សុវណ្ណកច្ឆបៈទី១	៤៧-សុវណ្ណកច្ឆបៈទី២	៤៨-សុវណ្ណវង្ស	៤៩-សុរវង្សវរវង្ស	៥០-អតិទេវរាជ

ខ. រឿងពុទ្ធនិយមភ្លាយហួសហេតុ : ស្នាដៃប្រភេទនេះពុំមាននៅក្នុងគម្ពីរក្បួនខ្នាតពីបុរាណណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធត្រាន់តែថាប៉ុណ្ណោះ ពុំមានដំណើររឿងដូចគ្នាបេះបិទឡើយ ។ ដំណើររឿងមានគោលគំនិតទាក់ទងនឹងពុទ្ធទស្សនៈតែបន្តិចបន្តួច ចំណែកឯតួអង្គនៃរឿងច្រើនមានសកម្មភាពប្រកបដោយគុណវិបត្តិហួសហេតុ រហូតដល់មនុស្សធម្មតាធ្វើមិនកើត ហើយរឿងពុំមានការកសាងបារមីអ្វីមួយច្បាស់លាស់ឡើយ តែទោះជាតួអង្គធ្វើអំពើខុសយ៉ាងណាក្តី លុះដល់ចប់រឿងមានការសជាតិ អ្នកនិពន្ធប្រារព្ធថា តួអង្គនោះជាព្រះពោធិសត្វ។ អក្សរសិល្ប៍ប្រភេទនេះច្រើនជាសាស្ត្រាល្បែង ដែលកើតនៅសតវត្សរ៍ទី១៨ ឬទី១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ដូចជា៖

- រឿងក្រុងសុភមិត្រ និពន្ធដោយ កោសាធិបតីកៅ ១៧៩៨
- រឿងកោគកុលកុមារ និពន្ធដោយ ឧកញ៉ាព្រះឃ្លាំងនង ១៨០៤
- រឿងកាកី និពន្ធដោយ ព្រះបាទអង្គឌួង ១៩១០
- រឿងមរណមាតា និពន្ធដោយ ឥន្ទបញ្ញាអ៊ុក ១៨៧៧

[20] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២, ទំព័រទី៩៧, ២០១៦

[21] ក្រសួងអប់រំ, សៀវភៅគ្រូ ភាសាខ្មែរ ថ្នាក់ទី១០, ទំព័រទី៧៣,២០១២

៥. លក្ខណៈសម្គាល់នៃអក្សរសិល្ប៍ពុទ្ធនិយម

៥.១. វិធីតែងនិពន្ធ

ក.ផ្នែកអត្ថន័យ

អត្ថន័យរឿងច្រើនទាក់ទងនឹងការកសាងបារមីរបស់តួអង្គព្រះពោធិសត្វ ទាក់ទងនឹងជំនឿកម្មផល ។

ខ.បញ្ហាចោទ និងដោះស្រាយ

បញ្ហាចោទស្ថិតនៅលើទំនាស់រវិលត្តិរវាងព្រះពោធិសត្វ និង ទ្រព្យសម្បត្តិ រវាងទ្រពសម្បត្តិ និង បិតា ភរិយា ដើម្បីផ្តាច់លោភៈ ទោសៈ មោហៈ និង ស្នេហា រវាងទ្រព្យសម្បត្តិ និង ប្រជាពលរដ្ឋ។ដំណោះស្រាយបញ្ហានៅក្នុងរឿងគឺតាមបែបសន្តិវិធី អហិង្សា ។ បង្ហាញពីស្នេហាស្មោះត្រង់រវាងពោធិសត្វ និងកន្សែសារពេជ្ជ ។ នៅទីបញ្ចប់ពោធិសត្វទទួលជ័យជំនះ បានជួបជុំគ្រួសារឡើងសោយរាជ្យ ត្រូវបានមហាជនគោរព និង សរសើរចំពោះបារមីរបស់ព្រះអង្គ។

គ.ផ្នែករូបភាព

មានលក្ខណៈ ឯកភាពគ្នាដូចតទៅ :

គ.១-ផ្តើមរឿង

អ្នកនិពន្ធច្រើនចាប់ផ្តើមរឿងដោយធ្វើបទនមសការគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និង ការនឹកគុណដល់មាតា បិតា គ្រូបាធ្យាយ ។

គ.២.តួរឿង ឬ ដំណើររឿង

ជាការបរិយាយប្រៀបបាននឹងធម៌ទេសនារបស់ព្រះពុទ្ធអង្គចំពោះភិក្ខុសង្ឃ ពុទ្ធបរិស័ទទាំងឡាយ ដើម្បីមើលឃើញពីការកសាងបារមីរបស់ព្រះអង្គដ៏ស្ងិតស្ងាញក្នុងអនេកជាតិ ។ ច្រើនបំពេរចិត្តគំនិតពុទ្ធសាសនិកឱ្យជឿបុណ្យបាប ខ្លាចអំពើអាក្រក់ ។ ប័រលោយឡំរវាងពុទ្ធចក្រ និង ចក្រ ។

- តួអង្គក្នុងអក្សរសិល្ប៍ពុទ្ធនិយម : តួអង្គឯកប្រុសជាពោធិសត្វ តួអង្គឯកនារីជាកន្សែសារពេជ្ជដែល ជាគូរបស់ព្រះពោធិសត្វ ។
- កាលអាកាស : ច្រើនប្រព្រឹត្តទៅក្នុងនគរពារាណសី សាវត្ថី ស្រុកស្រីពិរាស្ត្រ កលិង្គរាស្ត្រ លង្កា ព្រៃហេមពាន្ត ..ពោលគឺនៅប្រទេសឥណ្ឌា ។

គ.៣.បញ្ចប់រឿង

បញ្ចប់ដោយការសរជាតិ ឱ្យតួអង្គពោធិសត្វសំរេចជោគជ័យក្នុងសកម្មភាពអ្វីមួយរដោយការលើកសរសើរប្រសិទ្ធពរចំពោះការបំពេញកុសលកម្ម រក្សាសីលរហូតអស់ជន្មាយុ រួចទៅកើតក្នុងស្ថានេតុសិតទេវលោកសោយសម្បត្តិទិព្វ សុខក្សេមក្សាន្ត ។

៥.២.គោលគំនិតអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍ពុទ្ធនិយម បានបង្កប់នូវតម្លៃអប់រំយ៉ាងជ្រាលជ្រៅក្នុងការដុសខាត់ចិត្តគំនិតមនុស្សសង្គមខ្មែរ ឱ្យប្រព្រឹត្តនូវអំពើល្អស្រឡាញ់នូវគុណធម៌ ស្រឡាញ់សុខសន្តិភាព គ្មានការប្រកាន់វណ្ណៈ មិនមានការលោភលន់ ជាពិសេស រួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិគ្រប់វិស័យទាំងអស់។ ខាងក្រោមនេះ យើងសូមលើកយកទស្សនៈអប់រំសំខាន់ៗ ក្នុងអក្សរសិល្ប៍ពុទ្ធនិយមដូចតទៅ ៖

ក. អប់រំឱ្យជឿលើទស្សនៈកម្មផល

គ្រប់ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម នៅក្នុងដំណើររឿងតាំងពីដើមដល់ចប់ អ្នកនិពន្ធបានបង្ហាញពីទស្សនៈកម្មផល ពោលគឺធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ហើយកម្មនេះវាផ្តល់ឲ្យអ្នកប្រព្រឹត្តក្នុងអតីតជាតិ បច្ចុប្បន្នជាតិ និងអនាគតជាតិ។ ទស្សនៈនៃព្រះពុទ្ធសាសនា បានអប់រំមនុស្សឲ្យប្រព្រឹត្តអំពើល្អគ្រប់បែបយ៉ាង ដែលគំនិតនោះ វាជួយឲ្យមនុស្សរស់នៅក្នុងសុខសន្តិភាពគ្មានអំពើហិង្សា។

ខ. អប់រំកាយ វាចា និងចិត្ត

លទ្ធិព្រះពុទ្ធសាសនា ក៏ដូចជាអក្សរសិល្ប៍ពុទ្ធនិយមដែរ គឺបានបណ្តុះទឹកចិត្តពុទ្ធសាសនិកគ្រប់រូបឱ្យប្រព្រឹត្តល្អទាំងកាយ និងវាចាចិត្ត[22]។

គ. អប់រំឱ្យស្រឡាញ់សន្តិភាព

ក្នុងទ្រឹស្តីពុទ្ធសាសនាក្តី អក្សរសិល្ប៍ពុទ្ធនិយមក្តី អ្នកនិពន្ធនៅសម័យនោះ បានប្រើវិធីដោះស្រាយទំនាស់ដោយអហិង្សាដើម្បីឱ្យពុទ្ធបរិស័ទ និងអ្នកសិក្សារៀនសូត្រអនុវត្តតាម។ ជាពិសេស អប់រំមនុស្សឱ្យជៀសវាងនូវការប្រព្រឹត្តអំពើមិនល្អសព្វបែបយ៉ាង ដែលជាមាគ៌ាដឹកនាំមនុស្សឆ្ពោះទៅរកសុភមង្គល។ រាល់ដំណោះស្រាយបញ្ហាក្នុងអក្សរសិល្ប៍ពុទ្ធនិយម សុទ្ធតែដោះស្រាយដោយអហិង្សាឬដោយសន្តិភាព និងវៀរចាកអំពើបាបឈ្លានពានគ្រប់បែបយ៉ាង។ឥទ្ធិពលនេះបានអប់រំឲ្យជនជាតិខ្មែរមានចិត្តស្រឡាញ់សន្តិភាពគ្មានគំនិតឈ្លានពានអ្នកដទៃ[23]។

ឃ. អប់រំមនុស្សឲ្យចេះសន្តោសប្រណី និងធ្វើទាន

តាមរយៈរឿងពុទ្ធនិយមសុទ្ធសាធ (ទសជាតក) និងពុទ្ធនិយមក្លាយ (បញ្ញាសជាតក) បានបណ្តុះទឹកចិត្តមនុស្សឱ្យមានព្រហ្មវិហារធម៌ចំពោះគ្នា ចេះចែករំលែកសេចក្តីសុខ មតិយោបល់ និងទ្រព្យសម្បត្តិដល់ជនក្រីក្រ ដើម្បីគ្នាមានលទ្ធភាពរស់នៅបានសុខស្រួលដូចគ្នានៅក្នុងសង្គមដែរ។ តាមរយៈរឿងព្រះតេមិយ រឿងសុវណ្ណសាម រឿងព្រះវេស្សន្តរ...អ្នកនិពន្ធបានឆ្លុះបញ្ចាំងពីបញ្ហាទាំងនោះ ដូចជាការធ្វើទាន មេត្តាករុណា ក៏យើងសង្កេតឃើញប្រជាពលរដ្ឋខ្មែរនៅតាមភូមិស្រុកចេះជួយសង្គ្រោះគ្នាទៅវិញទៅមក នៅពេលនរណាម្នាក់ ឬក្រុមគ្រួសារណាមួយជួបប្រទះនូវការងារដ៏លំបាកលំបិនណាមួយដូចជាការសង់ផ្ទះ រំលាយសព[24]។

ង. អប់រំគំនិតមិនឱ្យមានគំនិតលោភលន់

តណ្ហា ដែលជារងើកភ្លើងទ្រទ្រង់នូវចំណង់ឲ្យចង់មាន ចង់បានហួសហេតុ និងជាប្រភពនាំឱ្យវិនាសដល់ទ្រព្យសម្បត្តិសុភមង្គលនិងអាយុជីវិតផ្ទាល់ខ្លួន ឬក្រុមគ្រួសារទៀតផង។ តាមរយៈរឿងព្រះតេមិយ រឿងព្រះវេស្សន្តរ តួអង្គព្រះពោធិសត្វ សុទ្ធតែបានពិចារណាយ៉ាងល្អិតល្អន់ គឺមិនលោភលន់នឹងអំណាចទ្រព្យសម្បត្តិបន្តិចសោះឡើយ។ គំរូល្អប្រពៃនេះ ក៏បានអប់រំ និងជួយបន្ធូរបន្ថយដល់ទឹកចិត្តលោភលន់របស់មនុស្សសាមញ្ញទាំងឡាយ កុំឱ្យភ្លើតភ្លើនទៅតាមតណ្ហា[25]។

---

[22] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥១ (១៩៩៤)

[23] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥២ (១៩៩៤)

[24] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥៣ (១៩៩៤)

[25] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥៣ (១៩៩៤)

ច. អប់រំឱ្យអត់ធ្មត់ និងព្យាយាម

អ្នកកាន់ពុទ្ធសាសនា ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវអក្សរសិល្ប៍បានទទួលនូវចំណេះដឹងផ្លូវចិត្តឱ្យចេះអត់ធ្មត់ តស៊ូព្យាយាមគ្រប់ការងារលំបាកលំបិនទាំងអស់ ដើម្បីដណ្តើមយកជ័យជម្នះលើខ្លួនឯង ក៏ដូចជាអ្នកដទៃ។ ក្នុងរឿងមហាជនក ព្រះបាទជនកបានតស៊ូព្យាយាមហែលទឹកសមុទ្រដ៏ធំធេងល្វឹងល្វើយរហូតដល់ទេពធីតារក្សាមហាសាគរនាងមណីមេខលាជួយស្រោចស្រង់រួចពីសេចក្តីស្លាប់។ នៅទីបំផុតព្រះបាទជនកបានឡើងគ្រងរាជ្យសម្បត្តិ នគរមិថិលា ដោយសារតែការតស៊ូព្យាយាមរបស់ព្រះអង្គ។រឿងព្រះវេស្សន្តរ ព្រះពោធិសត្វ បានធ្វើបុណ្យដាក់ទានដល់ជនក្រីក្រនូវទ្រព្យសម្បត្តិសព្វបែបយ៉ាង អាយុជីវិតកូនប្រពន្ធប្រយោជន៍បានគ្រាស់ដឹងជាព្រះពុទ្ធ។ ការដាក់ទាន ដំរីបច្ចយនាគេន្ទ្រ ដល់នគរកលិង្គរាស្ត្រ ដែលគ្មានទឹកភ្លៀង ត្រូវអ្នកស្រុកស្រីពិរាស្ត្រក្តៅក្រហាយបណ្តេញព្រះអង្គចេញពីនគរ ពីព្រោះតែពួកគេមិនទាន់មានទឹកចិត្តទូលំទូលាយ និងប្រកាន់ជាតិសាសន៍ខ្លាំងពេក។ ទោះបីជាត្រូវប្រជារាស្ត្របណ្តេញចេញពីនគរយ៉ាងនេះក្តី នៅតាមផ្លូវព្រះអង្គនៅតែព្យាយាមដាក់ទានទ្រព្យសម្បត្តិ ឱ្យជនក្រីក្រនៅក្នុងព្រៃ ព្រះអង្គដាក់ទានកូន និងប្រពន្ធដល់តាជូកជក និងឥន្ទ្រព្រាហ្មណ៍ដើម្បីបានគ្រាស់ដឹង។ តាមរយៈសកម្មភាពរបស់តួអង្គព្រះពោធិសត្វ ក្នុងការតស៊ូព្យាយាមដើម្បីធ្វើអំពើល្អនេះ បានជះឥទ្ធិពលដល់សតិអារម្មណ៍ពុទ្ធសាសនិកយ៉ាងខ្លាំង ឱ្យអនុវត្តតាមជាច្រើនសម័យកាលមកហើយ។

ឆ. អប់រំឱ្យចេះត្រិះរិះពិចារណា

អក្សរសិល្ប៍ពុទ្ធនិយម អ្នកនិពន្ធក៏បានប្រើប្រាស់ពាក្យពេចន៍សម្រាប់អប់រំជាច្រើននៅក្នុងដំណើររឿងឱ្យពុទ្ធបរិស័ទអ្នកគោរពប្រណិប័តន៍ទាំងអស់ ធ្វើការពិចារណាឲ្យបានល្អិតល្អន់។ ដៀសវាងការជឿងប់ងល់ខ្លាំង ធ្វើឱ្យធ្លាក់ខ្លួនក្រដោយសារមានបាបកម្ម សូម្បីតែចិញ្ចឹមមាន់ទា ក៏មិនឲ្យប្រកបដែរ។ ការដែលមនុស្សចេះគិតពិចារណាយកបញ្ញាជាអាវុធ និងធ្វើឱ្យពួកគេរស់នៅបានយ៉ាងសុខស្រួល គ្មានការបៀតបៀនពីអ្នកដទៃហើយមានជីវភាពធូរធារទៀតផង។ ក្នុងរឿងមហោសថជាតកព្រះអង្គបានកសាងបារមីបញ្ញាពេញមួយជីវិត ហើយព្រះអង្គអាចដោះស្រាយប្រាជ្ញារបស់អាចារ្យទាំងបួននាក់ ធ្វើឱ្យព្រះអង្គរួចផុតពីបំណងអាក្រក់ និងមានបារមីលើសគេឯង រហូតដល់សព្វថ្ងៃអ្នកណាក៏ប្រាថ្នាចង់បានប្រាជ្ញាឈ្លាសវៃដូចព្រះមហោសថដែរ។

៥.៣. សន្និដ្ឋាន

ដូចនេះ អក្សរសិល្ប៍ពុទ្ធនិយមអប់រំមនុស្សឲ្យយល់ដឹងអំពីទស្សនៈកម្មផលមកដោះស្រាយសេចក្តីសុខទុក្ខ យកធម៌ខន្តីមកទប់ទល់ និងការវេទនាលំបាកយកលទ្ធិសន្តិភាពនិយមមកដោះស្រាយទំនាស់តាមពុទ្ធសាសនា។ អក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតសំខាន់សម្រាប់អប់រំប្រជាពលរដ្ឋ ដែលជាពុទ្ធសាសនិកជនទាំងអស់គ្នាឱ្យធ្វើល្អគ្រប់បែបយ៉ាង ទាំងកាយវាចាចិត្ត វៀរចាកអំពើអាក្រក់ទាំងឡាយ។ អក្សរសិល្ប៍ពុទ្ធនិយមជាផ្នែកមួយនៃអក្សរសិល្ប៍ជាតិ ដែលជាមធ្យោបាយមួយដ៏សំខាន់ក្នុងការអប់រំប្រជាពលរដ្ឋខ្មែរយើងឱ្យប្រព្រឹត្តអំពើល្អគ្រប់បែបយ៉ាង មានសណ្តាប់ធ្នាប់សមសួន និង មានប្រពៃណីល្អប្រសើរសក្តិសមជាពលរដ្ឋដែលគោរពព្រះពុទ្ធសាសនា និង មានអរិយធម៌ខ្ពស់។ អក្សរសិល្ប៍ពុទ្ធនិយមត្រូវតែមានតួនាទីសមស្របនៅក្នុងកម្មវិធីសិក្សាក្នុងសាលារៀននាពេលបច្ចុប្បន្ន ។

៦. ឥទ្ធិពលពុទ្ធសាសនាក្នុងសង្គម

៦.១. ប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយម

អរិយធម៌ខ្មែរ មានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេសគឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។ ចលនាអក្សរសិល្ប៍បែបពុទ្ធនិយមមានរូបសេចក្តី និងសណ្ឋាន ដែលដកស្រង់ពីប្រភពនៃគម្ពីរព្រះត្រៃបិដក។ ពោល គឺការយកគោលគំនិត និងទស្សនវិជ្ជាព្រះពុទ្ធសាសនា មកឆ្លុះបញ្ចាំងក្នុងស្នាដៃអក្សរសិល្ប៍៖ ១. វិន័យបិដក(ព្រះវិន័យ) ២.សុត្តន្តបិដក (ព្រះសូត្រ)៣.អភិធម្មបិដក(ព្រះអភិធម្ម)។[26]

ព្រះត្រៃបិដក ជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈ ដែលមាន៨៤ ០០០ធម្មក្ខន្ធ ចែកចេញជាគម្ពីរ៣[27]សំខាន់គឺ៖

- វិន័យបិដក មាន៥ គម្ពីរ ចែកជា ១៣ភាគ មាន២១ ០០០ធម្មក្ខន្ធ
- សុត្តន្តបិដកមាន៥គម្ពីរ ចែកជា៦៤ភាគ មាន២១ 000ធម្មក្ខន្ធ និង
- អភិធម្មបិដកមាន៧គម្ពីរ ចែកជា៣៣ភាគ មាន៤២ ០០០ធម្មក្ខន្ធ ។

៦.២. ឥទ្ធិពលនៃលទ្ធិព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

ក. ទិស័យនយោបាយ គ្រប់គ្រង និងដឹកនាំប្រទេស

ក្នុងសម័យអានានិគមនិយមបារាំង ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងនយោបាយរក្សាពូជសាសន៍ឱ្យមានលក្ខណៈ និង អត្តសញ្ញាណជាតិដោយប្រកាន់ខ្ជាប់នូវទំនៀមទំលាប់ប្រពៃណី និង វប្បធម៌របស់ជាតិ។ ឥទ្ធិពលលើវិស័យនយោបាយ ការគ្រប់គ្រង និងដឹកនាំប្រទេសរបស់ព្រះពុទ្ធសាសនា នាសម័យនោះជាឧបសគ្គដល់នយោបាយរំលាយវប្បធម៌ខ្មែរយើងរបស់ពួកបារាំង ។

ដល់សម័យសង្គមរាស្ត្រនិយម សម្តេចនរោត្តម សីហនុគ្រប់គ្រងប្រទេសជាតិដោយផ្សារភ្ជាប់ទាំងស្រុងទៅនឹងព្រះពុទ្ធសាសនា ។ ព្រះអង្គតែងតែសុំយោបល់ពីសម្តេចព្រះសង្ឃរាជទាំងពីរគណៈ។ ដោយសារនយោបាយដ៏ប្រសើរនេះ ព្រះពុទ្ធសាសនាបានចូលរួមយ៉ាងសកម្មក្នុងការកសាងជាតិនាសម័យនោះ ធ្វើឱ្យមានការរីកចំរើន និងទទួលបានឈ្មោះថា ជាកោះសន្តិភាព ។

ខ. ទិស័យវប្បធម៌

- **អប់រំចិត្តគំនិត** ៖ ព្រះពុទ្ធសាសនាអប់រំមនុស្សខ្មែរឱ្យមានចិត្តស្លូតបូត សុភាពរាបសារ ប្រកាន់អកប្បកិរិយាស្រឡាញ់សន្តិភាព អប់រំមនុស្សឱ្យមានមេត្តា ករុណា ចេះធ្វើទាន ជៀសវាងហិង្សា ។
- **ភាសា** : ព្រះពុទ្ធសាសនាបាននាំភាសាសំស្ក្រឹត និង បាលីបញ្ចូលក្នុងភាសាជាតិខ្មែរយើង ។ នៅសម័យអង្គរ ភាសាសំស្ក្រឹត និង បាលីត្រូវបានគេចាត់ទុកជាភាសាផ្លូវការ និង ថ្លៃថ្នូរ ។
- **អក្សរ** : អក្សរដែលខ្មែរយើងប្រើសព្វថ្ងៃនេះមានប្រភពមកពីអក្សរសំស្ក្រឹត ដែលយកតាមលំនាំអក្សរព្រាហ្មី ។
- **អក្សរសាស្ត្រ អក្សរសិល្ប៍** : រហូតមកដល់ពេលនេះអក្សរសិល្ប៍ខ្មែរយើងចែកចេញជា៣ចលនា ដែលមានចលនាអក្សរសិល្ប៍ពុទ្ធនិយមផងដែរ ។
- **ផ្នែកអប់រំផ្តល់ចំណេះដឹង** : នៅសម័យមុន១ វត្តអារាមជាសាលាពហុបច្ចេកទេស ។ ឪពុកម្តាយត្រូវនាំកូនទៅផ្ញើព្រះសង្ឃ ។ កាលបើរៀនសូត្រចេះអក្សរ និង លេខនព្វន្តខ្លះហើយ កុមារត្រូវរៀនធម៌ បួសជាសាមណេរ

[26] បណ្ឌិត ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ, ទំព័រ៥២, ២០១៩

[27] ទេស ហាវ, ទេព ណន, ធុក ផល្លីនី, តែ ស្រីសោភ័ណ វប្បធម៌អរិយធម៌ខ្មែរ ទំព័រ៧៤, ២០០៩

និង ភិក្ខុទៀត ដើម្បីរៀនសូត្រកាន់តែជ្រៅជ្រះ ។ អ្នកដែលធ្លាប់បានបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា គេហៅថា អន្ទិត ដែលក្លាយមកពីពាក្យ បណ្ឌិត មានន័យថា អ្នកមានចំណេះដឹងជ្រៅជ្រះ ។ មានអ្នកនិពន្ធ ជាច្រើនធ្លាប់បានបួសរៀន ដូចជា សុតន្តប្រីជាឥន្ទ្រ សន្ធរម៉ុក ភិរម្យង៉ុយ សម្តេចព្រះអង្គឌួង ព្រះរាជសម្ភារ ភិក្ខុសោម ឧកញ៉ានូ កន ជាដើម ។

- **ផ្នែកសិល្បៈ** : វត្តអារាមជាមណ្ឌលថែរក្សាការពារ និង ផ្សព្វផ្សាយសិល្បៈ ។ នៅពេលស្រុកមានកោលាហល កើតចំបាំងរាំងជល់ក្នុងស្រុក ឬ មានសង្គ្រាមឈ្លានពានពីបរទេស ជាពិសេសសម័យអានានិគមនិយមបារាំង សិល្បៈគ្រប់ប្រភេទរបស់ខ្មែរត្រូវរត់ទៅជ្រកកោននៅវត្តអារាម ដែលមានព្រះសង្ឃជាអ្នកថែរក្សា និងបង្ហាត់បង្រៀន។ ព្រះសង្ឃច្រើនមានចំណេះដឹងខាងសិល្បៈឆ្លាក់ គំនូរ និង ក្បាច់រចនាសំរាប់លំអតាមព្រះវិហារ កុដិ សាលាឆាន់ ចេតីយ៍ ។ ល ។ ព្រះសង្ឃដឹកនាំកសាងកុដិ សាលា ស្ពាន មន្ទីរពេទ្យ ព្រះវិហារ... ។
- **ផ្នែកជំនឿ** : ព្រះពុទ្ធសាសនាអប់រំមនុស្សឱ្យជឿទៅលើបុណ្យ បាប កម្ម ផល ដែលជំនឿនេះធ្វើឱ្យពុទ្ធ សាសនិកមិនរមិលគុណ ចេះគោរពមាតា បិតា គ្រូអាចារ្យ និង អ្នកមានគុណទាំងឡាយ ។
- **ទំនៀមទម្លាប់ប្រពៃណី** : ទំនៀមទំលាប់ប្រពៃណីដែលទទួលឥទ្ធិពលពីពុទ្ធសាសនាមានដូចជា បុណ្យ ពិសាខបូជា មាឃបូជា ភ្ជុំបិណ្ឌ ចូលឆ្នាំ ចូលវស្សា ចេញវស្សា កឋិន បុណ្យផ្កា ... ។
- **ផ្នែកកសិកម្ម** : កាលពីជំនាន់ដើម វត្តអារាមនីមួយៗ តែងតែមានស្រែ ដែលគេហៅថា ស្រែវត្ត ឬ ស្រែព្រះ ។ ព្រះសង្ឃចូលរួមក្នុងការកសាងទំនប់ ប្រឡាយទឹក លើកផ្លូវ ។ ល ។
- **ផ្នែកសង្គមកិច្ច** : វត្តអារាមផ្តល់ដល់យុវជន និង ប្រជាពលរដ្ឋនូវវិជ្ជាជីវៈផ្សេងៗដូចជា ជាងឈើ ជាងចម្លាក់ ជាងគំនូរ ជាងកំបោរ...។ វត្តអារាមជាកន្លែងចិញ្ចឹមអ្នកគ្មានទីពឹង ជាអន្តេវាសិកសម្រាប់សិស្ស និស្សិតដែលមានស្រុកឆ្ងាយៗ ដើម្បីស្នាក់នៅរៀនសូត្រ ។ មុនពេលវិទ្យាសាស្ត្រផ្នែកពេទ្យមានការរីកចំរើន វត្តអារាមគឺជាមន្ទីរពេទ្យ ព្រះសង្ឃជាគ្រូពេទ្យ ដែលខ្មែរយើងច្រើននិយមហៅថា គ្រូខ្មែរ ជាពិសេសគឺការព្យាបាលតាមចិត្តសាស្ត្រប្រើមន្តអាគម តាថា និង ធម្មទេសនាសំរាប់អ្នកជំងឺផ្លូវចិត្ត ។

៧. តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអន្តរ

៧.១. តួនាទីអប់រំដើម្បីស្វែងរកសច្ចភាពនៃជីវិត

ពុទ្ធសាសនា គឺជាសាសនាផង និងជាទស្សនវិជ្ជាផង។ ព្រះពុទ្ធបានបញ្ញត្តិក្រមចរិយាធម៌មួយយ៉ាងល្អ សម្រាប់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា និងពុទ្ធសាសនិកជនជាគ្រហស្តឱ្យវៀរចាកនូវការធ្វើអំពើអាក្រក់ទាំងពួង (សព្វបាបស្សអករណំ) ងាកមកប្រព្រឹត្តសេចក្តីល្អ(កុសលស្សូបបសម្បទា) និងតាមដានពិនិត្យផ្លូវចិត្តខ្លួនឯងឱ្យច្បាស់លាស់ដើម្បីសម្អាតផ្លូវចិត្ត(សចិន្តបរិយោទបនំ)ដោយត្រូវបដិបត្តតាមមាគ៌ាអដ្ឋង្គិកមគ្គ។

ពុទ្ធសាសនា គឺជាសាសនាមនុស្សនិយម ។ រូបមន្តដំបូងបំផុតរបស់ព្រះពុទ្ធសាសនា ត្រូវបានគេរកឃើញនៅក្នុងអ្វីដែលគេស្គាល់ថាជា "**ចតុរារិយសច្ចៈ**" ដែលត្រូវតែជាការយកចិត្តទុកដាក់របស់មនុស្ស ប្រកបដោយប្រាជ្ញាគ្រប់រូប និងជាសេចក្តីប្រកាសត្រឹមត្រូវ ស្តីពីធម្មជាតិនៃលោកនិងធម្មជាតិនៃមនុស្ស។

ក. ចតុរារិយសច្ច: (អរិយសច្ច:បួន)[28]គឺ :

ក.១. ទុក្ខអរិយសច្ច: ទាក់ទងនិងធម្មជាតិពិតនៃជីវិត សេចក្តីសោកសៅ និងសេចក្តីសប្បាយតែខាងក្រៅនៃជីវិតការខកចិត្ត និងទោមនស្សនៃជីវិតអនិច្ចតានិងអនត្តានៃជីវិត។ បុគ្គលគប្បីយល់ប្រការនេះជាការណ៍ពិតដោយច្បាស់លាស់និងដោយពេញលេញ ។ ទុក្ខអរិយសច្ច:ទុក្ខដែលជាសភាពពិត មាន ជាតិទុក្ខ គឺទុក្ខព្រោះកំណើត ។ ជរាទុក្ខ គឺជាទុក្ខព្រោះចាស់ ។ ព្យាធិទុក្ខ គឺទុក្ខព្រោះឈឺ ។ មរណទុក្ខ គឺទុក្ខព្រោះស្លាប់ ។

ក.២. សមុទយអរិយសច្ច: (ហេតុនៃទុក្ខ) សម្តែងថាទុក្ខបណ្តាលមកពីប្រភេទនៃរាគៈ ឬតម្រេកដែលជិតដាមដោយកាមតណ្ហា កិលេស និងសេចក្តីសៅហ្មងដទៃទៀត។ បុគ្គលមិនគ្រាន់តែយល់ដឹងនូវការពិតនេះដោយច្បាស់ លាស់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសេចក្តីព្យាយាមរំលើងឫសគល់រាគៈទាំងនោះថែមទៀត។ សមុទយអរិយសច្ច: ហេតុដែលនាំឱ្យកើតទុក្ខ ព្រោះវិជ្ជានិងតណ្ហា។ អវិជ្ជា គឺមកពីមិនដឹងមិនយល់ហេតុនៃទុក្ខ។ តណ្ហា គឺចំណង់ចង់បាននូវអ្វីៗគ្រប់យ៉ាងមានកាមតណ្ហា ចំណងជាដើម ។

ក.៣. និរោធទុក្ខអរិយសច្ច: សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជាជាប្រភពដើមនៃទុក្ខ។ ជាលទ្ធភាពដំនះទុក្ខបានដែលសម្រេចដល់ធម៌ដ៏ខ្ពស់បំផុតនៃពុទ្ធសាសនាគឺនិព្វាន(ការរំលត់ទុក្ខ)។

ក.៤. មគ្គអរិយសច្ច: មាគ៌ានាំទៅកាន់ការរំលត់ទុក្ខពិតប្រាកដ ការយល់ដឹងនូវមគ្គតែប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ គេត្រូវខិតខំដើរតាមមាគ៌ានេះ និងប្រតិបត្តិតាមដោយទៀតទាត់ទៀត។ មគ្គអរិយសច្ច: វិធីរំលត់ទុក្ខប្រកបដោយមគ្គ (ត្រូវ) មាន ៨ យ៉ាងគឺ (ហៅថា អដ្ឋង្គិកមគ្គ)

- សម្មាទិដ្ឋិ : យល់ឃើញត្រូវ
- សម្មាសង្កប្ប : ត្រិះរិះត្រូវ
- សម្មាវាចា : សម្តីត្រូវ
- សម្មាកម្មន្ត : ការងារត្រូវ
- សម្មាអាជីវៈ : ការចិញ្ចឹមជីវិតត្រូវ
- សម្មាវាយាម : ព្យាយាមត្រូវ
- សម្មាសតិ : រឭកត្រូវ
- សម្មាសមាធិ : តាំងចិត្តត្រូវ

ខ. លក្ខណៈនៃភាវៈ (ត្រៃលក្ខណ៍)

លក្ខណៈសកលបីយ៉ាងនៃជីវិតគឺ៖

- អនិច្ចំ : ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់ ក្នុងការកើតស្លាប់ចម្រើនវិនាស មិនទៀងទាត់ ។
- ទុក្ខំ : ភាវៈទាំងអស់ឱ្យតែមាននាមនិងរូប សុទ្ធតែមានទុក្ខដូចគ្នា។
- អនត្តា : ភាវៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

សរុបមក ភាវៈទាំងពួងក្នុងធម្មជាតិត្រូវតែមានការប្រែប្រួលដោយភ្ជាប់ហេតុនិងផល ។

[28] អ្នកស្រី ត្រឹង-ងា, សៀវភៅអរិយធម៌ខ្មែរ ទំព័រ ២៥-៣៣

គ. បញ្ហាកម្មផល

- **កម្មផល** : ទ្រឹស្តីកម្មផល ដែលបង្ហាញពីចំណងនៃអំពើនិងផលដែលបុគ្គលបានសាងឡើង។ មនុស្សមានការចេះដឹង លង់ខ្លៅ ល្អ អាក្រក់ ស្រេចទៅលើខ្លួនឯង អំពើរបស់ខ្លួននិងមានវិជ្ជាចេះដឹងបានសម្រេចមគ្គផលក៏ដោយសារខ្លួនឯងបានសិក្សាសន្សំប្រឹងស្មឹងស្មាធ៏ បើលង់ខ្លៅអប្បប្រាជ្ញាក៏ដោយសារកម្មនិងផល ២យ៉ាង :
  - **កល្យាណកម្ម** : អំពើល្អឱ្យផលល្អ (ធ្វើបុណ្យបានបុណ្យ)
  - **បាបកម្ម** : អំពើអាក្រក់ឱ្យផលអាក្រក់ (ធ្វើបាបបានបាប) ។

  ពុទ្ធភាសិត "***អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ***" ។
- **កម្មពៀរ** : ផលអាក្រក់ដែលបុគ្គលបានទទួលដោយសារអំពើអាក្រក់ ដែលបុគ្គលនោះបានប្រព្រឹត្តពីអតីតជាតិ ជាការប៉ះពៀរគ្នា។

ឃ. បដិច្ចសមុប្បាទធម៌ ១២ ប្រការ គឺ៖

- អវិជ្ជា ជាបច្ច័យឱ្យកើតសង្ខារ
- សង្ខារ ជាបច្ច័យឱ្យកើតវិញ្ញាណ
- វិញ្ញាណ ជាបច្ច័យឱ្យកើតនាមរូប
- នាមរូប ជាបច្ច័យឱ្យកើតសឡាយតន:
- សឡាយតន: ជាបច្ច័យឱ្យកើតផស្ស:
- ផស្ស: ជាបច្ច័យឱ្យកើតវេទនា
- វេទនា ជាបច្ច័យឱ្យកើតតណ្ហា
- តណ្ហា ជាបច្ច័យឱ្យកើតឧបាទាន
- ឧបាទាន ជាបច្ច័យឱ្យកើតភព
- ភព ជាបច្ច័យឱ្យកើតជាតិ
- ជាតិ ជាបច្ច័យឱ្យកើតជរា
- ជរា ជាបច្ច័យឱ្យកើតមរណ: ។

ង. បញ្ហាសុខ

ដើម្បីបានសេចក្តីសុខ គឺលះបង់តណ្ហា ក៏ចាត់អវិជ្ជា មិនប្រមាថធ្វេសប្រហែស តម្កល់ចិត្តក្នុងសីល សមាធិ បញ្ញា និងលះបង់អត្ត: (កុំប្រកាន់ថាខ្លួន ជារបស់ខ្លួន)

សម្បត្តិ ៣ប្រការ

- សម្បត្តិមនុស្ស ឬមនុស្សសម្បត្តិ គឺសម្បត្តិដែលប្រសើរជាងសត្វតិរច្ឆាន ។
- សម្បត្តិសួគ៌ ឬសួគ៌សម្បត្តិ គឺសម្បត្តិដែលកើតឡើងដោយចំណងនិស្ស័យនៃបុញ្ញកម្ម ។
- សម្បត្តិនិព្វាន ឬនិព្វានសម្បត្តិ គឺសម្បត្តិខ្ពស់បំផុតឥតមានភ័យណាមួយក្នុងលោកចូលមកបៀតបៀនបានឡើយ ។

ជារួម ទ្រឹស្តីជាមេរៀននៃអង្គព្រះសម្មាសម្ពុទ្ធនៃយើង គឺជាប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយមនេះឯង។ ដូច្នេះ ហើយតួនាទីនៃអក្សរសិល្ប៍ពុទ្ធនិយមត្រូវតែផ្សារភ្ជាប់ឥតដាច់ជាមួយនឹងមេរៀនត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ។ តួនាទីអក្សរសិល្ប៍ពុទ្ធនិយមដើម្បីស្វែងរកសច្ចភាពនៃជីវិតគឺឆ្លុះបញ្ចាំងតាមរយៈរឿងពុទ្ធនិយមសុទ្ធទាំង១០រឿង។

៧.២. តួនាទីកម្សាន្តបន្ធូរអារម្មណ៍ផ្សារភ្ជាប់ការអប់រំ

តួនាទីអក្សរសិល្ប៍បានរួមចំណែកជួយបន្ធូរបន្ថយភាពតានតឹងរបស់ប្រជាជន ហើយស្នាដៃអក្សរសិល្ប៍ទាំងនោះច្រើនជាអត្ថបទសាស្ត្រាល្បែងនានា ដែលច្រើនមានតែមានប្រភពមកពីគម្ពីរបញ្ញាសជាតក។ លក្ខណៈនេះអាចបង្ហាញថាសាស្ត្រាល្បែងទាំងនោះគឺបញ្ជាក់យ៉ាងច្បាស់ពីទំនោររបស់អ្នកនិពន្ធ គឺបានជ្រើសយកគោលសាសនាជាសំខាន់ក្នុងការតាក់តែងសាច់រឿងរបស់ខ្លួន។ ជាពិសេសសាស្ត្រាល្បែងទាំងនោះគឺចង់បង្ហាញពីឥទ្ធិពល នៃសាសនាទៅលើសន្តានចិត្តសតិអារម្មណ៍របស់ប្រជាជន។ មួយវិញទៀតសិល្ប៍និពន្ធនៃសាស្ត្រាល្បែងទាំងនោះក៏អាចបកស្រាយពីជីវភាពស្មារតីរបស់ប្រជាជនផងដែរ។ មានន័យថាចាប់តាំងពីប្រទេសចុះខ្សោយមកជីវភាពប្រជាជនក៏លែងមានលំនឹង។ ដោយសារសង្គ្រាម ការព្រាត់ប្រាស និងមានគ្រោះទុរភិក្សក្នុងរយៈពេលដ៏វែងបានធ្វើ ឱ្យប្រជាជនឆ្អែតឆ្អន់នឹងការលំបាកវេទនានិងទុក្ខសោកទាំងនោះ។ ក្តីប្រាថ្នាដែលពួកគេចង់រស់នៅ ក្នុងសង្គមមួយដ៏សុខដុមរមនាមិនអាចសម្រេចបានក្នុងសច្ចភាព។ ហេតុដូចនេះគេបានយកក្តីប្រាថ្នា ទៅធ្វើក្នុងតថភាពគឺបកស្រាយតាមរយៈអក្សរសិល្ប៍ទៅវិញ ដើម្បីបំពេញអារម្មណ៍ សម្រាលទុក្ខ បន្ធូរភាព គ្រោតគ្រាត និងជូរចត់ក្នុងជីវិតជាក់ស្តែង។ ដោយហេតុនេះហើយបានជាសាស្ត្រាល្បែងក្នុងសម័យក្រោយអង្គរវៀងមកដល់សម័យអាណានិគមមិនព្រមលើកឡើងពីជីវភាពសង្គមពីជីវិតពិតរបស់ប្រជាជនសោះ តែបែរជាបង្ហាញពីជីវិតដ៏រុងរឿង និងសម្បូរសប្បាយរបស់ត្រកូលស្តេចទៅវិញ។ បើពុំដូច្នោះទេ កាលណាគេបង្ហាញពីការលំបាកវេទនាដ៏ហួសនិស្ស័យរួចហើយ ទីបំផុតអ្នកដែលទទួលទុក្ខទោស ដោយសារអយុត្តិធម៌ទាំងប៉ុន្មាន តែងបានវិលមកសោយសុខសុភមង្គលបរិបូរវិញជានិច្ច។ ជាតួយ៉ាងនៅក្នុងរឿងក្រុងសុភមិត្រ គឺពោរពេញដោយជីវិតខ្វាត់ព្រាត់រសាត់អណ្តែត ព្រាត់មហេសី ព្រាត់បុត្រ បន្ទាប់ពីបាត់បង់នគរ និងរាជបល្ល័ង្ក ប៉ុន្តែនៅទីបញ្ចប់ក៏បានមកជួបជុំគ្នាវិញ ហើយបានទាំងនគរមួយ ផ្សេងទៀតមកគ្រប់គ្រងថែមទៀត។ ចំណែកឯក្នុងរឿងមរណមាតា គឺថានាងមរណមាតាបានស្លាប់ ហើយរស់ឡើងវិញស្ទើរតែដប់ដងទៅហើយ ដើម្បីបានមកវិលមកធ្វើជាអគ្គមហេសីរបស់ស្តេចវិញ មុននឹងរឿងត្រូវបានបញ្ចប់។

៧.៣. តួនាទីអប់រំស្វែងរកសច្ចភាពនៃជីវិតតាមរយៈស្នាដៃអក្សរសិល្ប៍ទសជាតក

៧.៣.១. រឿងព្រះតេមិយជាតក

ក. ប្រធានរឿង

រឿងតេមិយ បង្ហាញពីព្រះពោធិសត្វ បំពេញនេក្ខកម្មបារមី គឺការសាងផ្នួស។

ខ. មូលបញ្ហារឿង

ទី១៖ បញ្ហាធ្វើទណ្ឌកម្មចោរ

សាច់រឿងបានលើកយករឿងចោរ៤នាក់មកធ្វើ ជាប្រធាននៃរឿងនឿយណាយមិន ចង់គ្រងរាជ្យជាស្តេចផែនដី ហើយប្រាថ្នាលះបង់សម្បត្តិជាក្សត្ររបស់តេមិយដើម្បីយាងចូលព្រៃបួសជាឥសី។ រឿងចោរនេះមាន៤នាក់៖ ចោរម្នាក់ត្រូវវាយដោយរំពាត់១៣ន់ខ្ចាប់, ចោរម្នាក់ចងដោយច្រវាក់ដាក់ក្នុងពន្ធធនាគារ, ចោរម្នាក់ត្រូវចាក់សម្លាប់ដោយលំពែង,ចោរម្នាក់ទៀតត្រូវដោតឆ្កាងអណ្តាតគឺដែកស្រួច។

ពោធិសត្វឃើញព្រឹត្តិការណ៍បែបនេះ ក៏ស្តុតស្មារតីកិតភ័យពន់ប្រមាណ ហើយទ្រង់ពិចារណាថា៖« **អាត្មាអញមកពីណា មកនៅក្រោមស្វែតច្ឆត្រនេះ** មកពីឋានតាវត្តឹង្សមកនៅទីនេះ មកពីនរកទៅកាន់ឋានតាវត្តឹង្ស ទៅពីកន្លែងនេះទៅនរក ព្រោះធ្លាប់ជាស្តេចសោយរាជ្យនៅនគរនេះអស់២០ឆ្នាំដោយទោសនៃការសោយរាជ្យបានជានៅរងទុក្ខឧស្សុទនរក៨ម៉ឺនឆ្នាំ»។[29]

ដូចនេះបញ្ហាធ្វើទណ្ឌកម្មចោរដោយខ្លាចភ័ន្តច្រឡំត្រូវជាខុសល្អជាអាក្រក់,ទោស...ទាំងអស់នេះហើយដែលធ្វើឲ្យពោធិសត្វតក់ស្លត់ភ័យខ្លាចចំពោះខ្លួនឯងខ្លាចនូវអំណោយទ្រព្យសម្បត្តិហើយនឿយណាយទៅជាមធ្យោបាយធ្វើគ ថ្លង់ ខ្វិនខ្វង់ ដើម្បីរំដោះខ្លួនចេញពីរាជសម្បត្តិ ដែលទ្រង់យល់ថា ជា**ចំណង** ជា**ទោស** ជាគ្រឿងសៅហ្មង ជាមន្ទិលអាចទាញព្រះអង្គធ្លាក់ចុះឋាននរករងខ្ទុះឈាមនោះ ។

ទី២៖សកម្មភាព និងលក្ខណៈរបស់តេមិយ

កាលបើពិចារណាឃើញបុព្វហេតុនៃទោសកំហុសយ៉ាងនេះ ទើបតេមិយទទួលស្តាប់នូវសម្តែង នៃ នាងទេពធីតាដែលជាសម្តែងវិចារណញ្ញាណ សម្តែងសុភនិច្ឆ័យ សំឡេងនៃមនសិការដោយធ្វើ ឧបាយជាគ ជាថ្លង់ ជាខ្វិនខ្វង់ លែងនិយាយស្តី ទោះបីព្រះបវរបិតាខិតខំប្រើមធ្យោបាយបន្លាចបំភ័យ យ៉ាងណាក៏ដោយ ក៏ព្រះរាជកុមារនៅតែខិតខំរក្សា អាកប្បកិរិយា ជំហរស្មារតីរបស់ខ្លួនមិនតបឆ្លើយមិនព្រមនិយាយស្តី ធ្វើទាល់ តែព្រះមហាក្សត្របិតាទាល់តម្រិះខ្លាល់ប្រើរាជអាមាត្យនាំយកទៅដីកដីកប់ទាំងរស់។ សកម្មភាព និងលក្ខណៈរឹងប៉ឹង តាំងស្មារតីស៊ប់គ្មានប្រៃប្រួលក្នុងឧត្តមគតិ ក្នុងគោលបំណង ត្រូវរបស់ខ្លួនបែបនេះ ដែលធ្វើឱ្យព្រះតេមិយ ឆ្លងផុតពីទោសច្រឡំ ទោសអគតិ អយុត្តិធម៌ឬ ចាកអំពើបាប គ្រោតគ្រាតបាន ។

ទី៣ ៖ បញ្ហានេក្ខម្មបារមី

នេក្ខម្មបារមី ឬការបួសជាមធ្យោបាយរំដោះខ្លួនឱ្យផុតអំពីកងកង្វល់ទុក្ខទោសក្នុងជីវភាពជាក្សត្រជាអ្នកកាន់អំណាច ជាអ្នកធ្វើទោសទណ្ឌគេ ជាមនុស្សស្រលាញ់ទ្រព្យសម្បត្តិ...។ តាមដំណើររឿង កំហុសនៃព្រះបាទកាសិករាជ ជាបិតាមានដល់ទៅ ពីរលើកស្ងួនៗគ្នា គឺ

- លើកទីមួយ ធ្វើទោសចោរបួននាក់នៅ ចំពោះមុខកូនធ្វើកូនភ័យខ្លាចស្អប់ខ្ពើមអំណាចបែប នេះយ៉ាងខ្លាំង
- លើកទីពីរ ធ្វើមធ្យោបាយ ដោយប្រើអំពើទណ្ឌកម្មបន្លាចបំបាក់ស្មារតីដោយពិសោធន៍ហេតុ ដប់ប្រាំមួយប្រការ ។រហូតដល់ប្រើនាយសុនន្ទសារថីឱ្យចាប់ចងយកទៅកប់ទាំងរស់ ។ ទាំងនេះ គឺជាអំពើដែលរាជ កុមារយើញផ្ទាល់នឹងព្រះនេត្រដែលសឲ្យឃើញកំហុសច្រើនឥតគណនារបស់ស្តេចបិតាដែលខ្លួនត្រូវតែខ្លាចគេចចេញកុំទៅស្នងរាជ្យ ដើម្បីកុំឲ្យដើរតាមកំហុសបែបនេះទៀត។ដូច្នោះមានតែការបួសទេ គឺចាក ភាពជាគ្រហស្តដើម្បីចូលព្រៃបួស ជាសមណៈឥសីលះបង់ នូវអំណាចទ្រព្យសម្បត្តិជាចំណងច្រើនប្រការ ។

សរុបមក **ការបួស** គឺជាការផ្តាច់ឫសគល់នៃលោភៈ ទោសៈ មោហៈ និង**អវិជ្ជា**ដើម្បីស្វែង រកបរមសុខ មានមោក្សៈ ជាការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ជាទី**អវសាន**។ នៅក្នុងរឿងនេះបានបង្ហាញឱ្យ ឃើញថារឿងទូទៅក្នុងពុទ្ធនិយមសុទ្ធតែបានបង្ហាញថាព្រះពោធិសត្វលះបង់រាជសម្បត្តិដើម្បីយាងទៅបួស។ ដូចនេះរាជសម្បត្តិជាឧបសគ្គជាចំណងយ៉ាងមាំសម្រាប់ភ្ជាប់ពោធិសត្វនេះឯង ។ បើជាមនុស្សសាមញ្ញ គឺ សម្បត្តិទ្រព្យ កេរ្តិ៍អាករនេះឯងដែល

[29] ឈឹម សុមន៍ សង្ខេបទសជាតក ព.ស២៥០២ ទំព័រ៥

ជាចំណង។ ផ្តាច់ពារហិទ្រព្យនេះបានទើបរំដោះចិត្តគំនិតឱ្យផុតពី កាម តណ្ហា រាគៈ កិលេស កម្មអាក្រក់ អកុសលកម្មបាន។

ទី៤ ៖ លក្ខណៈ និងសកម្មភាពរបស់ព្រះបាទកាសិករាជ និងនាងចន្ទាទេវី

ព្រះបាទកាសិករាជ ជាក្សត្រស្រលាញ់បុត្រ ប៉ុន្តែមិនខ្លាចប្រើគ្រប់មធ្យោបាយ អាក្រក់ដើម្បី អូសទាញបុត្រឱ្យលុះក្នុងគន្លងគោលបំណងរបស់ព្រះអង្គបានឡើយ។ នេះក៏ ព្រោះអ្វី ? គឺព្រោះអកុសល កម្មរបស់លោកជាផ្លូវជាមធ្យោបាយពុំត្រូវ ពុំល្អនេះឯង។ ឯនាងចន្ទាទេវីជាមាតា គឺចេះថ្នាក់ថ្នមបុត្រ ប៉ុន្តែអូសទាញមក ក្នុងគោលបំណងរបស់ព្រះរាជស្វាមីពុំបានសម្រេច ព្រោះចិត្តគំនិតមធ្យោបាយដើរខុសគ្នា (មួយត្រជាក់ មួយក្តៅចូលគ្នាពុំកើត)។ ប៉ុន្តែទឹកចិត្តប៉ងប្រាថ្នាឲ្យព្រះរាជបុត្រលះបង់ឧត្តមគតិការបួសមកឡើង គ្រងរាជ្យ ជាក្សត្រ សុទ្ធតែខុសពីសច្ចាអធិដ្ឋានរបស់ព្រះតេមិយទាំងអស់។ ដូច្នោះមធ្យោបាយរបស់ក្សត្រទាំងពីរអង្គ ជាព្រះបវរបិតាមាតាត្រូវខកខានបរាជ័យជាអសារបង់។

គ. តួនាទីអប់រំនៃរឿងតេមិយជាតក

គ្រប់អក្សរសិល្ប៍ទាំងអស់ សុទ្ធមានតម្លៃអប់រំជានិច្ចមិនថាអក្សរសិល្ប៍បុរាណ ឬអក្សរសិល្ប៍ទំនើបឡើយ។ យ៉ាងណាមិញរឿងតេមិយជាតក ក៏បានលើកយកទស្សនៈនៃការអប់រំ មកពន្យល់ ឱ្យអ្នកអាន អ្នកទស្សនាស្គាល់និងយល់អំពីចលនាពុទ្ធនិយម។ តេមិយជាតក ជារឿងពុទ្ធនិយមដែលនិយាយពីការសាងបារមី ដោយការបួសដើម្បីបានត្រាស់ដឹង និងបានបង្ហាញអំពីតម្លៃអប់រំដែលមានលក្ខណៈល្អជាច្រើន។

ឆ្លងតាមការវិភាគទៅលើ ប្រធានរឿង និងមូលបញ្ហារឿង ធ្វើឱ្យយើងយល់អំពីគំនិតសំខាន់ៗ និងតម្លៃអប់រំជាច្រើនដូចជា ៖

- **អប់រំមនុស្សឱ្យជឿលើកម្មផល**
  អ្នកណាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ កម្មសឲ្យផលស កម្មខ្មៅឲ្យផលខ្មៅ បានន័យថារាល់ទង្វើទាំងអស់ កាលណាយើងប្រព្រឹត្តិតែអំពើល្អ នោះអំពើល្អនឹងតបស្នងយើងវិញ ប៉ុន្តែបើយើងប្រព្រឹត្តិអាក្រក់នោះអំពើអាក្រក់នឹងបៀតបៀនយើងវិញ ។ តួយ៉ាងដូចជាក្នុងរឿងបានបញ្ជាក់ថាព្រះ ពោធិសត្វធ្លាប់ ជាស្តេចសោយរាជ្យ អស់រយៈពេលម្ភៃឆ្នាំ ដោយសារទោសនៃសោយរាជ្យបានធ្វើឲ្យព្រះ អង្គរងទុក្ខក្នុងឧស្សុទនរកអស់៨ម៉ឺនឆ្នាំ។សរបញ្ជាក់ឱ្យឃើញថាកាលពីព្រះពោធិសត្វសោយរាជ្យបានប្រព្រឹត្តិខុសធ្វើឱ្យមានកម្មពារហូតជាប់ក្នុងនរកអស់ប្រាំបីម៉ឺនឆ្នាំ។
- អប់រំកុំឱ្យលោភលន់ នឹងទ្រព្យសម្បត្តិបុណ្យសក្តិ ផលអាក្រក់ពីការចង់មាន ចង់បានហួសព្រំដែនហួស ពីសមត្ថភាពរបស់ខ្លួន ។ ជួនកាលទ្រព្យសម្បត្តិបែជានាំទុក្ខវេទនាដល់យើងទៅវិញដូចជាព្រះ ពោធិសត្វ នៅក្នុងរឿងតេមិយព្រះអង្គមិនចង់បានអ្វីឡើយ ទាំងទ្រព្យសម្បត្តិ ទាំងការឡើងសោយរាជ្យ ព្រោះព្រះអង្គខ្លាចរង ទុក្ខវេទនាទទួលផលបាបពីវត្ថុទាំងនោះទើបព្រះអង្គ ធ្វើគ ធ្វើថ្លង់ ធ្វើខ្វិនដើម្បីគេចពីការសោយរាជ្យ។
- ត្រូវមានភក្តីភាពនិងការដឹងគុណ សេចក្តីស្មោះត្រង់ នឹងគ្នាធ្វើឲ្យមនុស្សទទួលបានសេចក្តីសុខរាប់អានដោយភាពជឿជាក់ដៃល ជាសេចក្តីប្រសើរបំផុតរបស់មនុស្ស។ ព្រះពោធិសត្វបានមានព្រះបន្ទូលទៅកាន់នាយសារថីអំពីបុគ្គលណា មិនទ្រុស្តមិត្ត គឺបុគ្គលនោះតែងទទួលផលល្អ មានកិត្តិសព្ទ មានអ្នកចាំជួយជានិច្ចមិនមាន បុគ្គលណាអាច គ្របសង្កត់បានឡើយ គឺដោយសារតែភាពស្មោះត្រង់របស់ខ្លួន។ ការដឹង

គុណរាល់បុគ្គលម្នាក់ៗត្រូវមានភាពកតញ្ញូចំពោះឪពុកម្តាយ បងប្អូន ឬក៏អ្នកដែលធ្វើគុណមក លើយើងដូចជាព្រះពោធិសត្វមានបន្ទូលថា«បុគ្គលអង្គុយឬដេកក្រោមម្លប់ឈើណាមិនគប្បីកាប់មែកឈើនោះទេ។»

- អប់រំឱ្យមនុស្សខ្លាចអំពើបាបសាង នូវអំពើកុសលដូចការសាងផ្នួស ដើម្បីសន្សំកុសលស្វែងរក សេចក្តីសុខឱ្យខ្លួនដោយមិនប្រកាន់ភ្ជាប់នូវកិលេសទាំងឡាយ។

៧.៣.២. រឿងមហាជនកជាតក

ក. ប្រធានរឿង

នៅក្នុងរឿងមហាជនកជាតកអ្នកនិពន្ធក៏បានបង្ហាញពីការតស៊ូ អំណត់ព្យាយាម និងភាពឈ្លាសវៃរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ជាព្រះសាមណគោតម ។

ខ. មូលបញ្ហារបស់រឿង

ក្នុងការសិក្សាមូលន័យនៃរឿងណាមួយ ជាដំបូងយើងត្រូវស្គាល់ឲ្យច្បាស់ថាមូលន័យមានន័យយ៉ាងណា? មូលន័យជាសមិទ្ធផលនៃប្រធានរឿងនៃស្នាដៃជាក់ស្តែងមួយ ឬជាគំនិតសំខាន់ឬច្បងនៅក្នុងសាច់រឿងទាំងមូល ។ អ្នកនិពន្ធបង្កើតស្នាដៃនេះឡើងក្នុងគោលបំណង ចង់អប់រំប្រៀនប្រដៅឱ្យបុគ្គលគ្រប់រូបចេះថ្លឹងថ្លែង មានអំណត់អត់ធន់ក្នុងការងារណាមួយច្បាស់លាស់ មានទំនួលខុសត្រូវលើការងារដែលបំពេញ មិនត្រូវចុះចាញ់នូវរាល់ ឧបសគ្គដែលកើតឡើងចំពោះមុខមិនថាតូចឬធំឡើយ ព្រោះការព្យាយាមរមែងឱ្យយើង ទទួលបាននូវជោគជ័យមួយពិតប្រាកដ។ ក្នុងនោះមូលន័យនៅក្នុងរឿងមហាជនក គឺចង់និយាយពីលក្ខណៈនៃការតស៊ូព្យាយាម អ្វីក៏ដោយក៏ អាចទទួលបានលទ្ធផលល្អដែរ ក៏អាស្រ័យដោយការខំប្រឹងប្រែងតែមួយគត់ ។

ក្នុងរឿងទាំងមូលគំនិតទូទៅ គឺត្រង់ការតស៊ូរបស់មហាជនក និងការលះបង់ដ៏ខ្ពស់របស់ទ្រង់បានបង្ហាញឱ្យយើងដឹងពីសារប្រយោជន៍នៃការព្យាយាមទោះតិច ឬច្រើនក្តី។

គ. តួនាទីអប់រំនៃរឿងមហាជនកជាតក

នៅក្នុងរឿងមហាជនកជាតកនេះក៏និយាយពីការខិតខំប្រឹងប្រែងតស៊ូព្យាយាមរបស់តួអង្គ ព្រះពោធិសត្វពិសេសគឺបានបង្កប់នូវការអប់រំជាច្រើនដល់បុគ្គលគ្រប់រូប ក្នុងការធ្វើអ្វីមួយដើម្បីកុំឱ្យធាប់ចុះចាញ់ភ្លាមៗពេកព្រោះការចុះចាញ់នេះ វារមែងតែទទួលបាននូវផលអវិជ្ជមានជាមិនខាន។រឿងនេះមានគោលបំណង អប់រំឱ្យយើងចេះមានជំនឿជាក់លើសមត្ថភាពរបស់ខ្លួន មានភាពអង់អាច អំណត់មិនតក់ស្លុតភិតភ័យមានកក្តីភាពចំពោះការងារដែលខ្លួនធ្វើមិនរាថយ ឬរុញរានៅពេលដែលជួបបញ្ហាចំពោះមុខ ។

ពិសេសទៅទៀតរឿងនេះក៏បានលើកឡើងពីការតស៊ូយ៉ាងមុតមាំរបស់តួអង្គព្រះពោធិសត្វ នៅពេល ដែលជួបវិបត្តិផ្ទាល់ខ្លួន។ មួយវិញទៀតបង្ហាញឲ្យយើងដឹងពីការប្រុងប្រយ័ត្នរាល់ឧបសគ្គទាំងឡាយ ជាពិសេសសកម្មភាពទាំងអស់ដែលកើតមានឡើងនៅអតីតកាលឬក្នុងសង្គមជាតិនាពេលបច្ចុប្បន្ននេះ ។ ចំណុចដែលគួរ កត់សំគាល់នោះ គឺអ្នកនិពន្ធយើងចេះលើកយកសមុទ្រមកបញ្ចូលក្នុងសាច់រឿងដើម្បីបញ្ជាក់ថាវាគឺជាការស្មុគ ស្មាញធំដុំធំហួសប្រមាណដែលមនុស្សខ្លះមិនអាចធ្វើបាន ហើយមានតែមហាជនកទេដែលបានលិចសំពៅ នៅកណ្តាលមហាសាគរមិនអស់សង្ឃឹមខិតខំហែលរហូតដល់ចុងក្រោយ គឺមានទេវតារក្សាសមុទ្រមកជួយ ស្រោចស្រង់ឱ្យរស់

រានមានជីវិត នេះហើយជាលទ្ធផលនៃការប្រឹង ប្រែងរបស់ទ្រង់។ ដូចនេះអត្ថន័យនៃសាច់រឿងទាំងមូលគឺ ***សេចក្តីព្យាយាមអំណត់*** នេះឯង ។ អ្នកនិពន្ធបានបង្កប់នូវទស្សនៈសំខាន់ ៗសម្រាប់ការអប់រំទូន្មានប្រៀនប្រដៅដល់មនុស្ស ទូទៅតាំងពីអតីតកាលដល់បច្ចុប្បន្ន។ ដូច្នេះក្នុងរឿងនេះយើងអាចទាញបានទស្សនៈសំខាន់ៗដូចជា៖

- សេចក្តីព្យាយាមនាំឱ្យសម្រេច
- តក់ៗពេញបំពង់
- សេចក្តីព្យាយាមរមែងផុតទុក្ខ
- ចំណេះជាអាហារប្រាជ្ញាជាអាវុធ
- ចំណេះវិជ្ជាជាឃ្លាំងទ្រព្យ

រឿង**មហាជនកជាតក**ជារឿងពុទ្ធនិយមដែលមានលក្ខណៈបរិបូរពេញទៅដោយគោលដៅ អប់រំសមហេតុផល ម្យ៉ាងទៀតអ្នកនិពន្ធក៏បានលើកយកទ្រឹស្តីពុទ្ធនិយមក្នុងព្រះពុទ្ធសាសនាមកបកស្រាយ យ៉ាងជាក់លាក់គឺ"**អត្តាហិអត្តនោនាថោ**" ខ្លួនទីពឹងខ្លួនរបស់ព្រះអង្គដែលជាតួព្រះពោធិសត្វ។ ទស្សនៈនៃការ អប់រំគឺអ្នកនិពន្ធបានយកតួអង្គមហាជនក ជាគោលដៃលអនុវត្តនូវការព្យាយាមយ៉ាងខ្ជាប់ខ្ជួន តាំងពីដើមទីរហូតដល់ចប់។ ទោះជាមានឧបសគ្គធ្ងន់ធ្ងរយ៉ាងណាក៏ទ្រង់មិនរាថយហើយខំប្រឹងប្រែងលុះសម្រេចបានតាមបំណង។ ក្នុងរឿងនេះដែរក៏បានអប់រំដល់កូនចៅជំនាន់ក្រោយៗឱ្យចេះតែធ្វើអំពើល្អចេះគិតពិចារណាល្អិតល្អន់ ជឿលើសមត្ថភាពខ្លួនមានសីលធម៌ល្អក្នុងខ្លួន ជាពិសេសមានសេចក្តី អត់ធ្មត់ក្នុងការងារ ដែលខ្លួនត្រូវ បំពេញ។បញ្ហាដែលមនុស្សលោកជួបប្រទះក្នុងវាលវដ្តសង្សារដ៏ធំធេង ហើយវាបានផ្តល់បទពិសោធន៍យ៉ាងជោគជាំ សម្រាប់សត្វលោក ម្យ៉ាងទៀតរឿងនេះបានធ្វើឱ្យមនុស្សខ្មែរស្គាល់ និងយល់ច្បាស់ពីកំណើតការតស៊ូ និងលទ្ធផលនៃការតស៊ូផងដែរ ។

៧.៣.៣. រឿងសុវណ្ណសាមជាតក

ក.ប្រធានរឿង

ក្នុងស្នាដៃអក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ ឬ ទសជាតក អ្នកនិពន្ធតែងតែលើកយកការកសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ដឹងជា ព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ ។ ចំពោះរឿងសុវណ្ណសាម គឺសម្តែងពីការបំពេញមេត្តាបារមី របស់ព្រះពោធិសត្វ ដែលស្តែងឡើងដូចខាងក្រោម ៖

-មេត្តាចំពោះមាតាបិតា

ការដឹងគុណចំពោះមាតាបិតា គឺជាទង្វើប្រកបដោយគុណធម៌ កតញ្ញូ កតវេទី របស់បុត្រធីតា ជាពិសេសនៅពេលលោកទាំងពីរចាស់ជរា និងមានជំងឺ ។ ជាក់ស្តែងនៅពេលដែលឥសីទាំងពីរ ជាមាតាបិតាត្រូវពស់ព្រួសពិសខ្វាក់ភ្នែកទាំងពីរ សុវណ្ណសាមទទួលខុសត្រូវចិញ្ចឹមថែរក្សា និងខិតខំថែទាំ ទាំងអាហារ ផ្លែឈើ ទឹក និងកិច្ចការបម្រើសព្វគ្រប់ទាំងអស់ ។"សុវណ្ណសាមទុកមាតាបិតាក្នុងអាស្រម ទៅសន្សំមូលផលាក្នុងព្រៃ ព្រឹកៗបោសលំនៅនៃមាតាបិតា ហើយកណ្តៀតក្អមចុះទៅស្ទឹងមិគសម្មតា ដងទឹកសម្រាប់មាតាបិតាឆាន់ ប្រើប្រាស់ ហុចទឹកខ្ពុរព្រះឥសី និងឈើស្មន្ត ហើយប្រគេនមធុរផលានុផល លុះមាតាបិតាឆាន់ឆ្អែតស្កប់ស្កល់ ទើបយកសំណល់មកឆាន់ខ្លួនឯង...”។

- មេត្តាចំពោះសត្វ (ម្រឹគ -កិន្នរ- ចតុបាទ)

ការមិនសម្លាប់ជីវិតសត្វ ជាអំពើល្អ ជាកុសលកម្ម ដែលព្រះពោធិសត្វតែងតែមានចំពោះសព្វសត្វទាំងឡាយក្នុងភពត្រៃ ។ ដោយសេចក្តីមេត្តានោះហើយ ទើបនៅពេលសុវណ្ណសាម ចេញដំណើរស្វែងរកផលានុផល និងដងទឹកជូនមាតាបិតា តែងមានពួកកិន្នរាកិន្នរី ដើរដង្ហែរអមជានិច្ច ។ ដូចមានសេចក្តីថា ៖ "ពួកកិន្នរីតែងនាំគ្នាបេះផលានុផលប្រគេនដល់ពោធិសត្វ ″

- មេត្តាចំពោះបិលយក្ខក្សត្រដែនកាសី

ការតាំងចិត្តមិនខឹងក្រោធ ចំពោះអ្នកដែលប្រព្រឹត្តអំពើមិនគប្បី ឬ ទង្វើព្រៃផ្សៃមកលើខ្លួន វាជាការ តាំងចិត្តដ៏ឧត្តម និងជាសកម្មភាពដ៏កម្រ ដែលមនុស្សទូទៅ ពុំអាចធ្វើបាន ។ ជាក់ស្តែងបិលយក្ខ ជាអ្នកចូលចិត្ត សាច់ម្រឹគ ហើយនៅពេលឃើញសុវណ្ណសាម ស្និទ្ធស្នាលជាមួយម្រឹគ ក៏ច្រណែន ហើយបានបាញ់ពោធិសត្វដោយព្រួញ ព្រួញនោះធ្វើឱ្យសុវណ្ណសាមឈឺចាប់ពេតផ្សាណាស់ ប៉ុន្តែពុំមានចិត្តខឹងសម្បារនិងបិលយក្ខឡើយ។"...ទូលបង្គំឈ្មោះសាម ជាកូនឥសី ថ្ងៃនេះ ទូលព្រះបង្គំដល់មាត់មច្ចុរាជ ហើយសូមទ្រង់ទតចុះ ទូលព្រះបង្គំទទួលព្រះរាជទានដំណេកត្រាំក្នុងឈាមរបស់ខ្លួន មានព្រួញមុតពីខាងស្តាំទៅធ្លាយឆ្វេង មានឈាមខ្ពុរ ចេញតាមមាត់ចាប់ពើតណាស់ព្រះអង្គអើយព្រះអង្គ! ″

តើការកសាងបារមី(មេត្តាបារមី)របស់ព្រះពោធិសត្វជាប់ទាក់ទងនឹងបញ្ហាអ្វីខ្លះ?

ខ- ម្ងលបញ្ហារឿង

ការកសាងបារមី គឺជាលក្ខណៈពិសេស នៅក្នុងរឿងទសជាតក ។តាមរយៈដំណើររឿងតួអង្គព្រះពោធិសត្វបានបំពេញនូវសកម្មភាពផ្សេងៗ ដើម្បីបានសម្រេចនូវ បារមីធម៌ របស់ខ្លួន។ ក្នុងរឿងសុវណ្ណសាម តួអង្គព្រះពោធិសត្វបំពេញនូវមេត្តាបារមី ហើយជុំវិញការបំពេញ មេត្តាបារមីនេះ ជាប់ទាក់ទងនឹងបញ្ហាដូចតទៅ ៖

ក. បញ្ហាការចេញទៅបួសជាឥសីនៃទុកូល និងបារិកា

រឿង បានលើកយកបញ្ហាការមិនធ្វើបាណាតិបាតា(មិនសម្លាប់ជីវិត)ការមិនសេពនូវកាម និងការចេញទៅបួស ជាឥសី នៃប្តីប្រពន្ធ ជាកូននាយនេសាទទាំងពីរគ្រួសារមកចងជាបញ្ហាក្នុងដំណើររឿង។ការបួសជាឥសីនិងការមិនប្រព្រឹត្តកាមជារឿងត្រេកអរនៃព្រះឥន្ទ្រ ប៉ុន្តែដោយការប្រមើលមើលរបស់ព្រះឥន្ទ្រទៅអនាគតឥសី ទាំងពីរ(ទុកូល និងបារិកា)នឹងពិការភ្នែកទាំងពីរ ហេតុនេះទើបមានពោធិសត្វពីស្ថានទេវលោកមកចាប់កំណើត នៅពេលព្រះឥន្ទ្រឱ្យទុកូល យកដៃស្ទាបផ្ទៃបារិកា។

ដូច្នេះ ការចេញបួសជាឥសី ការមិនសម្លាប់ជីវិតសត្វ និងការមិនប្រព្រឹត្តក្នុងផ្លូវកាមនៃអ្នកទាំងពីរ គេថា ជាកិរិយាមួយប្រកបដោយធម៌ ធ្វើឱ្យព្រះឥន្ទ្រស្ថានទេវលោកមានចិត្តរំភើប ទើបយាងពោធិសត្វឱ្យច្យុតមកចាប់កំណើត ហើយមានចិត្តប្រកបដោយក្តីមេត្តាក្រៃលែង។

ខ. បញ្ហាពិការភ្នែកនៃឥសីទាំងពីរជាមាតាបិតា

ការលើកយក បញ្ហាទុកូល-បារិកាឥសី ជាមាតាបិតានៃពោធិសត្វ រស់នៅក្នុងអាស្រមក្នុងព្រៃក្បែរស្ទឹងមិគសម្មតា ពេលចេញទៅរកបេះផ្លែឈើបានជ្រកភ្លៀងនៅក្រោមដើមឈើលើដំបូក ហើយត្រូវពស់វែកព្រួសពិស ឱ្យខ្វាក់ភ្នែកទាំងពីរនាក់។ ការពិការភ្នែកនៃមាតាបិតា ជាឱកាសល្អសម្រាប់ពោធិសត្វ(សុវណ្ណសាម) ក្នុងការ ថែទាំបម្រើ តបស្នងសងគុណអ្នកទាំងពីរគ្រប់ពេលវេលា ហើយសុវណ្ណសាមបានសម្តែងនូវសេចក្តីរីករាយដោយ បាន

បម្រើមាតាបិតា។" ពោធិសត្វបិតនៅពីចម្ងាយ ហុចឈើច្រត់មួយដ៏វែង ឱ្យមាតាបិតាគោងចុះអំពីដំបូករួចមកក៏យំសោក សង្រែងសង្រៃ ដោយក្តីអាណិតមាតាបិតា ហើយបែរជាសើចវិញដោយគិតថា នឹងបានបម្រើមាតាបិតាជាប់មិនដាច់។"

មួយវិញទៀត ទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ សុវណ្ណសាម នៅតែនឹកគិត និងព្រួយបារម្ភចំពោះមាតាបិតាពិការទាំងពីរជានិច្ច។ ជាក់ស្តែង ខ្លួនឯងត្រូវព្រួញធ្លាយពីស្តាំទៅឆ្វេង ហូរឈាម ឈឺចាប់ជិតដាច់ខ្យល់ស្លាប់ហើយនៅតែគិតគួរពីបញ្ហាសុខទុក្ខរបស់មាតាបិតាជានិច្ច នៅពេលដែលគ្មានរូបខ្លួន។

"ឱមាតាបិតាជាទីគោរពរបស់កូនអើយ! លោកមានជីវិតយ៉ាងយូរណាស់ត្រឹម៦ថ្ងៃប៉ុណ្ណោះ ព្រោះមាន ត្រឹមតែកោគជនជាផលានុផល ងងឹតងងល់រកទឹកពុំបាន មុខជានឹងស្លាប់ដោយឥតទឹកពុំខានឡើយ ព្រះអង្គអើយ ព្រះអង្គ! ការត្រូវកាំសរនេះ មិនជាសេចក្តីទុក្ខធ្ងន់ របស់ទូលបង្គំទេ មានតែខានឃើញមាតាបិតា ទើបជាសេចក្តី ទុក្ខធ្ងន់ដ៏ក្រៃលែងរបស់ទូលព្រះបង្គំ ... ។"

បញ្ហាការពិការភ្នែកនៃមាតាបិតានេះហើយ អាចឱ្យពោធិសត្វបម្រើគ្រប់សព្វទាំងថ្ងៃទាំងយប់ វាជាមូលដ្ឋាន ឬ ជាបច្ច័យក្នុងការកសាងនូវមេត្តាបារមី មិនតែប៉ុណ្ណោះវាជាដំណាក់កាលមួយសម្រាប់ដកពិសោធ និងជាឧបសគ្គដែលតម្រូវឱ្យពោធិសត្វត្រូវឆ្លងកាត់ ដើម្បីសម្រេចនូវសម្ពោធិញ្ញាណ ជាព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ ។

គ. បញ្ហាព្រះបិលយក្ខក្សត្រដែនកាសីចូលចិត្តសាច់ម្រឹគ និងការបរបាញ់

ដំណើរនៃការសាងបារមីនៃព្រះពោធិសត្វតែងតែជួបប្រទះនូវបញ្ហា ដែលជាឧបសគ្គរាំងស្ទះដែលធ្វើឱ្យអាក់ដំណើរបំពេញបារមីរបស់ពោធិសត្វជានិច្ច។ ម៉្យាងវិញទៀតការសាងបារមីបានសម្រេច លុះត្រាតែមានការពិសោធពីខ្លួនឯងផង និងពីអ្នកដទៃផង។ សកម្មភាពរបស់ បិលយក្ខ ជាផ្នែកមួយចូលរួមធ្វើឱ្យ សុវណ្ណសាម បានសម្រេចនូវមេត្តាបារមីរបស់ខ្លួន ។ នៅពេលត្រូវគ្រាប់ព្រួញរបស់បិលយក្ខហើយ សុវណ្ណសាម នៅតែសម្តែងនូវ សេចក្តីមិនខឹងក្រោធ ហើយថែមទាំងផ្សាយនូវសេចក្តីមេត្តាចំពោះក្សត្រដែនកាសីអង្គនោះទៀតផង។ ពោធិសត្វ បានទូន្មានចំពោះបិលយក្ខក្សត្រ ឱ្យប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតា កូន ប្រពន្ធ និងអ្នកដទៃ ហើយប្រកាន់នូវ សីលប្រាំ ឬ សិក្ខាបទទាំង ប្រាំ ជាពុទ្ធបញ្ញត្តិ ទៀតផង។

" សត្វណាចិញ្ចឹមនូវមាតាបិតាដោយធម៌ ទេវតាទាំងឡាយតែងរក្សានូវសត្វនោះ បណ្ឌិតទាំងឡាយតែងសរសើរនូវសត្វនោះ ។ បពិត្រព្រះបាទបិលយក្ខ សូមព្រះអង្គប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតា បពិត្រព្រះរាជាលុះព្រះអង្គបានប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតាក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ពុំខាន។"

ឃ- តួនាទីអប់រំនៃរឿងសុវណ្ណសាមជាតក

តាមរយៈសាច់រឿងទាំងមូល អ្នកនិពន្ធបានបង្ហាញពីគោលគំនិត (គំនិតអប់រំ)សំខាន់ៗ ដូចតទៅ៖

- ការដឹងគុណចំពោះមាតាបិតា

កូនត្រូវមានចិត្តកតញ្ញូ និងមានកាតព្វកិច្ចតបគុណចំពោះមាតាបិតា ព្រោះលោកជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចដល់ធំ និងផ្តល់នូវអ្វីៗគ្រប់បែបយ៉ាងដល់កូន។ ឪពុកម្តាយជាអ្នកមានគុណដ៏លើសលប់ និងជាបុគ្គលដែលជាទីសក្ការបូជាចំពោះកូនលោកតែងមានព្រហ្មវិហារធម៌ចំពោះកូន ការពារកូន ណែនាំកូនឱ្យដើរផ្លូវល្អ។ ឪពុកម្តាយ ត្រូវបានគេចាត់ទុកថាជាព្រះកន្លោង នៅក្នុងផ្ទះ លោកជាបុព្វទេវតា ថែរក្សាកូនមុនគេបង្អស់ និង ជាបុព្វាចារ្យ គឺជាគ្រូ បង្រៀនូវអ្វីៗដល់កូន មុនគ្រូដទៃណាណា ទាំងអស់។ ដូចនេះ កូនត្រូវតែមានចិត្តកតញ្ញូ និងកតវេទី ចំពោះ

មាតាបិតា ត្រូវដើរតាមគន្លងធម៌ និងស្តាប់តាមការទូន្មានប្រៀនប្រដៅរបស់លោកទាំងពីរ ។ បុគ្គលដែលបានធ្វើនូវ ការតបស្នងសងគុណចំពោះមាតាបិតា តែងទទួលបាននូវសេព្វសាធុការពរ និង កុសលធម៌ដែលអាចជៀសផុតពី ឧបសគ្គ និងគ្រោះថ្នាក់ផងទាំងពួងបានថែមទៀតផង។ ជាក់ស្តែង សុវណ្ណសាម ជាបុគ្គល ដឹងគុណមាតាបិតា និង មានមេត្តាចំពោះមនុស្ស សត្វ ដទៃ ទទួលបាននូវការស្រលាញ់រាប់អានពីសព្វសត្វក្នុងព្រៃ មនុស្ស ទេវតា ជា ពិសេសដោយអានុភាពនៃ ការដឹងគុណចំពោះមាតាបិតា និងសេចក្តីមេត្តាចំពោះ មនុស្ស សត្វ ធ្វើឱ្យទេវតារំភើប ផ្តល់ពរសព្វសាធុការ ឱ្យរស់រានមានជីវិតឡើងវិញ ក្រោយពេលដែលត្រូវព្រួញរបស់បិលយក្ខ ។

- ឱ្យមនុស្សប្រព្រឹត្តអំពើល្អ មានសេចក្តីមេត្តា ប្រកាន់នូវចរិយាធម៌ និងសីលប្រាំ

អំពើបាប ជាប្រភពនៃទុក្ខ ដែលនាំទៅកាន់ភាពលំបាកវេទនា និងនរក។ ដូចនេះ សេចក្តីមេត្តា ការមិនចង គំនុំ និងការរក្សានូវសីលប្រាំ គឺ ៖

១- បាណាតិបាតា គឺ ការមិនសម្លាប់សត្វ

២- អទិន្នា គឺ ការមិនឆក់ប្លន់ លួចទ្រព្យសម្បត្តិអ្នកដទៃ

៣-កាមេសុមច្ឆាគឺការមិនប្រព្រឹត្តខុសក្នុងផ្លូវកាម (ប្រព្រឹត្តខុសលើ ប្រពន្ធ កូនអ្នកដទៃ)

៤- មុសា គឺការមិនពោលពាក្យកុហក

៥- សុរា គឺការមិនសេពនូវគ្រឿងស្រវឹងផ្សេងៗ (សុរា និង មេរាយ)

ការប្រកាន់នូវធម្មចរិយា និងសីល៥ នេះ នាំមកនូវសេចក្តីសុខចំពោះ ខ្លួនឯងគ្រួសារ និងសង្គម នៅក្នុង បច្ចុប្បន្នជាតិ និងអនាគតជាតិ ។ ដូចមានសេចក្តីនៅក្នុងទំព័រ៧០-៧១ ថា ៖

"... បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម្មចរិយាក្នុងលោកនេះហើយ ទ្រង់នឹងទៅកាន់ឋានសួគ៌ ធម្មចរិយា ដែលទ្រង់ប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្តីសុខ។ ...ទេវតាឥន្ទ្រព្រហ្មទាំងឡាយ ដែលបានទៅកាន់ឋានសួគ៌ក៏ ព្រោះតែធម្មចរិយាដែលខ្លួនប្រព្រឹត្តល្អនេះឯង សូមព្រះអង្គកុំប្រហែសធ្វេស នឹងធម្មចរិយាឡើយ។ ព្រះពោធិសត្វ ថ្វាយដំបូន្មានដល់ព្រះរាជាយ៉ាងនេះហើយ ទើបថ្វាយសីលប្រាំតទៅទៀត ។"

- អប់រំឱ្យមនុស្សចេះរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព

ការអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក និងចេះជួយគ្នាក្នុងគ្រាមានអាសន្ននាំមកនូវសន្តិភាព ។ មនុស្សមិនអាច រស់នៅតែម្នាក់ឯងបានឡើយ គឺតែងមានការពឹងពាក់គ្នាទៅវិញទៅមក ជួយយកអាសារគ្នាពេលជួបបញ្ហាអ្វីមួយ ដោយយថាហេតុ ។ ជាក់ស្តែងដូច ទេវធីតាវេសន្ទរី បានណែនាំបិលយក្ខ ឱ្យមានការភ្ញាក់រលឹក និងទំនួលខុសត្រូវ ចំពោះទង្វើខ្លួន ហើយថែមទាំងជួយអាសារដល់សុវណ្ណសាម ពេលជួបនឹងគ្រោះថ្នាក់ទៀតផង ។ ជាពិសេសទៅទៀត មនុស្សត្រូវមាន ការដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ជៀសវាងការប្រើកម្លាំងបាយ កំហឹងទល់នឹង កំហុស គំនុំ គំគួន សងសឹកគ្នាទៅវិញទៅមក ដែលនាំឱ្យចំណងកាន់ជ្រៅដោះស្រាយមិនបាន។

៧.៣.៤. រឿងនេមិរាជជាតក

ក.ប្រធានរឿង

រឿងនេមិរាជ បានបង្ហាញពីការអធិដ្ឋានបារមី គឺការជឿស៊ប់ទៅលើកុសលកម្ម។

ខ. មូលបញ្ហារឿង

ជុំវិញប្រធានរឿងនេះយើងអាចកំណត់នូវបញ្ហាជាច្រើន ជាមែកធាង ដែលស្ថិតនៅជុំ វិញការអធិដ្ឋានបារមី

(ការជឿស៊ប់) យើងអាចដឹងនូវបញ្ហាមួយចំនួនដូចជា៖

- ការចេញទៅសាងផ្នួសរបស់ព្រះអង្គ
- ការរក្សាសីលឧបោសថ
- ការធ្វើកុសលបរិច្ចាគទាន
- ការធ្វើទណ្ឌកម្មចំពោះអ្នកដែលធ្វើអំពើបាបផ្សេងៗ
- ការសោយសុខលើទិព្វសម្បត្តិ ដែលបានមកពីការកសាងបុណ្យ

តាមរយៈការលើកឡើងនេះ ពិតជាបានធ្វើឲ្យយើងដឹងពីមូលហេតុនៃការជឿស៊ប់ទៅ លើការកសាងអំពើបុណ្យ ដែលផ្តល់ជាកុសល និងការសាងអំពើបាប ។

គ.តួនាទីអប់រំនៃរឿងនេមិរាជជាតក

+បញ្ហាទី១ ការយាងចេញទៅសាងផ្នួសរបស់ព្រះអង្គ

ដើម្បីសម្រេចសម្មាសម្ពោធិញ្ញាណ ត្រាស់ដឹងជាព្រះពុទ្ធ ព្រះអង្គត្រូវយាងចេញទៅ សាងភ្នួស ស្វែងរកធម៌នៅ ក្នុងព្រៃព្រឹក្សា ។ ព្រះអង្គយល់ថា ការចេញទៅសាងភ្នួសអាច ជួយឲ្យខ្លួនព្រះអង្គផ្ទាល់ និងប្រជារាស្ត្រ បានជ្រះស្រឡះពីកាមកិលេស និងអាច ដំរះអស់ នូវ បាបកម្មទាំងឡាយ ។ ក្នុងពុទ្ធសាសនាគេច្រើននិយាយពីការ ចេញទៅសាងផ្នួសបំពេញ បារមី ដែលអាចរកឃើញនូវផ្លូវត្រឹមត្រូវ វៀរចាកអំពើអកុសល ។ ដូច្នេះការចេញសាងភ្នួស មានសារៈសំខាន់ណាស់ចំពោះព្រះពុទ្ធសាសនា។ ក្នុងការចេញទៅសាងផ្នួសរបស់ព្រះអង្គ ព្រះអង្គបានរក្សា នូវសីល ឧបោសថ និងការធ្វើកុសល បរិច្ចាគទាន។ ព្រះអង្គបានឱ្យទាន ដល់ជនទុរគតគ្រប់ពេលវេលា ហើយបានយកចិត្តទុកដាក់ទេសនា អប់រំណែនាំអាណា ប្រជានុរាស្ត្រ មន្ត្រីតូចធំ ឲ្យសាងនូវអំពើសុចរិត កុំលោភលន់ កុំកេងប្រវ័ញ្ចគ្នាកុំកាប់សម្លាប់គ្នា កុំបង្កវិនាសកម្មផ្សេងៗដល់សង្គម។ ព្រះអង្គបានរក្សានូវព្រហ្មវិហារធម៌ទាំង៤ ក្នុងការដឹកនាំចាត់ចែងនគរ ហើយតែងតែរក្សានូវសីលប្រាំយ៉ាងខ្ជាប់ខ្ជួន ដើម្បីតម្រង់ផ្លូវចិត្ត ឱ្យតាំងចិត្តនូវក្នុងផ្លូវល្អ។ ព្រះអង្គមិនប្រព្រឹត្តអំពើប្រទូស្តនឹងផលប្រយោជន៍អ្នកដទៃ ដោយព្រះអង្គតែងតែបានណែនាំឱ្យពលរដ្ឋគ្រប់ៗគ្នា កសាងនូវប្រយោជន៍ ជៀសវាងកុំឱ្យមានការក្តៅក្រហាយដល់ខ្លួនទៅថ្ងៃក្រោយ។ ដូចនេះ ការចេញទៅសាងផ្នួស រក្សាសីល និងការធ្វើនូវកុសល អាចធ្វើឱ្យព្រះអង្គសម្រេចត្រាស់ដឹងជាព្រះពុទ្ធ ។

+បញ្ហាទី២ ការធ្វើកុសលបរិច្ចាគទាន

ការធ្វើកុសលបរិច្ចាគទាន វាមានសារៈសំខាន់ណាស់ក្នុងការជួយសង្គ្រោះគ្នាទៅវិញ ទីមក ហើយវាក៏បានបង្ហាញនូវចិត្តមេត្តាសន្តោសប្រោសប្រណី និងចិត្តសប្បុរសធម៌ពីសំ ណាក់ព្រះអង្គ។ ព្រះនេមិរាជ ព្រះអង្គបានបរិច្ចាគទានយ៉ាងច្រើនដល់ប្រជានុរាស្ត្រ ដូចជាទ្រង់

ឲ្យកសាងនូវសាលាទានប្រាំខ្នង ទ្រង់បរិច្ចាគប្រាក់ព្រះរាជទ្រព្យមួយពាន់កហាបណៈ សំរាប់ ព្រះរាជទានដល់អ្នកកំសត់ទុគត៌ ក្នុងសាលានីមួយៗរាល់ៗថ្ងៃ ដោយព្រទ័យជ្រះថ្លា និងសទ្ធាដ៏ មហិមារបស់ព្រះអង្គ។ ការបរិច្ចាគទានរបស់ព្រះ ព្រះអង្គចង់បង្ហាញអោយឃើញនូវកុសល ផលបុណ្យដែលទទួលបានពីផលទាន គឺអោយខិតខំកសាងអំពើល្អ នឹងអាចកើតនៅឋាន សួគ៌ ដែលជាឋានរបស់ទេវតា។

+បញ្ហាទី៣ ការរក្សាសីលឧបោសថ

ព្រះអង្គបានរក្សាសីល៥ជានិច្ច តែព្រះអង្គក៏មិនភ្លេចការរក្សាសីលឧបោសថផងដែរ ទ្រង់តែងបបួលប្រជានុ

រាស្ត្រក្នុងការធ្វើបុណ្យជាកុសល ទ្រង់តែងសំដែងធម៌ប្រាប់ផ្លូវឋាន សួគ៌ ព្រមទាំងនាំប្រជានុរាស្ត្រឲ្យចេះខ្លាចនរក។

+បញ្ហាទី៤ ការធ្វើទណ្ឌកម្មចំពោះអ្នកដែលធ្វើអំពើបាបផ្សេងៗ

មនុស្សម្នាក់ៗ ដែលកសាងអំពើអាក្រក់ តែងតែទទួលបាននូវផលអាក្រក់ជាពុំខាន ហើយក៏មិនអាចទូទាត់ដោយអំពើល្អបានឡើយ។ គួយ៉ាងព្រះអង្គបានយាងទៅដល់ឋាននរក នៅទីនោះមាតុលីបានបង្ហាញពីគ្រប់សត្វនរកដែលទទួលទណ្ឌកម្មសព្វសារពើ ដែលបានធ្វើបាបកាលពីនៅមានជីវិតរស់រាន ជាមនុស្សមិនបានធ្វើបុណ្យសាងកុសលទេ ដល់ពេលស្លាប់ទៅធ្លាក់ទៅនរក ហើយទទួលទណ្ឌកម្មដែលបានធ្វើ អ្នកដែលមានកម្មច្រើន ទទួលការធ្វើទារុណកម្មច្រើន ដូចជា ពីដើមជាស្រីលេងល្បែងផ្សេងៗ ជើរលេងមិនឆ្អែត លះបង់ស្វាមី អ្នកសម្លាប់សត្វ កេងបន្លំស្រូវអង្គរ .... ។

+បញ្ហាទី៥ ការសោយសុខលើទិព្វសម្បត្តិ ដែលបានមកពីការកសាងបុណ្យ

ដើម្បីរស់នៅប្រកបដោយសេចក្តីសុខ សុភមង្គល មនុស្សត្រូវកសាងអំពើ ដែលជា កុសល លះបង់នូវកិលេសទាំងឡាយ ប្រកាន់ខ្ជាប់នូវសីលប្រាំ ខិតខំធ្វើបុណ្យទាន ដើម្បីសម្រេចបំណងប្រាថ្នារបស់ខ្លួន។ ព្រះអង្គបានទៅទតនៅ ឋានសួគ៌ ដែលជាឋានដែលល្អវិចិត្រ ប្រណិតទៅដោយវិមានដ៏រុងរឿង សំបូរទៅដោយកែវពិទូរ្យសូកាន្ត នេះក៏ដោយការធ្វើអំពើរបស់ទេវបុត្រ ទេវធីតាដែលបានធ្វើបុណ្យ នៅពេលដែលព្រះអង្គរស់នៅជាមនុស្សពួក គេខិតខំប្រព្រឹត្ត និងប្រតិបត្តិនូវអំពើល្អ កសាងនូវអំពើជាកុសល ចែកទាន កសាងសួនច្បារ ស្រះទឹក អណ្តូងទឹក ផ្លូវថ្នល់ និងស្ពាន ហើយរក្សានូវសីលឧបោសថ ម្ល៉ោះហើយនៅពេលពួកគេស្លាប់ទៅ ក៏កើតនៅឋានសួគ៌ ដែលមនុស្សជាច្រើនប្រាថ្នាចង់ទៅ ពីព្រោះនៅទីនោះជាឋានដែលសប្បាយរីករាយ មានគ្រប់អម្ពរគ្រប់បែបយ៉ាង និងសូរតន្ត្រីទិព្វ ជាសំឡេង ដ៏ពិរោះរងំគួរឱ្យចង់ស្តាប់ ។

+គំនិតទូទៅរបស់រឿង

-**កុសលកណ្ឌ** ជាការបរិយាយរៀបរាប់ពីការធ្វើបុណ្យ បរិច្ចាគទានដោយការកសាងសាលាទានប្រាំខ្នង និងប្រាក់ផ្គាល់ព្រះអង្គ សម្រាប់ពួកកំសត់ទុគតនិងរក្សាសីលឧបោសថ។ ការធ្វើអំណោយទានរបស់ទ្រង់បានផ្តល់ ជំនឿ និងសទ្ធាជ្រះថ្លារបស់ប្រជាជន រឹងរឹតតែឱ្យ គេមានជំនឿលើពុទ្ធសាសនាកាន់តែខ្លាំង និងមានការកោតខ្លាច គោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន។ កុសលរបស់ទ្រង់បានធ្វើឲ្យទ្រង់មានសំណាងបានជួបព្រះឥន្ទ្រ ដែលជាស្តេចទេវតា មិនត្រឹមតែប៉ុណ្ណោះ ព្រះឥន្ទ្របានបំភ្លឺឱ្យឃើញពីព្រហ្មចរិយាធម្មថ្លៃថ្លាជាងផលនៃទានធម្មតា។ កិត្តិនាមរបស់ទ្រង់បានល្បីរន្ទឺដល់ឋានលើ ធ្វើឱ្យទេវតាទាំងឡាយ ចង់ស្តាប់នូវពុទ្ធឱវាទរបស់ទ្រង់ ធ្វើឱ្យទ្រង់មានភព្វសំណាងបានចុះទតឋាននរក និងឋានសួគ៌ ឃើញពីភាពខុស ប្លែកគ្នារវាងស្ថានទាំងពីរ ។

- **និរយកណ្ឌ** ការចុះទតឋាននរករបស់ព្រះបាទនេមិរាជ លោកបានឃើញ នូវសត្វ នរក ទាំងឡាយទទួលទោសទណ្ឌដែលខ្លួនបានសាង ។ អ្នកណាធ្វើបែបណា នឹងទទួល បាន ផលនោះមកវិញ ។ មាតលី បានរៀបរាប់សព្វគ្រប់នូវសត្វនរក ដែលទទួលរងនូវអំពើ ទារុណកម្មដូច នេះ មកពីជាតិមុនបានសាងអ្វីខ្លះដល់ព្រះបាទនេមិរាជ ។ ការរៀបរាប់ របស់ មាតលី ធ្វើឲ្យយើងមានអារម្មណ៍ព្រឺព្រួចគួរខ្លាច ហើយអំពើទាំងនោះកើតមាន ក្នុងសង្គម មនុស្សជាក់ស្តែង វា កាន់តែធ្វើឲ្យមនុស្សខ្លាចបាបកាន់តែខ្លាំង ។ ដូចនៅក្នុងឃ្លាដែលរៀប រាប់ពីសត្វនរក ដែលត្រូវពួកនិរយកាន់អាវុធ ដេញវាយសំពងធ្លាក់ចុះក្នុងស្នឹងវេតរណីស្នឹង នោះដេរដាសដោយព្រៃផ្តៅមានបន្លាប៉ុនៗចំពុះទង់ ។ សត្វនរកទាំងនោះស្ទុះទម្លាក់ធ្លាក់ ទៅលើព្រៃផ្តៅ ត្រូវបន្លាមុតជ្ជក់រយះរយោយដូចគេអង្កន់ ភ័យស្លន់កញ្ជ្រោល ទម្លាក់ខ្លួន

ទៅ លើ ចម្រូងដែកស្រួចប៉ុនដៃមត្នោត ប្រឹងលើច្រឡោតធ្លាក់ទៅលើស្លឹកឈូកដែក មានឡាមមុតដូចកាំបិតកោ ..... ធ្លាក់ក្នុងស្នឹងនោះទៅទៀត ។ ពួកនេះពីមុនជាមនុស្ស មានកម្លាំង មានអានុភាព មានចិត្តអាក្រក់ បៀតបៀនរំលោភលើអ្នកទន់ខ្សោយ។ សត្វ នរកដែលធ្វើបាបកម្មអ្វីទទួលផលគួរឱ្យតក់ស្លុត ។ មនុស្សដែលមានជំនឿកាន់ឧបោសថនៅ ពេលស្តាប់ និងទទួលពុទ្ធឱវាទ ពួកគេមានសទ្ធាជ្រះថ្លានឹងទទួលបានផលល្អពីអំពើរបស់គេ ។

- **សគ្គកណ្ឌ** បន្ទាប់ពីទតឋាននរក ការរងទារុណរបស់សត្វនរក ដែលប្រព្រឹត្តអំពើបាប ព្រះនេមិរាជបានទតនូវឋានសួគ៌ ដែលជាឋានរបស់ទេវតាឃើញភាពល្អ ល្អះនៃឋានសួគ៌ និងពពួកទេវតាដែលសោយសុខនៅលើទិព្វសម្បត្តិ។ ព្រះបាទនេមិរាជមិនបានភ្លើតភ្លើននឹងភាពឡូយឆាយទាំងនោះឡើយ ទ្រង់នូវតែ ប្រកាន់ខ្ជាប់ការធ្វើកុសលដោយការឲ្យទាន ទ្រង់មិនព្រមទទួលនៅអ្វីដែលគេឱ្យឡើយ។ នៅត្រង់ឃ្លាមួយដែលព្រះបាទនេមិរាជដោះស្រាយប្រស្នាតបនឹងព្រះឥន្ទ្រថា " ខ្ញុំព្រះអង្គ អរព្រះគុណ ណាស់ហើយ ប៉ុន្តែ**វត្ថុណាដែលបានព្រោះគេឱ្យ វត្ថុនោះមិនខុសពីទ្រព្យដែលខ្ជីគេទេ** "។ នេះជាទស្សនៈ អប់រំដ៏ល្អ ការឱ្យទានរបស់ទ្រង់ដោយកុសលជ្រះថ្លា តែក៏ បង្កប់ទៅដោយខ្លឹមសារអប់រំមួយចំនួន ដូចជាពាក្យដែលទ្រង់និយាយជាមួយព្រះឥន្ទ្រ អប់រំដល់មនុស្សទូទៅត្រូវចេះពឹងលើខ្លួនឯងពុំគប្បីពឹងទៅលើការឱ្យទានរបស់គេឡើយ។ ត្រូវសង្វាតស្វាធ្យាយរកបរចិញ្ចឹមជីវិតប្រកបដោយផ្លូវធម៌ មិនគេងប្រវ័ញ្ចដណ្តើមឈ្នា នីសរបស់ទ្រព្យអ្នកដទៃ ត្រូវស្ថិតនៅក្នុងភាពស្មើភាពនោះ ទើបជីវិតស្លាប់ទៅជួបសុខជួបឋានសួគ៌ ។

+គោលដៅអប់រំ

រឿងនេមិរាជជាតក៍ ជារឿងដែលលើកយកទស្សនៈនៃការអប់រំមកពន្យល់បង្ហាញដល់ អ្នកអានឱ្យយល់ច្បាស់ពីចលនាពុទ្ធនិយម ដូចជាៈ

- អប់រំមនុស្សឱ្យកសាងអំពើល្អ ដែលជាកុសលដើម្បីឲ្យខ្លួនរៀចាកឱ្យផុតពីទុក្ខលំបាកវេទនា ដែលយើងមើលមិនឃើញទៅថ្ងៃអនាគត។ ជាពិសេសការកសាងអំពើល្អអាចធ្វើ ឱ្យមនុស្សជ្រះស្រឡះពីអំពើបាបផ្សេងៗនិងមានសេចក្តីសុខហើយក៏ជាគំរូដ៏ល្អ មួយសម្រាប់ អ្នកកាន់ពុទ្ធសាសនា ។
- អប់រំមនុស្សឱ្យប្រកាន់ខ្ជាប់នូវសីលប្រាំ ដែលជាផ្នែកនៃព្រះពុទ្ធសាសនាដែលអប់រំ មនុស្សឱ្យរៀវឆ្ងាយពី អំពើអបាយមុខផ្សេងៗ ដូចជាសម្លាប់សត្វ ផឹកស្រាលួចឆក់ទ្រព្យ សម្បត្តិ និយាយកុហក និងលួចប្តីប្រពន្ធគេ អ្វីដែល មិនមែនជារបស់ខ្លួនឯង។
- អប់រំមនុស្សឱ្យប្រកាន់នូវសីលឧបោសថ (សីលប្រាំបី) ដែលវាបន្ថែមទៅលើសីលប្រាំ ហើយត្រូវតែ ប្រកាន់ឱ្យបានខ្ជាប់ខ្ជួន និងប្រតិបត្តិតាម ជាពិសេសត្រូវរៀចាកនូវការ ស្លៀកពាក់ធើតឆាយ ពាក់គ្រឿងអលង្ការ គ្រែដេកមិនឲ្យលើសពីកន្លះម៉ែត្រ និងមិនត្រូវ លេងល្បែងស៊ីសង។
- អប់រំមនុស្សឱ្យចេះបែងចែកខុសត្រូវ អាក្រក់ល្អ សខ្មៅឱ្យដាច់ស្រឡះពីគ្នា។

៧.៣.៥. រឿងមហោសថជាតក

ក. ប្រធានរឿង

ក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយម ច្រើនលើកយកប្រធានបទ "ការកសាងបារមី "មកចោទ និងដោះស្រាយ។ ក្នុងរឿងព្រះមហោសថ គឺបានបង្ហាញពីការកសាងបញ្ញាបារមីទាំង ១៩ របស់ តួអង្គព្រះពោធិសត្វ ។

ខ. មូលបញ្ហារឿង

មូលបញ្ហារឿងជាគំនិតសំខាន់នៅក្នុងសាច់រឿងហើយវាជាសមិទ្ធផលរបស់ប្រធានរឿង។ មូលបញ្ហា

ដែលធ្វើឱ្យព្រះមហោសថទទួលបាននូវបញ្ហាបារមីមាន:

បញ្ហាទី១ ការដោះស្រាយលើបញ្ហាទាំង១៩ ដែលមានរូបភាពផ្សេងៗគ្នាដូចខាង ក្រោម:

-**ទី១ មំសំ(សាច់)**មានសត្វខ្លែងមួយបានឆាបឆក់យកសាច់មួយដុំពីជ្រុញអ្នកលក់ហើរឆ្ពោះ ទៅកាន់អាកាស ហើយក្មេងឃើញក៏រត់ដេញ ខ្លះដួល តែសត្វនោះមិនព្រមទម្លាក់ ព្រះមហោសថ ក៏ឃាត់ក្មេងទាំងនោះ ពេលនោះ មហោសថបានស្ទុះមួយទំហឹងទៅជាន់ស្រមោលសត្វខ្លែងហើយ ស្រែកខ្លាំងៗ ធ្វើឱ្យរលកសំឡេងនោះ ទៅប៉ះនឹង សត្វខ្លែង ហើយធ្វើឱ្យសត្វខ្លែងភ័យក៏ទម្លាក់ដុំសាច់នោះមក ។

- ទី**២ គោណោ (សត្វគោ)** ការដោះស្រាយបញ្ហារវាងបុរសម្ចាស់គោ និងចោរ។ ការប្តឹង គ្នារវាងម្ចាស់គោ និង ចោរ ធ្វើឱ្យព្រះមហោសថចេញមុខដោះស្រាយប្រកបដោយ យុត្តិធម៌ ។

- **ទី៣ កណ្ហិ (សង្វារ)** ដោះស្រាយបញ្ហាដោយឱ្យស្ត្រីម្ចាស់សង្វារឈ្នះលើស្ត្រីជាចោរ ។

- **ទី៤ សុត្តំ(អំបោះ)** មានស្ត្រីម្នាក់រវៃអម្បោះដាក់ផ្លែទម្លាប់ខាងក្នុងធ្វើជាហុងអម្បោះ ពេលធ្វើដំណើរទៅដល់ ស្រះបោក្ខណីមួយ ក៏ទុកហុងអំបោះនៅលើសំពត់ ហើយក៏ចុះទៅងូតទឹក ពេលនោះមានស្ត្រីចោរម្នាក់មកលួច ហើយ ម្ចាស់មកទាន់ទាយកវិញ ស្រីចោរមិន ព្រមឱ្យរឿង នេះបានដឹងដល់ព្រះមហោសថ ហើយមហោសថបានហៅអ្នក ទាំងពីរមកសួរ តាមដំណើររឿង ពេលដឹងរឿងហើយក៏បានកាត់ក្តីស្រីជាម្ចាស់ហុងអំបោះឈ្នះ ។

- **ទី៥ បុត្តោ (កូន)** ការដោះស្រាយទៅលើបញ្ហាមានស្រីម្នាក់មានកូនមួយទុកចោល នៅមាត់ស្រះ ហើយចុះ ទៅងូតទឹកក្នុងស្រះបោក្ខណី ពេលនោះមានយក្ខមួយប្រែក្រឡា យកកូននោះបំរុងហែកស៊ី ម្តាយមកទាន់ក៏ដណ្តើម យក្ខនោះមិនព្រមហើយប្រកែកឮដល់ មហោសថ ហើយមហោសថក៏បានគូសវង្វង់ដាក់កូននោះនៅចំកណ្តាលឱ្យ ស្រីទាំង២នាក់ នោះដណ្តើមគ្នា ម្ខាងចាប់ដៃ ម្ខាងចាប់ជើង ម្តាយពិតជាមានចិត្តអាណិតអាសូរកូនក៏បាន លែងទៅ ពេលនោះមហោសថក៏បានដឹង ហើយបង្ហាញនូវស្រីជាយក្ខនោះ ។

- **ទី៦ គោធោ** (បុរសឈ្មោះគោធកាឡ) មានបុរស និងស្ត្រីជាប្តីប្រពន្ធនឹងគ្នាបានធ្វើ ដំណើរទៅលេងស្រុក កំណើតខាងប្តីទៅដល់មាត់ស្ទឹងមួយមិនហ៊ានឆ្លងពេលនោះមានបុរសម្នាក់មកជួយចម្លង តែការចម្លងនោះយក ប្រពន្ធទៅមុនហើយក៏បង្ហួសទៅបុរសជាប្តីខឹងយ៉ាងខ្លាំង ហើយឆ្លងទៅទាន់ក៏ប្រកែកគ្នាដំណឹងនេះឮដល់មហោសថ មហោសថក៏បានដោះស្រាយបញ្ហានេះប្រកបដោយយុត្តិធម៌ ។

- **ទី៧ រថោ (រទេះ)** ការដោះស្រាយទៅលើបញ្ហាការក្រឡាខ្លួនរបស់ព្រះឥន្ទ ទៅលួចរទេះ បុរសម្នាក់ ដើម្បី សាកល្បងប្រាជ្ញាព្រះមហោសថ។ ព្រះមហោសថបានដោះស្រាយ ប្រកបដោយ ភាពវាងវៃ និងត្រឹមត្រូវ ។

- **ទី៨ ទណ្ឌោ** (កំណាត់ឈើ) ព្រះរាជាបានល្បងប្រាជ្ញាមហោសថដោយយកកំណាត់ ឈើឈួសយ៉ាងស្អាត ទៅឱ្យអ្នកស្រុកបាចីនគ្រាមទាយថាខាងណាចុងខាងណាគល់ អ្នកស្រុកពុំដឹង ក៏ទៅពិគ្រោះជាមួយសេដ្ឋី សេដ្ឋីក៏ បានហៅមហោសថមកសួរ ហើយមហោសថ ក៏បានពន្យល់ មនុស្សគ្រប់គ្នាឲ្យយល់ ដោយឲ្យយកសូត្រមកចងត្រង់ កណ្តាលកំណាត់ឈើ នោះទម្លាក់ទឹក ហើយមហោសថប្រាប់ថា ខាងដែលលិចទឹកមុនជាគល់ ខាងដែលលិចទឹក ក្រោយជាចុង ។

- **ទី៩ សីសំ (ក្បាល)** ព្រះរាជាពិសោធបញ្ញាមហោសថ ដោយឱ្យយកក្បាល់ខ្មោចប្រុស មួយ ស្រីមួយឱ្យអ្នក ស្រុកបាចិនគ្រាមទាយអ្នកស្រុកមិនដឹងក៏ទៅសួរមហោសថ ពេលនោះ មហោសថ បានបកស្រាយថា លលាដ៍ក្បាល ដែលមានថ្នេរត្រង់ៗ ជាលលាដ៍ក្បាលមនុស្ស ប្រុសឯលលាដ៍ ក្បាល មានលក្ខណៈរៀចរិល ជាលលាដ៍ក្បាលមនុស្សស្រី។

-**ទី១០ អហិ (ពស់)**ព្រះរាជាបានបញ្ជូនពស់ញីឈ្មោល១គូទៅឲ្យអ្នកស្រុកបាចីនគ្រាមទស្សន៍ទាយ អ្នកស្រុក បាចិនគ្រាមមិនស្គាល់ថាណាមួយញីណាមួយឈ្មោល ក៏ទៅ ពិគ្រោះជាមួយ មហោសថ ពោធិសត្វក៏បានប្រាប់ថា ពស់ឈ្មោលក្បាលក្រាស់រាងក្រមឹប ក្នែកធំ សង្វារឆ្នូត អន្លាយៗ ឯពស់ញីក្បាលស្តើង រាងឆ្លឹម ក្នែកតូច សង្វារឆ្នូតកំបុតៗ ។

- **ទី១១ កុក្កដោ(មាន់)** ព្រះបាទវិទេហរាជបានឲ្យអ្នកស្រុកបាចិនគ្រាម បញ្ជូនឧសភ មាន សម្បុរសសុទ្ធមានស្នែងឰដ៏ជើងមានបួរលើក្បាល ស្រែករោទ៍មួយថ្ងៃ៣កាលទៅឱ្យជាប្រញាប់។ អ្នកស្រុកមិនស្គាល់ ក៏ទៅពិគ្រោះជាមួយមហោសថ ព្រះមហោសថបានប្រាប់ថា ឱ្យយកមាន់ស ឈ្មោលដែលមានដុះធ្នាល់នាជើង ដុះសិរលើក្បាលរងារ៣ដងក្នុង១ព្រឹកទៅថ្វាយ ។

- **ទី១២ មណិ (កែវមណី)** មានកែវមណីមួយដោតសូត្រចូលទៅ ហើយដាច់យកមិន បាន ព្រះរាជាបានបញ្ជូនទៅឱ្យអ្នកស្រុកបាចីនគ្រាមហូតចេញ ហើយបញ្ចូលសូត្រថ្មី អ្នកស្រុកគ្មាន វិធីដោះស្រាយក៏ទៅសួរព្រះមហោសថ មហោសថក៏បានប្រាប់ឱ្យយកកែវមណី លាបទឹកឃ្មុំ ត្រង់ រន្ធសងខាង ហើយត្របាញ់សូត្រថ្មីលាបទឹកឃ្មុំទៅដាក់បញ្ចូលបន្តិចទៅក្នុងរន្ធ ទើបឱ្យយកទៅ ដាក់ត្រង់រន្ធស្រមោចស្រមោចធុំក្លិនក៏ចូលមកហើយបានខាំទាញសូត្រ ចាស់ចេញ សូត្រថ្មីក៏ចូលទៅ ។

- **ទី១៣ វិជាននំ (ការប្រសូត្រ)** ព្រះរាជាបានបញ្ជូនគោឈ្មោល ពោះធំឱ្យអ្នកស្រុកបាចីនគ្រាមបង្កើតកូន គ្មានវិធីអ្នកស្រុកក៏ទៅសួរព្រះមហោសថ ពោធិសត្វក៏បានប្រាប់ឱ្យរកអ្នកមាន ថ្វីមាត់ ធ្វើជាយំស្រែកដើរតំរង់ទៅរាជវាំង ពេលនោះស្តេចក៏ហៅ សួរ បុរសនោះក៏ប្រាប់ថាឪពុក កើតកូនមិនរួចឱ្យព្រះអង្គជួយបង្កើត ស្តេចមានបន្ទូលថាមិន ដែលមានទេវើយ ! បុរសនោះក៏តបវិញថាម្តេចក៏ព្រះអង្គបញ្ជូនគោឈ្មោលឱ្យខ្ញុំម្ចាស់បង្កើតកូន ?

- **ទី១៤ ឱទនំ (បាយ)** ស្តេចបានប្រាប់ដល់អ្នកស្រុកបាចីនគ្រាមថា ចំអិនបាយប្រកបដោយ អង្គ៨ ដោយវៀរចោកអង្គរ ទឹក ឆ្នាំង ចង្ក្រាន ភ្លើង អុស មនុស្សប្រុសស្រី ហើយកុំដើរ យកទៅ តាមផ្លូវ អ្នកស្រុកបានទៅពិគ្រោះនឹងមហោសថ មហោសថក៏បានប្រាប់ឲ្យយកចុងអង្គរទឹក សន្សើម ភាជន៍ដីថ្មីមិនមែនជាឆ្នាំង ឱ្យចោះគល់ឈើតម្កល់ភាជន៍នោះ ហើយឱ្យយកភ្លើង រន្ទះ បង្កាត់ នឹងស្លឹកឈើ ឲ្យមនុស្សខ្ចីយ នាំយកទៅដើរក្បែរផ្លូវ ។

-**ទី១៥ វាលុកា(ដីខ្សាច់)** ស្តេចបង្គាប់ឱ្យអ្នកស្រុកបាចីនគ្រាមវេញខ្សែពួរដីខ្សាច់មួយ បញ្ជូន ទៅរាជវាំង ជនទាំងបានទៅសួរមហោសថ ព្រះមហោសថក៏បានឱ្យរកបុរសពីរនាក់ ចេះសម្តី ហើយបង្គាប់ថា អ្នកត្រូវចូលទៅក្រាបបង្គំព្រះរាជាថា សូមទ្រង់មេត្តាប្រោស ពួកអ្នកស្រុកពុំដឹង ពីទំហំខ្សែពួរនោះតូចឬធំទេ សូមព្រះអង្គកាត់ខ្សែពួរចាស់ប្រវែងមួយចំអាម ទូលបង្គំនឹងបានយក ធ្វើជាគម្រូ ស្តេចតបថា មិនធ្លាប់មានខ្សែពួរវេញពីដីខ្សាច់ពីកាលណាទេ បើគ្មានម្តេច ព្រះអង្គ ឱ្យអ្នកស្រុកបាចីនគ្រាមវេញខ្សែពួរខ្សាច់ដូចម្តេចកើត។

- **ទី១៦ តឡាកំ(ស្រះ)** ព្រះរាជាបានបង្គាប់ឱ្យអ្នកស្រុកបាចីនគ្រាមបញ្ជូនស្រះបោក្ខណី ទៅរាជវាំងដើម្បីក្រសាល អ្នកស្រុកគ្មានមធ្យោបាយក៏បានទៅសួរមហោសថពោធិសត្វក៏បានឱ្យ ហៅមនុស្សពីរបីនាក់ដែលមានថ្វីមាត់ កាន់ដំបង និងខ្សែពួរ ចុះទៅមុជទឹកស្រះលេង ឱ្យក្នែក ក្រហម និងប្រលាក់កក់ ហើយឡើងទៅទូលស្តេចថាស្រះដែលព្រះអង្គឱ្យខ្ញុំយកមក ថ្វាយនោះ បានផ្អើលដាច់ចូលទៅព្រៃវិញហើយ សូមព្រះអង្គប្រទានស្រះចាស់ឱ្យទូលបង្គំ យកទៅធ្វើធ្នាក់ ទាក់ស្រះនោះមកវិញផង។ ស្តេចថាមិនធ្លាប់មានស្រះនាំមកពីព្រៃទេ បើមិនមាន ម្តេចឱ្យអ្នក ស្រុកបាចីនគ្រាមបញ្ជូនស្រះបោក្ខណីមកថ្វាយដូចម្តេចកើត ។

- **ទី១៧ឧទ្យានំ (សួនឧទ្យាន)** ព្រះរាជាត្រាស់បង្គាប់ឱ្យបញ្ជូនឧទ្យានថ្មីមានដើមឈើលាស់ខ្ចីទៅរាជវាំង អ្នកស្រុកក៏ទៅសួរ មហោសថ ពោធិសត្វបានហៅមនុស្សពីរបីនាក់ឱ្យ យកខ្សែពួរ និងដំបងដើរទៅរាជវាំងទូលព្រះរាជាថា ខ្ញុំនាំឧទ្យានដ៏ធំមកថ្វាយ ប៉ុន្តែឧទ្យាននោះធ្លាប់តែនៅក្នុងព្រៃ បានឃើញបុរីក៏ផ្អើលដាច់បោលចូលព្រៃវិញទៅ សូមព្រះអង្គប្រទានឧទ្យានចាស់ឱ្យទូលបង្គំ ដើម្បីយកទៅផ្សាំងជាធ្នាក់ ព្រះរាជាថាមិនធ្លាប់មានឧទ្យាននាំ មកពីព្រៃទេ អ្នកទាំងនោះថា បើគ្មានព្រះអង្គឱ្យបញ្ជូនឧទ្យានថ្មីម្តេចកើត ។

- **ទី១៨ កទ្រភោ (សត្វលា)** អស្សតរព្រះរាជាបាក់ជើង ហើយបង្គាប់ឱ្យមហោសថយកអស្សតរ ដែលប្រសើរដូចអស្សតរស្តេចឬប្រសើរជាងទៅថ្វាយ ពេលនោះមហោសថយក សត្វលាទៅថ្វាយ ដោយទូលថាអស្សតរដែលប្រសើរ គឺកើតចេញពីមេសេះអាជានេយ្យ និងបាជា សត្វលាដូច្នេះសូមព្រះអង្គទទួលយកសត្វលានេះចុះព្រះរាជាក៏យល់ព្រមថែមទាំង យកមហោសថ ធ្វើជារាជបុត្ររបស់ព្រះអង្គ ។

- **ទី១៩ មណិ (កែវមណី)** មានកែវមណីមួយនៅក្នុងសំបុកក្អែកលើដើមត្នោតក្បែរស្រះ បោក្ខណី ចាំងរស្មីទៅក្នុងទឹកស្រះ ។ ព្រះរាជាឲ្យអាចារ្យសេនក:យកចេញឲ្យបាន តែ អាចារ្យយក មិនបានទាល់តែសោះ ស្តេចក្រុងមិថិលាសួរមហោសថថា ហៃបាឯងអាចឲ្យ យកកែវមណីនោះ បានឬទេ មហោសថទូលថាការនេះពុំធ្ងន់ធ្ងរទេ មហោសថបានបង្ហាញ ដោយឲ្យយកភាជន៍ទឹក មកដាក់ក្បែរដើមត្នោតនោះ ឃើញពន្លឺចាំងមកក្នុងភាជន៍នោះ ទើបក្រាបបង្គំទូលព្រះរាជាថាកែវ មណីនៅលើចុងត្នោតឯនោះទេ ។

លើសពីនេះទៅទៀត ក៏នៅមានការដេញដោលប្រស្នារវាងនាងកេរីបរិព្វាជិកាដែលជាទី រាប់អាននៃព្រះបាទចុល្លនី និងព្រះមហោសថ អំពីសញ្ញាក្នុងការល្បងប្រាជ្ញា ។

បញ្ញាទី២ បញ្ហាបំពេញបញ្ញាបារមីដុំវិញបញ្ហាការធ្វើសង្គ្រាម។ ក្នុងការធ្វើសង្គ្រាមជាមួយ ព្រះបាទចុល្លនី ក្សត្រនគរឧត្តរបញ្ចាល ព្រះមហោសថបានប្រើបញ្ញាក្នុងដោះស្រាយរាល់ឧបសគ្គ ដែលកើតឡើងចំពោះមុខប្រកបដោយសន្តិវិធី។ ព្រះមហោសថបានប្រើប្រាស់បញ្ញាបូកផ្សំជាមួយយុទ្ធវិធីក្នុងការធ្វើសង្គ្រាម ដើម្បីទទួលបានជោគជ័យលើសត្រូវ ហើយបានប្រើគ្រប់វិធីដូចជា សង់កំពែង ជីកស្រះជុំវិញ ចិញ្ចឹមក្រពើ មានទ្វារតូចធំ ប្រកបដោយ អាវុធយុទ្ធភ័ណ្ឌ ពិសេស បានបញ្ជូនសេកទៅស៊ើបការណ៍ថែមទៀតផង ។

គ. តួនាទីអប់រំនៃរឿងមហោសថជាតក

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានបង្ហាញពីគោលគំនិត(គំនិតអប់រំ)សំខាន់ៗដូចតទៅ៖

- អប់រំមនុស្សទូទៅឱ្យចេះកសាងសមិទ្ធផលផ្សេងៗ ដើម្បីជាប្រយោជន៍ដល់គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល ។ ជាក់ស្តែងយើងឃើញថា តួអង្គព្រះមហោសថនៅ ពេលមាន អាយុ៧ឆ្នាំ ក៏មានគំនិតរៃអង្គាសប្រាក់ដើម្បីកសាង នូវសាលាជាច្រើនទុកសម្រាប់ ជួយដល់ទុគ៌ត ជន ស្ត្រីមានផ្ទៃពោះអាណាថា ពួកឈ្មួញ និងព្រាហ្មណ៍ជនៃទៀត ។
- អប់រំមនុស្សទូទៅឲ្យចេះសាមគ្គីគ្នា រួបរួមគ្នា ក្នុងការដោះស្រាយបញ្ហាដែលកើតមាន ចំពោះមុខ ដូចជាពួកអ្នកស្រុកបាចីនគ្រាម ពេលជួបបញ្ហាដោះស្រាយប្រស្នាពុំរួច ក៏ពិគ្រោះ ផ្លាស់ ប្តូរយោបល់គ្នា ដើម្បីរកដំណោះស្រាយ ។
- អប់រំឱ្យយើងឱ្យចេះប្រើប្រាស់ប្រាជ្ញា សម្រាប់យកទៅដោះស្រាយបញ្ហាផ្សេងៗ ដែលជួបប្រទះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ឧទាហរណ៍ ព្រះមហោសថ បានយកបញ្ញា ទៅដោះ ស្រាយប្រស្នាទាំង១៩ នៅក្នុងដំណើររឿង ។

- អប់រំមនុស្សទូទៅឱ្យចេះស្រឡាញ់គ្នា កុំមានការច្រណែន ឈ្នានីសគ្នាកុំតាមព្យាបាទគ្នា ឱ្យចេះលើកតម្កើងអ្នកមានចំណេះដឹង ចេះរស់នៅជាមួយគ្នាប្រកបដោយសេចក្តីសុខសន្តិភាព។
- អប់រំអ្នកដឹកនាំទូទៅ ឱ្យចេះស្រឡាញ់សន្តិភាព ជៀសវាងការបង្កសង្គ្រាម ដែលជាហេតុ នាំមកនូវក្តីវិនាសអន្តរាយចំពោះប្រទេសជាតិ។ តាមរយៈរឿងមហោសថ ព្រះបាទចុល្លនី ព្រហ្មទត្ត បានបង្កសង្គ្រាម ទីបំផុតត្រូវបាត់បង់ធនធានមនុស្ស ចំណែកឯ ព្រះបាទវិទេហរាជ ជាស្តេចប្រកបដោយទសពិតរាជធម៌ស្រឡាញ់សន្តិភាពនាំឱ្យនគរមានភាពថ្កុំថ្កើងប្រជារាស្ត្រសម្បូរសប្បាយ ។
- អប់រំមនុស្សទូទៅឱ្យស្រឡាញ់យុត្តិធម៌ មិនលំអៀង ភាពទៀងត្រង់ ក្នុងការវិនិច្ឆ័យ ឬ ការកាត់ក្តី។
- អប់រំមនុស្ស កុំឲ្យមានចិត្តលោភលន់ ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ។
- អប់រំមនុស្សឲ្យចេះគិតពិចារណាឲ្យបានត្រឹមត្រូវមិនត្រូវល្មោភកាមតណ្ហាតាមការស្រេក ឃ្លានោះទេ ដូចជាព្រះបាទវិទេហរាជដែលលង់នឹងសម្រស់នាងបញ្ចាលចន្ទី ដែលធ្វើឲ្យខ្លួនស្ទើរ តែបាត់បង់ជីវិត ។

៧.៣.៦. រឿងភូរិទត្តជាតក

ក. ប្រធានរឿង

តាមរយៈការសិក្សារឿងនេះ បានបង្ហាញអ្នកសិក្សាឱ្យស្វែងយល់អំពីការបំពេញបារមីរបស់ព្រះពោធិសត្វ ពោល"សីលបារមី"។ ភូរិទត្តជាតកនេះគឺ លោកចង់ឆ្លុះបញ្ចាំងឱ្យយើងបានយល់អំពីគុណតម្លៃរបស់សីលបារមីប្រៀបបានជាមេសន្តិភាពសម្រាប់មនុស្សជាតិទូទៅ ។

ខ. មូលបញ្ហារឿង

ជុំវិញប្រធានរឿងនេះ យើងអាចកំណត់បញ្ហាជាច្រើន ដែលស្ថិតនៅជុំវិញការកសាងនូវ សីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន ៖

- ការបំពេញនូវទានបារមីរបស់ព្រះពោធិសត្វ
- បញ្ហាទ្រឹស្តីកម្មផល(អំពើបាបកម្មរបស់នាយព្រហ្មណ៍នេសាទ)
- អណ្តាតជាអាថកន្លងបានសុខទុក្ខផងពីព្រោះអណ្តាត
- ការបំពេញបារមីរបស់ព្រះពោធិសត្វ

បញ្ហាទី១ ៖ ការបំពេញនូវទានបារមីរបស់ព្រះពោធិសត្វ

តាមរយៈការសិក្សាវិភាគស្នាដៃរឿងនេះមក យើងដឹងថាបញ្ហាដែលកើតមានដំបូងឡើង នោះបណ្តាលអំពីការបំពេញបារមី"សីល"នេះឯង ដែលព្រះពោធិសត្វទ្រង់បានបំពេញ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួនបំផុត។ យើងដឹងស្រាប់មកហើយថាភូរិទត្តជាបុគ្គលមួយរូបមាន សមត្ថ ភាពខាងប្រាជ្ញា អាថ៌កំបាំង រហូតទៅដល់ឋានព្រះឥន្ទ្រ ដោះ ប្រស្នានានាផងទៀត ។ ដោយព្រះអង្គឈ្វេងយល់ឃើញអំពីសីលបារមីនេះមានសារៈសំខាន់ ទើបធ្វើឱ្យព្រះអង្គលាព្រះមាតាបិតាឋានកុដង្គនាគមកធ្វើសីលនៅឋានមនុស្សលោក។[30] តមកព្រះអង្គលាព្រះមាតាបិតា ចេញទៅរក្សាឧបោសថសីលនៅឋានមនុស្សលោក នៅនាដំបូកក្រោមដើមជ្រៃជិតស្ទឹងយមុនា ព្រះអង្គតាំងអធិដ្ឋានបារមី ផ្តោតព្រះទ័យចំពោះឧបោសថសីល ... ។

[30] រឿងភូរិទត្តជាតក ទំ.១៧៧-១៧៨

សរុបខ្លី បញ្ហាការបំពេញបារមីនេះ វាជាប្រភពដំបូងដែលធ្វើឲ្យរឿងបង្កជាបញ្ហាចំពោះ តួអង្គព្រះពោធិសត្វ ក្នុងការរក្សានូវឧបោសថសីល សម្រាប់ការស្វែងរកសេចក្តីសុខផ្ទាល់ខ្លួន និងមនុស្សជាតិ ។

ដូចនេះ សេចក្តីសុខកើតមានចំពោះបុគ្គលបាន លុះត្រាបុគ្គលនោះប្រព្រឹត្តផងដែរ គ្មានសេចក្តីស្ងប់នោះ ។

បញ្ហាទី២ ៖ បញ្ហាទ្រឹស្តីកម្មផល(អំពើបាបកម្មរបស់នាយព្រាហ្មណ៍នេសាទ)

មុនឆ្លងចូលដល់ការបកស្រាយបញ្ហានេះ យើងគម្បីស្វែងយល់ន័យរបស់គុណធម៌ និងការគប់មិត្តសិន ។

គុណធម៌ តាមវចនានុក្រមជួន ណាត លោកឱ្យន័យថា[31] ៖ ធម៌ដែលមានដំណើរចម្រើន សេចក្តីសុខទុក្ខទៅតាមជាន់ថ្នាក់ បានខាងអំពើល្អអាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ។

ការគប់មិត្ត: ដំណើររាប់រកគ្នា ចងសម្ពន្ធជាមួយគ្នា ។ យើងដឹងស្រាប់មកហើយ មនុស្សនៅក្នុងសង្គម មិនមានបុគ្គលណាមួយអាចរស់ឯកឯងនោះទេ ។ ម្ល៉ោះហើយគេត្រូវតែមានទំនាក់ទំនងជាមួយគ្នា ក្នុងជីវភាពរស់នៅនេះជាចាំបាច់ ហៅថា ការសេពគប់មិត្ត។ ប៉ុន្តែក្នុងទំនាក់ទំនងនេះ គេត្រូវពិនិត្យលើចិត្តសាស្ត្ររបស់បុគ្គលនោះ ដែរ មុនឈានចូលដល់ការរាប់អាននោះ។ តាមរយៈសៀវភៅស្រីហិតោបទេស[32] ដែលជាស្នាដៃ រៀបរៀងរបស់អាចារ្យវិរិយបណ្ឌិតោ ប៉ាង ខាត់ នៅត្រង់អារម្ភកថាលោកក៏បានបញ្ជាបអំពីគម្ពីរ បញ្ចសស្ត្រៈ ក្នុងនោះដែរលោកក៏បានបង្ហាញអំពីការគប់មិត្តដែរ ។ ចំណែកសៀវភៅគតិលោក របស់អ្នកនិពន្ធសុត្តន្តប្រីជាឥន្ទ លោកបានពង្រីកគំនិតលោកិយ៍សច្ចៈមនុស្សនិយម(អក្សរសិល្ប៍ ទំនើប) បង្ហាញប្រាប់ត្រង់អំពីការគប់មិត្តនេះដែរ[33]។ មិនត្រឹមតែប៉ុណ្ណោះ ការសិក្សារឿងភូរិទត្តជាតកនេះ លោកបង្ហាញឲ្យយើងដឹងអំពីឫសគល់នៃការចងសម្ពន្ធមិត្តនេះដែរដូចមានឃ្លាលើកឡើង៖

.....[34]ព្រះពោធិសត្វ កាលបានជ្រាបថា ព្រានឃើញព្រះអង្គហើយក៏នឹកថា "សេចក្តីអន្តរាយនឹងមាន បើដូច្នេះគួរតែអាត្មាអញនាំព្រាននេះទៅបំប៉នដោយគ្រឿងសក្ការៈ និងសេចក្តីរាប់អាន ឯឋានកុដង្គនាគ .... សោមទត្តកូនអើយយើងនឹងបានកែវមណីវិញហើយ កូនសួរថា ធ្វើម្តេចនឹងបាន? យើងត្រូវបង្ហាញផ្លូវភូរិទត្តដល់អាលម្ពាយន៍នេះណា ... ទេឪ! ពុំត្រូវទេ ខុសមនុស្សធម៌ឆ្ងាយ ណាស់ ។ ... កូនតបថា: គិតតែខាងបានប៉ុណ្ណោះ មិនល្អទេឪ! ព្រោះថាភូរិទត្តបានធ្វើសក្ការៈបូជា ដល់ឪ ឱ្យទីនៅសំណាក់អាស្រ័យយ៉ានេះ ឈ្មោះថាកល្យាណមិត្តប្រពៃ ... ។ បើយើងពិនិត្យតាម សង្គមជាក់ស្តែងវិញគេតែងតែឮសូរតាមបណ្តាញព័ត៌មាននានា អំពីការចាញ់បោកមិត្តភ័ក្តិជាដើម មិនខុសប្លែកអំពីអក្សរសិល្ប៍ប៉ុន្មានឡើយ ព្រោះថាអក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីតថភាពនៃ សង្គម អក្សរសិល្ប៍បែបណា សង្គមយ៉ាងនោះដែរ ។

ដូចនេះយើងឃើញថា បញ្ហាអក្សរសិល្ប៍ជាបញ្ហារបស់មនុស្សក្នុងសង្គម ។ ផ្អែកតាមការ រៀបរាប់ត្រួសៗ មកនេះ សបញ្ជាក់ឱ្យឃើញថាការសេពគប់មិត្ត វាតែងផ្សារភ្ជាប់អំពីគុណធម៌។

បញ្ហាទី៣ ៖ អណ្តាតជាអាទិកន្លងបានសុខទុក្ខផងពីព្រោះអណ្តាត

តាមរយៈរឿងភូរិទត្តជាតកនេះ លោកបានបង្ហាញអំពីហឹង្សា ក្នុងគ្រួសាររបស់នាយ ព្រាហ្មណ៍នេសាទ និងប្រពន្ធ ។ ក្រោយពេលដែលនាយព្រាហ្មណ៍នេសាទ វិលត្រឡប់ពីឋាន កុដង្គនាគកុហកព្រះពោធិសត្វថា មកបួសនៅ

---

[31] ជួន ណាត "វចនានុក្រមខ្មែរ" ទំ. ៩៩

[32] វិរិយបណ្ឌិតោ ប៉ាង ខាត់ "ស្រីហិតោបទេស"

[33] ឧកញ្ញា សុត្តន្ត ប្រីជាឥន្ទ "សៀវភៅគតិលោក"

[34] រឿង ភូរិទត្តជាតក ទំ.១៨៣

ឯឋានមនុស្សលោកនោះ ពេលធ្វើដំណើរទៅដល់ ផ្ទះវិញនោះ នាយព្រហ្មណ៍នេសាទបានចូលទៅរកកន្លែងសម្រាក ព្រោះអស់កម្លាំងពេក ។ ប្រពន្ធ ត្រេកអរខ្លាំងណាស់ បានសួរកូនចំពោះការបាត់ខ្លួនមួយរយៈនោះ កូនសោមទត្ត កុមារជាមនុស្ស ល្អ មិនកុហកបានរៀបរាប់ប្រាប់អ្នកម្តាយទៅតាមដំណើររឿងទាំងអស់ នៅពេលបានសេចក្តីជ្រាប ហើយ នាងប្រពន្ធទៅយកដំបងវាយសំពងប្តីកំពុងសម្រាន្តនោះ ។ នាយព្រហ្មណ៍នេសាទរត់ ចោលភូមិស្រុកពីរនាក់ ឪពុកកូន ។ ... កូនអើយ អ្នកនាំគ្នាទៅណាបាត់យូរម្ល៉េះ ? ប្រាប់ថា: ទៅឋានកុដង្គនាគ។ សួរថា: បានមាសពេជ្រកែវ មណីមកទេ? ប្រាប់ថា: ឪពុកពុំព្រមយកមកទេ ព្រោះគាត់ថានឹងបួស បានខ្លះមកបាត់អស់ទៅ ។ ភរិយាឮតែ ប៉ុណ្ណោះស្ទុះទៅសំពងប្តី ....[35] ។

ដូចនេះយើងឃើញថា មនុស្សយើងមុននឹងនិយាយត្រូវចេះ គិតពិចារណាឱ្យបានត្រឹមត្រូវ សិនសមតាម សុភាសិតបុរាណ បានពោលថាអណ្តាតជាអាថកន្លងបានសុខទុក្ខ ផងពីព្រោះអណ្តាត។

បញ្ហាទី៤ ៖ ការបំពេញបារមីរបស់ព្រះពោធិសត្វ

គ្រប់អក្សរសិល្ប៍បុរាណផ្នែកពុទ្ធនិយម ទោះបីអ្នកនិពន្ធនិម្មិតបង្កើតស្នាដៃរបស់ខ្លួន លើក និយាយអំពីរឿងរ៉ាវ ទាក់ទងជាមួយសាសនាក៏ដោយ ប៉ុន្តែរឿងនោះបានស្តែងចេញអំពីជីវភាពរស់ នៅរបស់មនុស្សនៅក្នុងសង្គម ។ យើងដឹងស្រាប់មកហើយថា កអក្សរសិល្ប៍បុរាណ អ្នកនិពន្ធ បញ្ជូបពីអច្ឆរិយៈហួសហេតុពីការពិតមែន តែក្នុងគោល បំណងឱ្យអ្នកអានសប្បាយរីករាយប៉ុណ្ណោះ។ អំពីអច្ឆរិយៈនេះ ក៏អ្នកនិពន្ធមិនភ្លេចអំពីលោកិយសច្ចៈនៅក្នុងអក្សរ សិល្ប៍ដែរ។ តាមរយៈអក្សរសិល្ប៍កបុរាណ ភូរិទត្តជាតកនេះ លោកបានបញ្ចូលចង្អុលប្រាប់អំពីលោកិយសច្ចៈ ត្រង់ៗ ដល់អ្នកសិក្សាសម្រាប់ការត្រិះរិះពិចារណា ។ តាមឯកសារបង្រៀនគរុកោសល្យ យើង ឃើញគំនិតរបស់អ្នកប្រាជ្ញម៉ាស្លូ លោកបានឲ្យតម្លៃសំខាន់ទៅលើមនុស្សនិយម ហៅថាតម្រូវការ សរីរៈ ឬតម្រូវការមូលដ្ឋាន ក្នុងនៅលោកក៏បាន និយាយអំពីភាពចាំបាច់របស់មនុស្សមុនគេគឺ ការ ហូបចុក ស្នាក់នៅ សំលៀកបំពាក់ ទ្រព្យសម្បត្តិ .... ។ ដោយផ្នែកលើទ្រឹស្តីនេះ យើងអាចទាញ តាមលក្ខណៈលោកិយ៍សច្ចៈ រឿងភូរិទត្តជាតក ដូចមានបង្ហាញតាមរយៈសកម្មភាព របស់តួអង្គ ខាងក្រៀម ៖

+ តួអង្គនាយព្រហ្មណ៍នេសាទ: ដោយមានភាពចំណង់ចង់បាន ទ្រព្យសម្បត្តិរបស់គាត់ នេះហើយ ទើបធ្វើ ឱ្យនាយព្រហ្មណ៍នេសាទភ្លេចអស់នូវសីលធម៌ គុណធម៌របស់ខ្លួនភ្លេចអស់ នូវការជួយសង្គ្រោះពីជនដទៃ សូម្បីតែ ពោធិសត្វដែលធ្លាប់ជួយសង្គ្រោះ ផ្តល់ការឱ្យស្នាក់នៅ អាស្រ័យទំនុកបំរុងឱ្យមាស ប្រាក់ ទ្រព្យសម្បត្តិ កែវមណីនោះ ដោយការខ្វះខាតក្រីក្រលើតម្រូវការសរីរៈនេះហើយ ទើបមករស់នៅក្នុងព្រៃរសាត់អណ្តែតពីនាក់ឪពុកកូន ដោយ កំសត់វេទនា ព្រោះតែប្រពន្ធដេញវាយមិនឱ្យចូលផ្ទះ ។ តាមរយៈរឿងនេះទៀតសោត លោកឆ្លុះបញ្ចាំងឱ្យយើង ដឹង ការបាត់បង់គុណធម៌នេះ បណ្តាលមកពីកត្តាខាងក្រោមនេះ ៖

- ភាពក្រីក្រ សេចក្តីទុក្ខលំបាកវេទនា
- ភាពអនាថា រស់នៅដោយគ្មានអ្នកទីពឹង
- ភាពអវិជ្ជា តណ្ហា លោភៈ មោហៈ ទោសៈចាក់ស្រែះ
- សេចក្តីបម្រើខាងអំណាច ការពារកិត្តិយស បុណ្យសក្តិ
- ភាពអួតអាង បម្រើមហិចតា មិនចេះចប់មិនចេះហើយ

[35] រឿងភូរិទត្តជាតក ទំ.១៨១

- បាត់បង់មនសិកា សីលបារមី ជាដើម

+តាមរយៈតួអង្គហ្មពស់ (ព្រាហ្មអាលម្ពាយន៍)

ព្រាហ្មអាលម្ពាយន៍ ក្រោយពេលជួបជាមួយព្រាហ្មណ៍នេសាទ ហើយគេទាំងពីរនេះមាន ទំនាក់ទំនងជាមួយគ្នាអំពីបញ្ហាត្បូងកែវមណីនោះ។នាយព្រាហ្មណ៍នេសាទបានណែនាំព្រាហ្មណ៍ឱ្យទៅជួបព្រះពោធិសត្វ..។ ព្រាហ្មណ៍អាលម្ពាយន៍ ជាមនុស្សលោភលន់ចង់មានបានហួសពីតម្រូវការ។ ដោយភាពអវិជ្ជា លោភៈ ទោសៈ មោហៈ ធ្វើឱ្យព្រាហ្មណ៍អាលម្ពាយន៍ ភ្លេច អស់គុណធម៌ សីលធម៌ ពុំស្គាល់គុណទោស បុណ្យបាប គេដើរបៀតបៀនអ្នកដទៃឱ្យរងទុក្ខវេទនា ក្រោមកណ្តាប់ដៃដ៏កខ្វក់ប្រកបដោយបាបមិត្រ ធ្វើឱ្យព្រះពោធិសត្វកូវិទត្ត រងទុក្ខលំបាកហូរ ឈាម ដើរសម្តែងសិល្បៈគ្រប់ទីកន្លែងទាំងអស់ តាមការបញ្ជារបស់ព្រាហ្មណ៍អាលម្ពាយន៍ ។

សរុបន័យមកឃើញថា លោកិយ៍សច្ចៈតាមរយៈរឿងនេះ ពិតជាបានស្តែងអំពីតម្រូវការរស់ នៅរបស់មនុស្សក្នុងសង្គម ជាពិសេសបង្ហាញអំពីចរិតលក្ខណៈចិត្តសាស្ត្ររបស់មនុស្ស ។

គ. តួនាទីអប់រំនៃរឿងកូវិទត្តជាតក

រឿងកូវិទត្តជាតក ជាប្រភេទអក្សរសិល្ប៍បុរាណផ្នែកពុទ្ធនិយម ដែលបង្ហាញអំពីរឿងរ៉ាវផ្សេងៗ របស់តួអង្គព្រះពោធិសត្វ ទាក់ទងជុំវិញការបំពេញសីលបារមីរបស់ព្រះអង្គ នៅជាតិទីប្រាំមួយ។ ឆ្លងតាមរយៈការសិក្សារឿងនេះមក ក្រុមយើងខ្ញុំអាចទាញជាឧត្តមគតិរឿងនេះ គឺអ្នក និពន្ធលោកចង់អប់រំយើងដូចតទៅ ៖

- អប់រំមនុស្សយើងកុំឱ្យប្រកាន់បក្សពួក រើសអើងប្រកាន់វណ្ណៈ
- អប់រំមនុស្សឱ្យចេះស្រឡាញ់គ្នា ចេះជួយសង្គ្រោះ
- អប់រំមនុស្សឱ្យចេះធ្វើទាន រក្សាសីលបារមី
- អប់រំមនុស្សឱ្យចេះអំណត់ព្យាយាម អត់ធ្មត់ ខន្តី មិនក្រោធខឹង
- អប់រំមនុស្សឱ្យប្រើវិធីដោះស្រាយសមស្រប
- អប់រំមនុស្សកុំឱ្យប្រើអំពើហិង្សា
- អប់រំមនុស្សកុំឱ្យដើរបៀតបៀនសេចក្តីសុខអ្នកដទៃ
- អប់រំកុំឱ្យមនុស្សភ្លេចគុណអ្នកដទៃ
- បណ្តុះស្មារតីមនុស្សឱ្យចេះសេពគប់មិត្ត
- អប់រំមាតាបិតាត្រូវមានព្រហ្មវិហារធម៌
- អប់រំមនុស្សឱ្យជឿលើកម្មផល
- អប់រំមនុស្សឱ្យធ្វើអំពើល្អទាំងកាយ វិចារ

សរុបសេចក្តីមកយើងឃើញថា អក្សរសិល្ប៍ខ្មែររឿងកូវិទត្តជាតកនេះ ឆ្លុះបញ្ចាំងឲ្យឃើញ អំពីសមត្ថភាពទេពកោសល្យរបស់អ្នកប្រាជ្ញ កាលពីសម័យបុរាណ បង្កប់នូវទស្សនៈវិស័យ ចក្ខុវិស័យយ៉ាងវិសេសវិសាលសម្រាប់សង្គមជាតិ ។

៧.៣.៧. រឿងចន្ទកុមារជាតក

ក. ប្រធានរឿង

ក្នុងរឿងចន្ទកុមារនេះគឺ"ការបំពេញបារមី(ខន្តីបារមី)របស់ព្រះពោធិសត្វ"។រឿង "ចន្ទកុមារជាតក"ជារឿងនៃជាតិទី៧ ក្នុងជាតិចុងក្រោយទាំង១០របស់ព្រះពុទ្ធសមណគោតមដែលបានរៀបរាប់ពីដំណើរជីវិតរបស់ ព្រះពោធិសត្វ ក្នុងការកសាង និងសន្សំបារមីដើម្បីការត្រាស់ដឹង។

ខ. មូលបញ្ហារឿង

មូលបញ្ហាក្នុងរឿងនេះគឺ និយាយពីទំនាស់ដែលកើតចេញពីការគុំគួន តាមព្យាបាទព្រះចន្ទកុមាររបស់កណ្ឌហាលព្រាហ្មណ៍។

នៅក្នុងដំណើររឿងនេះ បានរៀបរាប់ពីការចង់បានរបស់ព្រះបាទឯករាជាព្រះបិតារបស់ចន្ទកុមារដែលចង់ទៅកើតនៅស្ថានសួគ៌ទើបប្រឹក្សាជាមួយកណ្ឌហាលព្រាហ្មណ៍។ កណ្ឌហាលព្រាហ្មណ៍ជាមនុស្សអាក្រក់អន្ទាលដែលមានចិត្តគុំគួនជាមួយព្រះចន្ទកុមារបរមពោធិសត្វដោយសារទំនាស់កន្លងមក គឺថាកណ្ឌហាលព្រាហ្មណ៍នេះពីមុនត្រូវព្រះរាជាតែងតាំងជាអ្នកទទួលកាត់ក្តីក្នុងរឿងវិវាទឲ្យប្រជានុរាស្ត្រ ដោយចិត្តលោភព្រាហ្មណ៍នេះតែងតែទទួលសំណូកសូកប៉ាន់ពីគេ ហើយកាត់ក្តីមួលបង្កាច់ឱ្យអាក្រក់ទៅជាល្អ សជាខ្មៅ ម្ចាស់ទៅជាចោរ ឯចោរទៅជាម្ចាស់ទៅវិញ។ ក្រោយមកប្រជារាស្ត្រស្លូតត្រង់ដែលចាញ់ក្តីបានទៅប្តឹងព្រះចន្ទកុមារ ទ្រង់ក៏សើរើកាត់ក្តីជាថ្មី ដោយយុត្តិធម៌។ ព្រះរាជាទ្រង់ជ្រាបរឿងនេះ ក៏ដកសេចក្តីទុកចិត្តពីកណ្ឌហាលព្រាហ្មណ៍ ដែលធ្វើឱ្យព្រាហ្មណ៍ទទួលការខាតបង់លាភសក្ការៈ។ ការណ៍នេះហើយដែលនាំឱ្យកណ្ឌហាលព្រាហ្មណ៍អន្ទាលមានចិត្តគុំគួនខ្លាំងជាមួយចន្ទកុមារ ។ ដោយសារបានឱកាសសម្រាប់ការសងសឹកជាមួយចន្ទកុមារ កណ្ឌហាលព្រាហ្មណ៍បានទូលព្រះរាជាទាំង ទោសាគតិថា"សូមឱ្យព្រះអង្គធ្វើទានដ៏ក្រៃលែងគឺសម្លាប់នូវបុគ្គលដែលមិនគួរសម្លាប់"។ ការទូលបែបនេះគឺដើម្បីឲ្យព្រះរាជាសម្លាប់ព្រះចន្ទកុមារតែម្តង។

នៅក្នុងរឿង "ចន្ទកុមារ" គេសង្កេតឃើញថា មានទំនាស់តូចៗជាច្រើនដែលជាបច្ច័យឈានទៅដល់ទំនាស់ធំរួចក៏ឈានដល់ដំណោះស្រាយជាចុងក្រោយ។ ទំនាស់ទាំងអស់បានផ្តួចឡើងជារឿងតាមដំណាក់ៗដូចតទៅ៖

- **ទី១៖ ការចងគំនុំរបស់កណ្ឌហាលព្រាហ្មណ៍ចំពោះព្រះចន្ទកុមារ**

ទំនាស់ផ្តើមចេញដំបូងគឺដោយសារតែកណ្ឌហាលព្រាហ្មណ៍ជាបុគ្គលមានចិត្តលោភ ប្រព្រឹត្តទុច្ចរិតស៊ីសំណូករួចវិនិច្ឆ័យដោយអយុត្តិធម៌។ ដោយមូលហេតុនេះ ធ្វើឲ្យអ្នកចាញ់ក្តីមានសេចក្តីក្តៅក្រហាយ និងបានទូលរឿងវ៉ាវដល់ព្រះចន្ទកុមារ ទ្រង់ក៏វិនិច្ឆ័យរឿងក្តីសារជាថ្មី។ កណ្ឌហាល ត្រូវបាត់បង់មុខតំណែង និងលាភសក្ការៈ ក៏ចេះតែមានចិត្តគុំគួនគួចចង់សងសឹកនឹងព្រះចន្ទកុមារជានិច្ច។

ឧទាហរណ៍៖ "កណ្ឌហាលព្រាហ្មណ៍នោះកាន់តំណែងខាងការវិនិច្ឆ័យផង គាត់តែងស៊ីសំណូកធ្វើម្ចាស់ឱ្យមិនមែនជាម្ចាស់វិញ.....ផលអាក្រក់របស់កណ្ឌហាលព្រាហ្មណ៍ក៏ជាប់រលត់ទៅ បានជាព្រាហ្មណ៍កើតក្តីមួម៉ៅគិតផ្តន្ទាព្រះចន្ទកុមារ"។ (សង្ខេបទសជាតក ទំ.១៩៣-១៩៤)

- **ទី២៖ បញ្ហាការសុបិនរបស់ព្រះបាទឯករាជ**

ព្រះបាទឯករាជទ្រង់សុបិននិមិត្តឃើញឋានត្រៃត្រឹង្ស ក៏មានព្រះទ័យចង់ទៅកើតសោយសុខនាស្ថាននោះ។ ព្រះអង្គទ្រង់ទៅពិភាក្សាជាមួយកណ្ឌហាលព្រាហ្មណ៍ ពីរឿងថា តើត្រូវធ្វើយ៉ាងណាដើម្បីបានទៅកើតនៅស្ថានសួគ៌។

ជាឱកាសល្អសម្រាប់ការសងសឹក កណ្ឌហាលព្រាហ្មណ៍ដែលជាមនុស្សអន្ធពាលឥតដឹងការណ៍អ្វីសោះ ក៏ទូលថ្វាយព្រះបាទឯករាជដោយមោហៈនិងទោសៈឱ្យទ្រង់ធ្វើនូវទានក៏ក្រៃលែងគឺការសម្លាប់នូវបុគ្គលដែលមិនគួរសម្លាប់។ ការទូលបែបនេះ កណ្ឌហាលព្រាហ្មណ៍មានគោលបំណងធំមួយគត់ គឺដើម្បីឱ្យព្រះរាជាសម្លាប់ព្រះ ចន្ទកុមារ។

ឧទាហរណ៍នៅក្នុងរឿង៖ "ថ្ងៃមួយទ្រង់សុបិននិមិត្តថា: បានទៅឃើញឋានត្រៃត្រឹង្ស.....ទើបសួរកណ្ឌហាលព្រាហ្មណ៍ថា ខ្ញុំត្រូវធ្វើបុណ្យដូចម្តេចដើម្បីនឹងបានទៅកើតឯស្ថានត្រៃត្រឹង្ស?" (សង្ខេបទសជាតក ទំ.១៩៤-១៩៥) "ព្រាហ្មណ៍ក្រាបបង្គំទូលថា: សូមទ្រង់ព្រះមេត្តាប្រោស ជនទាំងឡាយឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទើបបានទៅកើតនៅឋានសួគ៌"។ (សង្ខេបទសជាតក ទំ.១៩៥)

- **ទី៣៖ បញ្ហាការបូជាយញ្ញរបស់ព្រះបាទឯករាជ**

ដោយសារជាមនុស្សល្ងង់អាប់ប្រាជ្ញា ព្រះបាទឯករាជក៏ទទួលជឿតាមពាក្យមុសាផ្តេសផ្តាសប្រកបដោយគំនិតយ៉ាងអាក្រក់របស់កណ្ឌហាលព្រាហ្មណ៍ ប្រៀបដូចជាមនុស្សដែលវង្វេងផ្លូវមួយសប្តាហ៍ទៅសួរកផ្លូវចំមនុស្សដែលវង្វេងផ្លូវកន្លះខែដូច្នោះ។ ដើម្បីបានទៅកើតនាស្ថានត្រៃត្រឹង្ស ព្រះអង្គសុខចិត្តបញ្ជាឲ្យគេសម្លាប់ បុត្រ មហេសី សេដ្ឋី គោឧសភរាជ សេះជា អាជានេយ្យ ដំរីរាជ គឺចំនួន៤ៗក្នុងមួយមុខ។ ដំណាក់កាលនេះព្រះចន្ទកុមារកំពុងជួបបញ្ហាព្រោះនឹងត្រូវគេយកទៅបូជាយញ្ញជាមួយមនុស្ស និងសត្វជាច្រើនទៀត។ ដំណើររឿងកាន់តែតានតឹងឡើងជាលំដាប់។ ព្រះរាជកុមារព្រះចន្ទកុមារទ្រង់ព្យាយាមដោះស្រាយបញ្ហាដែលកើតឡើងចំពោះមុខដោយចិត្តខន្តី។ ព្រះចន្ទកុមារបានទូលអង្វរ ដល់ព្រះរាជាជាបិតាដោយសុខចិត្តធ្វើជាទាសៈរបស់កណ្ឌហាលព្រាហ្មណ៍ ឬត្រូវនិរទេសពីនគរ ទ្រង់សុខចិត្តដើរ សុំទានគេចិញ្ចឹមជីវិត។ ក្នុងនាមជាមហាឧបរាជដែលមានអំណាចសុខចិត្តបន្ទាបខ្លួន ធ្វើជាទាសៈមនុស្សអាក្រក់ដូចកណ្ឌហាលព្រាហ្មណ៍នេះ សបញ្ជាក់ថាព្រះចន្ទកុមារមានចិត្តអំណត់ អត់ធ្មត់ខ្លាំងណាស់ដើម្បីទប់ទល់នឹងបញ្ហា។ ទោះបីជាការអង្វរកររបស់ព្រះចន្ទកុមារធ្វើឲ្យបិតាទ្រង់មានចិត្តអាណិត និងបញ្ឈប់យញ្ញពិធីពិតមែន ប៉ុន្តែព្រាហ្មណ៍កណ្ឌហាលនៅតែទទូចតវ៉ាឲ្យព្រះបាទឯករាជបន្តការបូជាយញ្ញដដែល។ ព្រះចន្ទកុមារមិនព្រមចុះចាញ់នៅតែព្យាយាមពន្យល់ព្រះបិតាដោយលើកយកហេតុផលជាច្រើន ថាទង្វើបែបនេះមិនមែនជាដំណើរទៅសួគ៌លោកទេ តែជាដំណើរទៅកាន់នរកដោយពិតប្រាកដ។ ឯកណ្ឌហាលក៏នៅតែតវ៉ាដូចមុនដដែលៗទៀត។ ទំនាស់កាន់តែតានតឹងដោយព្រះនាងចន្ទាទេវីសម្រេចចិត្តសម្លាប់ខ្លួនតាមព្រះចន្ទកុមារជាស្វាមី និងបួងសួងសូមឲ្យពួកអមនុស្ស ទេវតាជួយថែរក្សាព្រះនាង និងស្វាមីផង។

ឧទាហរណ៍៖ "ព្រះមាតានៃព្រះបាទឯករាជ និងព្រះបាទវេសវតីជាព្រះបិតាទ្រង់ឃាត់ថា: ម្នាលកូន! អ្នកកុំជឿកណ្ឌហាលព្រាហ្មណ៍.....ផ្លូវហ្នឹងជាផ្លូវទៅកាន់នរកទេកូន"។ (ទំ.១៩៧)

"ព្រះចន្ទកុមារអង្វរថា: បពិត្រព្រះបិតា សូមព្រះអង្គកុំសម្លាប់ទូលព្រះបង្គំជាខ្ញុំឡើយ សូមព្រះអង្គរាជទានទូលបង្គំជាខ្ញុំទាំងឡាយឲ្យជាទាសៈនៃកណ្ឌហាលព្រាហ្មណ៍ចុះ .....ទូលបង្គំជាខ្ញុំទាំងឡាយសុខចិត្តដើរសុំទានគេចិញ្ចឹមជីវិតដែរ"។ (ទំ.១៩៨)

- **ដំណោះស្រាយបញ្ហាដោយអន្តរាគមន៍របស់ព្រះឥន្ទ្រាធិរាជ**

ខណៈដែលទំនាស់ចេះតែតានតឹង និងឈានដល់កម្រិតកំពូលហើយនោះ ដំណោះស្រាយចុងក្រោយនៃដំណើររឿងគឺមានការជួយអន្តរាគមន៍ពីព្រះឥន្ទ្រាធិរាជ។ ក្រោយពីទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រះនាង-ចន្ទាទេវីរួចមក សក្កទេវរាជទ្រង់ត្រីដំបងដែកស្រែកគម្រាមដល់ព្រះបាទឯករាជ កុំឲ្យសម្លាប់ជីវិតព្រះចន្ទកុមារដែលជា

មនុស្សប្រកបដោយគុណធម៌យ៉ាងវិសេសឲ្យសោះ។ វត្តមានរបស់ព្រះឥន្ទ្រាធិរាជ បានធ្វើឲ្យព្រះរាជា និងកណ្ហាហាល មានការកិតក័យយ៉ាងខ្លាំង ហើយទ្រង់បានចេញបញ្ជាយ៉ាងប្រញាប់ឲ្យគេដោះលែងព្រះចន្ទ-កុមារ ជនទាំងឡាយ និងសត្វទាំងឡាយ។ ចំណែកកណ្ហាហាលព្រហ្មណ៍ត្រូវមនុស្សទាំងឡាយគប់នឹងដុំដី ដល់នូវមរណាទៅសោយទុក្ខនៅនរក។ ព្រះចន្ទកុមារត្រូវបានអភិសេកដោយមានសក្តទេវរាជ និងទេវបរិស័ទ ទេពកញ្ញា សម្តែងសេចក្តីអបអរពាសពេញអាកាស។ ព្រះចន្ទកុមារសោយរាជសម្បត្តិប្រកបដោយធម៌ ត្រេកអរក្នុងការបរិច្ចាគទាន លុះអវសានជីវិតបានទៅកើតនៅស្ថានសួគ៌។

ឧទាហរណ៍៖ "ព្រះឥន្ទ្រាធិរាជ ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយក៏គ្រវីដៃកស្រែកគម្រាមព្រះបាទឯករាជថា: ម្នាលស្តេចកាឡកណ្ណីអប្រិយលាមក ចូរឯងដឹងចុះកុំឲ្យអញសំពងក្បាលទាន់! ឯងកុំសម្លាប់បុត្រច្បង ដែលជាអ្នកអង់អាចដូចរាជសីហ៍ឥតសេចក្តីប្រទូស្ត!.....ក៏ស្ទុះទៅស្រាយចំណងពីជនទាំងឡាយមួយរំពេច"។(ទំ.២០៣)

ឃ. តួនាទីអប់រំក្នុងរឿងចន្ទកុមារជាតក

ជាការពិតណាស់ រឿង"ចន្ទកុមារ"ស្ថិតក្នុងចលនាពុទ្ធនិយម ដែលចង់បង្ហាញនូវការអប់រំដ៏ជ្រាលជ្រៅដល់មនុស្សឱ្យចេះប្រើធម៌ខន្តីក្នុងការដោះស្រាយបញ្ហាដើម្បីសម្រេចបានជោគជ័យ។

មួយវិញទៀត រឿងនេះបានចូលរួមបង្ហាញទស្សនៈកម្មពៀរដែលជាទ្រឹស្តីសំខាន់របស់ព្រះពុទ្ធសាសនាគឺថា បុគ្គលណាបានប្រព្រឹត្តអ្វីតែងតែបានទទួលផលចំពោះទង្វើរបស់ខ្លួន ដាក់ស្តែងកណ្ហាហាលព្រហ្មណ៍ដែលជាមនុស្សចិត្តបាបមានគំនិតប្រទូស្តជាមួយមនុស្សល្អមានគុណធម៌យ៉ាងប្រសើរ ចុងបញ្ចប់ត្រូវគេគប់នឹងដុំដីរហូតដល់ស្លាប់ហើយថែមទាំងទៅសោយទុក្ខនៅនរកទៀត។ ចំណុចនេះធ្វើឲ្យមនុស្សមានទឹកចិត្តប្រព្រឹត្តអ្វីដែលវៀរចាកអកុសលពោលគឺធ្វើតែអំពើល្អជាកុសលដែលជាកត្តានាំមកនូវសន្តិភាព សាមគ្គីភាព ភាតរភាព សណ្តាប់ធ្នាប់ និងភាពរីកចម្រើនរុងរឿងដល់សង្គមជាតិ។

ម្យ៉ាងទៀតបុគ្គលជាចៅក្រមដែលមានការវិនិច្ឆ័យក្តីប្រកបដោយសុគតិ យុត្តិធម៌នោះ រមែងទទួលនូវការគាំទ្រ កោតសរសើរ និងគោរពស្រឡាញ់ពីអ្នកដទៃ។ ផ្ទុយទៅវិញបុគ្គលជាចៅក្រមដែលកាត់ក្តីប្រកបដោយលោភាគតិ គឺកាត់ក្តីដោយអយុត្តិធម៌ព្រោះតែលាភសក្ការៈនោះតែងតែទទួលនូវការស្អប់ខ្ពើមពីមនុស្សទូទៅ ចៀសមិនផុតត្រូវទទួលការបាត់បង់តំណែងថែមទៀត។

លើសពីនេះរឿងនេះអប់រំមនុស្សថា មុននឹងធ្វើអ្វីមួយត្រូវចេះគិតពិចារណាឱ្យបានល្អិតល្អន់ និងត្រឹមត្រូវជាមុនសិន ជាពិសេសគឺកុំសេពគប់នឹងបុគ្គលពាលព្រោះបុគ្គលដំពូកនេះតែងនាំខ្លួន ក្រុមគ្រួសារ និងសង្គមជាតិទៅរកសេចក្តីវិនាសជាក់ជាពុំខាន។ ឧទាហរណ៍ ព្រះបាទឯករាជដែលទៅកប់ប្រសព្វរាប់អានបុគ្គលពាលដូចជាកណ្ហាហាលព្រហ្មណ៍ វិះតែនឹងធ្វើឱ្យក្រុមគ្រួសាររាជវង្សានុវង្ស និងប្រជារាស្ត្រទូទាំងនគរមានអន្តរាយ នេះក៏ដោយសារការសេពគប់បុគ្គលពាលទាំងងងឹតងងល់ដែរ។

ជាចុងក្រោយរឿងនេះអប់រំយើងឱ្យចេះអត់ធ្មត់ ទប់ទល់ចំពោះកំហឹង ប្រើធម៌អហិង្សាក្នុងការដោះ-ស្រាយបញ្ហា នោះទើបជាជោគជ័យពិតប្រាកដជាជោគជ័យដែលមានន័យយ៉ាងទូលាយសម្រាប់មនុស្សជាតិ។ជាក់ស្តែងការដែលព្រះចន្ទកុមារអង្វរព្រះរាជាដោយសុខចិត្តធ្វើជាទាសៈកណ្ហាហាល ឬដើរសុំទានគេ។ តាមរយៈទង្វើរបស់ព្រះចន្ទកុមារនេះ យើងអាចយកមកធ្វើជាគំរូមួយដ៏ល្អ សម្រាប់យកមកអនុវត្តក្នុងជីវភាពប្រចាំថ្ងៃផងដែរ។

៧.៣.៨. រឿងនារទព្រហ្មជាតក

ក. ប្រធានរឿង

ព្រះពោធិសត្វជានារទព្រហ្មគឺនិយាយពីបំពេញឧបេក្ខាបារមីដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

ខ. មូលបញ្ហារឿង

បញ្ហាទី១៖ មិច្ឆាទិដ្ឋិរបស់អាលាតអាមាត្យ និងព្រាហ្មណ៍គុណាជីវកៈ

អាលាតអាមាត្យ ជាមនុស្សប្រកាន់ខ្ជាប់នូវមិច្ឆាទិដ្ឋិ ខ្វះការឈ្វេងយល់ ត្រិះរិះពិចារណារកហេតុផល មិនស្គាល់ល្អអាក្រក់។ គាត់បានណែនាំព្រះរាជាឱ្យធ្លាក់ក្នុងអំពើអកុសល បង្កសង្គ្រាមជាមួយនគរដទៃ។ ម្យ៉ាងទៀតអាលាតអាមាត្យនេះបានរកឧបាយកលញុះញង់ឱ្យព្រះរាជាទៅជួបនឹងគ្រូគុណាជីវកៈ ដែលជាគ្រូរបស់ខ្លួន និងជាមនុស្សមានមិច្ឆាទិដ្ឋិដូចខ្លួន។ មនុស្សប្រភេទនេះនាំគ្រោះថ្នាក់ដល់នគរណាស់ ព្រោះគេមិនខ្វល់ខ្វាយអ្វីទាំងអស់ក្រៅពីប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ។ ចំណែកអាចារ្យគុណាជីវកក៏ជាបុគ្គលមិច្ឆាទិដ្ឋិ គឺយល់ខុសពីសច្ចភាពដឹកនាំមនុស្សទៅរកផ្លូវខុសឆ្គាក់នរក ព្រោះគាត់យល់ថាក្នុងលោកនេះមិនមានផលល្អ ផលអាក្រក់ មិនមានលោកដទៃ ដីដូនដីតាឪពុកម្តាយគ្មានគុណ គ្រូអាចារ្យក៏គ្មានគុណដែរ ព្រោះថាសត្វទាំងឡាយជាប់តគ្នាដូចជាទូកតូចជាប់នឹងទូកធំទៅតាមខ្សែទឹកដូច្នោះដែរ ព្រោះថាបុគ្គលដែលគេទូន្មានមិនបាននៅតែគេទូន្មានមិនបានដដែល បុគ្គលណាដែលគេរាប់អានថាជាមនុស្សគេទូន្មានបាន ក៏ជាអ្នកមានបទស្រាប់ៗមកទេ។ មនុស្សបែបនេះតែតែគ្រោះថ្នាក់ខ្លាំងណាស់ទៅទៀត ពោលគឺនាំឱ្យប្រទេសជាតិធ្លាក់ក្នុងក្តីអន្តរាយ។ ដោយសារការអួសទាញប្រកបដោយភាពប៉ិនប្រសប់របស់គុណាជីវកបណ្តាលឱ្យព្រះរាជាជឿស៊ប់ស្តុងគំនិតលែងចែកទាន លែងធ្វើបុណ្យអ្វីទាំងអស់ ព្រោះយល់ថាជាការឥតប្រយោជន៍។

បញ្ហាទី២៖ ការវង្វេងស្មារតីរបស់ព្រះបាទអង្គតិ

ក្រោយពីបានគ្រូគុណាជីវកអួសទាញកុំឱ្យជឿបុណ្យបាប ល្អ អាក្រក់ ហូរហែមក ព្រះបាទអង្គតិក៏វង្វេងស្មារតីជឿស្តុងគំនិតក្នុងផ្លូវអកុសល លែងស្គាល់បុណ្យបាប គុណទោសដូចមុនទៀតហើយ ទៅជាស្តេចចិត្តអាក្រក់អាត្មានិយម ទោះបីជាព្រះនាងរុចាបុត្រីជាទីស្រឡាញ់ខិតខំលើកហេតុផលមកពន្យល់បែបណាក៏ដោយ។ ព្រះរាជាអង្គតិត្រូវអំពើអកុសលដឹកនាំឱ្យលែងដឹងខុសត្រូវ លែងជាស្តេចមានព្រហ្មវិហារធម៌ ទសពិធរាជធម៌ចំពោះរាស្ត្រទៀតរបស់ព្រះអង្គហើយ។ ប្រការនេះ គឺជាគ្រោះថ្នាក់ណាស់សម្រាប់អ្នកដឹកនាំប្រទេសដោយសារតែការបាត់បង់នូវចិត្តឧបេក្ខាស្តាប់តែការញុះញង់របស់មនុស្សតែមួយក្រុម។ អ្នកដឹកនាំត្រូវមានចិត្តកណ្តាលស្តាប់ហេតុផលឱ្យបានគ្រប់ជ្រុងជ្រោយ ឈរលើគោលការណ៍ត្រឹមត្រូវទើបសង្គមមានសន្តិភាព។

បញ្ហាទី៣ ការបំពេញនូវឧបេក្ខាបារមីរបស់ព្រះពោធិសត្វ(នារទព្រហ្ម)

នៅពេលឃើញបិតាស្តុងទៅក្នុងលទ្ធិរបស់គុណាជីវកហើយ ព្រះនាងរុចាខិតខំប្រើប្រាជ្ញារបស់ខ្លួនពន្យល់អួសទាញព្រះបិតាឱ្យងាកមកសភាពជាមនុស្សដូចដើមវិញ។ ប៉ុន្តែបំណងព្រះនាងមិនបានសម្រេច ព្រះនាងក៏បួងសួងថ្វាយបង្គំគ្រប់ទិសទាំងដប់រកអ្នកទ្រទ្រង់មកជួយ។ គ្រានោះព្រះនារទព្រហ្ម ដែលតែងតែប្រមើលមើលជីវិតសត្វលោក ព្រះអង្គក៏និម្មិតជាឥសីចុះពីអាកាសមកឈរចំពោះព្រះភក្ត្រព្រះបាទអង្គតិ។ ព្រះពោធិសត្វនារទព្រហ្មបានទូន្មានព្រះបាទអង្គតិឱ្យយល់ជ្រួតជ្រាបអំពីទោសនៃអំពើអកុសល និងផលនៃអំពើកុសល។ ព្រះរាជាក្រោយពីទ្រង់

ព្រះសណ្តាប់ព្រះមហាបុរសបរមពោធិសត្វទូន្មានរួចមក ព្រះអង្គក៏កិតក័យតក់ស្លុតញាប់ញ័រចំពោះអំពើអកុសលដែលនាំឱ្យធ្លាក់ទៅក្នុងអបាយភូមិ ហើយត្រេកអរប្រៃស្មារតីមករកអំពើកុសលវិញ។

ក. តួនាទីអប់រំនៃរឿងនារទព្រហ្មជាតក

ឧត្តមគតិសំខាន់នៃរឿងនារទព្រហ្មនេះផ្តោតជាសំខាន់ទៅលើឧបេក្ខាធម៌ គឺធម៌ទី៤នៃព្រហ្មវិហារធម៌។ រឿងនេះអប់រំមនុស្សពិសេសឱ្យអ្នកដឹកនាំចេះត្រិះរិះពិចារណាឱ្យបានម៉ត់ចត់ កុំចេះតែស្តាប់តាមពាក្យញុះញង់របស់ជនអគតិមួយចំនួន ហើយត្រូវចេះស្តាប់ឱវាទរបស់ជនជាបណ្ឌិតដែលដឹកនាំក្នុងផ្លូវធម៌ឆ្ពោះទៅរកសេចក្តីសុខចម្រើន បានសេចក្តីថាត្រូវប្រកាន់ផ្លូវកណ្តាល(មជ្ឈិមាបដិប្បទា) តាមមាគ៌ាអដ្ឋង្គិកមគ្គរបស់ព្រះសម្មាសម្ពុទ្ធ ជាមាគ៌ាដ៏ឧត្តុង្គនាំសត្វទៅកាន់បរមសុខ។ ឧបេក្ខាបារមី សំដៅដល់ការតាំងចិត្តព្រងើយកន្តើយ មិនមានសោមនស្ស ទោមនស្សក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង៥ ក្តី ការតាំងចិត្តឱ្យនៅជាកណ្តាល មិនត្រេកអររីករាយ មិនមានថ្នាំងថ្នាក់អាក់អន់ ចំពោះសត្វ និងសង្ខារទាំងឡាយ ទោះមានឧបការគុណក្តី មិនមានឧបការគុណក្តី ឬក៏សត្វដែលគួរស្រឡាញ់រាប់អានក្តី សត្វដែលគួរស្អប់ខ្ពើមធុញទ្រាន់ក្តី ក៏នៅតែតាំងចិត្តឲ្យព្រងើយ។ តាមប្រក្រតីទៅបាន តែងមានស្មារតី នឹកឃើញដឹងខ្លួនជានិច្ចមិនភ្លាំងភ្លាត់ យ៉ាងនេះ ហៅថាឧបេក្ខាបារមីៗប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយគឺព្រះនិព្វាន ព្រោះតែការតាំងចិត្តព្រងើយៗ កណ្តាលៗ។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ៖

- **បុត្តទារស្សបិ** ការតាំងចិត្តឲ្យព្រងើយកន្តើយចំពោះបុត្រភរិយា ព្រមទាំងសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់នៅជាកណ្តាលយ៉ាងនេះ ហៅថា **ឧបេក្ខាបារមី។**
- **អត្តនោ អង្គស្សបិ** ការតាំងចិត្តព្រងើយកន្តើយ ចំពោះអវយវៈរបស់ខ្លួន ព្រមទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងនៅស៊ប់យ៉ាងនេះ ហៅថា **ឧបេក្ខាឧបបារមី។**
- **ជីវិតស្សបិ** ការតាំងចិត្តព្រងើយកន្តើយ ចំពោះជីវិតព្រមទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់នៅជាកណ្តាលយ៉ាងនេះហៅថា **ឧបេក្ខាបរមត្ថបារមី**។

៧.៣.៩. រឿងវិធុរបណ្ឌិតជាតក

ក. ប្រធានរឿង

រឿងវិធុរបណ្ឌិត បានបង្ហាញឲ្យឃើញពីការកសាងបារមីដ៏មហាអស្ចារ្យរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ ដែលអាចកំណត់បានថា ជាការកសាងសច្ចៈបារមី របស់វិធុរបណ្ឌិតនេះឯង ។

ខ. មូលបញ្ហារឿង

ជុំវិញប្រធានរឿង យើងអាចកំណត់បាននូវបញ្ហាជាច្រើន ដែលជាមែកធាងជុំវិញការកសាងសច្ចៈបារមីរបស់វិធុរបណ្ឌិត នូវបញ្ហាមួយចំនួនដូចជា ៖

បញ្ហាទី១ : ការវិវាទគ្នារបស់ស្តេចទាំងបួន ជុំវិញបញ្ហាសីល

ព្រះវិធុរបណ្ឌិត ជាបុគ្គលដែលពោរពេញដោយប្រាជ្ញាឈ្លាសវៃ ទាំងក្នុងគតិលោក និងគតិធម៌ គឺបានសម្តែងនូវធម៌ដល់ជនទាំងឡាយ ដែលស្ថិតនៅក្រោមឱវាទនៃព្រះធម៌។ ព្រះបាទធនញ្ជ័យកោរព្យ ក៏ស្ថិតនៅក្រោមឱវាទនៃព្រះវិធុរបណ្ឌិត ដែលទ្រង់តែងតែធ្វើឧបោសថរក្សាសីលជាប្រចាំ ជួនជាថ្ងៃមួយបានជួបស្តេចបីអង្គ កំពុងធ្វើសមណៈធម៌ដែរ។ ស្តេចទាំងបួនបានជួបគ្នា ក៏អួតអាងបង្ហាញពីសីលរបស់ខ្លួនរៀងៗខ្លួន ថាសីលរបស់ខ្លួនគឺប្រសើរជាង ហេតុនេះទើបបង្កឱ្យមានបញ្ហាស្មុគស្មាញ មានទំនាស់ វិវាទគ្នាកើតឡើង ដោយដោះស្រាយបញ្ហាមិនបាន ទ្រង់បាន

ទៅជួបព្រះវិធុរបណ្ឌិត ឱ្យជួយស្រាយចម្ងល់ពីការរក្សាសីលនេះ។ វិធុរបណ្ឌិតបានស្រាយចម្ងល់រួច ក៏សម្តែងនូវធម៌ទេសនា ដែលធ្វើឱ្យស្តេចទាំងបួនយល់ជ្រួតជ្រាបពីសីលដ៏ពិតប្រាកដ គឺគ្មានសីលណាល្អជាងសីលណានោះទេ សីលរបស់ព្រះអង្គនីមួយៗ ល្អប្រសើរទាំងអស់ គឺសុទ្ធតែធ្វើឱ្យមានចិត្តជ្រះថ្លាមានចិត្តស្ងប់ រៀរចាកនូវកិលេសបានដូចគ្នា ទើបកើត បានជាសីលនេះឯង។ ដោយក្តីអំណរយ៉ាងល្អគុណពេក ស្តីពីការសម្តែងធម៌នេះ ស្តេចទាំងបួនបានថ្វាយនូវវត្ថុមានតម្លៃ ដូចជាសំពត់ទិព្វ សុវណ្ណមាលា គោ១ពាន់ និងស្តេចនាគ គឺកែវមុណី ដល់ការបូជាដែល ប្រកបដោយសទ្ធាជ្រះថ្លា ស្តីអំពីការសម្តែងនូវព្រះធម៌ដ៏ចម្រើនធ្វើឱ្យមនុស្សចេះរក្សាសីល ទើបនាំមកនូវចិត្តស្ងប់ ទើបអាចបំបាត់នូវមូលហេតុនៃទំនាស់ឱ្យកាន់តែជ្រាបច្បាស់ថែមទៀត ។

បញ្ហាទី២ : ការឈឺស្តមស្តាំងរបស់នាងវិមលាទេវី ព្រោះចង់បរិភោគបេះដូងវិធុរបណ្ឌិត

បញ្ហាចម្បង ដែលជាមូលហេតុបង្កឱ្យមានរឿងរ៉ាវផ្សេងៗ កើតឡើងជុំវិញការស្វែងរកបេះដូង វិធុរបណ្ឌិតឱ្យនាងវិមលាទេវី ដែលទ្រុឌទ្រោមស្តមស្តាំងព្រះកាយ បញ្ហានេះកើតឡើង ពីព្រោះក្រោយពីស្តេចវិរុណនាគរាជ ត្រឡប់មកពីការធ្វើឧបោសថវិញ ព្រះអង្គបានប្រគល់កែវមុណីបូជាឱ្យវិធុរបណ្ឌិត ជាមនុស្សប្រកបដោយបញ្ញាបារមី មានវាចាពីរោះ ពេលទ្រង់សម្តែងធម៌ទេសនាដ៏ប្រសើរក្រៃលែង។ ក្រោយពីបានស្តាប់ឮស្វាមីនិយាយពីព្រះវិធុរជាមនុស្សជាទីប្រសើរនេះរួចមក ធ្វើឱ្យនាងកើតមានចិត្តចង់ស្តាប់ព្រះធម៌ទេសនា របស់ព្រះវិធុរឱ្យខានតែបាន រហូតទៅជាធ្លាក់ទ្រុឌទ្រោម ស្តាំងស្តមព្រះកាយ។ ស្តេចនាគដោយឃើញវិមលាទេវីឈឺដូច្នេះក៏សួរ។ នាងប្រាប់ថាចង់ទទួលទានបេះដូងព្រះវិធុរបណ្ឌិត បើពុំបានមុខជាស្លាប់ហើយ។ ក៏ប៉ុន្តែសំណើរនេះ ត្រូវបានស្តេចវិរុណនាគបដិសេធដោយថានាងចង់បានព្រះអាទិត្យ ព្រះចន្ទ យើងធានានឹងយកឱ្យនាងបាន ប៉ុន្តែវិធុរបណ្ឌិតគ្រាន់តែចង់ឃើញ លោកក៏ មិនងាយនឹងបានឃើញផង កុំថាឡើយរហូតដល់ទៅចង់ទទួលទានបេះដូងទៀតនោះ វាប្រាកដជាពុំបានឡើយ ។ វិធុរបណ្ឌិតជាបុគ្គលថ្លៃថ្លាពិសេស សូម្បីតែព្រះបាទធនញ្ជ័យកោរព្យ ក៏គោរពស្រឡាញ់ព្រមទាំងចាត់ទុកជាមនុស្សជាទីគាប់ចិត្តប្រសើរក្នុងជីវិតផ្ទាល់ ដោយធ្វើឱ្យរាស្ត្រក្នុងនគរករុរដ្ឋ មានសេចក្តីសុខ ចម្រើន ក្រោយពីស្តាប់នូវឱវាទនៃធម៌ទេសនារួចហើយ ។

ទាំងនេះជាបញ្ហាដែលពិបាកស្មុគស្មាញ របស់ស្តេចវិរុណនាគ ដែលចង់ឱ្យមហេសីជាសះស្បើយនោះ គឺពិតជាពិបាកដោះស្រាយណាស់។ ក្រោយមកនាងឥរន្ធតីជាបុត្រី បានមើលឃើញពីអាការ នៃមាតាដូច្នេះ ក៏សម្រេចចិត្តតាមបិតាឱ្យយកប្តីដែលជាអ្នកមានអំណាចសក្តិសិទ្ធ មានសមត្ថភាពខ្លាំង ពូកែ ទើបអាចយកអាសារឿងនេះបាន ។ ពេលនោះនាងក៏បាន ក្លែងខ្លួនជាស្រីក្រមុំច្រៀងរាំរំពើន ហើយប្រកាសថា "**បើនរណាអាចយកបេះដូងវិធុរបណ្ឌិតបាន ខ្លួននឹងក្លាយជាភរិយានៃអ្នកនោះ**"។ ពេលនោះបុណ្ណកយក្ស បានលង់នឹងសម្រស់នាង ហើយក៏ព្រមយកអាសាដោយធានាថានឹងយកបេះដូង វិធុរបណ្ឌិតឱ្យបាន ។ នេះជាបញ្ហាដែល នាំឱ្យកើតមាននូវបញ្ហាផ្សេងៗ ទៀតជុំវិញការស្វែងរកបេះដូង វិធុរបណ្ឌិតនេះឯង ។

បញ្ហាទី៣ : ការគោរពពាក្យសច្ចៈ

នៅពេលដែលបុណ្ណកយក្ស បានក្លែងខ្លួនជាមាណពមកនគរករុរដ្ឋ មកសុំព្រះបាទធនញ្ជ័យ កោរព្យលេងភ្នាល់ល្បែងបាស្កា ដោយដាក់សេះមនោម័យមានល្បឿនលឿន និងកែវមណីមនោហរ ដែលអាចឆ្លុះមើលឃើញរូបភាពអ្វីៗនៅក្នុងពិភពលោកបានតាមចិត្តចង់ គឺក្នុងគោលបំណងដើម្បីយកបេះដូងវិធុរបណ្ឌិត។ ស្តេចយល់ព្រមហើយថាបើចាញ់នឹងប្រគល់ទ្រព្យសម្បត្តិក្នុងនគរ តាមតែត្រូវការ លើកលែងតែព្រះអង្គ និងមហេសី ព្រមទាំងសិរីរាជ

សម្បត្តិចេញ។ បុណ្ណកយក្សភ្នាល់ឈ្នះក៏សុំតែវិធុរបណ្ឌិតប៉ុណ្ណោះ តែស្តេចធនញ្ជ័យកោរព្យមិនយល់ព្រម គឺចាត់ទុកវិធុរបណ្ឌិត ជាមនុស្សជាទីគាប់ចិត្តស្មើជីវិតខ្លួន ទ្រង់មិនអាចឱ្យបានឡើយ។ រួចក៏កើតមានការវិវាទប្រកែកគ្នា ដោយស្តេចមិនគោរពពាក្យសត្យរបស់ខ្លួន ដូចនេះទើបបុណ្ណកយក្សសុំឱ្យវិធុរបណ្ឌិតមកដោះស្រាយបញ្ហានេះ។ វិធុរបណ្ឌិតសុខចិត្តលះបង់ជីវិត គឺដើម្បីពាក្យពិតរបស់របស់ចៅហ្វាយនាយ និងនគរកុំឱ្យកើតអន្តរាយមានទំនាស់វិវាទកើតឡើងព្រោះតែខ្លួននិងដើម្បីសេចក្តីសុខរាស្ត្រទូទាំងនគរ ព្រមទាំងឱ្យស្តេចគោរពនូវពាក្យសច្ចៈរបស់ទ្រង់ ដែលទ្រង់បានសន្យានោះកុំឱ្យខុសនឹងពាក្យពិតទៀងត្រង់របស់ស្តេច។ ដូចនេះវិធុរបណ្ឌិត គិតថាមានតែការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈជាត្រីមុខ គឺលះបង់ជីវិតផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិរួម ជាសំខាន់ នោះមានតែការគោរពពាក្យសច្ចៈទេដែលជាគុណធម៌ដ៏ប្រសើរ នាំឱ្យសត្វលោកមានសេចក្តី សុខចម្រើន ទើបសម្រេចចិត្តទៅតាម បុណ្ណកយក្សដោយឥតលក្ខខណ្ឌ ទាំងនេះជាដំណោះស្រាយដោយសន្តិវិធីរបស់ព្រះវិធុរបណ្ឌិត ។

ដោយសេចក្តីពិតទៀតត្រង់ ទោះបីយក្សចាប់បោះបោកសម្លាប់យ៉ាងណាក៏មិនស្លាប់ ដោយសារអំណាចនៃពាក្យសច្ចៈ នោះទើបខាខាំងរារាំង មិនឱ្យអន្តរាយកើតមានដល់ជីវិតបាន។ ដោយទ្រង់បាន សួរដឹងពីដំណើររឿង ថាហេតុអ្វីក៏ចង់យកបេះដូងរបស់ខ្លួនទៅឱ្យវិរុណនាគនោះ ក៏បានសម្តែងនូវធម៌ ទេសនាឱ្យបុណ្ណយក្សស្តាប់។ បុណ្ណកយក្សស្តាប់ហើយកើតមានចិត្តបុណ្យមានចិត្តជ្រះថ្លាបានដឹងនូវកំហុសរបស់ខ្លួនថាយកខ្លួនមនុស្ស ដែលជាទីប្រសើរក្រៃលែងទៅសម្លាប់នោះ គឺជាការប្រព្រឹត្តខុសនូវ សាធុនរធម៌ហើយតើគិតហើយទើបសម្រេចចិត្តដោះលែងវិធុរវិញ ប៉ុន្តែវិធុរបណ្ឌិតដោយចង់គោរព ពាក្យសច្ចៈពាក្យពិតហើយនឹងចង់ឱ្យបុណ្ណកយក្សគោរពពាក្យសន្យា ក៏បានសម្រេចចិត្តទៅពិភពនាគបន្តទៀត ប៉ុន្តែដោយសេចក្តីធម៌នាងវិមលាទេវីគ្រាន់តែស្តាប់ ឮនូវព្រះធម៌ទេសនាភ្លាមនោះធ្វើឱ្យនាងជាសះស្បើយមួយរំពេច ទើបស្តេចថាព្រះធម៌ទេសនានេះហើយ ជាបញ្ញារបស់វិធុរបណ្ឌិតទើបជាបេះដូងរបស់ព្រះវិធុរបណ្ឌិតពិតប្រាកដ ។

គ. តួនាទីអប់រំនៃរឿងវិធុរបណ្ឌិតជាតក

- កតញ្ញូ ជាប្រភពនៃសេចក្តីចម្រើន សេចក្តីស្រឡាញ់ ជាប្រភពនៃសុភមង្គល
- លះបង់ប្រយោជន៍បុគ្គល ដើម្បីប្រយោជន៍រួម
- ការលេងល្បែងភ្នាល់ នាំឱ្យវិនាសបាត់បង់ប្រយោជន៍ ការត្រិះរិះពិចារណា ជាប្រភពនៃជ័យជំនះ
- បញ្ញា ជាអាវុធសម្រាប់ដោះស្រាយបញ្ហាដោយសន្តិវិធី
- ការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ នាំឱ្យមានសីលធម៌ល្អ និងសេចក្តីថ្លៃថ្នូរ
- ការគោរពពាក្យសច្ចៈ គឺជាប្រភពនៃគុណធម៌ដ៏ល្អប្រសើរ
- ការគោរពពាក្យសន្យា ជាប្រភពនៃជោគជ័យ និងក្តីសង្ឃឹម
- ការរក្សាសីល គឺរក្សាបាននូវចិត្តស្ងប់ ចិត្តជ្រះថ្លា វៀរចាកនូវអំពើបាប
- ការស្តាប់នូវព្រះធម៌ទេសនា នាំឲ្យមនុស្សកើតមាននូវបញ្ញា
- សភាវៈ ដែលគួរឱ្យខ្លាច គឺកាយវាចា ចិត្ត ជាទុច្ចរិត
- ប្រភពនៃសេចក្តីទុក្ខ គឺកើតឡើងអំពីតណ្ហានៃចិត្ត

រឿងរ៉ាវផ្សេងៗ ក្នុងគម្ពីរទេសជាតក សុទ្ធតែបានលើកយកទស្សនៈនៃការអប់រំមកពន្យល់បង្ហាញ អ្នកអានអ្នកស្តាប់ឱ្យបានស្គាល់ និងយល់ច្បាស់នូវចលនាពុទ្ធនិយមពិតប្រាកដ។ រឿងវិធុរបណ្ឌិតជា រឿងដែលពោរពេញទៅ

ដោយទស្សនៈអប់រំ ហើយបានបង្ហាញពីការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ គឺសេចក្តីពិតទៀតត្រង់តាំងពីដើមរហូតដល់ចប់ ជាតួអង្គគំរូមានលក្ខណៈពិសេស មានប្រាជ្ញាវាងវៃ មានព្រះទ័យ ទូលំទូលាយចំពោះមនុស្សទូទៅ ដោយសទ្ធាជ្រះថ្លា ហ៊ានលះបង់នូវជីវិតផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិ។ ហេតុនេះទើបធ្វើឲ្យតួអង្គអាក្រក់ ដែលចង់យកបេះដូងវិធុរបណ្ឌិត ដែលជាមនុស្សជាទីគោរពស្រឡាញ់ របស់រាស្ត្រ បែរទៅជាទន់ចិត្ត ទន់កាយ ត្រឡប់ជាមានសទ្ធាជ្រះថ្លា ក៏ព្រោះតែសេចក្តីពិត ក្រោយពីការ សម្តែងនូវធម៌ទេសនាអប់រំនេះហើយ ក៏ធ្វើឱ្យអ្នកទាំងអស់នោះ ប្រែក្លាយទៅជាមានចិត្តស្ងប់ ចូលចិត្ត គោរពស្រឡាញ់ ចង់ស្តាប់ ចង់ឮនូវការសម្តែងព្រះធម៌ទេសនាដ៏ប្រពៃថ្លៃថ្លានេះទៅវិញ ។

ក្រោយពីបានសិក្សារឿង វិធុរបណ្ឌិតនេះរួចមក យើងអាចបង្ហាញបាននូវតម្លៃអប់រំដូចតទៅ ៖

- អប់រំឱ្យមានភាពកតញ្ញូចំពោះមាតាបិតា និងចេះតបស្នងសងគុណ ចំពោះអ្នកមានគុណ។
- អប់រំឱ្យចេះប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ គឺសេចក្តីពិតទៀតត្រង់ ដែលជាប្រភពនៃសេចក្តីថ្លៃថ្នូរ និង សីលធម៌ល្អ នោះទើបជាគុណធម៌ដ៏ប្រសើរ ។
- អប់រំឱ្យចេះយកបញ្ញាមកដោះស្រាយបញ្ហាដោយសន្តិវិធី គឺជៀសវាងការប្រើប្រាស់នូវកម្លាំងបាយ នេះជាដំណោះស្រាយដ៏ប្រសើរ ។
- អប់រំឱ្យចេះលះបង់នូវប្រយោជន៍បុគ្គល ដើម្បីប្រយោជន៍រួមជាសំខាន់ ។
- អប់រំឱ្យមានកក្តីភាព និងស្មោះត្រង់ចំពោះស្នេហា គឺជាប្រភពនៃសុភមង្គល ។
- អប់រំកុំឱ្យលេងល្បែង នាំឱ្យវិនាសបាត់បង់ទ្រព្យសម្បត្តិ និងមនុស្សជាទីគាប់ចិត្ត ។
- អបរំឱ្យចេះត្រិះរិះពិចារណាឲ្យសមហេតុផលជាមុនសិន មុននឹងធ្វើការសម្រេចចិត្ត ។
- អប់រំឱ្យចេះរក្សាសីលប្រកបដោយចិត្តជ្រះថ្លា ដើម្បីជៀសផុតអំពីសេចក្តីទុក្ខ ដែលកើតឡើងអំពីតណ្ហានៃចិត្ត គឺរក្សាបាននូវចិត្តស្ងប់ ។

៧.៣.១០. រឿងវេស្សន្តរជាតក

ក. ប្រធានរឿង

ព្រះវេស្សន្តរជាជាតិកំណើតពោធិសត្វចុងក្រោយបង្អស់របស់ព្រះពុទ្ធ។ ក្នុងរឿងនេះ ព្រះពោធិសត្វមាននាមថា "វេស្សន្តរ" ។ ឯដំណើររឿងទាំងមូលបានលាតត្រដាងពីដំណើរជីវិតព្រះអង្គដែលផ្សារភ្ជាប់តែ "ការដាក់ទាន" តែប៉ុណ្ណោះ ។ ដូចនេះប្រធានរឿងគឺ "ការបំពេញទានបារមីរបស់ព្រះពោធិសត្វព្រះនាមវេស្សន្តរ"។ ការបំពេញទានបារមីនេះ គឺការបំពេញមហាបរិច្ចាគ៥គឺ ធនបរិច្ចាគបុត្តបរិច្ចាគ ភរិយាបរិច្ចាគ អង្គបរិច្ចាគ និងជីវិតបរិច្ចាគ ។

ខ. មូលបញ្ហារឿង

តាមរយៈសាច់រឿងព្រះវេស្សន្តរឃើញថា ការបរិច្ចាគទានទាំង៥នេះ មនុស្សធម្មតាមិនអាចធ្វើបានទេ។ ដូចនេះការបំពេញទានបារមីរបស់ព្រះវេស្សន្តរអាចសម្រេចបានដោយរបៀបណា? ហើយការបរិច្ចាគទាំងនេះជាការងារធម្មតាចំពោះព្រះអង្គ ឬវាស្ថិតក្នុងដំណាក់ការតស៊ូព្យាយាមដែរឬទេ?

តាមដំណើររឿងយើងឃើញថាថ្វីត្បិតតែព្រះវេស្សន្តរជាទេវបុត្រ ដែលច្យុតមកលើផែនដីដើម្បីបំពេញទានបារមីក៏ដោយ ក៏ការបំពេញទាននោះវាមិនមែនជាការងារធម្មតាចំពោះព្រះអង្គឡើយ ព្រោះពេលដែលបំពេញទានព្រះអង្គថា "មនុស្ស" ពេលមិនទាន់ក្លាយជាព្រះនៅឡើយទេ ។

តាមរយៈការបំពេញទានបារមីនេះគេអាចឃើញនូវបញ្ហាចោទសំខាន់ៗមួយចំនួនដូចខាងក្រោម៖

បញ្ហាទី១-បញ្ហាបុគ្គល និងកម្លាំងប្រជាប្រជាធិបតេយ្យ

ទោះបីព្រះវេស្សន្តរកើតក្នុងត្រកូលក្សត្រ ឬក៏ក្នុងគំនរទ្រព្យសម្បត្តិងាយស្រួលក្នុងការបំពេញទានក៏ដោយ ក៏ព្រះអង្គត្រូវជួបប្រទះបញ្ហាមួយក្នុងសង្គមមនុស្ស គឺការមិនយល់ស្របពីសំណាក់ប្រជារាស្ត្រទេ។ អ្នកនគរស្រីពិរាស្ត្រគេមិនទាន់យល់ពីការដាក់ទាននោះទេ ហើយការដែលព្រះវេស្សន្តរបរិច្ចាគទ្រព្យសម្បត្តិរបស់ប្រទេសជាតិ ដោយមិនទាន់បានពន្យល់ដល់មហាជន នោះព្រះអង្គត្រូវតែជួបនឹងឧបសគ្គដែលជា " មតិប្រជាធិបតេយ្យ " នេះដោយខានពុំបាន។ ដូចនេះហើយទើបពេលព្រះអង្គប្រទានដំរីមង្គលឈ្មោះ«បច្ច័យនាគេន្ទ្រ» ទៅពួកព្រាហ្មណ៍នៅស្រុកកលិង្គរាស្ត្រ ព្រះអង្គត្រូវអ្នកនគរស្រីពិរាស្ត្របះបោរបណ្តេញចេញពីនគរ ។

បញ្ហាទី២-បញ្ហាបុគ្គលនិងព្រហ្មវិហារធម៌

ជាការពិតណាស់ដែលព្រះវេស្សន្តរបានធ្វើការបរិច្ចាគទានដោយគ្មានរញ្ជួរ សូម្បីពេលដែលត្រូវគេបំបរបង់ហើយក៏នៅតែហ៊ានលះបង់គ្មានស្តាយស្រណោះ ដូចជាតាមផ្លូវទៅភ្នំគិរីវង្គត ព្រះអង្គបានដាក់ទានអាជានេយ្យទាំង៤ព្រមទាំងរាជរថទៅពួកព្រាហ្មណ៍ ហើយចែកកូនគ្នាពធ្វើដំណើរដោយជើង។ ប៉ុន្តែប្រការមួយដែលមនុស្សធម្មតារហូតដល់ព្រះពោធិសត្វពិតជាពុំអាចចៀសផុតបាន គឺមនោសញ្ចេតនាជាព្រហ្មវិហារធម៌របស់ឪពុកចំពោះកូន។ ព្រះអង្គអាចដាក់ទានវត្ថុគ្មានវិញ្ញាណដោយគ្មានបង្ខំចិត្ត តែព្រះអង្គត្រូវតែខ្លោចចិត្តអាណិតបុត្រពេលដែលដាក់ទានបុត្រឱ្យទៅព្រាហ្មណ៍ឬស្សាដោយឮវាចាគ្លួញត្អែរ យំស្រែកពីការឈឺចាប់របស់បុត្រ ។

ដូចនេះហើយទើបព្រះអង្គរិះតែនឹងប្រហារជូជកចោល។ នេះមិនមែនជាឥទ្ធិពលនៃកំហឹងទេ តែវាជាការជំរុញនៃព្រហ្មវិហារធម៌ ។ល

បញ្ហាទី៣-បញ្ហាបុគ្គល និងប្រយោជន៍អ្នកជាទៃ

បើនិយាយដល់សម័យកាលនោះ ការចំណាយទ្រព្យធនរបស់ព្រះវេស្សន្តរពុំអាចចាត់ទុកថាជាការប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជនឡើយ។ ប៉ុន្តែតាមដំណើររឿង ដំរីបច្ច័យនាគេន្ទ្រ គឺជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គជាអំណោយរបស់មេដំរីសួគ៌ដែលហោះមកថ្វាយ ។ ដូចនេះហើយទើបព្រះអង្គមិននឹកនាដល់ការប្រឆាំងពីអ្នកនគរស្រីពិរាស្ត្រ។ មុនពេលត្រូវគេបណ្តេញទើបព្រះអង្គយល់ពីបញ្ហានេះ ហើយសុខចិត្តចាកចោលនគរដោយគ្មានប្រកែក។ ប្រការនេះហើយទើបនាំឱ្យព្រះវេស្សន្តរតែងតែស្ថាបស្ងប់ ឬអង្វរអ្នកដែលទាក់ទងដល់ផលប្រយោជន៍នៃទានរបស់ព្រះអង្គជានិច្ច ។

- ពេលធ្វើបុត្តបរិច្ចាគ ព្រះអង្គបានអង្វរបុត្រយ៉ាងច្រើន ទាល់តែបុត្រយល់ព្រមដោយខ្លួនឯង ។
- ហើយពេលដាក់ទានភរិយាទៅឱ្យឥន្ទ្រព្រាហ្មណ៍ ក៏ព្រះអង្គចោលកន្ទុយភ្នែកស្ថាបស្ងប់ចិត្តព្រះនាងមទ្រីទាល់តែព្រះនាងឆ្លើយថាយល់ព្រម ទើបទ្រង់ធ្វើ "ភរិយាបរិច្ចាគ " ។

និយាយរួមការបរិច្ចាគតាមបែបរឿងព្រះវេស្សន្តរ គឺជាការបរិច្ចាគដ៏តឹងតែងជាទីបំផុតដែលមនុស្សសាមញ្ញប្រាកដជាមិនអាចធ្វើបាន មានតែព្រះវេស្សន្តរទើបអាចសម្រេច ។

បញ្ហាទី៤- សីលធម៌សាសនាតាមរយៈរឿងព្រះវេស្សន្តរ

ចំពោះមហាបរិច្ចាគទានរបស់ព្រះវេស្សន្តរនេះ អ្នកនិពន្ធមានគំនិតមួយអប់រំមនុស្សឱ្យហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីឱ្យមនុស្សជាតិទូទៅពិសេស គឺការដាក់ទានចំពោះជនអ្នកក្រីក្រគោកយ៉ាក។ ព្រះវេស្សន្តរតែងព្យាយាមបំពេញទានបារមីនោះ គឺដើម្បីបានត្រាស់ជាព្រះពុទ្ធ និងបានជួយប្រោសសត្វលោកឱ្យផុតចាកពីអវិជ្ជា។ យើងឃើញ

ថាតួអង្គសំខាន់ៗដទៃទៀតក៏ឯកភាពក្នុងឧត្តមគតិនេះដែរ ដូចជាកុមារជាលីនិងក្រស្នា ទោះបីត្រូវទទួលទណ្ឌកម្ម យ៉ាងខ្លោចផ្សាពីតាជូដក ក៏គេនៅតែជួយការពារឧត្តមគតិឪពុករបស់ខ្លួន។ ឯនាងមទ្រីដោយបាត់កូន នាងយំសោក ស្វែងរកហូតសន្លប់បាត់ស្មារតី តែនៅពេលដឹងថាព្រះស្វាមីឱ្យកូនជាទានដល់ព្រាហ្មណ៍នោះ ព្រះនាងក៏ស្ងប់ដែរ។ ពិសេសទៅទៀត នាងហ៊ានលះបង់ខ្លួនថ្វាយព្រះឥន្ទ្រដែលប្រែជាភេទព្រាហ្មណ៍ដើម្បីជួយបំពេញបារមីរបស់ស្វាមី ។ ដូចនេះសូម្បីតែទេវតា ព្រះឥន្ទ ក៏ជួយជ្រោមជ្រែងឱ្យព្រះវេស្សន្តរសម្រេចឧត្តមគតិនេះដែរ។ ឧត្តមគតិនេះជាសំណូមពរនៃយុគសម័យដែលមនុស្សកំពុងស្ថិតក្រោមឥទ្ធិពលលទ្ធិព្រាហ្មណ៍ ដែលនិយមគិតតែប្រយោជន៍ផ្ទាល់ខ្លួន។ ឧត្តមគតិនេះហើយជាសីលធម៌និងជាទិសដៅសំខាន់បំផុតនៃលទ្ធិព្រះពុទ្ធសាសនា។ ដូចនេះហើយទើបអ្នកនិពន្ធបានជំរុញឱ្យតួអង្គទាំងអស់បែរឆ្ពោះទៅរកសីលធម៌នេះ ទោះបីបន្សារតួអង្គទាំងឡាយដែលពីដំបូងមិនយល់បញ្ហានេះក៏ដោយ ក៏ទីបញ្ចប់បានអបអរសាទរនឹងទានបារមីរបស់ព្រះវេស្សន្តរដែរ ។

ដោយឡែកពួកព្រាហ្មណ៍ដែលតំណាងឱ្យគុណវិបត្តិនៃសម័យកាលត្រូវបានអ្នកនិពន្ធនិយាយតែពីលក្ខណៈអាក្រក់ និងអន្តរាយ។ មរណភាពរបស់តាជូដក វាស្ថិតក្នុងន័យអត្តទត្ថបុគ្គលលោភលន់ចង់មានបានកេងកិបពីអ្នកដទៃនោះត្រូវរលាយបន្ទាប់ពីការកើតឡើងនូវការដាក់ទាន ពោលគឺការបរិច្ចាគដល់អ្នកដទៃ។

បញ្ហាទី៥- ការិះគន់ទស្សនៈបរិច្ចាគបែបពុទ្ធសាសនា

ការលះបង់ដើម្បីមនុស្សជាតិជាគោលការណ៍ដ៏ប្រពៃ ដូច្នេះបើមនុស្សម្នាក់ៗគិតដល់អ្នកដទៃច្រើនជាងខ្លួននោះពិភពលោកនឹងបានសេចក្តីសុខសាន្ត។ ក៏ប៉ុន្តែតាមការពិនិត្យជីវភាពជាក់ស្តែង យើងឃើញថា ការគិតដល់អ្នកដទៃមានតែតាមរយៈការដាក់ទានតែមួយមុខនេះវាពុំអាចលុបបំបាត់ភាពក្រីក្រគោកយ៉ាករបស់មនុស្សបានឡើយ។ ម្យ៉ាងទៀតវិធីដាក់ទានអាចមានចំណុចអសកម្មជាច្រើន៖

- អ្នកទទួលមិនអាចលុបបំបាត់ភាពគោកយ៉ាកបានរហូតទេ ពេលអស់ជំនួយត្រូវធ្លាក់ក្នុងសភាពដើមវិញ ។
- អ្នកទទួលអាចក្លាយជាជនអសកម្ម មិនខិតខំដោយខ្លួនឯង អាងលើជំនួយអ្នកដទៃ។
- និយាយរួមទៅគឺ មិនអាចជួយបានគ្រប់អ្នកក្រីក្រគោកយ៉ាកនោះឡើយ ។

ដូចនេះគោលការណ៍មនុស្សធម៌នៃពុទ្ធសាសនាជាគោលការណ៍ល្អប្រសើរ ក៏ប៉ុន្តែវិធីដាក់ទានតាមបែបព្រះវេស្សន្តរ មិនអាចនាំឱ្យយើងអាចសម្រេចគោលការណ៍នេះបានឡើយក្នុងសង្គមបច្ចុប្បន្ន។ ហេតុនេះយើងអាចឈរលើគោលការណ៍នេះបាន តែគួរអនុវត្តវិធីផ្សេងៗដែលជឿនលឿនជាងនេះដូចជា៖

- តាមរយៈការអប់រំស្មារតីតស៊ូ ឬការអប់រំវិជ្ជាជីវៈ និងសីលធម៌រស់នៅ ។
- ជួយតាមរយៈមធ្យោបាយសាងសង់សាលារៀន មន្ទីរពេទ្យ វត្តអារាម ផ្លូវថ្នល់ ជីកស្រះ ... ។ល ។

ការជួយដូចនេះវាអាចមានប្រសិទ្ធភាពច្រើន និងយូរអង្វែងជាងការដាក់ទានប្រាក់កាស ឬសម្ភារៈ ជាក់ស្តែងចំពោះមុខ។ និយាយរួមគោលការណ៍និងវិធីបែបពុទ្ធសាសនា វាកើតឡើងក្នុងសម័យកាលមួយដែលមនុស្សជាតិកំពុងស្រែកឃ្លាន ការសន្តោសទៅវិញទៅមក ដូចនេះវាមានតម្លៃយ៉ាងលើសលប់។ បច្ចុប្បន្ននេះប្រជាជនដែលគោរពព្រះពុទ្ធសាសនាក៏នៅតែរក្សាគោលការណ៍ និងវិធីនេះដោយមិនបានចាប់អារម្មណ៍ពីការវិឌ្ឍពីទស្សនៈនិងវិធីសាស្ត្ររស់នៅដែលចេះតែរីកចម្រើនជាលំដាប់។

៧.៤. តួនាទីកម្សាន្តតាមរយៈស្ថាដែអក្សរសិល្ប៍មរណាមតា

ក. ប្រធានរឿង

តាមរយៈការអានរឿងនេះជាច្រើនលើកច្រើនសារ ក្រុមយើងខ្ញុំរកឃើញនិងសំរេចជ្រើសរើសយក ប្រធានរឿងដែលក្តោបសាច់រឿងទាំងមូលនោះគឺ ការមានប្រពន្ធច្រើនគឺជាប្រភពនៃសេចក្តីសុខផងនិងទុក្ខផង ។ ប្រការនេះជាដើមចមនិងជាមូលហេតុដែលនាំឱ្យកើតមាននូវសោកនាដកម្ម ភាពកំសត់ និងទុក្ខវេទនាដែលតែងតែកើតឡើងក្នុងសង្គមគ្រប់សម័យកាលទាំងអស់។ ដូចនេះយើងអាចនិយាយបានថា រឿងមរណាមតាក៏គួរត្រូវគេដាក់បញ្ចូលជាអក្សរសិល្ប៍ដែលមានតំលៃកល ព្រោះយើងឃើញថារឿងនេះ មិនមែនត្រឹមតែអប់រំតាមបែបពុទ្ធសាសនាប៉ុណ្ណោះទេ ពោលគឺទស្សនៈកម្មផល បានន័យថាកម្មបែប ណាផលបែបនោះ ដូចឧទាហរណ៍ជាក់ស្តែងក្នុងរឿងនេះស្រាប់ម្យ៉ាងវិញទៀតរឿងក៏បានបង្ហាញពីគ្រួសារដែលធ្លាប់តែមានសុខសុភមង្គល តែបែរប្រែក្លាយជាគ្រួសារដែលពោរពេញដោយសេចក្តីប្រចណ្ឌ ច្រណែន ឈ្នានីស និងសេចក្តីលោភលន់ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ព្រោះតែស្នេហាត្រីកោណ។ ហើយការដែលមានប្រពន្ធច្រើននេះ គឺរមែងតែងតែទទួលគុណវិបត្តិច្រើនជាគុណសម្បត្តិ ។

ខ-មូលបញ្ហារឿង

យោងតាមខ្លឹមសារនៃរឿងទាំងមូល មូលបញ្ហានៃរឿងគឺបិតត្រង់ថាតើអ្វីជាបញ្ហាដែលនាំឱ្យកើត រឿងកំសត់និងទុក្ខវេទនាចំពោះនាងមរណាមតា នរណាជាអ្នកធ្វើ ហើយនរណាជាអ្នករងនូវអំពើទាំង អស់នោះ រួចនរណាជាអ្នកទទួលខុសត្រូវនៅក្នុងរឿងនេះ បន្ទាប់មកគេដោះស្រាយបញ្ហាដោយរបៀបណា។ តាមរយៈគំនិតនិងទស្សនៈរបស់កវីនិពន្ធរឿងនេះបានដោះស្រាយតាមបច្ច័យហេតុនិងផល ពោល គឺ ៖

១- បញ្ហាការជឿទៅលើអបិយជំនឿឥតសមហេតុផលនិងមន្តអាគមដែលមានការធ្វើស្នេហ៍។

២- អំពើល្អ ការដឹងគុណ និងដឹងខុសដឹងត្រូវគឺរមែងតែងតែទទួលនូវបុណ្យកុសលល្អ ព្រមទាំងយុត្តិធម៌។

៣- ហើយអំពើធិតក្បត់ មានគំនិតព្យាបាទគេតែងតែទទួលនូវបាបកម្មនូវអំពើដែលខ្លួនបានសាងជាក់ជាមិនខានឡើយ គ្រាន់តែថាយូរនិងឆាប់ដោយមិនចាំបាច់រងចាំដល់ទៅជាតិមុខជាតិក្រោយឡើយ ជាពិសេសគឺផលវិបាកនៃការមានប្រពន្ធច្រើន។

៤- ទ្រព្យសម្បត្តិនិងបុណ្យសក្តិពុំមែនជាសេចក្តីសុខពិតប្រាកដនោះទេ ។

៥- បញ្ហាការងប់ងល់នឹងស្នេហាខ្លាំងពេកឬយកស្នេហាជាត្រីមុខនាំឱ្យវិនាស។

គ. តួនាទីកម្សាន្តបែបអប់រំ

តាមរយៈរឿងមរណាមតា ដូចយើងបានដឹងស្រាប់ហើយថាជារឿងដែលទាក់ទងនឹងគតិធម៌និងគតិលោក។ ជារឿងមួយដែលយើងពុំធ្លាប់បាននឹកគិតដល់ទាល់តែសោះឡើយ ថាវាមានតំលៃពុំអាចកាត់ ថ្លៃបាន ។ អ្នកនិពន្ធច្រើនលើកយកទស្សនៈកម្មផលក្នុងវិស័យពុទ្ធសាសនាផ្សាភ្ជាប់និងលោកិយ៍សច្ច: ។

តើការលើកយកទស្សនៈកម្មផលក្នុងវិស័យពុទ្ធសាសនាផ្សាភ្ជាប់នឹងលោកិយ៍សច្ច:បានផ្តល់ផល ប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ?

- ជារឿងមួយដ៏ល្អមានសារៈសំខាន់បំផុតសំរាប់បំភ្លឺផ្លូវដល់បច្ឆាជនឲ្យបានយល់ពីបាតុភូតរបស់ សង្គមក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិ ។

- អប់រំទាំងផ្លូវកាយផ្លូវចិត្ត សំរាប់ជាស្ពានចម្លងមនុស្សឲ្យផុតពីទុក្ខវេទនាក្នុងឆាកជីវិតរបស់ខ្លួនឱ្យប្រជាជនខ្មែរយើងមានកាយ វាចា ចិត្តស្លូតបូត សុភាពរាបសារ ដឹងខុសត្រូវ មិនច្រងេងច្រងាង។
- អប់រំឲ្យស្អប់អំពើអាក្រក់ស្រឡាញ់អំពើល្អ ដោយគោរពប្រតិបត្តពុទ្ធសាសនាឲ្យបានខ្ជាប់ខ្ជួន ប្រកាន់នូវធម៌អហិង្សានិងខន្តី ជាពិសេសការអប់រំឲ្យមានជំនឿលើកម្មផល ។
- អប់រំឱ្យស្រឡាញ់សន្តិភាព គ្មានគំនិតឈ្លានពានអ្នកដទៃ
- អប់រំឲ្យមានចិត្តមេត្តា ករុណា និងចេះធ្វើទានចំពោះអ្នកក្រីក្រជាពិសេសកត្តញ្ញូចំពោះអ្នកមានគុណ។
- អប់រំចិត្តគំនិតមិនឲ្យលោភលន់ហួសហេតុ ហួសពីសមត្ថភាពខ្លួន។
- អប់រំឲ្យប្រកាន់ខ្ជាប់នូវសេចក្តីព្យាយាម
- អប់រំឲ្យចេះយកបញ្ញាមកដោះស្រាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មុននឹងធ្វើអ្វីមួយៗត្រូវគិតត្រិះ រិះពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ មិនត្រូវទទួលយកនូវឃោសនាអកុសលទាំងឡាយណាដោយគ្មាន ការពិចារណានោះឡើយ។ ហើយមុននឹងដាក់ទោសទណ្ឌដល់នរណាម្នាក់នោះគួរគប្បីស៊ើបឲ្យបានច្បាស់ ជាមុនសិន។
- អប់រំកុំឱ្យយើងយកស្នហាធ្វើជាត្រីមុខ។ល។

៨. សន្និដ្ឋាន

អក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ ពោលគឺសម័យលង្វែកនិងឧត្តុង្គ បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងព្រះពុទ្ធសាសនា ហើយពិតជាមានការរីកចម្រើនឆ្ពោះទៅរកយុគមាសនៃអក្សរសាស្ត្រខ្មែរតាមរយៈស្នាដៃ និងអ្នកនិពន្ធដ៏សម្បូរបែប។ អក្សរសិល្ប៍ពុទ្ធនិយមមានតួនាទីយ៉ាងសំខាន់ក្នុងការជួយអប់រំជនានុជនជាពុទ្ធបរិស័ទ និងសត្វលោកទូទៅឱ្យវៀរចាកការប្រព្រឹត្តអំពើអាក្រក់ ងាកមកប្រព្រឹត្តអំពើល្អ និងព្យាយាមដុះខាត់សម្អាតចិត្តឱ្យស្អាតតាមមាគ៌ានៃអង្គព្រះសម្មាសម្ពុទ្ធ។ ក្នុងនោះព្រោះអង្គបានបន្សល់ទុកមេរៀនដ៏ល្អឯកដូចជា៖ ទ្រឹស្តីបដិច្ចសមុប្បាទ ដែលបង្ហាញបុព្វហេតុនៃការវង្វេងក្នុងកាមភពនៃសត្វលោកងោកងុយរកផ្លូវចេញចាកមិនបានបើនៅតែអវិជ្ជា។ ចំណែកទ្រឹស្តីចតុរារិយសច្ចៈ ឬអរិយសច្ចៈ បង្ហាញពីជីវិតនេះជាទុក្ខ មូលហេតុនៃទុក្ខគឺតណ្ហា ផ្លូវរំលត់ទុក្ខគឺនិព្វាន ហើយមាគ៌ានៃការរំលត់ទុក្ខគឺតាមរយៈអដ្ឋង្គិកមគ្គ។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ ពោលគឺទសជាតកបានរួមចំណែកបណ្តុះការអប់រំដែលជាតួនាទីបើកបង្ហាញផ្លូវមនុស្សឱ្យមើលឃើញពីទុក្ខលំបាកវេទនានៃសត្វលោកទាំងពួង ហើយការចេញចាកទុក្ខគឺមានតែការសាងព្រះផ្ទួសស្វែងរកសេចក្តីពិតដែលជាសច្ចភាពរបស់ធម្មជាតិនេះឯង។

មួយចំណែកទៀតតាមរយៈអក្សរសិល្ប៍ពុទ្ធនិយមក្លាយ ដែលក្នុងនោះមានសាស្ត្រាល្បែងជាដើម គឺបានរួមចំណែកជួយបន្ធូរភោគតានតឹងនៃមនុស្សឱ្យធូរស្រាលបានខ្លះដែរ។ ទន្ទឹមនឹងនេះផងដែរ ទំនោរនៃឥទ្ធិពលរបស់ព្រះពុទ្ធសាសនា បានចាក់ឫសផ្សារភ្ជាប់ជាមួយផ្នត់គំនិត ជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិខ្មែរយ៉ាងជ្រាលជ្រៅតាមរយៈការប្រើប្រាស់អក្សរសិល្ប៍ធ្វើជាឱសថសម្រាប់បំពេលួងលោមអារម្មណ៍ និងព្យាបាលជំងឺផ្លូវចិត្តខេមរជនឱ្យបានល្ហែល្ហើយធូរស្បើយពីទុក្ខលំបាកផងទាំងពួង។

ហេតុនេះហើយបានជាយើងឃើញមានស្នាដៃជាច្រើនកើតមានឡើង ដោយសារអ្នកនិពន្ធអក្សរសិល្ប៍បានចូលរួមចំណែកឆ្លុះបញ្ចាំងពីសង្គមជាក់ស្តែងផង និងផ្តល់ផលប្រយោជន៍ដល់ជាតិមាតុភូមិក្នុងការបណ្តុះស្មារតីប្រជាជនខ្មែរ ដែលធ្លាប់បាក់ស្បាតដោយសារសង្គ្រាមរ៉ាំរ៉ៃអស់ពេលជាយូរ ។ អក្សរសិល្ប៍បានផ្តល់ឱកាសឱ្យអ្នកនិពន្ធយើង

បានបញ្ចេញស្នាដៃផ្សំជាមួយទ្រឹស្តីព្រះពុទ្ធសាសនា ដែលមានក្នុងគម្ពីរទេសជាតកមកផ្សំជាមួយទំនោរ ផ្នត់គំនិត និងមនោសញ្ចេតនាដែលកើតពិតៗក្នុងជីវភាពរស់នៅរបស់ជាតិខ្មែរផ្ទាល់តែម្តង ។

ដូច្នេះអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងតួនាទីដឹកនាំ ក៏ដូចជាអប់រំមនុស្សឱ្យដើរតាមគន្លងរបស់ព្រះពុទ្ធសាសនាស្របតាមពុទ្ធវចនៈ ក៏ដូចជាបានចូលរួមកាត់បន្ថយភាពតានតឹងនៃប្រជាជនដែលមានការពិបាករស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ លើសពីនេះទៅទៀត អក្សរសិល្ប៍សម័យនោះ បានបន្សល់ទុកនូវស្នាដៃ ឯកសារ គម្ពីរ ក្បួនខ្នាតជាច្រើន ជាកេរមត៌កដ៏មានតម្លៃខ្លឹមសារជាច្រើនឱ្យកូនខ្មែរជំនាន់ក្រោយសិក្សារៀនសូត្រ និងបណ្តុះស្មារតីស្នេហាជាតិមាតុភូមិ ដើម្បីចូលរួមចំណែកកសាង និងអភិវឌ្ឍសង្គមជាតិទាំងមូល។

ឯកសារយោង

- ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២
- លាង ហាប់អាន សិក្សាអត្ថបទ ភាគទី១ (សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) ភ្នំពេញ ១៩៦៦
- បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក (១៩៦៣)
- ជុំ កាណាល់ សិក្សាស្វែងយល់អក្សរសាស្ត្រខ្មែរសង្ខេបបែបទំនើប (១៩៩៦)
- បណ្ឌិត ឈឹម ស៊ុមន៍ សង្ខេបទសជាតក (១៩៥៩)
- លី ធាមតេង អក្សរសាស្ត្រខ្មែរ (១៩៦៦)
- បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម (១៩៩៤)
- បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក (១៩៦៣)
- បណ្ឌិត ញ៉ុក ថែម មហាវេស្សន្តរជាតក (១៩៦៣)
- ត្រឹង ងា , អរិយធម៌ខ្មែរ, ឆ្នាំ១៩៧៥
- លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរសម័យនគរភ្នំ ដល់សម័យឧដុង្គ (ស.វ.ទី១ ដល់ឆ្នាំ១៨៥៩)* ឆ្នាំ១៩៦៧
- ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ* ឆ្នាំ១៩៧៧
- សិលាចារឹកនគរវត្ត និងបទានុក្រម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៥៨។
- គោលប្រវត្តិនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ ការផ្សាយរបស់បណ្ណាគារភ្នំពេញ ឆ្នាំ១៩៥៦។
- ម៉ក់ ស៊ីនេត *អក្សរសិល្ប៍ក្រោយអង្គរ*
- ឃួន សុខម្ភ *គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ* សន្និសីទធ្វើទៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៤ នៅភ្នំពេញ
- សម្តេច ជួន ណាត, វចនានុក្រមខ្មែរ ១៩៦៧
- ក្រសួងអប់រំ, សៀវភៅគ្រូ ភាសាខ្មែរ ថ្នាក់ទី១០,២០១២
- បណ្ឌិត ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ, ទំព័រ៥២, ២០១៩
- ទេស ហាវ, ទេព ណន, ធុក ផល្លីនី, តែ ស្រីសោភ័ណ វប្បធម៌អរិយធម៌ខ្មែរ ទំព័រ៧៤, ២០០៩

ស្នាដៃសិក្ខាកថា

ជ័យលាភីចំណាត់ថ្នាក់លេខ៣

ដោយលោក មី សុភណ្ណ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

វិទ្យាល័យ ហ៊ុន សែន បាត់ដឹង

អបអរសាទរទិវាជាតិអំណាន លើកទី៧

១១ មីនា ២០២២

សិក្ខាកថាក្រោមប្រធានបទ

«ភ្នាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»

ដោយ មី សុវណ្ណា

ព.ស. ២៥៦៥ គ.ស. ២០២២

ប្រវត្តិរូបសង្ខេបបេក្ខជន

ព័ត៌មានទូទៅ

- ឈ្មោះ : មី សុវណ្ណ
- ភេទ : ប្រុស
- ថ្ងៃ ខែ ឆ្នាំកំណើត : ១៦ ធ្នូ ១៩៩០
- ទីកន្លែងកំណើត : ភូមិក្រាំងពញ្ញា ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- ទីលំនៅបច្ចុប្បន្ន : ភូមិដំណាក់ស្មាច់ ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- កម្រិតជំនាញ : មធ្យមសិក្សាទុតិយភូមិ
- ថ្ងៃ ខែ ឆ្នាំចូលបម្រើការងារ : ០១-១០-២០១៤

ការសិក្សា

- ២០០៧-២០០៩ : មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យឧដុង្គ កំពង់ស្ពឺ)
- ២០០៩-២០១៣ : បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១៣-២០១៧ : បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១២-២០១៤ : គរុសិស្សភាសាបារាំង-ខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០១៧-២០១៨ : គរុនិស្សិតកម្រិតឧត្តម អក្សរសាស្ត្រខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០០៩ ជាអតីតជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ ឆ្នាំ២០០៩

អត្ថាភាពការងារ

- ឆ្នាំ២០១៤- បច្ចុប្បន្ន គ្រូអក្សរសាស្ត្រខ្មែរវិទ្យាល័យ ហ៊ុន សែន បាត់ដំបង

ទំនាក់ទំនងបេក្ខជន

- ទូរស័ព្ទទាក់ទង : ០១៧ ៤២៤ ២៦៣
- តេឡេក្រាម : ០១៥ ៤០៤ ៤៨៣
- អ៊ីម៉ែល : sovannbandit@gmail.com

មាតិកា

I- សេចក្តីផ្តើម.....1

II- តួសេចក្តី.....1

II.១- ពន្យល់បច្ចេកសព្ទ.....1

II.១.១- បច្ចេកសព្ទ«អក្សរសិល្ប៍».....1

II.១.២- បច្ចេកសព្ទ«ពុទ្ធនិយម».....2

II.២- ពន្យល់ប្រធានបទ.....4

II.៣- បកស្រាយប្រធានបទ.....5

II.៣.១- ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសម័យកណ្តាល.....5

II.៣.២- ទិដ្ឋភាពព្រះពុទ្ធសាសនាថេរវាទនៅសម័យកណ្តាល.....10

II.៣.៣- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ.....12

II.៣.៣.១- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះបញ្ញាពុទ្ធិ.....12

II.៣.៣.២- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការអប់រំ.....14

II.៣.៣.៣- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះសោភ័ណជីវិត.....17

II.៣.៣.៤- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការចូលរួមអភិវឌ្ឍសង្គម.....18

II.៣.៣.៥- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងបញ្ហានយោបាយ.....20

II.៣.៣.៦- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការព្យាបាលផ្លូវចិត្ត.....21

II.៣.៣.៧- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងវប្បធម៌.....23

II.៣.៣.៨- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងព្រលឹងជាតិខ្មែរ.....24

II.៣.៣.៩- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះគំនិតវិទ្យាសាស្ត្រ.....26

II.៣.៣.១០- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងសន្តិភាពផ្លូវចិត្ត (សីល សមាធិ បញ្ញា).....27

II.៤- សរុបខ្លឹមសារ.....28

III-បញ្ចប់សេចក្តី.....29

ឯកសារពិគ្រោះ

ឧបសម្ព័ន្ធ

ប្រធានបទ៖ «តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»

<u>សេចក្តីអធិប្បាយ</u>

I- សេចក្តីផ្តើម

ប្រទេសកម្ពុជាបានឆ្លងកាត់របបនៃការដឹកនាំសង្គមជាច្រើនសម័យកាលមកហើយ ។ ក្នុងនោះផងដែរ យើងសង្កេតឃើញថាព្រះរាជាណាចក្រមួយនេះបានផ្លាស់ប្តូររបបសង្គមរបស់ខ្លួនស្របទៅតាមបរិបទជាក់ស្តែង ។ តាំងពីសម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ តួនាទីអក្សរសិល្ប៍ពិតជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរយើង។ ដោយឡែកនៅសម័យក្រោយអង្គរ ស្នាដៃអក្សរសិល្ប៍ខ្មែរនៅតែត្រូវបាននិពន្ធតាក់តែងឡើងស្របទៅតាមសង្គមបរិបទជាក់ស្តែងនៃសង្គមខ្មែរ។ កវីនិពន្ធខ្មែរភាគច្រើនជាគ្រហស្ថសុទ្ធសឹងតែធ្លាប់បួសរៀន ឬជាព្រះសង្ឃ ជាព្រះគ្រូចៅអធិការ និងមានចំណេះដឹងយល់ជ្រួតជ្រាបជ្រៅជ្រះទ្រឹស្តីព្រះពុទ្ធសាសនា ហើយតាក់តែងជាកំណាព្យបទផ្សេងៗទៅតាមទេពកោសល្យរបស់ខ្លួន។ វិធីនិម្មិតកម្មស្នាដៃអក្សរសិល្ប៍ទាំងអស់នោះច្រើនបង្កប់នូវទស្សនៈកម្មផលដែលមានទំនោរទៅរកព្រះពុទ្ធសាសនាជាជាងឆ្លុះបញ្ចាំងពីតថភាពសង្គមជាក់ស្តែងរបស់សង្គមខ្មែរ ហើយដែលយើងហៅស្នាដៃទាំងនោះថាជាអក្សរសិល្ប៍ពុទ្ធនិយម។ ទោះបីជាស្នាដៃទាំងនោះមានចរិតលក្ខណៈបែបណាក៏ដោយ ប៉ុន្តែស្នាដៃកវីនិពន្ធទាំងឡាយសុទ្ធសឹងតែជាស្នាដៃដែលបានបម្រើសង្គមខ្មែរ ចំណង់ចំណូលចិត្តមនុស្សខ្មែរ និងឆ្លាក់ជាប់នៅក្នុងក្រអៅបេះដូងមនុស្សខ្មែរពិតៗនាសម័យក្រោយអង្គរ។

តើអក្សរសិល្ប៍ពុទ្ធនិយមបានដើរតួនាទីយ៉ាងដូចម្តេចខ្លះនៅសម័យក្រោយអង្គរ?

II-តួសេចក្តី

II.១- ពន្យល់បច្ចេកសព្ទ

II.១.១- បច្ចេកសព្ទ«អក្សរសិល្ប៍»

បើតាមវចនានុក្រមខ្មែរបានផ្តល់និយមន័យចំពោះពាក្យ «អក្សរ» និង«សិល្ប៍» ជាមុនថា អក្សរ (ន.)(សំ.បា.)អក្ខរៈ។ រីឯសិល្ប៍ (ន) (សំ.បា. សិប្ប:) សិប្បៈ។ ហេតុនេះគេអាចទាញបានថា «អក្សរសិល្ប៍»ជាសិល្បៈនៃការប្រើប្រាស់តួអក្សរដើម្បីបង្កើតទៅជាសាច់រឿង។

លោក ពៅ សាមី «អក្សរសិល្ប៍» មានន័យថាវិទ្យាស្បង់ដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយដោយសិល្បវិធីតាមសម័យកាលនីមួយៗ។

តាមលោក កែង វ៉ាន់សាក់ «អក្សរសិល្ប៍»គឺជាវិទ្យាសាស្ត្រដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយដោយសិល្បវិធីតាមសម័យកាលនីមួយៗ។

លោក ម៉ាស៊ីម គ័រគី បានផ្តល់និយមន័យចំពោះអក្សរសិល្ប៍ថា«អក្សរសិល្ប៍ជាការសិក្សាពីមនុស្ស»។

លោក ធ សោ «អក្សរសិល្ប៍ជាវិទ្យាសាស្ត្រមួយសិក្សាពីមនុស្សដោយលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយតាមសិល្បរូបារម្មណ៍»។

ស្តង់ដាល់ «អក្សរសិល្ប៍គឺជាកញ្ចក់ដែលគេដាក់តាមដងផ្លូវ»។ ពំនោលនេះបានន័យសេចក្តីថាអក្សរសិល្ប៍បានឆ្លុះបញ្ចាំងឱ្យឃើញនូវរាល់សកម្មភាពទាំងឡាយដែលបានឆ្លងកាត់វា។

អក្សរសិល្ប៍ជាសិល្បៈនៃការប្រើប្រាស់តួអក្សរប្រកបទៅដោយសិល្បៈក្នុងការសម្តែងនូវអារម្មណ៍ចិត្តគំនិតព្រលឹងស្មារតី។

សរុបមក អក្សសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាពសង្គមពិតៗ ហើយដែលបានបកស្រាយពីអ្វីដែលបានកើតឡើងស្របតាមព្រឹត្តិការណ៍របស់មនុស្ស។ មនុស្សជាអ្នកបង្កើតនូវប្រវត្តិសាស្ត្រជីវិតរបស់ខ្លួនពីសម័យកាលមួយមកដល់សម័យកាលមួយទៀត។ ដូច្នេះដើម្បីឱ្យជីវិតមានភាពប្រសើរជឿនលឿនទៅមុខគឺមនុស្សទាមទារជាចាំបាច់ដើម្បីកត់ត្រារាល់អ្វីៗដែលខ្លួនបានជួបប្រទះជាសាក្សីសង្គម និងជាតឹកតាងសម្រាប់មនុស្សជំនាន់ក្រោយ។

II.១.២- **បច្ចេកសព្ទ«ពុទ្ធនិយម»**

អក្សរសិល្ប៍ពុទ្ធនិយម គឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលបានទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ ក្នុងនោះផ្តោតសំខាន់ទៅលើបញ្ហាកម្មផលជាចម្បងបានសេចក្តីថា កម្មល្អឱ្យផលល្អ កម្មអាក្រក់ឱ្យផលអាក្រក់ ហើយអំពើល្អ និងអំពើអាក្រក់មិនអាចសងគ្នារួចបានឡើយ ។ ជាការពិតណាស់ថា តាមទ្រឹស្តីព្រះពុទ្ធសាសនាបានចែងយ៉ាងច្បាស់ថា ធម៌សឱ្យផលស ធម៌ខ្មៅឱ្យផលខ្មៅ។ បើអ្នកសាបព្រោះអ្វីអ្នកនឹងទទួលបានផលហ្នឹងមកវិញ។ អ្នកព្រះកិរម្យភាសាអ៊ូ ហៅង៉ុយ ឬកវីង៉ុយក៏ធ្លាប់បានពោលដែរថាដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ ។ បើអ្នកសាបព្រោះខ្យល់ អ្នកនឹងទទួលបានខ្យល់ ហើយបើអ្នកសាបព្រោះនូវព្យុះសង្ឃរា អ្នកនឹងទទួលបានមកវិញជាព្យុះសង្ឃរាជាក់ជាមិនខាន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមចែកជាបីប្រភេទ គឺអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ផ្លូម)។ អក្សរសិល្ប៍ទាំងបីប្រភេទដែលគេកំណត់ហៅឈ្មោះនេះ ដោយគេសម្គាល់លើខ្លឹមសារនៃរឿងដែលបង្ហាញពីឥទ្ធិពលព្រះពុទ្ធសាសនាតិច ឬច្រើនតាមរយៈការពិពណ៌នារបស់អ្នកនិពន្ធនៅក្នុងរឿងនីមួយៗសម្គាល់លើប្រភព និងអត្ថរូបនៃរឿង។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធជារឿងដែលទទួលឥទ្ធិពលខ្លាំងបំផុតពីព្រះពុទ្ធសាសនា ហើយសំដៅយករឿងទាំងដប់ ដែលថ្លែងពីអតីតប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធក្នុងដប់ព្រះជាតិ មុនព្រះជាតិដែលបានត្រាស់ដឹង។ រឿងទាំងដប់នោះសម្គាល់លើរឿងក្នុងស្នាដៃទសជាតកដែលគេចាត់ទុកជាគម្ពីរដ៏សំខាន់នៃលទ្ធិព្រះពុទ្ធសាសនា ព្រោះរឿងទាំងដប់នៃទសជាតកនេះមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក ហើយបានលើកឡើងពីការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធក្នុងពេលដែលព្រះអង្គយោនយកកំណើតជាតួអង្គពោធិសត្វក្នុងជាតិផ្សេងៗក្នុងការបំពេញបារមីដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយជារឿងដែលទទួលឥទ្ធិពលព្រះពុទ្ធសាសនាច្រើនបង្គួរដែរ តែឈ្មោះរឿងទាំងនោះមិនមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតកទាំងអស់ទេ មានមួយចំនួនតូចប៉ុណ្ណោះ។ រឿងខ្លះមានចំណងជើងរឿងដូចគ្នាទៅនឹងចំណងជើងជាតកនៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក តែខ្លឹមសាររឿងខុសគ្នាដោយអន្លើ រឿងមួយចំនួនទៀត ចំណងជើងរឿងខុសគ្នា តែខ្លឹមសាររឿងប្រហាក់ប្រហែលគ្នា។ រឿងមួយទៀត ចំណងរឿងក៏ដូចគ្នា និងខ្លឹមសាររឿងក៏ដូចគ្នា។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះសំដៅយករឿងទាំងហាសិបក្នុងបញ្ញាសជាតក។ តួអង្គនៅក្នុងរឿងអក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះមិនមែនជាតួអង្គព្រះពោធិសត្វ ដែលខំបំពេញបារមីដើម្បីត្រាស់ជាព្រះពុទ្ធនោះឡើយគឺគ្រាន់ជាតួអង្គពោធិសត្វដែលខំកសាងអំពើជាកុសលផ្សេងៗជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬហៅពុទ្ធនិយមផ្លូមជាស្នាដៃអក្សរសិល្ប៍មួយបែបដែលពុំមែនជារឿងទសជាតក និងពុំមែនជារឿងបញ្ញាសជាតក។ វាជាស្នាដៃអក្សរសិល្ប៍ខ្មែរដែលកើតឡើងនៅសម័យកណ្តាល (លង្វែកនិងឧដុង្គ) ហើយទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនាដែរ។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុនេះ ជាស្នាដៃរឿងនិពន្ធជាពាក្យកាព្យដោយកវីបណ្ឌិតខ្មែរក្នុងសម័យកណ្តាលពិសេសក្នុងសតវត្សរ៍ទី១៧-១៩។ គេហៅស្នាដៃប្រភេទនេះថាជា រឿងល្បែង ឬសាស្ត្រាល្បែងក៏បានដែរ។

II.១.៣- អក្សរសិល្ប៍ក្រោយសម័យអង្គរ

សម័យក្រោយអង្គរ អក្សរសិល្ប៍ខ្មែរត្រូវបានចែកចេញជាពីរដំណាក់កាល៖

- អក្សរសិល្ប៍ក្នុងដំណាក់កាលសម័យលង្វែក (ចាប់ពីសតវត្សទី១៥ ដល់ដើមសតវត្សទី១៧)
- អក្សរសិល្ប៍ក្នុងដំណាក់កាលសម័យឧត្តុង្គ (ចាប់ពីសតវត្សទី១៧ ដល់សតវត្សទី១៩)

ក្នុងដំណាក់កាលសម័យលង្វែក អក្សរសិល្ប៍ពុំសូវមានការរីកចម្រើនទេ។ គេសង្កេតឃើញស្នាដៃអក្សរសិល្ប៍តិចណាស់ស្ទើរតែគ្មាន។ ការមិនរីកចម្រើនអាស្រ័យដោយស្ថានភាពចុះដុនដាបទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងវប្បធម៌ដែលបណ្តាលមកពីសង្គ្រាមផ្ទៃក្នុង និងវប្បធម៌ការត្បាតរបស់ជនជាតិបរទេស (ថៃ ឬសៀម)។ មិនតែប៉ុណ្ណោះក្រោយឈ្នះសង្គ្រាម គេបានយកក្បួនគម្ពីសំខាន់ៗរបស់ជាតិយកទៅប្រទេសរបស់គេថែមទៀត ដែលធ្វើឱ្យខ្មែរយើងអស់មូលដ្ឋានរបស់ខ្លួនក្នុងការកសាងវិស័យអក្សរសាស្ត្រ-អក្សរសិល្ប៍នេះឯង ។

ក្នុងដំណាក់កាលសម័យឧត្តុង្គ ចាប់ពីសតវត្សទី១៧មក អក្សរសិល្ប៍បានចាប់កសាង និងរីកចម្រើនឡើងវិញ។ នាពេលនោះ គេឈប់ចារឹកលើថ្មទៀតហើយ គេចាប់ផ្តើមសរសេរលើសាស្ត្រាស្លឹករឹកនិងនៅលើក្រាំង។ អត្ថន័យនៃអក្សរសិល្ប៍នៅក្នុងសម័យនេះច្រើនមានទំនោរទៅរកព្រះពុទ្ធសាសនាបែបហីនយាន។ ព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយានបានរីកដុះដាលនៅក្នុងសម័យអង្គរ ហើយបានចុះអានុភាពបន្តិចម្តងៗតាំងពីចុងសម័យអង្គរ និងបានរលាយខ្លួនបន្តិចម្តងៗនៅក្នុងសម័យឧដុង្គនេះ។ តែទោះបីយ៉ាងដូចនេះក៏ដោយក៏ឥទ្ធិពលខ្លះនៃព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាននៅតែមានទោះបីតិច ឬច្រើនក្តី។ អាស្រ័យហេតុនេះ ទើបស្នាដៃអក្សរសិល្ប៍នៅសម័យនេះ មានទំនាក់ទំនងទៅរកពុទ្ធសាសនា តែក៏នៅមានលាយឡំបែបព្រាហ្មណ៍និយមខ្លះ និងមានលក្ខណៈអច្ឆរិយៈលាយឡំផងដែរ។

II.២- ពន្យល់ប្រធានបទ

ស្របតាមការពន្យល់បញ្ញត្តិខាងលើនេះ ប្រធានបទទាំងមូលចង់ឱ្យស្មេរធ្វើការស្រាយបំភ្លឺពីតួនាទីចម្បងនៃស្នាដៃអក្សរសិល្ប៍ខ្មែរដែលមានទំនោរទៅលើព្រះពុទ្ធសាសនានាសម័យក្រោយអង្គរនេះឯង។ សម័យក្រោយអង្គរនេះ យើងសូមកំណត់ថាជាសម័យកាលកណ្តាលដែលយើងនឹងលើកយកសម័យកាលសំខាន់ពីរគឺ សម័យលង្វែក និងសម័យឧដុង្គ។ ប្រវត្តិសាស្ត្រមែងជាប់ទាក់ទងយ៉ាងស្អិតរមួតជាមួយនឹង

ស្នាដៃអក្សរសិល្ប៍ខ្មែរ។ ដូចនេះដើម្បីស្វែងយល់ពីតួនាទីនៃអក្សរសិល្ប៍ពុទ្ធនិយមនាសម័យកណ្តាលបាន លុះត្រាតែយើងស្វែងយល់ពីព្រឹត្តិការណ៍សង្គមសំខាន់ៗ ឬហេតុការណ៍ប្រវត្តិសាស្ត្រខ្លះនៃសម័យកាលនោះជាមុនសិន។ ពីព្រោះថាប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ប្រៀបបានដូចជាបងប្អូនភ្លោះដែលមិនអាចកាត់ផ្តាច់ពីគ្នាឱ្យដាច់ស្រឡះបានឡើយ។ ត្រង់ន័យនេះ ការលើកឡើងលម្អិតពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅសម័យកណ្តាលគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការយល់ដឹងពីតួនាទីអក្សរសិល្ប៍ពុទ្ធនិយមនាសម័យក្រោយអង្គរ។

II.៣- បកស្រាយប្រធានបទ

II.៣.១- ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសម័យកណ្តាល

ដើម្បីសិក្សាស្វែងយល់ពីតួនាទីអក្សរសិល្ប៍នាសម័យក្រោយអង្គរ ជាដំបូងយើងគប្បីស្វែងយល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនាសម័យកាលនោះជាមុនសិន។ នៅសម័យក្រោយអង្គរជាសម័យកាលមួយដែលប្រទេសកម្ពុជាកំពុងតែរីកវរ និងញាំញីដោយភ្លើងសង្គ្រាម។ ប្រការទាំងអស់នេះច្រើនតែកើតឡើងដោយសារតែទំនាស់ផ្ទៃក្នុង និងបច្ចាមិត្រដែលបានប៉ងលេបត្របាក់យកទឹកដីខ្មែរ។ ត្រង់នេះ យើងសូមលើកយកនូវសម័យកាលពីរមកបង្ហាញគឺសម័យលង្វែក និងសម័យឧដុង្គ។

ក. សម័យលង្វែក៖

សម័យលង្វែកគឺជាសម័យក្រោយពីរជ្ជកាលព្រះបាទពញាយ៉ាត ប្រទេសកម្ពុជាកើតមានចម្បាំងជាច្រើនលើកច្រើនសា។ រាជធានីត្រូវបានផ្លាស់ប្តូរជាច្រើនកន្លែងវិលចុះវិលឡើងពីក្រុងអង្គរ ទួលបាសាន្ត (កំពង់ចាម) ភ្នំពេញ (ចតុមុខ) លង្វែក (កំពង់ផ្នាំង)។ ក្នុងរាជ្យព្រះអង្គចន្ទទី១ រាជធានីតាំងនៅក្រុងមានជ័យ ខេត្តពោធិ៍សាត់ រួចប្តូរមកក្រុងលង្វែកវិញ។ ព្រះបាទចន្ទរាជា ឬព្រះអង្គចន្ទទី១ ជាអនុជពៅព្រះស្រីសុគន្ធបទ ឬជាបុត្រធម្មរាជា។ ពេលដែលស្តេចកនធ្វើគុតស្រីសុគន្ធបទនៅបន្ទាយស្ទឹងសែននៅឆ្នាំ ១៥១២ ពញាចន្ទនៅក្រុងអយុធ្យានៅឡើយ។ ក្នុងពេលធ្វើសង្គ្រាមជាមួយស្តេចកន មន្ត្រី និងរាស្ត្រសុំឱ្យព្រះអង្គចន្ទឡើងសោយរាជ្យ ទ្រង់ក៏យល់ព្រម។ ទ្រង់ជាស្តេចមួយអង្គដ៏ល្បីល្បាញដែលបានរំដោះដីខ្មែរភាគខាងលិចពីសៀម។ ក្រៅពីបន្ទាយលង្វែក ទ្រង់បានកសាងវត្តអារាមជាច្រើននៅខែត្រពោធិ៍សាត់

បរិបូណ៌ ជួសជុលវត្តនៅឧដុង្គមានវត្តលើភ្នំរាជទ្រព្យជាដើម (ព្រះពុទ្ធរូបចូលព្រះនិព្វាន) វត្តត្រៃឡែងកែង នៅក្នុងបន្ទាយលង្វែកដែលស្ថិតនៅលើទួលមួយកន្លែង មានរាងជាជើងក្អែកក្នុងវិហារនេះតម្កល់ព្រះពុទ្ធរូប ត្រៃឡែងកែងគឺព្រះពុទ្ធរូបបួនអង្គគង់ឈរទល់ព្រះខ្នងនឹងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំងបួន ហើយនឹង បានកសាងបដិមាត្រៃឡែងកែងរូបព្រះគោ។ ប្រមូលអ្នកប្រាជ្ញ បណ្ឌិត កវីអោយចងក្រង និងសរសេរគម្ពីរ ក្បួនច្បាប់គ្រប់ប្រភេទសម្រាប់កូនខ្មែរជំនាន់ក្រោយ។ តែគួរឱ្យស្តាយនៅឆ្នាំ១៥៦៦ ទ្រង់ក៏សោយទិវង្គត អដ្ឋិធាតុតម្កល់ទុកលើភ្នំព្រះរាជទ្រព្យ។

គ្រិស្តសករាជឆ្នាំ១៥៩៤ ក្រុងលង្វែកត្រូវពួកសៀមវាយយកបាន។ ស្តេចសៀមបានតែងតាំង មេទ័ពម្នាក់ឈ្មោះ ព្យាមហាមន្ត្រី ព្រមទាំងរក្សាទុកកងទ័ពពីរម៉ឺននាក់ឱ្យនៅត្រួតត្រាក្រុងលង្វែក។ ការបែក បាក់ក្រុងលង្វែកបានបង្កឱ្យមានការវិនាសនៃទ្រព្យសម្បត្តិជាច្រើន មន្ត្រីសេនាបតី អ្នកប្រាជ្ញ ព្រហ្មណ៍ បុរោហិត អ្នកចេះដឹង គម្ពីរ ក្បួនច្បាប់ តម្រា និងវត្ថុមានតម្លៃជាច្រើនត្រូវបានសៀមប្រមូលទៅស្រុកវា រាជវង្សានុវង្សខ្មែរជាច្រើនដែលក្នុងនោះឧបរាជ និងជាមេទ័ពខ្មែរមួយអង្គគឺព្រះបាទស្រីសុរិយោពណ៌ក៏ត្រូវ សៀមនាំទៅស្រុកវាដែរ។ ការបែកបាក់នេះជាការធ្លាក់ចុះដ៏ធ្ងន់ធ្ងរនៃឥទ្ធិពលរបស់រាជាណាចក្រខ្មែរ ហើយ បណ្តាលឱ្យមានការបែកបាក់សាមគ្គីក្នុងប្រទេសកើតឡើង។ ទោះជាយ៉ាងនេះក្តី ការត្រួតត្រារបស់មេទ័ព សៀមលើក្រុងលង្វែកមិនបានរយៈពេលយូរប៉ុន្មានឡើយ។ រាមាជើងព្រៃ (១៥៩៤ - ១៥៩៦) ដែលជា ញាតិវង្សម្នាក់បានលើកទ័ពទៅវាយឆ្មក់ ហើយសម្លាប់មេទ័ពសៀមនោះបាន ហើយឡើងសោយរាជ្យ។ ប៉ុន្តែការភ័យខ្លាចចំពោះកម្លាំងរបស់សៀមក្រែងវិលត្រឡប់មកវិញបានធ្វើឱ្យរាមាជើងព្រៃត្រូវបង្ខំចិត្តប្តូរទៅ តាំងទីរាជវាំងនៅស្រីសន្ធរ (កំពង់ចាម) វិញ ដែលនៅទីនោះ ទ្រង់ត្រូវបានធ្វើគុតក្នុងពេលដែលទ្រង់ចេញ ទៅធ្វើការបង្ក្រាបជនជាតិអេស្ប៉ាញ ឈ្មោះ Ruiz និងជនជាតិប៉ទុយកាល់ឈ្មោះ Veloso ។

ញាតិវង្សមួយអង្គទៀតឈ្មោះ ពញាតន់ ដែលជាអនុជរបស់ព្រះបាទជ័យជេដ្ឋាទី១ ត្រូវបានគេ តែងតាំងអោយសោយរាជ្យពីឆ្នាំ ១៥៩៦-៩៧។ ស្តេចអង្គនេះបានតែងតាំង Beloso ឱ្យធ្វើជាស្តេចត្រាញ់ លើដែនដីបាភ្នំទុកជាការសងគុណ។ ប៉ុន្តែនៅខេត្តត្បូងឃ្មុំការបះបោរមួយដែលដឹកនាំដោយប៉ោរាត

និងលក្សីណាបានកើតឡើង ។ ទ្រង់ដឹកនាំទ័ពទៅបង្ក្រាបពួកនេះ ប៉ុន្តែត្រូវពួកនេះធ្វើគុត ។

ពួកមន្ត្រីសេនាបតីក៏យាងពញាអនដែលជាព្រះបិតុលា (ពូ) របស់ពញាតន់ ឱ្យស្នងរាជ្យនៅឆ្នាំ ១៥៩៧ ។ ទ្រង់បានកម្ចាត់ ប៉ោរាត និងលក្សីណា ហើយនាំទ័ពត្រឡប់មកវិញបានពាក់កណ្តាលផ្លូវក៏បោះ

ជំរំសម្រាក។ នៅទីនោះទ្រង់បានបង្ខំយកស្ត្រីម្នាក់ដែលមានរូបឆោមលោមពណ៌ល្អ ប៉ុន្តែនាងមានប្តីហើយ។ ប្តីនាងនោះឈ្មោះកែវដោយមានការខឹងសម្បារនឹងពញ្ញាអនក៏បះបោរឡើង មានឈ្មោះថាកែវព្រះភ្លើង កជាកម្លាំងប្រឆាំងឡើងរួចធ្វើគុត ពញ្ញាអន បានសម្រេចនៅឆ្នាំ១៥៩៨។

បុត្រទី៣ របស់ព្រះសត្ថាទី១ នាមពញ្ញាញោមទ្រង់ទទួលងារជារាជានុសិទ្ធិនៅឆ្នាំ១៥៩៩ គឺមានសិទ្ធិដូចព្រះរាជាប៉ុន្តែមិនមែនជាព្រះរាជាពេញសិទ្ធិទេ។ ទ្រង់បានកម្ចាត់កែវព្រះភ្លើងបាន។ ដោយឡែករាជានុសិទ្ធិម្នាក់នេះមានចរិតមិនល្អ ចូលចិត្តតែខាងស្រីស្រា បរបាញ់សត្វ ចាប់ប្រពន្ធកូនអ្នកស្រុក អ្នកធ្វើខុសមិនជាប់ទោស ហេតុនេះហើយទាំងប្រជារាស្ត្រ ទាំងមន្ត្រី មានការមិនពេញចិត្តជាខ្លាំង។ ព្រះអយ្យការរបស់ទ្រង់ក៏សូមយាងព្រះបាទស្រីសុរិយោពណ៌ដែលគង់នៅស្រុកសៀម ព្រមទាំងរាជវង្សទាំងប៉ុន្មានមកស្រុកខ្មែរវិញ។ ជាដំបូងសៀមបានអនុញ្ញាតអោយតែព្រះបាទស្រីសុរិយោពណ៌ និងឧទ័យដែលជាបុត្រទីពីររបស់ស្រីសុរិយោពណ៌ មកជាមុន រីឯជ័យជេដ្ឋាទី២ ដែលជាបុត្រច្បងមិនទាន់បានមកនៅឡើយទេ។ ពញ្ញាញោមបានព្រមព្រៀងថ្វាយរាជសម្បត្តិទៅព្រះបាទស្រីសុរិយោពណ៌នៅឆ្នាំ១៦០០គ.ស ហើយទ្រង់នៅកាន់ឋានៈជាព្រះកែវហ្វាដដែល។

ព្រះបាទស្រីសុរិយោពណ៌យាងមកពីសៀមតាមច្រកកំពតនៅឆ្នាំ១៦០០ ហើយគង់នៅរាជវាំងកោះស្លាកែតដែលនៅក្នុងខេត្តកណ្តាលសព្វថ្ងៃ។ ទ្រង់បានតែងតាំង តេជោយ៉តឱ្យធ្វើជាចៅហ្វាយខេត្តសំរោងទង ជំនួសតេជោមាសដែលបានស្លាប់ ហើយទ្រង់បានមកគង់នៅល្វាឯម។ ទ្រង់នៅស្រុកសៀមយូរបានទម្លាប់ព្រះកាយទ្រង់ទៅតាមបែបសៀម ដោយនិយមប្រើព្រះពស្ត្រលឿង និយាយភាសាសៀមច្បាស់ជាងភាសាខ្មែរ។ ទ្រង់បានឱ្យគេផ្លាស់សំលៀកបំពាក់សម័យលង្វែកចេញ ព្រមទាំងបានកែប្រែទំនៀមទម្លាប់នៃការប្រើពាក្យពេចន៍មួយចំនួនចេញដូចជា ទ្រង់បង្គាប់អោយគេហៅទ្រង់ថា ព្រះស្រីសុរិយោពណ៌ មនាថ, ស្ត្រីដែលមានឋានៈខ្ពស់ត្រូវឆ្លើយនិងព្រះអង្គថា ព្រះពរ, ឆ្លើយនិងព្រះមហាក្សត្រីថា ព្រះម៉ែ, ឆ្លើយនិងពួកអ្នកអង្គម្ចាស់ថា ព្រះបាទម្ចាស់ ។ នៅឆ្នាំ១៦១៣ ទើបទ្រង់ទទួលបានការអភិសេក ជាស្តេចពេញសិទ្ធិ។ ក្រោយមក ទ្រង់បានសុំពីសៀមមកវិញនូវបុត្រាច្បងរបស់ទ្រង់គឺ ជ័យជេដ្ឋាទី២ ដែលនៅឆ្នាំ ១៦១៨ ទ្រង់បានផ្ទេររាជសម្បត្តិអោយបុត្រច្បងនេះ។ ដោយធុញទ្រាន់ និងមេរៀនដដែលៗរបស់សៀមដែលតែងតែចិញ្ចឹមចិត្តវាយយកប្រទេសខ្មែរដាក់ជាចំណុះ ទ្រង់បានមើលឃើញកម្លាំងថ្មីមួយទៀតនៅភាគខាងកើតដែលទើបតែរំដោះខ្លួនចេញពីចំណុះប្រទេសចិន ហើយក៏ទើបតែលេបយកប្រទេសចម្ប៉ាបានថ្មីៗ នោះគឺប្រទេសអណ្ណាម ដោយទ្រង់បានផ្ញើសារទៅសុំចងមេត្រីភាពជាមួយ។ ចំណងមេត្រីភាពនេះបានចាប់ផ្តើម

ដោយការរៀបអភិសេក ព្រះបាទជ័យជេដ្ឋាទី២ និងបុត្រីក្សត្រអាណ្ណាម ព្រះនាងចូវ (ក្នុងភាសាអណ្ណាមហៅព្រះនាងថា ង៉ុកវ៉ាន់) នៅឆ្នាំ១៦១៨ ។ ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៦២០ ទ្រង់បានយាងមកគង់នៅរាជធានីថ្មីឯឧដុង្គ ដែលស្តេចក្រោយៗមកទៀតសុទ្ធតែគង់ក្រុងឧដុង្គនេះដែរ ជាហេតុធ្វើឱ្យប្រវត្តិវិទូដែលសិក្សាពីប្រវត្តិសាស្ត្រខ្មែរបានកំណត់យកឆ្នាំ១៦២០ ជាឆ្នាំចាប់ផ្តើមនៃសម័យឧដុង្គ។

ខ. សម័យឧដុង្គ:

សម័យឧដុង្គបានចាប់ផ្តើមក្រោយពីព្រះបាទជ័យជេដ្ឋាទី២ ទ្រង់បានឡើងសោយរាជ្យពីព្រះបិតាគឺព្រះស្រីសុរិយោពណ៌ដែលទ្រង់បានផ្សំផ្គុំព្រះជ័យជេដ្ឋាទី២ នឹងបុត្រីស្តេចគ្រាញ់យួនដើម្បីធ្វើជាសម្ព័ន្ធមិត្តទប់ទល់នឹងការលុកលុយរបស់សៀម។ សម័យកាលនោះមេទ័ពដែលល្បីឈ្មោះនៅក្នុងប្រវត្តិសាស្ត្រគឺតេជោមាស និងតេជោយ៉ត។ ឧដុង្គបើតាមរឿងនិទានយកឈ្មោះតាមតាចាស់ម្នាក់ឈ្មោះតាដុង្គ រឿងតំណាលថានៅពេលនោះមានក្សត្រមួយអង្គបានពេញចិត្តនឹងកូនស្រីរបស់គាត់។ ទើបក្រោយមក ព្រះរាជាក៏តាំងឈ្មោះនៅត្រង់នោះថា ឧដុង្គមានជ័យ លុះក្រោយមកទៀតក៏នៅហៅថា ឧដុង្គ ដូចសព្វថ្ងៃនេះ។

ព្រះបាទជ័យជេដ្ឋាទី២ បានឡើងសោយរាជ្យនៅរាជវាំងល្វាឯមក្នុងព្រះជន្ម៣៤វស្សា។ ព្រះអង្គមានមហេសីនាមអង្គចូវជាបុត្រីស្តេចយួន។ នៅឆ្នាំ១៦២០ ព្រះអង្គបានលើករាជធានីពីល្វាឯមមកឧដុង្គ។ ព្រះរាជកិច្ចដំបូងគឺកំណែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធតុលាការខ្មែរ ដោយយល់ឃើញថាមានក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ ព្រះអង្គបានកែប្រែក្រមបានចំនួន២៤។ ប៉ុន្តែការងារនេះត្រូវរំខានដោយសារការឈ្លានពានរបស់សៀមពីរលើកគឺនៅឆ្នាំ១៦២១ និង១៦២២។ ច្បាប់ដែលពិនិត្យរួចត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ១៦២៤នៅក្នុងតុលាការ។ ជាលើកទី១ ចាប់តាំងពីរជ្ជកាលព្រះបាទស្រីសុរិយោពណ៌រហូតដល់ជ័យជេដ្ឋាទី២ ពួកសៀមបានធ្វើការសោកល្បងដើម្បីដាក់ខ្មែរជាចំណុះម្តងទៀត។ នៅឆ្នាំ១៦២១ ស្តេចសៀមឈ្មោះសុងថាម បានលើកទ័ពដោយផ្ទាល់ជាពីរផ្នែក មួយផ្នែកចូលតាមខេត្តបាត់ដំបង និងពោធិ៍សាត់ ប៉ុន្តែត្រូវទ័ពខ្មែរវាយឱ្យខ្ចាត់ខ្ចាយរត់ចេញតាមខេត្តចន្ទបុរី។ មួយផ្នែកទៀតជាទ័ពជើងទឹកចូលមកតាមខេត្តកំពត និងបន្ទាយមាសក្នុងបំណងវាយយកខេត្តទ្រាំង ប៉ុន្តែទ័ពសៀមត្រូវបរាជ័យម្តងទៀត ដោយសារខ្មែរបំពុល។ មួយឆ្នាំក្រោយមកគឺឆ្នាំ ១៦២២ សៀមបានសាកល្បងលើកទ័ពមកម្តងទៀត ប៉ុន្តែត្រូវបរាជ័យ។ ចាប់តាំងពីពេលនោះមក រហូតដល់ដំណាច់សតវត្សទី១៧ សៀមពុំបានបញ្ចេញសកម្មភាពគាបសង្កត់ខ្មែរគួរឱ្យកត់សម្គាល់ឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ពួកយួនបានចាប់ផ្តើមកេរទឹកដីខ្មែរ

បន្តិចម្តងៗពីខាងកើត។ ការរៀបអភិសេករវាងជ័យជេដ្ឋាទី២ និងក្សត្រីអង្គចូវបានធ្វើឱ្យប្រទេសខ្មែរជាប់ជំពាក់រឿងចម្រូងចម្រាស់យ៉ាងខ្លាំង នៅពេលដែលពួកយួនបានលេបយកទឹកដីចាម្ប៉ាទាំងស្រុងនៅសតវត្សទី១៧។ នៅឆ្នាំ១៦២៣ គណៈបេសកកម្មទូតយួន បានលើកសំណើសុំឱ្យយួនបង្កើតគ្រឹះស្ថានជំនួញនៅប៉ែកខាងត្បូងប្រទេសខ្មែរពីរមានខេត្តព្រៃនគរ និងកំពង់ក្របី ព្រមទាំងសុំអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ក្រសួងគយនៅទីនោះផង។ ចំណុចនេះអ្នកប្រវត្តិសាស្ត្របានចាត់ទុកថា ខ្មែរចាញ់កលល្បិចបោកបញ្ឆោតរបស់យួនដែលសុំត្រួតពិនិត្យពន្ធដារនិងរស់នៅជាបណ្តោះអាសន្ន។ កាលដែលមិនទាន់សោយរាជ្យ ព្រះជ័យជេដ្ឋាទី២ មានព្រះជន្ម២៦វស្សា មានបុត្រពីរអង្គនាមចៅពញាតូ និងចៅពញានូ។ លុះសោយរាជ្យបាន២ឆ្នាំ ព្រះអង្គមានបុត្រនាមចៅពញាចន្ទ និងបុត្រីនាមចន្ទវតី (ឬបុប្ផាវតី)។ ឯព្រះឧទ័យរាជាមានបុត្រ៤អង្គ គឺអ្នកអង្គនន់ទី១ អ្នកអង្គសូរ អ្នកអង្គតន់ និងអ្នកអង្គអិម។

នៅសម័យឧដុង្គមានភាពចម្រូងចម្រាស់យ៉ាងខ្លាំងដោយសារតែមានទំនាស់វិបត្តិពោលគឺសង្គ្រាមរ៉ាំរ៉ៃ ការដណ្តើមរាជសម្បត្តិគ្នា ការឈ្លានពានពីសម្នាក់ប្រទេសជិតខាង និងទំនាស់ស្នេហាដ៏ល្បីល្បាញរវាងព្រះរាជសម្ភារ ឬព្រះចៅពញាតូ (ត្រូវជាក្មួយ) និងព្រះឧទ័យ (ដែលត្រូវជាឪពុកមា)។ នៅក្នុងសម័យឧដុង្គ ព្រះរាជាដែលមានទេពកោសល្យខ្លាំងក្នុងវិស័យអក្សរសាស្ត្រគឺមានមួយព្រះអង្គទៀតគឺព្រះអង្គដួង ដែលព្រះអង្គបានបន្សល់ទុកស្នាដៃយ៉ាងចំណានសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ ព្រះអង្គដួងនេះហើយជាព្រះមហាក្សត្រប្រកបដោយទសពិធរាជធម៌។ ពោលគឺនៅពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ គ្រានោះប្រទេសកម្ពុជាគ្រាំគ្រាជាខ្លាំងដោយស្ថិតក្រោមឥទ្ធិពលប្រទេសខ្លាំងទាំងពីរគឺសៀម និងយួនដែលមានគោលបំណងលេបត្របាក់យកទឹកដីនៃប្រទេសកម្ពុជា។ ដោយមើលឃើញពីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរ ព្រះអង្គដួងទ្រង់សុខចិត្តទទួលយកឥទ្ធិពលនៃប្រទេសទាំងពីរ ដោយយល់ព្រមនាំសួយសារអាករទៅថ្វាយស្តេចនៃនគរទាំងពីរជារៀងរាល់ឆ្នាំ។ ក្រោយមកទៀត ព្រះអង្គបានប្រមើលមើលទៅកាន់អនាគតគឺថាត្រូវតែពឹងពរកប្រទេសមហាអំណាចបារាំងសែសមកជួយស្រុកខ្មែរ ទើបអាចរំដោះបានពីសត្រូវខ្លាំងទាំងពីរនេះបាន។ ព្រះអង្គដួង លោកបានបញ្ជូននិស្សិតខ្មែរឱ្យប្រឹងរៀនភាសាបារាំង ហើយបានសរសេរចុតហ្មាយទៅថ្វាយព្រះចៅណាប៉ូឡេអុង ប៉ុន្តែត្រូវបានសៀមចាប់បានជាច្រើនលើក។ ជាចុងបញ្ចប់ទ្រង់មានគោលបំណងដើម្បីវាយដណ្តើមយកទឹកដីកម្ពុជាក្រោមពីយួនមកវិញ ប៉ុន្តែជាអកុសលទ្រង់បានយាងសោយទិវង្គត ហើយបន្សល់ទុកនូវកិច្ចការជាច្រើនដែលអ្នកស្នងរបស់ព្រះអង្គគឺព្រះបាទនរោត្តម ឬព្រះអង្គម្ចាស់ច្រឡឹងជាអ្នកបន្តវេនដើម្បីធ្វើកិច្ចការដ៏សំខាន់មួយនេះ។

II.៣.២- ទិដ្ឋភាពព្រះពុទ្ធសាសនាថេរវាទនៅសម័យកណ្តាល

ដោយសារតែសង្គ្រាមកើតមានមិនឈប់ឈរដែលបង្កឡើងដោយប្រទេសជិតខាងមានសៀម និង
យួន ព្រមទាំងសង្គ្រាមក្នុងស្រុកនានាជាច្រើនបានបង្កឱ្យប្រទេសជាតិទាំងមូលត្រូវធ្លាក់ស្រុតបាត់
កិត្យានុភាព អធិបតេយ្យភាព និងឯនភាពនៅគ្រប់វិស័យទាំងអស់ ក្នុងនោះព្រះពុទ្ធសាសនាបានហែលឆ្លង
កាត់នូវព្រឹត្តិការណ៍សង្គមដ៏ស្មុគស្មាញ នេះជាមួយពុទ្ធបរិស័ទចំណុះជើងវត្តទូទាំងប្រទេសផងដែរ។ វត្ត
អារាមគម្ពីរដីកាត្រូវបានដុតបំផ្លាញ និងវាយកម្ទេច ឯព្រះសង្ឃត្រូវបានគេធ្វើគុត ឬត្រូវគេបណ្តេញចេញពី
វត្តដោយគ្មានមូលហេតុច្បាស់លាស់ ក្រៅពីការបំផ្លាញដោយមិនរើសមុខ (ពីសម្ងាក់ប្រទេសយួន)។
ទោះបីមានការព្យាបាទពីសំណាក់សត្រូវយ៉ាងណាក្តីក៏ព្រះពុទ្ធសាសនានៅតែតស៊ូ យ៉ាងរឹងមាំជាមួយនឹង
ពុទ្ធបរិស័ទគ្រប់ស្រទាប់វណ្ណៈផងដែរ។ ដោយសារតែសទ្ធាដែលកើតចេញពីជំនឿដ៏ជ្រះថ្លារបស់ប្រជាជន
ខ្មែរ ទាំងព្រះមហាក្សត្រ ទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បានខិតខំកសាង ជួសជុល និងធ្វើការរៀបចំវត្ត
អារាមពុទ្ធសាសនា ឱ្យមានដំណើរការឡើងវិញប្រកបទៅដោយស្មារតី សាមគ្គីដ៏ខ្ពង់ខ្ពស់។

ចុងសម័យអង្គរ ព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនាចាប់ស្រុតចុះគួរឱ្យកត់សម្គាល់
ហើយពុទ្ធសាសនាថេរវាទក៏ចាប់មានឥទ្ធិពលយ៉ាងធំធេងនៅក្នុងស្ថានភាពដែលមានការប្រែប្រួលទាំង
នេះ។ លោក ហារី បេនដា បានចាត់ទុកថា ព្រះពុទ្ធសាសនាថេរវាទនៅប្រទេសខ្មែរនៅចុងសម័យអង្គរ និង
សម័យក្រោយអង្គរបន្តិចថាជាជំនឿនៃចលនាប្រជាជនទូទៅពោលគឺសាសនានេះមានបង្កប់នូវគំនិត
ប្រឆាំងនឹងរបបអភិជន។ ទស្សនៈរបស់លោក ហាក់ដូចជាឆ្លើយស្របទៅនឹងទស្សនៈរបស់លោក ឡឺក្លែរ
ដែលជឿថា "ព្រះពុទ្ធសាសនាជាកត្តាដែលធ្វើឱ្យមានការលុបបំបាត់នូវប្រព័ន្ធវណ្ណៈ»។

ពង្សាវតារជាច្រើនបានបង្ហាញថារជ្ជកាលរបស់ព្រះបាទធម្មរាជា (១៤៨៦-១៥០៤) ថាជាយុគ
មាសនៃការរីកចម្រើនខាងជំនឿព្រះពុទ្ធសាសនា។ ស្តេចអង្គនេះបានឧបត្ថម្ភដល់ការកសាង និងពង្រឹងព្រះ
ពុទ្ធសាសនាយ៉ាងខ្លាំងក្លា ដោយបានលើកលែងពន្ធអាករពីប្រជានុរាស្ត្រចំនួន៣ឆ្នាំថែមទៀតផង។ ព្រះអង្គ
ក៏ជាមហាក្សត្រដែលមានចំណេះដឹងខាងពុទ្ធសាសនាមួយព្រះអង្គផងដែរ។ នៅរវាងឆ្នាំ១៤៩៦ ព្រះអង្គ
បានចេញរាជបញ្ជាឱ្យគេផ្ទេរព្រះសារីរិកធាតុទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធពីចេតិយរបស់ព្រះថោង នៅ
អង្គរមកតម្កល់នៅចេតិយថ្មីនៅភូមិខ្វាវព្រះធាតុ នៅជិតភ្នំសន្ទុក ខេត្តកំពង់ធំវិញ។

ក្រោយពេលព្រះបាទអង្គចន្ទសោយទិវង្គតទៅ ដោយគ្មានរាជបុត្រស្នងរាជ្យ ប្រទេសអណ្ណាមបានឆ្លៀតឱកាសលូកដៃចូលក្នុងកិច្ចការរាជវាំងខ្មែរ ដោយបានលើករាជបុត្រីមួយអង្គរបស់ព្រះអង្គចន្ទ ព្រះនាមអង្គមីឱ្យឡើងសោយរាជ្យស្នងព្រះបិតា។ ឯប្រទេសអណ្ណាមក៏ឆ្លៀតឱកាសគ្រប់គ្រងប្រទេសកម្ពុជាតែម្តងទៅតាមរយៈការចាត់បញ្ជូនមេទ័ពមួយរូបឈ្មោះ ទ្រឿង មិញយ៉ាង ឱ្យមកគ្រប់គ្រងមើលការខុសត្រូវនៅកម្ពុជា។ គោលនយោបាយវៀតណាមការបូបនីយកម្មត្រូវបានចាប់ផ្តើមធ្វើនៅទូទាំងប្រទេសកម្ពុជា ដោយដាក់បញ្ចូលនូវទំនៀមទម្លាប់ប្រពៃណីវៀតណាមជំនួសទំនៀមទម្លាប់ប្រពៃណីខ្មែរទាំងអស់។ វត្តអារាមគម្ពីរដីកា និងព្រះសង្ឃរងការបំពានដោយការបំផ្លាញ និងធ្វើគុតព្រះសង្ឃ។ ការធើបបះបោរកើតមានជាញឹកញាប់ប្រឆាំងនឹងវត្តមានអណ្ណាម និងការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនាក៏ដូចជាប្រជាជនខ្មែរទូទាំងប្រទេស។ គ្រានោះមានឧកញ៉ាម្នាក់បាននិយាយថា "យើងសប្បាយនឹងសម្លាប់ជនជាតិយួន យើងលែងខ្លាចពួកយួនទៀតហើយ គ្រប់សមរភូមិរបស់យើង ពួកយើងបានចងចាំជានិច្ចនូវព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ" រហូតមកដល់រជ្ជកាលរបស់ព្រះអង្គឌួង ទើបគេសង្កេតឃើញថាសង្គមខ្មែរហាក់ដូចជាទទួលបានសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យឡើងវិញ ក្នុងនោះព្រះពុទ្ធសាសនាក៏ត្រូវបានស្តារ និងពង្រឹងពង្រីកឡើងវិញផងដែរ។ ទីអារាមដែលខូចខាតដោយសារការបំផ្លាញដោយសង្គ្រាម និងដោយហេតុផលផ្សេងៗត្រូវបានជួសជុល និងកសាងឡើងវិញក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គដួងផ្ទាល់ក៏ដូចជាក្រោមការជួយឧបត្ថម្ភរបស់មន្ត្រីរាជការទាំងឡាយដែលមានធនធានផងដែរ។ គេបានរៀបរាប់ថា នៅឆ្នាំ១៨៥៤ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី បានទ្រង់ឈ្វេងយល់ថា ក្នុងក្រុងកម្ពុជាធិបតី ព្រះពុទ្ធសាសនាបានទ្រុឌទ្រោមចុះ និងមិនច្បាស់លាស់ផង ត្បិតព្រះត្រៃបិដកពុំមានព្រះសូត្រក៏ពុំមានសម្រាប់ការរៀនសូត្រ ទើបព្រះអង្គបានប្រជុំសេនាបតីនាម៉ឺនសព្វមុខមន្ត្រីត្រាស់ថា គួរចាត់មន្ត្រី១រូប ឬអញ្ជើញព្រះរាជសារទៅស្រុកសៀមក្រាបបង្គំទូលស្តេចសៀម ព្រះចមក្លាវ (រាមាទី៤) ដើម្បីសូមទ្រង់តាំងព្រះត្រៃបិដក និងគណៈធម្មយុត្តក្នុងនគរខ្មែរ ដោយនិមន្តមហាប៉ានឱ្យទំនុកបម្រុងព្រះពុទ្ធសាសនាបានថ្កុំថ្កើងរុងរឿងតរៀងទៅ។

អវត្តមាននៃព្រះត្រៃបិដកនៅប្រទេសកម្ពុជាត្រង់ចំណុចនេះ ប្រហែលមិនមែនជាលទ្ធផលដែលកើតឡើងដោយសារតែសង្គ្រាមជាច្រើនសតវត្សរ៍យ៉ាងសាមញ្ញនោះទេ។ លោក ហ្វ្រង់ស្វា ប៊ីហ្សូត៍ បានអះអាងថាមុនការស្នើសុំរបស់ព្រះអង្គដួងនៅពាក់កណ្តាលសតវត្សទី១៩នោះ នៅក្នុងប្រទេសកម្ពុជាប្រហែលជាគេមិនធ្លាប់បានយកព្រះត្រៃបិដកមកប្រើឬក៏មិនស្គាល់ព្រះត្រៃបិដកទាំងស្រុងពីដើមដល់ចប់។

ទោះបីគេបានប្រើភាសាបាលីយ៉ាងទូលំទូលាយជាភាសាសាសនាតាំងពីសតវត្សទី១៣ ហើយយើងឃើញ មានភស្តុតាងនៅក្នុងសិលាចារឹកដូចជាពាក្យ "ព្រះវិន័យ" "ព្រះអភិធម៌" និង "ព្រះសូត្រ" នៅប្រទេសកម្ពុជាក៏ដោយ លោក ប៊ីហ្សូត៍ ឱ្យយោបល់ថាចំណងជើងនៃ"ល្ពីបី" (ព្រះត្រៃបិដក) ទំនងជាសំដៅលើក្បួនសម្រាប់ព្រះសង្ឃដែលក្នុងនោះមានសេចក្តីសង្ខេបដែលបានដកស្រង់ចេញពីគម្ពីរបាលីបម្រុងសម្រាប់ឱ្យព្រះសង្ឃសូត្រ ប៉ុន្តែមិនចាំបាច់សិក្សា និងយល់ពីខ្លឹមសារទេ។ បញ្ញត្តិ និងសិក្ខាបទពុទ្ធសាសនា ដូចជាវិន័យសម្រាប់ប្រតិបត្តិនៅក្នុងវត្តជាប្រចាំថ្ងៃទូទៅ គេបានសរសេរជាអត្ថបទសម្រាយវិញ។ កាលលើកឡើងរបស់លោក ប៊ីហ្សូត៍ ទំនងជាវិភាគនូវស្ថានភាពមួយក្នុងសតវត្សទី១៩ ប៉ុណ្ណោះ។ ទស្សនៈដ៏សំខាន់មួយនៃកំណែទម្រង់ព្រះពុទ្ធសាសនាបានចាប់ផ្តើមឡើងដោយព្រះបាទសម្តេចព្រះហរិរក្សារាធិបតី ដើម្បីកត់សម្គាល់ការចាប់ផ្តើមរជ្ជកាលរបស់ព្រះអង្គ គឺការប្រមូលឡើងវិញនូវគម្ពីរដែលបាត់បង់ ឬត្រូវបំផ្លិចបំផ្លាញនៅពេលមានសឹកសង្គ្រាមជាមួយនឹងសៀមនិងយួន។ ការស្តារគម្ពីរទាំងនោះឡើងវិញជានិមិត្តរូបនៃសកម្មភាពមួយក្នុងការធ្វើបុណ្យកុសលសម្រាប់ទ្រង់ និងអាណាចក្ររបស់ព្រះអង្គ ហើយក៏បានបង្ហាញផងដែរនូវទស្សពិធរាជធម៌របស់ព្រះអង្គដើម្បីលើកតម្កើង និងធ្វើឱ្យសាសនាបរិសុទ្ធ។ នេះគឺជាកាតព្វកិច្ចរបស់ព្រះអង្គដើម្បីការពារព្រះធម៌ តាមរយៈឥរិយាបថគំរូផ្ទាល់របស់ព្រះអង្គក្នុងការឧបត្ថម្ភព្រះសង្ឃ និងការយកចិត្តទុកដាក់ចំពោះគម្ពីរព្រះធម៌។

នៅក្នុងរជ្ជកាលព្រះបាទអង្គដួង ព្រះពុទ្ធសាសនាមានការអភិវឌ្ឍណាស់ ក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គផ្ទាល់ក៏ដូចជាការចូលរួមពីសម្នាក់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាជនខ្មែរទូទៅដែលជាពុទ្ធបរិស័ទចំណុះជើងវត្តជិតឆ្ងាយផងដែរ។

II.៣.៣- ឆ្នាំនីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ

II.៣.៣.១- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះបញ្ញាពុទ្ធិ

តាមការសិក្សាកន្លងមក យើងបានសង្កេតឃើញថា ស្នាដៃអក្សរសិល្ប៍ទាំងឡាយសុទ្ធសឹងតែមានតួនាទីក្នុងការផ្តល់ពុទ្ធិ ចំណេះដឹងសព្វគ្រប់សារពើ។ យ៉ាងណាមិញ តាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរបានផ្តល់នូវចំណេះដឹងផ្នែកព្រះពុទ្ធសាសនាយ៉ាងជ្រាលជ្រៅ។ ទស្សនវិជ្ជាព្រះពុទ្ធសាសនាបានសាបព្រោះមកក្នុងសង្គមខ្មែរ ផ្នត់គំនិតមនុស្សខ្មែរដល់សរសៃសសូងតែម្តង។ ជាពិសេសក្នុងការប្រតិបត្តិតាមគន្លងមាគ៌ាព្រះពុទ្ធប្រកបដោយធម៌អហិង្សា ដោយសេចក្តីសុខសន្តិភាព និងសុភមង្គល។

តាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនាំឱ្យខ្មែរចេះស្រឡាញ់គ្នា មិនទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ឡើយ។ នៅសម័យក្រោយអង្គរគឺជាសម័យកាលមួយដែលសង្គមខ្មែរដួបកលិយុគអាប់អួរក្រៃលែង ប៉ុន្តែអក្សរសាស្ត្រប្រជាលេចធ្លោរហូតក្លាយជាយុគមាសនៃអក្សរសិល្ប៍ខ្មែរ។

យើងឃើញថា ស្នាដៃពុទ្ធនិយមបានបណ្តុះបញ្ញា ការចេះដឹងដល់ប្រជាជនខ្មែរឱ្យចេះដោះស្រាយបញ្ហាជីវិត មានស្មារតីតស៊ូ ហ៊ានជម្នះគ្រប់ឧបសគ្គ និងយកព្រះធម៌ជាទីពឹងទីរឭក។ ពោលគឺទាំងស្នាដៃនៅក្នុងទសជាតក បញ្ញាសជាតក និងសាស្ត្រាល្បែងនានាសុទ្ធតែជាកម្រងពុទ្ធិដ៏ឧត្តមរបស់កូនខ្មែរ ឱ្យចេះចាប់យកឱកាស ក្រេបយកចំណេះដឹងក្លាយជាមនុស្សល្អនៅក្នុងសង្គមជាតិ។ នៅសម័យកាលនោះតាមអ្វីដែលយើងបានសិក្សា អ្នកប្រាជ្ញ កវីនិពន្ធខ្មែរ សុទ្ធតែមានប្រកពធ្លាប់បានបួសរៀននៅក្នុងសម្នាក់ព្រះពុទ្ធសាសនា។ នៅក្នុងពេលបួសរៀននោះ គេបានសិក្សាធម៌អាថ៌ គម្ពីរព្រះត្រៃបិដក ភាសាបាលី-សំស្ក្រឹតដែលសុទ្ធសឹងតែជាជម្រៅនៃព្រះពុទ្ធសាសនា។

រាជកវីខ្មែរព្រះអង្គឌួង ទ្រង់គឺជាក្សត្រដែលយកព្រះទ័យទុកដាក់ចំពោះជាតិ និងអក្សរសាស្ត្រយ៉ាងខ្លាំង។ ទ្រង់ជារាជកវីដែលស្ថិតក្នុងសម័យឧដុង្គ ហើយព្រះអង្គតែងតែយកព្រះទ័យទុកដាក់ចំពោះជាតិប្រជារាស្ត្រជានិច្ច ។ នៅសម័យកាលនោះ អក្សរសាស្ត្រខ្មែរបានរីកចម្រើនដល់កម្រិតកំពូលរហូតដល់យើងចាត់ទុកថាជាយុគមាសនៃអក្សរសិល្ប៍ខ្មែរថែមទៀតផង ។ តាមការឱ្យដឹងពីព្រឹទ្ធាចារ្យ ឆេង ផុន យើងបានដឹងថានៅសម័យឧដុង្គ ព្រះរាជាទ្រង់ជាគណៈមេប្រយោគដោយផ្ទាល់ក្នុងការប្រឡងជ្រើសរើសមន្ត្រីរាជការឱ្យចូលធ្វើការនៅក្នុងវាំង ឬមុខការក្រសួងនានា។ ក្នុងនោះវិញ្ញាសាសំខាន់រួមមានប្រឡងកំណាព្យ ការប្រែលោតប្រយោគភាសាបាលីជាន់ខ្ពស់ជាដើម។ លោកបានដំណាលថានៅពេលជិតភ្លឺ ប្រជារាស្ត្រខ្លះដែលបានលឺនង្គ័លទៅភ្ជួរស្រែបែរជាឈរទ្រឹងរឹងខ្លួនពួនចាំស្តាប់សំឡេងសូរស័ព្ទស្នូត្រយ៉ាងពីរោះរណ្តំាចិត្តដែលចេញមកពីរាជវាំងឧដុង្គមានជ័យក៏មានដែរ។ ត្រង់នេះយើងបានឃើញថា តម្លៃអក្សរសិល្ប៍បានជះឥទ្ធិពលមកលើសង្គមខ្មែរក្រៃលែង។ ហើយបើតាមសាស្ត្រាចារ្យភាសាបាលីគឺលោកតាផៃវិញ ហើយគាត់ជាសាក្សីរស់ដល់បច្ចុប្បន្ននេះ និងជាអ្នកតាក់តែងសៀវភៅប្រវត្តិសង្ខេបវត្តហរិរក្សារាជិនី ហៅវត្តវាំងចាស់ លោកក៏បាននិយាយដែរថា នៅពេលដែលព្រះមហាក្សត្រខ្មែរបានប្តូររាជធានីពីឧដុង្គមករាជធានីភ្នំពេញ គ្រានោះនៅវត្តវាំងចាស់មានព្រះភិក្ខុសង្ឃមួយព្រះអង្គព្រះនាមមឿង មានបុណ្យបារមីអស្ចារ្យដែលគង់ប្រថាប់នៅវត្តវាំងចាស់នេះ។ សម័យកាលនោះជាសម័យកាលដែលសម្បូរទៅដោយអ្នកប្រាជ្ញ កវីនិពន្ធដែលមានស្នាដៃល្អឯកសម្រាប់កូនខ្មែរយ៉ាងច្រើនក្រាស់ក្រែល។ បើនិយាយពីស្នាដៃវិញ ព្រះអង្គទ្រង់បាននិពន្ធរឿងកាកីដែលជាស្នាដៃតែងជាកំណាព្យប្រកបដោយកាព្យរូបារម្មណ៍ដ៏ល្អត្រកាល។ រឿងកាកីនេះ

យើងបានដឹងថាជាស្នាដៃដែលបានរំលេចឱ្យឃើញពីសោកនាដកម្មរបស់នាងកាកី ហើយចុងបញ្ចប់នៃជីវិតរបស់នាងគឺត្រូវស្លាប់យ៉ាងគួរឱ្យអាណោចអាធ័មក្រៃពេកដោយត្រូវបណ្តែតពោងពាយលើក្បូនម្នាក់ឯងចូលទៅក្នុងមហាសាគរ។ នាងត្រូវបានតាឥសីរើសមកចិញ្ចឹមតាំងពីកំណើតមកម្ល៉េះ។ នាងគ្មានម្តាយឪពុកអប់រំទូន្មានប្រៀនប្រដៅដូចកូនគេដទៃឡើយ។ អាស្រ័យហេតុនេះហើយនៅពេលដែលស្តេចព្រហ្មទត្តមកយកនាងជាមហេសីនោះ តាឥសីបានផ្តាំផ្ញើថ្វាយព្រះរាជាថា ប្រសិនបើនាងមានកំហុសឆ្គង សូមទ្រង់កុំដាក់ទោសទណ្ឌនាងធ្វើអ្វី។ បានជាតាឥសីលោកបានផ្តាំផ្ញើក្បត្រ ព្រោះលោកគិតថា នាងគ្មានម៉ែឪប្រៀនប្រដៅហ្នឹងគេឡើយ។ ដូចនេះ ថ្ងៃមុខនាងច្បាស់ជាប្រព្រឹត្តនូវកំហុសណាមួយជាក់ជាមិនខាន។ នៅក្នុងរឿងកាកីនេះដដែលក៏បានបង្ហាញពីចំណេះដឹងស្តីពីជំនឿលើហោរាសាស្ត្រ ការទស្សន៍ទាយ ការសេកមន្តសារិកា ការប្រែកាឡាខ្លួន ការនិម្មិតខ្លួនជាអ្វីបានតាមចិត្តចង់របស់ខ្លួននោះជាដើម។ ជាក់ស្តែងដូចជាគ្រុឧចេះកាឡាខ្លួនជាបុរសដែលមានរូបស្រស់សង្ហាដែលធ្វើឱ្យនាងកាកីចាប់អារម្មណ៍ដូចឃ្លាកំណាព្យលើកឡើងថា៖«ឯអង្គកាកី យល់គ្រុឧបក្សី មើលមកអាត្មា ញញឹមអរអៀន ចំហៀងនេត្រា ព្រឺព្រួចកាមា ត្រេកត្រង់ហឫទ័យ។ នាងធ្វើជាធ្លាក់ រំសាយសុភ័គ អំពីអង្សា គ្រុឧយល់សុដន ណែនក្តន់ឱរា ព្រឺព្រួចចិន្តា ស្រៀវស្រើបប្រតិព័ទ្ធ។ ស្ទើរស្ទុះទៅឱប ពារពក្រសោប ហោះចេញទៅថ្វាត់ មកគិតខ្លាចកេរ្តិ៍ចំណេរមិនបាត់ ខះខំតែកាត់ ចិត្តចាំលេងស្តារ»។ គ្រុឧដោយមានចិត្តលើកាកី ក៏ឆក់យករូបនាងកាកីទៅស្ថានលំនៅរបស់ខ្លួន។ ចំណែកព្រះបាទព្រហ្មទត្តវិញ ទ្រង់បានចាត់ ហោរាគន់គូរមើល ទើបដឹងថានាងកាកីត្រូវគ្រុឧជាអ្នកចាប់យកទៅ។ រីឯគន្ធំនវិញ ក៏ចេះប្រែកាឡាទៅតាមបំណងប្រាថ្នា ហើយតោងប្រាណគ្រុឧដល់ឋានសិម្ពលី និងបានជួបប្រាស្រ័យលួងលោមនាងកាកីបានដូច បំណង ហើយក៏ចុះមកវិញនាងស្ថានកណ្តាល។ ត្រង់នេះជាចំណេះដឹងមួយដែលយើងគិតថា នៅសម័យកណ្តាលប្រជាជនខ្មែរមានជំនឿទៅលើហោរាសាស្ត្រ និងជំនឿលើសិល្ប៍អាគមជាដើម។

ឆ្លងតាមការស្រាយបំភ្លឺ ស្នាដៃពុទ្ធនិយមញុំាងឱ្យមនុស្សខ្មែរកាលពីសម័យក្រោយអង្គរមានបញ្ញាពុទ្ធិ ចេះដោះស្រាយបញ្ហា ជម្រុះចោលទស្សនៈកំន្តច្រឡំ ជម្រុះចោលភាពអសកម្ម ឱ្យស្រវាចាប់យកវិជ្ជាជាក់នៅក្នុងខ្លួនប្រសើរជាង។ ដូចនេះក្នុងនាមជាកូនខ្មែរត្រូវប្រឹងប្រែងក្រេបជញ្ជក់នូវការចេះដឹងគ្រប់សព្វសារពើ ហើយអាចនាំខ្លួនក្លាយជាឧត្តមជនជាក់ជាមិនខាន។

II.៣.៣.២- អក្សរសិល្ប៍ពុទ្ធនិយម និងការអប់រំ

នៅក្នុងស្នាដៃពុទ្ធនិយម យើងបានសង្កេតឃើញថា អ្នកនិពន្ធខ្មែរបានយកការប្រៀនប្រដៅផ្សេងៗរបស់បុព្វបុរសខ្មែរផ្សារភ្ជាប់ជាមួយនឹងជីវិតព្រះពោធិសត្វមកតាក់តែងកែច្នៃបញ្ចេញបញ្ចូលគំនិតទស្សនៈ

របស់ខ្លួនឱ្យស្របទៅនឹងផ្នត់គំនិត ប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរដើម្បីបណ្តុះស្មារតីឱ្យមនុស្ស យល់ដឹងពីតម្លៃនៃការប្រព្រឹត្តកុសលកម្ម បានសេចក្តីថាជាអំពើល្អ អំពើជាកុសល និងឱ្យលះបង់ចោល ចេញនូវអំពើបាបទាំងពួង។ ក្នុងនោះអក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះឱ្យខ្មែរមានការស្វែងយល់ស៊ីជម្រៅគឺ តម្លៃនៃការអប់រំតាមគន្លងមាគ៌ាព្រះពុទ្ធអង្គ និងការគោរពចំពោះព្រះពុទ្ធសាសនា។ ជាក់ស្តែងដូចជា៖

ក. បណ្តុះស្មារតីមនុស្សឱ្យចេះដឹងគុណ និងជឿជាក់លើកម្លាំងខ្លួនឯង

ការផ្តើមរឿងដោយរំឭកគុណព្រះរតនត្រៃ រំឭកគុណគ្រូ គុណមាតាបិតា ប្រាប់ឈ្មោះអ្នកនិពន្ធ កាលបរិច្ឆេទ ខ្លឹមសាររឿង ដំណាលពីជីវិតរបស់ពោធិសត្វ និងការជួបជុំគ្រួសារ ព្រមទាំងបង្ហាញពីដំណើរ ជីវិតព្រះពោធិសត្វកាលទ្រង់យោនយកកំណើតនៅក្នុងជាតិផ្សេងៗ។

អក្សរសិល្ប៍ពុទ្ធនិយមប្រៀបបានជាឱសថដ៏ស័ក្តិសិទ្ធិគឺបានអប់រំមនុស្សខ្មែរឱ្យជឿទៅលើបុណ្យ បាប ខ្លាចរអាអំពើបាប និងចៀសឱ្យឆ្ងាយពីបាបកម្មគ្រប់បែបយ៉ាង។ ស្នាដៃបានបណ្តុះចិត្តមនុស្សខ្មែរឱ្យ ចេះដឹងគុណចំពោះមនុស្សដែលបានជួយសង្គ្រោះខ្លួននៅពេលដែលខ្លួនជួបទុក្ខលំបាក។ នៅក្នុងសង្គម យើងនេះ យើងបានសង្កេតឃើញថា មនុស្សមានច្រើនប្រភេទណាស់ មានល្អ មានអាក្រក់ និងមានចិត្តជា គុណធម៌ជាដើម។ នៅក្នុងសង្គមទៀតសោត រមែងមានរឿងរ៉ាវជាច្រើនដែលយើងមិននឹកស្មានដល់។ ដូច នេះគឺមានតែការខិតខំប្រព្រឹត្ត សាងតែអំពើល្អគ្រប់បែបយ៉ាង ទើបនាំឱ្យមនុស្សមានសុភមង្គល និងមាន ចិត្តស្ងប់នៅពេលដែលបានជួយសង្គ្រោះជនណាម្នាក។ ខ្មែរយើងតែងមានជំនឿថា ការជួយសង្គ្រោះ មនុស្សសូម្បីតែម្នាក់នៅពេលដែលគេត្រូវការជំនួយ ល្អជាងការធ្វើបុណ្យ៧វត្ត។ ត្រង់នេះមនុស្សដែលគេ បានជួយសង្គ្រោះរមែងដឹងគុណ និងតបគុណនៅពេលដែលឱកាសហុចឱ្យ។ ជាមួយគ្នានេះ ស្នាដៃពុទ្ធ និយមបានបណ្តុះទស្សនៈឱ្យមនុស្សជឿជាក់លើកម្លាំងផ្ទាល់ខ្លួន មិនមានទស្សនៈផ្តេកផ្តួលដោយសេចក្តី ខ្ជិលច្រអូសសោះឡើយ។ តួយ៉ាងនៅក្នុងស្នាដៃរឿងមហោសថ យើងបានសង្កេតឃើញថា ព្រះមហោសថ មានព្រះប្រាជ្ញាក្រៃពេក។ ទ្រង់បានមើលដឹងពីល្បិចកលរបស់គូសត្រូវដែលមានបំណងមិនល្អ ឬធ្វើអំពើ បានធម៌ជាដើម។ ព្រះមហោសថរមែងប្រើប្រាស់នូវការវិភាគរបស់ខ្លួនប្រកបដោយបញ្ញាញាណដើម្បីដឹង ជើងការណ៍មុនជានិច្ច។

ត្រង់នេះយើងឃើញថា ស្នាដៃបានបណ្តុះនូវស្មារតីតស៊ូឱ្យមនុស្សជឿជាក់លើកម្លាំងផ្ទាល់ខ្លួន ជា ប្រយោជន៍ដ៏ក្រៃលែងសម្រាប់ជីវិតមនុស្សខ្មែរកាលពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន។

ខ. អក្សរសិល្ប៍ពុទ្ធនិយមបណ្តុះស្មារតីឱ្យមនុស្សខ្មើលើអំពើបុណ្យបាប

តាមរយៈស្នាដៃមួយចំនួនដូចជា ពុទ្ធិសែននាងកង្រី មរណមាតា សព្វសិទ្ធិ កវីនិពន្ធខ្មែរបានលើកឡើងពីការបញ្ហាកម្មផល។ តួអង្គដែលសាងអំពើអាក្រក់ រមែងមានកម្មពៀរវេរា ហើយត្រូវទទួលរងបាបកម្មចំពោះអំពើដែលខ្លួនបានសាងយ៉ាងសែនទារុណ។

នៅក្នុងរឿងពុទ្ធិសែននាងកង្រីបានបង្ហាញថា ពុទ្ធិសែន និងនាងកង្រីព្រាត់ប្រាសគ្នាដោយសារតែកម្មផល។ ចំណែកនាងទាំង១២ ត្រូវគេខ្វេះភ្នែក ខ្វាក់ភ្នែកដូច្នេះដោយសារតែកាលពីជាតិមុន នាងទាំងដប់ពីរនាំគ្នាខ្វេះភ្នែកត្រី ទើបជាតិបច្ចុប្បន្នត្រូវគេខ្វេះភ្នែកវិញ ហើយរស់នៅអន្ទោលអន្ទោកវេទនាពន់ពេកក្រៃ។ នាងពៅគេដែលខ្វេះភ្នែកត្រីតែម្ខាង ទើបជាតិបច្ចុប្បន្ននេះ នាងត្រូវគេខ្វេះភ្នែកតែម្ខាង ហើយអាចបម្រើបាយទឹកដល់បងៗ និងមើលថែទាំងកូនបាន។ ត្រង់ប្រការនេះក៏ជាការផ្សារភ្ជាប់របស់កវីនិពន្ធខ្មែរក្នុងគោលបំណងអប់រំប្រជាជនខ្មែរឱ្យជឿជាក់មកលើកម្មផល និងចង់បង្ហាញថាកម្មពៀរវេរាមានពិតប្រាកដមែន។ អ្នកណាសាងកម្មអ្វីគឺរមែងទទួលនូវកម្មនោះជាក់ស្តែងស្របតាមអំពើដែលខ្លួនបានសាង។ ដូចនេះដើម្បីកុំឱ្យមានបាប គឺមនុស្សកុំត្រូវសាងអំពើបាបគ្រប់បែបយ៉ាង ឬវៀរចាកឱ្យឆ្ងាយពីអកុសលកម្ម។

នៅក្នុងរឿងមរណមាតា តួអង្គដែលប្រព្រឹត្តនូវអំពើបាបកម្មគឺនាងមេម៉ាយនាមកាឡឺ និងកូនៗទីបំផុតត្រូវកម្មពៀរវេរាមកផ្តន្ទាយ៉ាងទាន់ហន់ជាទីបំផុត។ អំពើអាក្រក់នេះគឺជាអ្វីដែលកវីនិពន្ធអប់រំមនុស្សឱ្យខ្លាចកុំប្រព្រឹត្តនូវអំពើបាបកម្មឱ្យសោះ។ នៅក្នុងរឿងសព្វសិទ្ធិដែលនិពន្ធដោយហ្មឺនភក្តីអក្សរ តន់ នាគ្រិស្តសករាជ១៨៩៩ បានបង្ហាញពីតួអង្គកីលៀងដែលមានចិត្តក្បត់នឹងម្ចាស់របស់ខ្លួន ទីបំផុតក៏ត្រូវកម្មតាមផ្តន្ទាយ៉ាងអកុសលជាទីបំផុត។ នៅទីបញ្ចប់នៃរឿង កវីហ្មឺនភក្តីអក្សរ តន់ បានលើកឡើងពីការសរជាតិដែលជាលក្ខណៈសម្គាល់នៃអក្សរសិល្ប៍ពុទ្ធនិយម។

ស្នាដៃពុទ្ធនិយមបានអប់រំ ជាស់តឿនក្រើនរំឭកមនុស្សខ្មែរឱ្យជឿលើកម្មផល វៀរចាកបាបកម្មគ្រប់បែបយ៉ាង។ ជាពិសេសគឺប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសីល ចម្រើន ភាវនា ទើបនាំនាវាជីវិតរបស់ខ្លួនឱ្យបានសេចក្តីសុខតរៀងអើយ។

គ. អក្សរសិល្ប៍ពុទ្ធនិយមបណ្តុះឱ្យមានស្មារតីតស៊ូគ្រប់កាលៈទេសៈ

ជាការពិតណាស់នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមមានតួនាទីយ៉ាងសំខាន់មួយទៀត គឺការអប់រំបានសេចក្តីថាជាការទូន្មានប្រៀនប្រដៅដល់មនុស្សខ្មែរឱ្យមានចិត្តតស៊ូគ្រប់កាលៈទេសៈ និងយកទស្សនៈ

ទ្រឹស្តីព្រះពុទ្ធសាសនាមកជាគ្រឿងអប់រំផ្លូវចិត្តរបស់ខ្លួន។ យើងអាចលើកឧទាហរណ៍ជាក់ស្តែងគឺបណ្ឌិត ជ័យ នន្ទ ដែលជាកវីឆ្នើមនៅសម័យឧដុង្គ ពោលគឺនៅពេលដែលលោកជួបនូវទុក្ខក្រៀមក្រំពីព្រោះតែការបែកបាក់ព្រាត់ប្រាសពីប្រពន្ធកូន គ្រានោះហើយ លោកបានយកធម៌ព្រះពុទ្ធមកអប់រំ និងញ៉ាំងចិត្តឱ្យបានជ្រះថ្លាជានិច្ច។ ជាក់ស្តែងដូចជាកំណាព្យខ្លះដែលលោកបានតាក់តែងមកនៅថៃវ៉ែនប្រាង្គប្រាសាទអង្គរវត្ត ជាតឹកតាងស្រាប់។ ឧទាហរណ៍ដូចជា៖

«នេះភូជង្គលីលា	លើកដោយកាព្យា	ជាល្អាទាំងឡាយ ។
លាអស់លោកទោសសម្ងាយ	លាភ័យអន្តរាយ	ព្រាត់ព្រាយប្រាសគ្នា ។
ខ្ញុំក្រាបទូលព្រះពុទ្ធា	ព្រះហើយខ្ញុំលា	ត្រង់នាទុក្ខសោក ។
ខ្ញុំលាត្រង់កំណើតថោក	កើតមកអស់លោក	សើចដៀលសន្តាន ។
ខ្ញុំលាសព្វជាតិវៀរស្តាន	ក្តីអាស្រូវប្រាណ	កុំមានឡើយណា ។
ខ្ញុំលាត្រង់ឥតប្រាជ្ញា	ឆ្ងល់ខ្លៅមោហា	ខ្មាសគេអៀនប្រៀន ។
ខ្ញុំលាត្រង់ឥតរបៀន	ចូលជំនុំស្ងៀម	ពុំចេះឆ្លើយថា ។» (...)

លោកបណ្ឌិត ជ័យ នន្ទ ជាកវីឆ្នើមនាសម័យកាលនោះដែលបានពលិកម្មដើម្បីជាតិ សាសនា និងព្រះមហាក្សត្រ។ យើងដែលជាកូនចៅជំនាន់ក្រោយពិតជាមានសេចក្តីកោតស្ងប់ស្ងែងចំពោះទឹកដៃតែងនិពន្ធប្រកបទៅដោយរូបារម្មណ៍។ ស្នាដៃរបស់លោកគឺជាការត្រួសត្រាយផ្លូវសម្រាប់មនុស្សជំនាន់ក្រោយឱ្យមើលឃើញពីដំណើរជីវិត និងការយកទ្រឹស្តីព្រះពុទ្ធសាសនាដែលប្រៀបបានជាឱសថមកព្យាបាលជំងឺផ្លូវចិត្តមនុស្សខ្មែរតាំងពីសម័យមុនរហូតមកដល់សម័យបច្ចុប្បន្ន ។

II.៣.៣.៣- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះសោភ័ណជីវិត

ជាការពិតណាស់នៅសម័យកណ្តាល អក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះនូវមនោសញ្ចេតនា ពោលគឺសោភ័ណជីវិតពិតៗនាសម័យកាលនោះ។ ស្នាដៃពុទ្ធនិយមបានលើកកម្ពស់ស្មារតីម្ចាស់ការទទួលស្គាល់ការពិតដែលបុគ្គលគ្រប់រូបរមែងជួបប្រទះនៅលើវិថីជីវិតរបស់ខ្លួន។ ស្នាដៃពុទ្ធនិយមនាំឱ្យមនុស្សស្គាល់នូវភាពផ្អែមល្ហែម និងជូរចត់នៃជីវិត ព្រមទាំងកាល:ទេស:ដែលបានសេចក្តីថាជាភាពចៃដន្យដែលកើតមានដោយមានអន្តរាគមន៍ពីទេវ:គ្រាពើបប្រទះនឹងការលំបាកជាដើម។

នៅត្រង់ស្នាដៃរឿងមួយចំនួនដូចជា ព្រះជិនវង្សដែលបានលាតត្រដាងពីការផ្សងព្រេងដ៏វែងអន្លាយរបស់តួអង្គថា ជីវិតពិតជាលំបាក ប៉ុន្តែមិនស្លាប់ឡើយ។ ព្រះជិនវង្សជាវីរជនដែលបានផ្សងព្រេងនៅគ្រប់ច្រកល្ហកនៃជីវិត ហើយនៅពេលទៅដល់ទីណាក៏ផ្សងព្រេងនឹងសេចក្តីស្នេហា ហើយដែលយើងឃើញថាតែងតែទទួលបានគូស្នេហ៍នៅទីនោះ។ ត្រង់ប្រការនេះហើយនាំឱ្យមនុស្សខ្មែរមានការចងចាំ និងជក់ចិត្តដិតអារម្មណ៍ទៅលើស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមពន់ពេកក្រៃ។ ប្រជាជនខ្មែរភាគច្រើនដែលនិយមចូលចិត្តរឿងនេះ ចងចាំទុក និងនិទានរឿងដំណាលប្រាប់ដល់កូនចៅជំនាន់ក្រោយមិនដែលភ្លេចឡើយ។ អាស្រ័យហេតុនេះទើបមានពាក្យបុរាណមួយដែលខ្មែរតែងនិយមពោលថា«ពូជព្រះជិនវង្សលំបាកបន្តិច ប៉ុន្តែមិនស្លាប់ឡើយ»។ ជាផ្នត់គំនិតរបស់ខ្មែរ គឺខ្មែរតែងប្រឃុំទ្ធតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិរបស់ខ្លួនគ្រប់កាល:ទេស:ដោយមិនអនុញ្ញាតឱ្យបរទេសជាន់ឈ្លីប្រមាថមាក់ងាយស្រេចតែអំពើចិត្តបានឡើយ។ ស្នាដៃពុទ្ធនិយមមានតួនាទីបណ្តុះឱ្យមនុស្សខ្មែរមានស្មារតីតស៊ូនៅក្នុងផ្លូវជីវិត ទោះបីជាពើបប្រទះទៅនឹងឧបសគ្គមករាំងជល់យ៉ាងណាក៏ដោយ។ បានសេចក្តីថា អក្សរសិល្ប៍ទាំងនោះបានកប់ជ្រៅទៅក្នុងសរសៃសសូងមនុស្សខ្មែរគ្រប់ស្រទាប់វណ្ណ:ហើយតែងនិទានប្រាប់កូនចៅឱ្យបានដឹង និងមានស្មារតីក្រោកឈរទទួលបាននូវសោភ័ណជីវិតពិតៗ។ សោភ័ណជីវិតទាំងអស់នោះ បានដល់សោភ័ណចិត្ត សោភ័ណកាយ សោភ័ណទឹកដី សោភ័ណព្រៃព្រឹក្សា ពោលគឺសោភ័ណនៃធម្មជាតិដែលមានទាំងអស់នៅលើទឹកដីខ្មែរ។ ការបណ្តុះឱ្យស្រឡាញ់សោភ័ណជីវិតទាំងអស់នោះហើយ ញុំាងឱ្យមនុស្សខ្មែរមានស្មារតីតស៊ូជម្នះរាល់ឧបសគ្គក្នុងការរស់នៅ ព្រមទាំងចេះសម្របខ្លួនទៅតាមបរិបទសង្គមជាក់ស្តែងថែមទៀតផង។ ជនជាតិខ្មែរជាជនជាតិមួយដែលមានអរិយធម៌ចំណាស់នៅតំបន់ឥណ្ឌូចិន ហើយដែលអាចនិយាយបានថាជាជាតិច្បង ឬជាទឹកដីសុវណ្ណភូមិដែលមានធនធានធម្មជាតិស្តុកស្តម្ភតាំងពីបុរាណកាលមក។ ត្រង់ប្រការនេះមនុស្សខ្មែរត្រូវចូលរួមដើម្បីរក្សាឱ្យបានជាជាច់ខាតនូវបូរណភាពទឹកដីរបស់ខ្លួនឱ្យបានស្ថិតស្ថេរជាអង្វែងតរៀងទៅ។ អូមែដែលជាកវីនិពន្ធជនជាតិក្រិចបានពោលថា«សោភ័ណគឺជាធម្មជាតិ ធម្មជាតិគឺជាប្រភពនៃសោភ័ណគ្រប់បែបយ៉ាង»។ ជាការពិតណាស់ ធម្មជាតិគ្រប់បែបយ៉ាងនេះហើយបានផ្សារភ្ជាប់ទៅនឹងដួងចិត្តមនុស្សខ្មែរ ហើយមនុស្សខ្មែរមិនអាចកាត់ផ្តាច់ខ្លួនចេញពីមនោសញ្ចេតនាលើមាតុភូមិរបស់ខ្លួនបានឡើយ។ បានសេចក្តីថាអារម្មណ៍ដែលស្រឡាញ់ទឹកចិត្តដែលមានចំពោះជាតិមាតុភូមិរបស់ខ្លួនពិតជាជ្រាលជ្រៅជាទីបំផុត។ មនុស្សខ្មែរនៅតែរស់គ្រប់សម័យកាលដោយសារការតាំងចិត្ត និងសេចក្តីសង្ឃឹមរបស់ខ្លួនគ្រប់កាល:ទេស:។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្នាដៃពុទ្ធនិយមបានបណ្តុះឱ្យមនុស្សខ្មែរមានស្នាមញញឹម មានសោភ័ណជីវិតពិតៗនៅក្នុងចិត្តគំនិតរបស់ខ្លួន។ យើងគប្បីថែរក្សាឱ្យបានជាដាច់ខាតនូវស្មារតីជាតិនិយមដើម្បីញុំាងប្រទេសរបស់យើងឱ្យបានជឿនលឿនយ៉ាងជាក់ប្រាកដ។ ស្របពេលនាសម័យនេះ ខ្មែរចេះជួយចែករំលែកគ្នាដើម្បីរស់ប្រកបដោយសុខដុមនីយកម្ម។

II.៣.៣.៤- អក្សរសិល្ប៍ពុទ្ធនិយម និងការចូលរួមអភិវឌ្ឍសង្គម

ស្នាដៃពុទ្ធនិយមជាច្រើនបានធ្វើឱ្យសង្គមនាសម័យកណ្តាលមានការងើបឡើងពីកក់ជ្រាំ ឬពីការគំរាមកំហែងពីបច្ចាមិត្រ។ ជាពិសេសស្នាដៃទាំងអស់នោះ បានជួយចម្រើនមិនត្រឹមតែផ្នែកស្មារតីនោះទេ ប៉ុន្តែថែមទាំងផ្តល់ឱ្យយើងនូវការចម្រើនផ្នែកសម្ភារៈថែមទៀតផង។

តាមរយៈប្រវត្តិសាស្ត្រខ្មែរយើងបានសង្កេតឃើញថា បន្ទាប់ពីការធ្លាក់ចុះខ្សោយនៅសម័យក្រោយអង្គរគឺនិន្នាការរបស់សង្គមបានងាកមករកព្រះពុទ្ធសាសនា។ និន្នាការនេះមិនមែនជារឿងដោយចៃដន្យឡើយ ប៉ុន្តែយើងអាចគិតថានេះក៏ព្រោះមនុស្សខ្មែរអាចមានការនឿយណាយនឹងជំនឿបែបព្រាហ្មណ៍និយមដែលដឹកនាំមនុស្សឱ្យជឿទៅលើទេវៈ។ ថ្វីបើខ្មែរងាកមកជឿទៅលើព្រះពុទ្ធសាសនា ប៉ុន្តែប្រជាជនខ្មែរមិនមានគំនិតផ្តេកផ្តួលនិយមទៅតាមតែកម្មផលឡើយ។ បានសេចក្តីថា ប្រជាជនប្រឹងប្រែងរស់ដោយខ្លួនឯង ប្រឹងធ្វើការចិញ្ចឹមជីវិត ធ្វើស្រែចម្ការច្បារដំណាំញុំាងឱ្យជីវភាពរបស់ខ្លួនសម្បូរសប្បាយ។ ដោយឡែកទស្សនវិជ្ជាព្រះពុទ្ធសាសនាគ្រាន់តែជាបង្អែមក្លែមជីវិតផ្នែកស្មារតីរបស់ជនជាតិខ្មែរតែប៉ុណ្ណោះ។
ស្មារតីនៃការចូលរួមកសាងសង្គមជាតិមួយទៀតគឺតាមរយៈស្នាដៃរឿងព្រះមហាវេស្សន្តរជាតក ស្តែងតាមរយៈតួអង្គព្រះវេស្សន្តរតែម្តង។ ថ្វីបើស្នាដៃនេះជាស្នាដៃមួយដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកក៏ពិតមែន ប៉ុន្តែយើងជឿថា ស្នាដៃនេះពិតជាបានដក់ជាប់នៅក្នុងក្រអៅ បេះដូងមនុស្សខ្មែរដែលកាន់ព្រះពុទ្ធសាសនាគ្រប់កាលៈទេសៈ។ ព្រះវេស្សន្តរ ទ្រង់បានបំពេញទានបារមី។ តាមរយៈដំណើររឿង យើងបានឃើញថាព្រះវេស្សន្តរបានបរិច្ចាគទានតាំងពីចាកចេញពីផ្ទៃព្រះមាតា។ លុះដល់ទ្រង់ធំពេញវ័យ ទ្រង់បានបំពេញនូវសត្តសតកមហាទានដែលជាទានដ៏អស្ចារ្យដែលមាន៧០០មុខ ហើយក្នុងមួយមុខៗមាន៧០០របស់។ កុំថាឡើយត្រឹមទ្រព្យសម្បត្តិផ្ទាល់ព្រះអង្គ ឱ្យតែគេចង់បានទាំងព្រះកាយក៏ព្រះអង្គព្រមបរិច្ចាគជាទានដែរ។ ព្រះអង្គបានបរិច្ចាគដំរីបច្ចយនាគេន្ទ្រដែលជាដំរីមង្គលដល់ព្រាហ្មណ៍ដែលមកពីនគរផ្សេង។ ថ្វីបើការបរិច្ចាគនោះធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តអ្នកស្រីពិរាស្ត្រក៏ដោយក៏ទ្រង់នៅតែបរិច្ចាគដែរ។ លើសពីនេះកុំថា

ឡើយទ្រព្យសម្បត្តិ ប្រពន្ធកូនក៏ព្រះអង្គបរិច្ចាគជាទានដែរ។ ស្នាដៃពុទ្ធនិយមជាទ្រឹស្តីនាំទៅរកការអភិវឌ្ឍសង្គមជាតិចេះជួយសង្គ្រោះគ្នាទៅវិញទៅមក។ ការជួយជាអំណោយមិនមែនចេះតែឱ្យនោះឡើយ ប៉ុន្តែត្រូវផ្សារភ្ជាប់ទៅនឹងទ្រឹស្តីសង្គមផងដែរ។ ជាក់ស្តែងដូចជាសម័យបច្ចុប្បន្ន យើងមានកាកបាទក្រហមសមាគមនានាដែលចុះជួយប្រជាជននៅតាមមូលដ្ឋានក្នុងគ្រាលំបាកដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងប្រធានសក្តិផ្សេងៗដែលកើតឡើងជាយថាហេតុ។ ឧទាហរណ៍ការជួយកសាងសាលារៀន មន្ទីរពេទ្យ វត្តអារាម សង់ស្ពាន សង់ផ្លូវថ្នល់ជាដើមដែលជាប្រយោជន៍សម្រាប់ជាតិ។ ការជួយសង្គ្រោះគ្នាជាកាយវិការដ៏ល្អរបស់ខ្មែរតាំងពីបុរាណមក។ ដោយឡែកនៅសម័យទំនើបនេះវិញ ពិភពលោកទាំងមូលកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីត១៩ ដែលជាជំងឺសាកលនោះ មានប្រទេសជាមិត្តមួយចំនួនបានផ្តល់វ៉ាក់សាំង និងសម្ភារៈបរិក្ខារពេទ្យជាច្រើនជួយដល់កម្ពុជា។ នៅកម្ពុជាខ្លួនឯងក៏មានបណ្តាសប្បុរសជនគ្រប់ស្រទាប់បានស្រាក់ដៃគ្នាបរិច្ចាគប្រាក់ខែ ធនធាន សម្ភារៈជូនរាជរដ្ឋាភិបាលដើម្បីសង្គ្រោះប្រជាជនពីជំងឺឆ្លងកាចសាហាវ។ យើងសង្ឃឹមថា នេះជាការជួយគ្នាក្នុងគ្រាលំបាកដែលឆ្លុះបញ្ចាំងពីវប្បធម៌ចែករំលែកដ៏ល្អថ្លៃថ្លាក្នុងនាមជាមនុស្សជាតិ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្នាដៃពុទ្ធនិយមពិតជាបានចូលរួមលើកកម្ពស់សង្គមខ្មែរនាសម័យកណ្តាលឱ្យមានការចែករំលែកគ្នា ជួយគ្នាក្នុងគ្រាលំបាក និងកសាងសង្គមខ្មែរឱ្យមានការរីកលូតលាស់គ្រប់សម័យកាល។ ស្របតាមពំនោលខ្មែរតែងពោលថា«ជួយគ្នាក្នុងគ្រាក្រ មិត្តល្អស្គាល់គ្នាក្នុងគ្រាលំបាក»ជាដើម។

II.៣.៣.៥- អក្សរសិល្ប៍ពុទ្ធនិយម និងបញ្ហានយោបាយ

អក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរក៏ដើរតួនៅក្នុងនយោបាយផងដែរគឺតាមរយៈទ្រឹស្តីព្រះពុទ្ធសាសនាដូចជា «អត្តាហិ អត្តនោ នាថោ ឬខ្លួនទីពឹងខ្លួន»។ ទ្រឹស្តីនេះជាមាគ៌ាដឹកនាំជីវិតឱ្យបានផ្លូវផង់ និងជឿនលឿន។ សង្គមខ្មែរតាំងពីបុរាណកាលមក មនុស្សខ្មែរមានស្មារតីម្ចាស់ការ មានចរិតឯករាជ្យ និងពឹងលើដៃខ្លួនឯងទាំងគូ។ មនុស្សខ្មែរនិយមពឹងលើសមត្ថភាពផ្ទាល់ខ្លួនជាជាងមានទស្សនៈពឹងលើអ្នកដទៃ ឬពឹងលើកម្លាំងទេវៈ។

ត្រង់នេះយើងអាចសង្កេតបានតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅសម័យឧដុង្គ។ គ្រានោះប្រទេសខ្មែរស្ថិតក្រោមការត្រួតត្រារបស់អណ្ណាម ហើយស្តេចអណ្ណាមបានលើកបន្តុបក្សត្រី អង្គម៉ីឱ្យឡើងគ្រងរាជ

សម្បត្តិ រួចបានបង្ខំខ្មែរឱ្យគោរពប្រពៃណីបែបយួន កាប់ដើមពោធិ៍បំផ្លាញព្រះពុទ្ធសាសនា។ ក្រោមមេបញ្ជាការយួនគឺទ្រឿង មិញយ៉ាង បានដាក់បញ្ជាយ៉ាងតឹងរ៉ឹង និងដាច់ណាត់គ្មានធម៌ប្រណីមកលើប្រជាជនខ្មែរ។ ប៉ុន្តែគ្រានោះ ប្រជាជនខ្មែរមានកំហឹងទៅលើស្តេចយួនយ៉ាងខ្លាំង ហើយក៏តាំងងើបឡើងបះបោរបង្កចលាចលកាប់សម្លាប់យួនទូទាំងប្រទេសដោយឥតរើសមុខ។ គ្រានោះយួនមិនអាចគ្រប់គ្រងខ្មែរបានឡើយ ព្រោះខ្មែរបានយកត្រៃសរណគមន៍មកជាទីពឹងជាទីរឭក ហើយបើនរណាមកប៉ះពាល់ដល់ព្រលឹងដួងជាតិរបស់ខ្លួនហើយ ខ្មែរច្បាស់ជាក្រោកឡើងប្រឆាំងតបតវិញជាក់ជាមិនខាន។ ស្នាដៃពុទ្ធនិយមនៅក្នុងសេចក្តីផ្តើមតែងរឭកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងគុណមាតាបិតាជាដើមដែលនេះជាធម៌កតញ្ញូ និងការដឹងគុណចំពោះត្រៃសរណគមន៍។ ត្រង់ប្រការនេះហើយ យើងអាចនិយាយបានថា ពុទ្ធនិយមនៅសម័យកណ្តាលមិនត្រឹមតែជាអក្សរសិល្ប៍-សិល្បៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឥទ្ធិពលនៃនយោបាយក្នុងសង្គមខ្មែរថែមទៀតផង។

ដូចនេះអក្សរសិល្ប៍ពុទ្ធនិយមជាអាវុធដ៏អស្ចារ្យដែលអាចកែប្រែជោគវាសនារបស់មនុស្ស ហើយឱ្យមានជំនឿជឿជាក់យ៉ាងមុតមាំលើព្រះពុទ្ធសាសនាដែលជាស្មារតីវិទ្យាសាស្ត្រ និងទស្សនវិជ្ជា។

II.៣.៣.៦- អក្សរសិល្ប៍ពុទ្ធនិយម និងការព្យាបាលផ្លូវចិត្ត

អក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរប្រៀបបានដូចជាឱសថដ៏ស័ក្តិសិទ្ធិដែលបានជួយព្យាបាលជំងឺផ្លូវចិត្តប្រជាជនខ្មែរឱ្យមានសេចក្តីសុខស្ងប់ស្ងាត់។ តាមប្រវត្តិសាស្ត្រ យើងបានឃើញថាប្រទេសកម្ពុជានាសម័យនោះមានចម្បាំងរាំងជល់មិនចេះល្ហែល្ហើយ។ ចម្បាំងទាំងអស់នោះកើតឡើងដោយកត្តាផ្ទៃក្នុងផង និងកត្តាបរទេសឈ្លានពានខាងក្រៅផងដែរ។ អាស្រ័យហេតុនេះ អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដ៏មានតម្លៃជាទីបំផុតដែលអាចជួយជម្រុះចោលនូវរឿងសៅហ្មងទាំងឡាយបាន។

ប្រការមួយទៀតជាការកត់សម្គាល់ស្នាដៃទាំងនោះជាសិល្បៈសម្រាប់កម្សាន្តនៅពេលទំនេរពីការងារពលកម្មធ្វើស្រែចម្ការជាដើម។ នៅពេលដែលប្រជាជនខ្មែរសម្រាកពីការងារស្រែចម្ការ គឺពួកគាត់តែងតែនិទានរឿងដែលបានចងចាំ ឬការនិយមសូត្រកំណាព្យឱ្យស្តាប់ក៏ជាវិធីមួយល្អផងដែរ។ ត្រង់នេះហើយ ទើបយើងអាចនិយាយបានថា ស្នាដៃពុទ្ធនិយមជាឱសថព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនឱ្យល្ហែល្ហើយពីការលំបាក។ នៅសម័យក្រោយអង្គរ យើងបានដឹងថា ប្រទេសជាតិកំពុងញាំញីដោយវិបត្តិជាច្រើនដែលកើតឡើងដោយសារជម្លោះផ្ទៃក្នុង និងបច្ចាមិត្តពីខាងក្រៅ។ ក្នុងនោះសត្រូវខ្លាំងគឺសៀម ហើយនឹង

យួនតែងតែចិញ្ចឹមចិត្តមកលើនគរខ្មែរ ហើយធ្វើសង្គ្រាមនៅលើទឹកដីខ្មែរដោយបែងចែកម្ខាងម្នាក់នៃទន្លេមេគង្គជាខ្សែបន្ទាត់កាន់កាប់រៀងខ្លួន។ តាមឯកសារមហាបុរសខ្មែរ ដែលរៀបរៀងដោយលោក អេង សុត បាននិយាយថា ប្រជារាស្ត្រខ្មែរនៅត្រើយខាងកើតធ្វើស្រែស្រូវបានចិញ្ចឹមទ័ពយួន រីឯប្រជារាស្ត្រខ្មែរនៅត្រើយខាងលិចធ្វើស្រែស្រូវបានចិញ្ចឹមទ័ពសៀម។ ត្រង់នេះហើយដែលធ្វើឱ្យប្រជារាស្ត្រខ្មែរវេទនាឥតមានពេលស្រាកស្រាន្ត។ ម្ល៉ោះហើយ អក្សរសិល្ប៍ពុទ្ធនិយមបានជួយបន្ធូរបន្ថយភាពតានតឹងផ្នែកផ្លូវចិត្តរបស់គេដោយប្រជារាស្ត្រខ្មែរងាកមកមានជំនឿទៅលើព្រះរតនត្រ័យ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថាអាចជួយស្រោចស្រង់ពួកគេឱ្យមានសេចក្តីសង្ឃឹម។ នេះជាព្រលឹងដួងកែវធំណាស់សម្រាប់ជាតិ គឺព្រលឹងសាសនាដែលបានជួយជំរុញទឹកចិត្តប្រជារាស្ត្រខ្មែរឱ្យមានសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ដូចដែលយើងបានដឹងស្រាប់មកហើយថា កាលពីសម័យដើមវត្តអារាមជាទីកន្លែងបណ្តុះបណ្តាលការសិក្សារៀនសូត្រសព្វគ្រប់សារពើ។ កូនប្រុសច្រើនតែមានឱកាសក្នុងការមកបួសរៀនសូត្រនូវវិជ្ជាផ្នែកខាងព្រះពុទ្ធសាសនា និងកិច្ចការងារ ហត្ថកម្ម សិល្បៈជាដើមដែលនេះជាប្រពៃណីរបស់ខ្មែរយើងតាំងពីដើមរៀងមក។ ស្នាដៃរឿងទាំងឡាយប្រៀបបានជាឱសថលាងជម្រះភាពនឿយហត់ឱ្យសប្បាយរីករាយ និងមានក្តីសង្ឃឹមក្រោយពីបានអាន សូត្រកំណាព្យចេញពីសាស្ត្រាល្បែងនានាដូចជារឿងព្រះជិនវង្ស ស្រទបចេក ហង្ស យន្ត ទេវន្ត សព្វសិទ្ធិ មរណមាតាជាដើម។ រឿងទាំងអស់នេះ ប្រជាជនខ្មែរនិយមចងចាំ និងនិទានតៗគ្នាទុកឱ្យកូនចៅជំនាន់ក្រោយស្តាប់លេងកម្សាន្តនៅពេលសម្រាកពីការងារ។ ជួនកាលគេយករឿងទាំងនោះមកច្រៀងលេងចាប៉ីថែមទៀតផង។ ចំពោះរឿងទុំទាវក៏ជាស្នាដៃដែលបានកើតឡើងនៅសម័យលង្វែកផងដែរ។ រឿងនេះចារឹកទុកនៅក្នុងឯកសារមហាបុរសខ្មែរដែលថាកើតមានពិតនៅសម័យលង្វែក។ រឿងនេះត្រូវបានគេយកមកច្រៀងចាប៉ី សាដៀវ ហើយមានអ្នកនិពន្ធជាច្រើនរូបដូចជាសន្ធរម៉ុកជាដើម។ លុះក្រោយមកព្រះកិត្តិសោមបានរៀបរៀងនិពន្ធសាជាថ្មី ជាបទពាក្យ៧តាំងពីដើមរហូតដល់ចប់។ រឿងនេះទៀតសោតមានតម្លៃគ្រប់សម័យកាល ព្រោះបានបង្ហាញពីតម្លៃសាកលភាពនៃស្នាដៃ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ យើងបានឃើញថា ស្នាដៃពុទ្ធនិយមបានជួយព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅសម័យក្រោយអង្គរឱ្យបានស្រាកស្រាន្ត បន្ធូរបន្ថយភាពតានតឹងក្នុងផ្លូវអារម្មណ៍ និងមានស្មារតីតស៊ូនៅក្នុងជីវិត។ ជាពិសេសស្នាដៃបានរំលេចឱ្យឃើញពីការបម្រើផ្នែកស្មារតី បំពេដួងចិត្ត និងផ្លូវចិត្តប្រជាជនឱ្យបានសេចក្តីសុខក្សេមក្សាន្តជារៀងរាប។ ក្នុងនាមជាកូនខ្មែរពិតជាមានមោទនភាពដែលបានកើតមកបម្រើជាតិ សាសនា និងព្រះមហាក្សត្រដែលជាបាវចនាជាតិលុះគ្រាអវសាន។

II.៣.៣.៧- អក្សរសិល្ប៍ពុទ្ធនិយម និងសង្គមវប្បធម៌

អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដែលបង្កប់តម្លៃសង្គមវប្បធម៌នៅក្នុងនោះផងដែរ។ សង្គមធម៌ដែលមាននៅក្នុងស្នាដៃត្រូវបានប្រជាជនខ្មែរនិយមយកមកបង្ហាញតាមរយៈទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។ ជាក់ស្តែង យើងឃើញថានៅលើទឹកដីខ្មែរមានបូជនីយដ្ឋានជាច្រើនពាសពេញប្រទេស ហើយជាកន្លែងដែលរក្សាទុកនូវមរតកវប្បធម៌ជាតិខ្មែរតាំងពីបុរាណកាលរហូតដល់សម័យបច្ចុប្បន្ន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមានឥទ្ធិពលលើវិស័យហោរាសាស្ត្រ វិស័យនយោបាយ វិស័យច្បាប់ វិស័យសិល្បៈជាដើម។ ក្នុងវិស័យសិល្បៈត្រូវបានគេយកស្នាដៃរឿងទាំងនោះ ថតជាខ្សែភាពយន្តលេងជាល្ខោនបាសាក់ ល្ខោននិយាយ ល្ខោនស្បែកពណ៌ ល្ខោនស្បែកតូច ចម្រៀង ជាចម្លាក់ ជាសិល្បៈសូនរូប ជាគំនូរជាដើម។ នៅតាមវត្តនីមួយៗឃើញមានរូប ចម្លាក់ព្រះវេស្សន្តរបររាជរថ តាជូដកឡើងដើមឈើមានឆ្កែពីរដេញខាំ តាជូដកដឹកដៃនាងអមិត្តធីតាបនា ព្រះសុវណ្ណសាម ព្រះមហោសថនៅតាមទីធ្លាក្នុងវត្តដើម្បីបង្ហាញប្រាប់មនុស្សទូទៅបានយល់ដឹងពីសកម្មភាព និងរូបរាងរបស់តួអង្គនីមួយៗ។ មិនតែប៉ុណ្ណោះនៅតាមវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាស្ទើរគ្រប់វត្តទាំងអស់សុទ្ធតែមានគំនូររឿងទសជាតកនៅតាមជញ្ជាំងព្រះវិហារ ឬជញ្ជាំងសាលាឆាន់ដើម្បីបង្ហាញពីដំណើរជីវិតផ្សេងៗដែលតួអង្គនីមួយៗបានប្រព្រឹត្តដល់ពុទ្ធបរិស័ទបានយល់។

តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម យើងឃើញមានបទពិសោធសម្បូរបែបនៃការផ្តល់យុត្តិធម៌ក្នុងសង្គម។ ការផ្តល់យុត្តិធម៌ពីសម័យបុរាណគឺផ្អែកលើព្រឹត្តិការណ៍ ឬស្ថានការណ៍ ការធ្លាប់អនុវត្តតថភាពពិត ហេតុការណ៍ពិតជាក់ស្តែង និងការឱ្យតម្លៃលើហេតុផលដើម្បីវិនិច្ឆ័យទោស។ មនុស្សរស់នៅក្នុងសង្គមតែងត្រូវការយុត្តិធម៌ និងការទទួលបានយុត្តិធម៌ វាជាបញ្ហាដ៏ស្មុគស្មាញបំផុតសម្រាប់បុគ្គល និងសង្គមនីមួយៗ។ លក្ខណៈនៃការផ្តល់យុត្តិធម៌ និងទទួលបានយុត្តិធម៌មានបែបផែនឬវិធីផ្សេងៗពីគ្នាទៅតាមសម័យកាលនីមួយៗ ឧទាហរណ៍នៅក្នុងស្នាដៃពុទ្ធនិយមជាច្រើន ពិសេសនៅក្នុងរឿងមហោសថ យើងឃើញការផ្តល់យុត្តិធម៌មានតាមរបៀបផ្សេងៗគ្នាទៅតាមបញ្ហាដែលកើតមានឡើង។ មិនត្រឹមតែរបៀបផ្តល់យុត្តិធម៌ប៉ុណ្ណោះទេ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះបានបង្ហាញពីទសពិធធម៌ដែលមានចែងនៅក្នុងកុដិសាសនារបស់ខ្មែរយើង ហើយត្រូវខ្មែរយើងចាត់ទុកដូចជាវិន័យ ឬច្បាប់សម្រាប់ទូន្មាន និងបង្ហាញពីគុណសម្បត្តិ ព្រមទាំងបុគ្គលិកលក្ខណៈល្អនៃបុគ្គលដែលអ្នកគ្រប់គ្រងក្នុងសង្គម។ ទសពិធរាជ

ធម៌ដែលបានបង្ហាញក្នុងរឿងវេស្សន្តរនោះគឺមាន៖ ១ ទាន ការធ្វើអំណោយ, ២-សីល ការរក្សាសីល៥ជានិច្ច ឬរក្សាសីល១០ មួយដងមួយកាល ៣-បរិច្ចាគ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ, ៤-អាជ្ជវៈ មានសេចក្តីត្រង់, ៥-មទ្ទវៈ មានសេចក្តីទន់ភ្លន់ស្លូតសុភាពរាបសា, ៦-តបៈ ការកាន់ឧបោសថសីល តាមកាលកំណត់ម្តងៗ, ៧-អក្កោធនៈ មិនកម្តៅក្រហាយអ្នកដទៃ, ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ ៩-ខន្តិ មានសេចក្តីអត់ធន់, ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់។ តាមរយៈខ្លឹមសារនិងបទពិសោធដែលបានបង្ហាញក្នុងរឿងវេស្សន្តរនេះ យើងយល់ថាបើអ្នកមានអំណាចគ្រប់គ្រងរដ្ឋ ទោះអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិក្តី និងតុលាការក្តីបានតម្កល់ខ្លួននៅក្នុងទសពិធរាជធម៌ទាំង១០នេះ លោកអាចត្រូវចាត់ទុកថាជាបុគ្គលជាថ្នាក់ដឹកនាំដ៏ល្អដែលប្រកបដោយធម៌។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្នាដៃពុទ្ធនិយមពិតជាបានផ្សារភ្ជាប់ទៅនឹងសង្គមធម៌នៅក្នុងសង្គមខ្មែរជាក់ប្រាកដមែន។ ដូចនេះក្នុងនាមជាកូនខ្មែរគ្រប់ប្រាណគប្បីព្យាយាមសិក្សាស្វែងយល់ និងរក្សាឱ្យបាននូវព្រលឹងអក្សរសិល្ប៍ពុទ្ធនិយមឱ្យបានជានិរន្តរ៍តរៀងទៅ។

II.៣.៣.៨- អក្សរសិល្ប៍ពុទ្ធនិយម និងព្រលឹងជាតិខ្មែរ

ស្នាដៃពុទ្ធនិយមបានឆ្លុះបញ្ចាំងពីព្រលឹងជាតិខ្មែរ។ តើព្រលឹងជាតិខ្មែរនោះមានអ្វីខ្លះ? ហើយព្រលឹងជាតិបានដើរតួនាទីយ៉ាងដូចម្តេចខ្លះនៅក្នុងជីវិតមនុស្សខ្មែរ? យើងបានដឹងហើយថា ជនជាតិខ្មែរជាជាតិសាសន៍ដ៏ចំណាស់មួយនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ជនជាតិនេះមានវប្បធម៌ដើមរបស់ខ្លួនមុនពេលដែលឥណ្ឌាចូលមកទៅទៀត។ តាមឯកសារស្តីពីប្រវត្តិរបស់ជនជាតិខ្មែរដោយអ្នកប្រាជ្ញបារាំង ល្វី ហ្វីណូ ដែលបានសរសេរនៅក្នុងស្នាដៃប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា «តាមប្រវត្តិវិទូចិនជនជាតិខ្មែរជាជនជាតិមួយដែលជាមិត្តជិតខាងល្អរបស់ប្រទេសចិន និងដែលមានបឋមក្សត្រីខ្មែរដំបូងព្រះនាមថាលីវយី ហើយក្រោយមកក្សត្រីអង្គនេះរៀបអភិសេកជាមួយនឹងរាជបុត្រឥណ្ឌា។

តាមឯកសាររបស់លោក សរ សារុន ក្នុងសៀវភៅមានចំណងជើងថា «សាកល្បងសិក្សាអំពីសង្គមវិជ្ជាខ្មែរ»បោះពុម្ពឆ្នាំ១៩៧៣ ព្រលឹងខ្មែរមាន១០រួមមាន៖ ១-ខ្មែរគោរពរបបមាតាធិបតេយ្យ ២-កម្លាំងការពាររបស់ខ្មែរ ៣-ខ្មែរចូលចិត្តអួត ៤-ខ្មែរជាប្រទេសកសិកម្ម ៥-ខ្មែរពុំសូវចេះគោរពច្បាប់ ៦-ខ្មែរជាជនជាតិអកម្ម ៧-ខ្មែរជាជនជាតិប្រចាំប្រកូវ ៨-ខ្មែរទំនោរទៅរកទស្សនៈជ្រុលនិយម ៩-ខ្មែរចូលចិត្តនិយាយពាក្យសច្ចៈ និងព្រលឹងទី១០ ខ្មែរមានកក្តីភាពនៃព្រហ្មចារី។ ប៉ុន្តែអ្វីដែលយើងចង់លើកយកបង្ហាញនៅក្នុង

ន័យនេះយើងបានសិក្សាឃើញថា នៅក្នុងស្នាដៃពុទ្ធនិយមមានបង្ហាញពីព្រលឹងខ្មែរដែលពាក់ព័ន្ធទៅនឹងព្រលឹងទឹកដី ព្រៃព្រឹក្សា និងព្រលឹងវប្បធម៌ជាដើម។ តាមរយៈស្នាដៃរឿងទាំងឡាយដែលជាស្នាដៃនិពន្ធដោយកវីខ្មែរ គឺពិតជាបានឆ្លុះបញ្ចាំងពីទឹកចិត្តស្នេហាជាតិ ស្នេហាទឹកដី ស្នេហាវប្បធម៌ និងកតញ្ញូក៏ដូចជាការប្រយុទ្ធតស៊ូមិនចេះចប់មិនចេះហើយដើម្បីទឹកដីរបស់ខ្លួនជាដើម។ រឿងព្រះជិនវង្សបានបង្ហាញពីការតស៊ូរបស់ព្រះជិនវង្ស ក៏ដូចជាការផ្សងព្រេងនៅក្នុងដំណើរជីវិត ការតស៊ូនៅក្នុងការកសាងខ្លួនពីកុមាររហូតបានក្លាយជាវីរជនមួយរូប។ ព្រះជិនវង្សបានពង្រាយសេចក្តីស្នេហាដោយកាលៈទេសៈស្របតាមស្ថានការណ៍ជាក់ស្តែង។ សេចក្តីស្នេហាកក្តីភាពដ៏បរិសុទ្ធក៏តំណាងឱ្យព្រលឹងពិតៗរបស់មនុស្សដែលកើតមកហើយរមែងមានសំពាយ ពោលគឺសេចក្តីស្នេហាកើតមានឡើងតាំងពីពេលដែលគេនៅក្នុងផ្ទៃនៃព្រះមាតាមកម្ល៉េះ។ ស្នេហាគឺជាជីវិត ។ នៅក្នុងន័យនេះស្នាដៃពុទ្ធនិយមបាននាំឱ្យមនុស្សមើលឃើញពីតម្លៃនៃការតស៊ូ ការរស់នៅថាត្រូវតែតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិរបស់ខ្លួន។ នៅលើទឹកដីខ្មែរមានវត្តអារាមជាច្រើនដែលសុទ្ធសឹងតែបានដំណាលពីបុព្វប្រវត្តិរបស់ព្រះពុទ្ធអង្គតាំងពីកុមារភាពរហូតដល់ព្រះអង្គទ្រង់បានត្រាស់ដឹង និងចូលបរិនិព្វាន។ ត្រង់កន្លែងខ្លះក៏មានបង្ហាញពីដំណើរជីវិតរបស់ព្រះពោធិសត្វដែលយោនយកកំណើតជាទន្សាយ ឬសសបណ្ឌិតហើយបានធ្វើជីវិតបរិច្ចាគដើម្បីជួយសង្គ្រោះដល់ឥន្ទ្រព្រាហ្មណ៍ជាដើម។ ត្រង់នេះជាព្រលឹងសាសនាដែលបង្ហាញពីកិរិយាដ៏អស្ចារ្យរបស់ព្រះពោធិសត្វបណ្ឌិតដែលខិតខំបំពេញបារមីគ្រប់បែបយ៉ាងក្នុងគោលបំណងតែមួយគត់គឺត្រាស់ដឹងជាព្រះពុទ្ធនាអនាគត។

នៅក្នុងរឿង ពុទ្ធិសែន នាងកង្រី បានបង្ហាញពីទឹកចិត្តស្វាមីភក្តិរបស់នាងកង្រីចំពោះព្រះស្វាមី។ ថ្វីបើនាងត្រូវស្លាប់ ប៉ុន្តែដួងចិត្តរបស់នាងគឺមានតែចំពោះពុទ្ធិសែនតែម្នាក់គត់។ នេះជាព្រលឹងភក្តីភាពដែលមាននៅក្នុងស្នាដៃរឿង។ ដោយឡែកពុទ្ធិសែនវិញក៏ដូចគ្នា ជម្រើសដែលពុទ្ធិសែនត្រូវតែបំពេញក្នុងនាមជាកូនប្រុសគឺការជួយសង្គ្រោះម្តាយ និងម្តាយធំឱ្យរួចផុតពីគ្រោះកាចពីទុក្ខវេទនា។ ពីព្រោះថានាងសន្ធមារជាយក្ខិណី ដែលមានគោលបំណងផ្តាច់ផ្តិលសម្លាប់ពុទ្ធិសែន និងនាងទាំង១២ ម្ល៉ោះហើយពុទ្ធិសែនក្នុងនាមជាកូនត្រូវតែបំពេញកតញ្ញូចំពោះព្រះមាតា។ តាមទស្សនៈរបស់ខ្មែរ កូនណាដែលមិនបានចិញ្ចឹមទំនុកបម្រុងមាតាបិតារបស់ខ្លួន កូននោះរាប់ថាជាកូនអកតញ្ញូ ជាកូនរមិលគុណ ហើយព្រះមិនអាចជួយបានឡើយ។ ពុទ្ធិសែនជាគំរូមួយសម្រាប់ជនានុជនគ្រប់ស្រទាប់វណ្ណៈដែលត្រូវបំពេញកិច្ចតបស្នងសងគុណលោកទាន់លោកនៅមានព្រះជន្ម។ ម្យ៉ាងទស្សនៈរបស់ខ្មែរតែងនិយាយថា«ប្តីប្រពន្ធរកបានទៀត តែម៉ែឪមានតែមួយគត់នៅក្នុងលោកាយើងនេះ»។ លោកកែង វ៉ាន់សាក់ នៅក្នុងស្នាដៃរបស់លោកធ្លាប់បានពោល

ថា«ជ្រៅហើយធំផងមហាសមុទ្រ គង់គេឆ្លងផុតបានដល់ត្រើយ គុណម្តាយនេះវិញគ្មានត្រើយឡើយ ជ្រៅហើយធំផងឆ្លងមិនផុត»។ ត្រង់ប្រការនេះយើងអាចចាត់ទុកបានថា ធម៌កតញ្ញូកតវេទីជាព្រលឹងមួយរបស់មនុស្សខ្មែរដែលរំលេចតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម។

ឆ្លងតាមការស្រាយបំភ្លឺខាងលើ ស្នាដៃពុទ្ធនិយមបានបណ្តុះព្រលឹងជាតិខ្មែរឱ្យប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈមានចិត្តស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្ររបស់ខ្លួនគ្រប់ស្រទាប់វណ្ណៈ។ ដូចនេះនៅពេលមានកលិយុគណាមួយកើតឡើង គឺជនជាតិខ្មែរតែងក្រោកឈរដើម្បីសម្រុកវាយរំដោះជាតិមាតុភូមិរបស់ខ្លួនដូចដែលមាននៅក្នុងពង្សាវតារមហាបុរសខ្មែរមកស្រាប់។

II.៣.៤.៩- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះគំនិតវិទ្យាសាស្ត្រ

នៅក្នុងស្នាដៃពុទ្ធនិយមបានបណ្តុះនូវគំនិតវិទ្យាសាស្ត្រដល់សង្គមខ្មែរនៅសម័យកាលនោះមកម្ល៉េះ ពោលគឺជាស្មារតីវិទ្យាសាស្ត្រដែលកើតឡើងតាមរយៈការស្រមើស្រមៃរបស់កវីនិពន្ធ ប៉ុន្តែបានឆ្លាក់ជាប់នូវការចេះដឹងលើការច្នៃប្រឌិតមធ្យោបាយធ្វើដំណើរដល់មនុស្សខ្មែរក៏ដូជាពិភពលោកទាំងមូល។

តាមរយៈរឿង ហង្ស យន្ត ដែលជាស្នាដៃនិពន្ធរបស់ចៅយមបុណ្យកក្តិ ឧក នាគ្រិស្តសករាជ ១៦៦៨ បានបង្ហាញថា ព្រះបាទអាទិត្យវង្សាសោយរាជ្យនៅនគរក្រុងទេពបុរី មានអគ្គមហេសីព្រះនាមពិម្ពា ហើយមានព្រះរាជបុត្រមួយព្រះអង្គព្រះនាម សុវណ្ណកុមារ។ ពេលដែលព្រះរាជបុត្រពេញកំលោះ ព្រះបិតាបានចេញព្រះរាជបញ្ជាឱ្យស្តេច១០១ ប្រទេសដែលជាប្រទេសសមន្តរាជយករាជបុត្រីមកថ្វាយដើម្បីសុវណ្ណកុមាររើសយកនាងណាម្នាក់ដែលមានរូបឆោមល្អធ្វើមហេសី។ ក្នុងបណ្តាព្រះរាជបុត្រីទាំងនោះសុវណ្ណកុមារពុំសព្វព្រះហឫទ័យដល់តិចណាសោះ។ ជាងទងពីររូបបានធ្វើហង្សយន្តមាសមួយថ្វាយសុវណ្ណកុមារ។ បានហង្សយន្តកាលណា ព្រះរាជកុមារនឹកក្នុកស្វែងរកមហេសីដោយព្រះអង្គឯង ហើយក៏ទ្រង់បានទៅសូមលាព្រះមាតាបិតាភរភូតថា: យាងទៅរៀនសិល្ប៍។ ក្រោយមកព្រះរាជកុមារបានទៅលបលួចប្រលោមលួងលោមព្រះនាងបទុមកេសរត្រាតែមានព្រះគភ៌។ បិតាព្រះនាងដឹង ក៏ប្រើពេជ្ឈឃាតចាប់ព្រះរាជកុមារ ប៉ុន្តែរាជកុមារក៏បានប្រើឧបាយដោះខ្លួនបាន និងឡើងបញ្ជិះហង្ស យន្ត ចាកចេញជាមួយនឹងព្រះនាងបទុមកេសររត់ចេញទៅ។

តាមរយៈស្នាដៃរឿង ហង្ស យន្ត បានផ្តល់ចំណេះដឹងវិទ្យាសាស្ត្រដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតខ្ពស់។ ដោយកវីនិពន្ធប៉ិនប្រសប់ក្នុងការរកនឹកត្រិះរិះបង្កើតយានជំនិះដែលកាលនោះ ពិភពលោក

ទាំងមូលពុំទាន់មានការរីកចម្រើនផ្នែកវិទ្យាសាស្ត្រជឿនលឿននៅឡើយផង។ ពោលគឺអ្នកនិពន្ធបានរកនឹកយានជំនិះដែលអាចបញ្ជាតាមខ្សែញាក់ មានស្លាបដោយគ្រឿងយន្ត។ ម្យ៉ាងវិញទៀត របស់នេះក៏អាចត្រូវភ្លើងឆេះនាំឱ្យគ្រោះថ្នាក់ផងដែរ។ ស្នាដៃរឿង ហង្ស យន្ត ពិតជាវិសេសវិសាលខ្លាំងណាស់។ ព្រោះបានផ្តល់ចំណេះដឹងដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតសម្រាប់ការរស់នៅជាប្រចាំ និងហ៊ានជំនះគ្រប់ឧបសគ្គមិនរាថយ។ បើងាកមកក្នុងសម័យកាលទំនើបនេះវិញ ពិភពលោកសព្វថ្ងៃជឿនលឿនណាស់ គេអាចបង្កើតជាយន្តហោះ ជាផ្តាយរណបដែលអាចហោះហើរ លើអាកាសដឹកអ្នកដំណើរឆ្លងទ្វីបបានយ៉ាងងាយស្រួលជាទីបំផុត។

II.៣.៣.១០- អក្សរសិល្ប៍ពុទ្ធនិយម និងសន្តិភាពផ្លូវចិត្ត (**សីល សមាធិ បញ្ញា**)

ស្នាដៃពុទ្ធនិយមនៅសម័យកណ្តាលប្រៀបបានជាឱសថដ៏ល្អឆើតសម្រាប់ព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅសម័យកាលនោះ។ ស្នាដៃនោះទៀតសោតបានបណ្តុះស្មារតីអហិង្សា ការបញ្ចប់ទំនាស់ដោយសន្តិវិធីដោយយកគន្លង ឬមាគ៌ាកណ្តាលនៃព្រះពុទ្ធបរមគ្រូជាគោល។

ស្នាដៃពុទ្ធនិយមតែងរំឭកដល់ត្រៃសរណាគមន៍ថា «ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ » ដែលបានន័យជាសម្រាយថា«ព្រះពុទ្ធ ជាទីពឹង ព្រះធម៌ជាទីពឹង ព្រះសង្ឃជាទីពឹង» ហើយប្រជាជនខ្មែរតែងចងចាំទុក។ យើងជឿជាក់ថា ប្រជាជនខ្មែរនៅសម័យកណ្តាលបានដក់ជិតទន្ទេញនៅក្នុងចិត្តនៅពេលដែលខ្លួនជួបគ្រោះភ័យជាដើម។ ពោលគឺនៅពេលដែលខ្មែរចួបគ្រោះភ័យ សេចក្តីសោកទាំងឡាយ ប្រជារាស្ត្រខ្មែរតែងនឹកដល់គុណកែវទាំងបីជាទីពឹងជាទីរឭកដែលនាំឱ្យចិត្តជ្រះថ្លា ស្ងប់ស្ងាត់ផ្លូវអារម្មណ៍ និងពោរពេញដោយថាមពលផ្លូវចិត្តមានស្មារតីតស៊ូមិនរាថយឡើយ។ ស្នាដៃពុទ្ធនិយមតែងរំឭកដល់គុណកែវទាំងបី គុណមាតាបិតា គុណគ្រូបាអាចារ្យ និងគុណរៀមច្បងដែលសបញ្ជាក់ថាខ្មែរជាជាតិសាសន៍មួយនិយមការដឹងគុណកតញ្ញូកតវេទី និងមានស្មារតីអហិង្សា ប្រកាន់ខ្ជាប់តែអំពើសុចរិតទៀងត្រង់មិនឱ្យប្រាសចាកពីគន្លងឱវាទព្រះពុទ្ធសមណគោត្តមឡើយ។ អក្សរសិល្ប៍ពុទ្ធនិយមសាបព្រោះតែសេចក្តីល្អ ធម៌អហិង្សា និងស្វែងរកតែសេចក្តីសុខសន្តិភាពដល់មនុស្សជាតិគ្រប់កាល:ទេស: ដោយមិនចង់ឃើញការបង្ហូរឈាមរវាងជាតិសាសន៍ណាមួយនៅទេ។

នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក៏បានបង្ហាញពីរាជទសពិធរាជធម៌ ជាពិសេសក្នុងរឿងវិធុរបណ្ឌិត ដំណើររឿងផ្នែកខ្លះបានបង្កប់នូវទសពិធរាជធម៌ ឬច្បាប់សម្រាប់អប់រំមនុស្សក្នុងរាជត្រកូល

ដូចជាច្បាប់ ឬវិន័យសម្រាប់អប់រំបុគ្គលជាអ្នករាជការនៅក្នុងប្រទេសទាំងមូលដែរ។ ទាំងនោះជាលក្ខណៈច្បាប់ដែលជះឥទ្ធិពលមកលើវិស័យច្បាប់រហូតបច្ចុប្បន្ន។ ទោះបីលក្ខណៈច្បាប់នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមពុំមានលក្ខណៈពេញលេញក៏ដោយ ក៏ច្បាប់ទាំងនោះជាគន្លងមួយដែលជាមូលដ្ឋានខ្លះនាំឱ្យលេចឡើងនូវច្បាប់សម្រាប់អប់រំដល់រាជសេវក (មន្ត្រីរាជការ) ប្រតិបត្តិដែរ។ ប្រសិនមន្ត្រីរាជការ ឬបុគ្គលជាអ្នកនៅក្រោមបង្គាប់ ក្រោមការគ្រប់គ្រងបានប្រព្រឹត្តតាមទសពិធរាជធម៌ដែលជាច្បាប់ឬជាវិន័យនេះ បុគ្គលនោះនឹងទទួលបាននូវសេចក្តីចម្រើនពុំខាន។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមបានឆ្លុះបញ្ចាំងពីតម្លៃពុទ្ធិដ៏ទូលំទូលាយក្នុងការដោះស្រាយបញ្ហាទាំងឡាយប្រកបដោយសុទិដ្ឋិឆ្លើយតបនឹងព្រះមហាក្សត្រ និងចំពោះមនុស្សទូទៅ ថែមទាំងបង្ហាញពីភាពកតញ្ញូចំពោះមនុស្សដែលធ្លាប់មានគុណចំពោះខ្លួន និងបង្ហាញពីការប្រឹងប្រែងរបស់ខ្លួនឯងយ៉ាងស្វាហាប់ដែលជាបទពិសោធជាគំរូ ជាការអប់រំដ៏ល្អសម្រាប់មនុស្សទូទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។ ខ្លឹមសារក្នុងស្នាដៃបង្ហាញពីទង្វើអហិង្សា គំនិតអហិង្សា មិនបៀតបៀនអ្នកដទៃចង់បានសន្តិភាពក្នុងសង្គម។ ការបណ្តុះគំនិតសន្តិភាពតាមរយៈតួអង្គក្នុងរឿងពុទ្ធនិយមនេះ វាជាបទពិសោធ ជាការទូន្មាន និងជាគំរូដល់មនុស្សគ្រប់គ្នាសម្រាប់អនុវត្តក្នុងសង្គមគ្រួសារ ឬសង្គមជាតិទាំងមូលនោះនឹងទទួលបាននូវភាពសុខដុម និងសេចក្តីចម្រើនមិនខាន។

ឆ្លងតាមការស្រាយបំភ្លឺ ស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមជាគំរូមួយក្នុងការអប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព ឱ្យស្រឡាញ់អំពើល្អ ឱ្យមានការព្យាយាម ឱ្យចេះស្គាល់គុណ ឱ្យខ្លាចបាប ឱ្យចេះប្រើបញ្ញា ឱ្យចេះពិចារណាលើហេតុនិងផលជាដើម។ ដូច្នេះទើបគេចាត់ទុកអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះជាស្នាដៃអក្សរសិល្ប៍តន្ត្រីរបស់ខ្មែរមួយផ្នែកខាងពុទ្ធសាសនា។ ស្នាដៃទាំងនេះ មានតម្លៃមហាសាលមានប្រយោជន៍យ៉ាងជ្រាលជ្រៅនៅក្នុងមជ្ឈដ្ឋានអ្នកសិក្សាជាតិនិងសង្គមមនុស្សទូទៅ និងជាខឿនយ៉ាងរឹងមាំរបស់វប្បធម៌អរិយធម៌ខ្មែរយើង។

II.៤- **សរុបខ្លឹមសារ**

សរុបមក តាមការស្រាយបំភ្លឺខាងលើនេះ យើងបានឃើញថាអក្សរសិល្ប៍ពុទ្ធនិយមពិតជាមានតួនាទីយ៉ាងសំខាន់នៅក្នុងសម័យក្រោយអង្គរប្រាកដមែន។ តួនាទីនេះបានដក់ជិតជាប់នៅក្នុងជីវិតរបស់មនុស្សខ្មែរកាលពីសម័យក្រោយអង្គរ (លង្វែក-ឧដុង្គ) ឱ្យក្រោកឈរតស៊ូជម្នះរាល់ការលំបាកទាំងក្នុងជីវភាពប្រចាំថ្ងៃ និងកាលៈទេសៈនៃការប្រែប្រួលរបស់សង្គម។ ខាងក្រោមនេះជាជាការសង្ខេបឡើងវិញនៃ

តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងសង្គមខ្មែរដូចជា អក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះពុទ្ធិ សាបព្រោះចំណេះដឹងសព្វសារពើដល់មនុស្សខ្មែរឱ្យយល់ដឹងពីទស្សនៈកម្មផល និងជឿទៅលើព្រះពុទ្ធសាសនា។ ក្រៅពីនេះ ស្នាដៃពុទ្ធនិយមបានអប់រំមនុស្សឱ្យចេះដឹងគុណ និងជឿជាក់លើកម្លាំងផ្ទាល់ខ្លួនស្របដូចពុទ្ធភាសិតថា «អត្តាហិ អត្តនោ នាថោ» បានន័យថា ខ្លួនទីពឹងខ្លួន។ បន្ថែមពីនេះបានអប់រំឱ្យមនុស្សជឿលើបុណ្យបាប ហើយបណ្តុះស្មារតីសន្តិភាពតាមគន្លងព្រះពុទ្ធសាសនា។ ស្នាដៃសម័យក្រោយអង្គរបានបណ្តុះសោភ័ណជីវិតឱ្យខ្មែរស្រឡាញ់ទឹកដី ព្រៃព្រឹក្សា និងជាតិមាតុភូមិរបស់ខ្លួន។ លើសពីនេះបានចូលរួមអភិវឌ្ឍសង្គមលើគ្រប់វិស័យ និងបង្ហាញពីបញ្ហានយោបាយដោយការតស៊ូជម្នះគ្រប់កាលៈទេសៈ។ ជាមួយគ្នានេះផងដែរ កវីនិពន្ធខ្មែរនាសម័យក្រោយអង្គរក៏បានបណ្តុះឱ្យខ្មែរមានគំនិតវិទ្យាសាស្ត្រ មានជំហររឹងមាំ តស៊ូ ខ្លួនទីពឹងខ្លួន មិនព្រមផ្តេកផ្តួលទៅលើព្រេងវាសនានោះឡើយ។ បានសេចក្តីថា ស្នាដៃពុទ្ធនិយមជាបង្អែមក្លែមជីវិតជាឱសថព្យាបាលផ្លូវចិត្តបានយ៉ាងពូកែសក្តិសិទ្ធិនាសម័យកាលនោះ។ ម្យ៉ាងដោយសារតែកវីនិពន្ធខ្មែរយើងសុទ្ធសឹងតែធ្លាប់បានបួសរៀនក្នុងសម្នាក់ព្រះពុទ្ធសាសនា ជារាជកវី ជាព្រះសង្ឃ ជាមន្ត្រី ដែលបានបញ្ចេញស្នាដៃរីកដុះដាលដូចផ្សិតប្រឡងប្រជែងគ្នាផ្នែកខាងអក្សរសាស្ត្រដោយសោមនស្សក្រៃពេករហូតមានខ្មែរចាត់ទុកថាយុគមាសអក្សរសិល្ប៍ទៀតផង។ ត្រង់នេះ យើងជាខ្មែរមានមោទនភាពក្រៃអនេក។

III- **បញ្ចប់សេចក្តី**

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ យើងអាចវាយតម្លៃបានថាប្រធានបទខាងលើនេះពិតជាមានខ្លឹមសារល្អណាស់ ព្រោះបានរំលេចឱ្យយើងស្វែងយល់ និងសង្កេតឃើញយ៉ាងច្បាស់ពីតួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ។ ពោលគឺចាប់តាំងពីក្រោយសម័យអង្គរមក សង្គមខ្មែរមានការប្រែប្រួលយ៉ាងខ្លាំងតាំងពីទឹកដី ប្រវត្តិសាស្ត្រ និងសង្គមវប្បធម៌ជាដើម ហើយចាប់ផ្តើមថមថយឥទ្ធិពលរបស់ខ្លួននៅអាស៊ីអាគ្នេយ៍។ ត្រង់នេះយើងបានឃើញថា អក្សរសិល្ប៍ពុទ្ធនិយមជាឱសថព្យាបាលផ្លូវចិត្តរបស់មនុស្សខ្មែរកាលពីសម័យនោះប្រកបដោយប្រសិទ្ធភាព។ អក្សរសិល្ប៍ពុទ្ធនិយមបានចូលរួមកសាងសន្តិភាពសង្គមខ្មែរតាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន។ ស្នាដៃពុទ្ធនិយមពិតជាមានតួនាទីសំខាន់ណាស់ចាក់គ្រឹះយ៉ាងមាំក្នុងសន្តានចិត្តមនុស្សខ្មែរនាសម័យក្រោយអង្គររហូតដល់បច្ចុប្បន្ន។ ពីព្រោះតាមតាមរយៈអក្សរសិល្ប៍ពុទ្ធនិយមនាំឱ្យមនុស្សខ្មែរដម្រុះចោលនូវអំពើបាប និងត្រងត្រាប់យកតែសេចក្តីល្អ បង្កើតតែសេចក្តីសុខគ្រប់ប្រការ។ ដូចនេះក្នុងនាមជាពុទ្ធសាសនិកជនស្វែងយល់ឱ្យបានស៊ីជម្រៅនូវមាគ៌ាព្រះពុទ្ធសាសនាដើម្បីរស់នៅក្រោមម្លប់នៃសន្តិភាពផ្លូវចិត្តគ្រប់ប្រការ។

ឯកសារពិគ្រោះ

-យឹង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ឆ្នាំ២០០៣

-ឌឹក គាម, បណ្ឌិតជ័យនន្ទ អ្នកនិពន្ធខ្មែរ, បណ្ណាគារ ងួន ហ៊ួត, ១៩៦៧

-ឈឹម ក្រសែម, សិលាចារឹកនគរវត្ត, ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៥៨

-លាងហាប់អាន, សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ, សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ ដល់ឆ្នាំ ១៨៥៩), ភ្នំពេញ, ឆ្នាំ ១៩៦៧

-លី ធាមតេង, អក្សរសាស្ត្រខ្មែរ, បណ្ណាគារ ងួន ហ៊ួត, ១៩៦០

-វង់ សុធារ៉ា, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល, គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត, ២០១២

-សិក្សាស្នាដៃអក្សរសិល្ប៍ដោយបណ្ណាល័យ សេង សុវណ្ណារ៉ា, ២០២២

-កាជ ណាង, និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ ឯកទេសអក្សរសិល្ប៍ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៥

-E. Aymonier, Le Cambodge, Tome III, 1904.

https://www.khsearch.com/qna/15672

https://km.wikipedia.org/wiki/%E%1

https://rac.gov.kh/royal-academy/research/attachments/original/135.pdf?1625998633